- នៅពេលក្រុមហ៊ុនដំណើរការ សូមឱ្យក្រុមហ៊ុនពង្រឹងវិន័យកម្មករ ដើម្បីចៀសវាងនូវជម្លោះ អំពើចោរកម្ម និងអនុញ្ញាតឱ្យប្រជាជនចេញចូល-ឆ្លងកាត់តំបន់គម្រោង ជាពិសេសប្រជាជនដែលមានចំការក្បែរតំបន់គម្រោង
- សូមម្ចាស់ក្រុមហ៊ុនគោរពតាមច្បាប់របស់ប្រទេសកម្ពុជា និងហាមឈូសឆាយលើសពីព្រំប្រទល់ដែលបានកំណត់ដោយរាជរដ្ឋាភិបាល។
- សូមឱ្យក្រុមហ៊ុនជួយសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធមួយចំនួនដូចជា៖ វត្តអារាម មន្ទីរពេទ្យ សាលារៀន បង្គន់អនាម័យ និងជួយបង្កើតទីទួលសុវត្ថិភាពសម្រាប់ប្រជាជនជម្លៀសខ្លួននៅពេលមានទឹកជំនន់ទន្លេសេសាន។

### ៦.២.១.៣ កិច្ចពិគ្រោះយោបល់នៅឃុំហាតប៉ក់

#### ➢ កិច្ចពិគ្រោះយោបល់ថ្នាក់ឃុំ

នាពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង ០៩:៣០នាទីព្រឹក ក្រុមការងាររបស់ក្រុមហ៊ុន RCBCC Co., Ltd. បានធ្វើកិច្ចប្រជុំពិភាក្សាជាមួយមេឃុំហាតប៉ក់ លោកជំទប់ទី១ និងមេភូមិចំនួន ៤នាក់ (បញ្ជីវត្តមានមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ)។ យោងតាមលទ្ធផលនៃកិច្ចពិភាក្សា នៅក្នុងឃុំហាតប៉ក់នេះទើបតែមានក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចមួយទេ គឺក្រុមហ៊ុន អេស ខេ ផ្លេនថេសិន ប៉ុន្តែក៏មានបញ្ហាដីធ្លីដែលពាក់ព័ន្ធជាមួយនឹងប្រជាជនផងដែរ។ តំណាងអាជ្ញាធរមូលដ្ឋានបានរៀបរាប់ថា ខាងក្រុមនិស្សិតបានចុះវាស់វែង និងបានកាត់ដី រួចចេញប្លង់កម្មសិទ្ធិឱ្យប្រជាជនរួចរាល់អស់ហើយ ថែមទាំងបានធ្វើការបោះបង្គោលរួចរាល់ទៀតផង នៅពេលមានបញ្ហាពាក់ព័ន្ធជាមួយនឹងដីធ្លីរបស់ប្រជាជនដំបូង ។ ប៉ុន្តែដោយសារក្រុមហ៊ុនផ្អាកដំណើរការយូរពេក ទើបមានប្រជាជនខ្លះដែលគ្មានដីស្រែធ្វើចំការចូលទៅទន្ទ្រានដីក្នុងដីព្រៃរបស់ក្រុមហ៊ុនទៀត ។ កន្លងមកក្រុមហ៊ុនក៏មិនទាន់មានវិធានការអ្វីដែរ គ្រាន់តែបានដាក់លិខិតស្នើទៅក្រសួងកសិកម្មសុំឱ្យមានវិធានការដោះស្រាយ។ តំណាងអាជ្ញាធរមូលដ្ឋានមិនបានបារម្ភចំពោះផលប៉ះពាល់លើប្រពៃណីវប្បធម៌ ដោយសារកំណើននៃជនចំណូលថ្មីនៅពេលដែលមានគម្រោងនេះទេ ដោយហេតុថាក្រុមហ៊ុនបានកាត់ទួលសុវត្ថិភាព ព្រៃអារក្ស ចេញមកឱ្យប្រជាជនវិញអស់ហើយ។ ប៉ុន្តែអ្វីដែលជាក្តីបារម្ភរបស់ពួកគាត់មានដូចជា៖

- ការបាត់បង់ដីដែលប្រជាជនកំពុងធ្វើស្រែចំការសព្វថ្ងៃ នៅពេលក្រុមហ៊ុនធ្វើការឈូសឆាយ
- ទំនាស់រវាងក្រុមហ៊ុននឹងប្រជាជនដែលកំពុងធ្វើស្រែក្នុងដីរបស់ក្រុមហ៊ុន
- ការបាត់បង់ទីវាលសម្រាប់ព្រលែងសត្វ គោក្របី និងសត្វពាហនៈ
- លទ្ធភាពនៃការបំពុលទឹក ប្រសិនបើគ្មានវិធានការណ៍ច្បាស់លាស់នៅដំណាក់កាលដែលក្រុមហ៊ុនធ្វើការដាំដុះ
- ការបាត់បង់ផ្លូវឆ្លងកាត់សម្រាប់ប្រជាជនចូលទៅរកផល-អនុផលព្រៃឈើ
- ការបាត់បង់ផ្លូវទៅស្រែចំការរបស់ប្រជាជនមួយចំនួនដែលនៅជាប់ដីក្រុមហ៊ុន

ការបារម្ភខ្លាចពេលឈូសឆាយជាក់ស្តែង ក្រុមហ៊ុនមិនគោរពសន្យាដែលថានឹងទុកដី១០០ម៉ែត្រសម្រាប់ដីចំការរបស់ប្រជាជន ប

ដើម្បីដោះស្រាយក្តីបារម្ភដែលបានរៀបរាប់ខាងលើ ពួកគាត់បានលើកឡើងនូវសំណូមពរមួយចំនួនដូចខាងក្រោមដល់ក្រុមហ៊ុនម្ចាស់គម្រោង៖

- ពេលដំណើរការគម្រោងសូមបើកផ្លូវទុកឱ្យប្រជាជនឆ្លងកាត់ផង

Draft

- ទុកផ្លូវ១០០ម៉ែត្រ ពីព្រំប្រទល់ដីក្រុមហ៊ុនសម្រាប់ឱ្យប្រជាជនដែលមានដីចំការក្បែរក្រុមហ៊ុនចេញចូលទៅធ្វើចំការរបស់ពួកគាត់
- សំណូមពរក្រុមហ៊ុនអនុវត្តន៍គម្រោងរបស់ខ្លួនឆ្ងាយពីដីប្រជាជន ប្រហែល៥-៦គីឡូម៉ែត្រ គួរមានទុកផ្លូវម្ខាងម្នាក់សម្រាប់ប្រជាជន
- សូមឱ្យក្រុមហ៊ុនជួយធ្វើផ្លូវ ស្ពាន សាលារៀន និងសាលាឃុំ
- សុំឱ្យក្រុមហ៊ុនជួយធ្វើផ្លូវពីបានលុងមកឃុំហាតប៉ក់ ដោយមិនបាច់ឆ្លងសាឡាង
- សុំឱ្យក្រុមហ៊ុនជួយធ្វើស្ពានពីឃុំហាតប៉ក់ទៅឃុំភ្នំកុក ដើម្បីប្រជាជនអាចមានលទ្ធភាពទៅរកសេវាមណ្ឌលសុខភាពភ្នំកុក បើអាចទៅដល់ស្រុកវឺនសៃកាន់តែប្រសើរ

➢ **កិច្ចពិគ្រោះយោបល់នៅភូមិហាតប៉ក់ និងភូមិឡាំប៉ាក**

កិច្ចពិភាក្សាជាក្រុមជាមួយមេភូមិ សហគមន៍ និងប្រជាជនភូមិហាតប៉ក់ និងភូមិឡាំប៉ាកនៃឃុំហាតប៉ក់ ត្រូវបានធ្វើឡើងនៅសាលាភូមិហាតប៉ក់ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង១៣:៣០នាទី ដល់ម៉ោង១៤:៣០នាទីរសៀល។ កិច្ចពិភាក្សាបានបង្ហាញថា ប្រជាជនបានដឹងឮអំពីវត្តមានគម្រោង ដោយសារសកម្មភាពបោះបង្គោលព្រំប្រទល់របស់ក្រុមហ៊ុន និងរយៈលោកមេឃុំហាតប៉ក់ផងដែរ។ ប្រជាជនបានត្អូញត្អែរថាពួកគាត់មិនសូវសប្បាយចិត្តនឹងវត្តមានរបស់ក្រុមហ៊ុនទេដោយសារការបាត់បង់ដីធ្វើស្រែចំការ ជាពិសេសដីស្រែបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ។ ប្រជាជនបានអះអាងថាប្រជាជនដែលមានបញ្ហាពាក់ព័ន្ធនឹងដីធ្លីរបស់ក្រុមហ៊ុននៅក្នុងភូមិហាតប៉ក់មានប្រហែល១០០គ្រួសារ ហើយគ្រួសារទាំងនេះគឺជាគ្រួសារដែលគ្មានដីធ្វើស្រែចំការ។ ពួកគាត់បានសម្តែងនូវការមិនពេញចិត្តនឹងវត្តមានក្រុមហ៊ុន ដោយពួកគាត់បារម្ភថាក្រុមហ៊ុននឹងឈូសឆាយដីស្រែចំការរបស់ពួកគាត់ដែលកំពុងធ្វើក្នុងព្រំដីរបស់ក្រុមហ៊ុន។ លើសពីនេះ ប្រជាជនដែលបានចូលរួមពិភាក្សា ក៏បានបង្ហាញនូវក្តីបារម្ភផ្សេងៗទៀតដូចជា៖

- ខ្លាចមានគ្រោះធម្មជាតិដូចជាភ្លើងឆេះព្រៃ ដោយសារកម្តៅកើនឡើងខ្លាំង ខ្យល់ព្យុះ និងទឹកជំនន់ ព្រមទាំងខ្លាចមានបម្រែបម្រួលប្រភពទឹកអូរធម្មជាតិ និងបាត់បង់គុណភាពដីដោយសារការហូរច្រោះខ្លាំងជាងមុន នៅពេលព្រៃឈើត្រូវបានបាត់បង់ដោយសារសកម្មភាពគម្រោង
- បារម្ភខ្លាចបាត់បង់ប្រភពចំណូលនៅពេលអនាគត ដោយសារតែការបាត់បង់ព្រៃ និងដីស្រែ-ចំការ។
- ការប្រើប្រាស់ជីគីមីក្នុងដំណើរការគម្រោង អាចបណ្តាលឱ្យប៉ះពាល់ដល់គុណភាពប្រភពទឹកធម្មជាតិ (អូរ បឹង ត្រពាំង)។

ដើម្បីឱ្យគម្រោងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋ ក៏ដូចជាសហគមន៍មូលដ្ឋាន និងដើម្បីកាត់បន្ថយផលប៉ះពាល់ដែលអាចនឹងកើតមាន ប្រជាជនដែលបានចូលរួមកិច្ចពិភាក្សាបានលើកឡើងនូវសំណូមពរមួយចំនួនដូចខាងក្រោម៖

- សូមឱ្យក្រុមហ៊ុនកាត់ដីទុកឲ្យប្រជាជន(គ្រួសារដែលគ្មានដីធ្វើស្រែចំការ)សម្រាប់ធ្វើចំការ
- សូមឱ្យក្រុមហ៊ុនធ្វើរបងហ៊ុំព័ទ្ធ ឬជីកប្រឡាយព័ទ្ធជុំវិញព្រំដីក្រុមហ៊ុន ដើម្បីចៀសវាងគោ-ក្របីរបស់អ្នកភូមិចូលទៅស៊ីដំណាំកៅស៊ូនៅពេលដំណើរការ
- សូមម្ចាស់ក្រុមហ៊ុនគោរពតាមច្បាប់ ដោយកំណត់បង្គោលព្រំដីឱ្យបានច្បាស់លាស់ និងហាមឈូសឆាយលើសពីព្រំប្រទល់ដែលបានកំណត់ដោយរាជរដ្ឋាភិបាល

- សូមឲ្យក្រុមហ៊ុនជួយសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធមួយចំនួនដូចជា៖ មណ្ឌលសុខភាព អណ្តូងទឹក ផ្លូវពីបានលុងមកឃុំហាតប៉ក់ និងស្ពានសំខាន់ៗដើម្បីងាយស្រួលប្រជាជនធ្វើដំណើរ ជាពិសេសដើម្បីស្វែងរកសេវាសុខភាព។

### ៦.២.១.៤ កិច្ចពិគ្រោះយោបល់នៅឃុំតឺន

កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង១០:៣០ព្រឹក នៅសាលាឃុំតឺន ក្រុមការងារនៃក្រុមហ៊ុន RCBCC Co., Ltd បានចុះជួបជាមួយ លោកមេឃុំតឺន ក្រុមប្រឹក្សាឃុំ ប្រធាននិងអនុប្រធានភូមិចំនួន ៨ នាក់ នៅក្នុងឃុំតឺន នៃស្រុកកូនមុំ ខេត្តរតនគិរី ដើម្បីសាកសួរព័ត៌មានទាក់ទងទៅនឹងក្រុមហ៊ុនដីសម្បទាន សេដ្ឋកិច្ច អេស ខេ ផ្លេនថេសិន (បញ្ជីវត្តមាន មានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ)។ តាមរយៈជំនួបពិភាក្សានេះ លោកមេឃុំតឺននិងសមាជិកនៃអង្គប្រជុំបានឲ្យដឹងថាថ្វីត្បិតផែនទីក្រុមហ៊ុនស្ថិតនៅជាប់ឃុំតឺនមែន ប៉ុន្តែមិនមានជាប់ជាមួយទីតាំងភូមិប្រជាជនរស់នៅ ឬទីតាំងរកអនុផលព្រៃឈើរបស់ពួកគាត់ឡើយ។ គម្លាតរវាងភូមិនានានៃឃុំតឺននិងទីតាំងគម្រោងមានចំងាយរហូតដល់១៥គីឡូម៉ែត។ អាស្រ័យហេតុនេះ មិនមានការពាក់ព័ន្ធ ឬជម្លោះដីធ្លីរវាងប្រជាជននិងក្រុមហ៊ុនកើតឡើងទេ។ ជារួមផ្ទៃដីនៅខាងឃុំតឺន មិនមានជាប់ពាក់ព័ន្ធនឹងទីតាំងគម្រោងអេស ខេ ទេ។

### ៦.២.១.៥ កិច្ចពិគ្រោះយោបល់នៅឃុំត្រពាំងក្រហម

កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង១:៣០រសៀល នៅសាលាឃុំត្រពាំងក្រហម ក្រុមការងារនៃក្រុមហ៊ុន RCBCC Co., Ltd បានចុះជួបជាមួយ លោកមេឃុំត្រពាំងក្រហម ក្រុមប្រឹក្សាឃុំ ប្រធានភូមិ និងតំណាងចាស់ទុំចំនួន៦នាក់ នៅក្នុងឃុំត្រពាំងក្រហម នៃស្រុកកូនមុំ ខេត្តរតនគិរី ដើម្បីសាកសួរព័ត៌មានទាក់ទងទៅនឹងក្រុមហ៊ុនដីសម្បទាន សេដ្ឋកិច្ច អេស ខេ ផ្លេនថេសិន (បញ្ជីវត្តមាន មានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ)។ តាមរយៈជំនួបប្រជុំពិគ្រោះយោបល់នេះ លោកមេឃុំត្រពាំងក្រហម និងសមាជិកនៃអង្គប្រជុំបានឲ្យដឹងថា ផ្ទៃដីគម្រោងមិនមានជាប់ពាក់ព័ន្ធជាមួយទីតាំងភូមិប្រជាជនរស់នៅ ឬទីតាំងរកអនុផលព្រៃឈើរបស់ពួកគាត់ឡើយ ទោះជាផែនទីក្រុមហ៊ុនស្ថិតនៅជាប់ឃុំត្រពាំងក្រហមមែន តែឃ្លាតឆ្ងាយពីភូមិនានាជាង១៥គីឡូម៉ែត្រ។ អាស្រ័យហេតុនេះ មិនមានការពាក់ព័ន្ធ ឬជម្លោះដីធ្លីរវាងប្រជាជននិងក្រុមហ៊ុនកើតឡើងទេ។ លើសពីនេះភូមិនានានៃឃុំនេះហើយស្ថិតនៅលើខ្សែទឹក ដែលមិនសូវទទួលរងផលប៉ះពាល់ពីការបំពុលនានាទេ។ ជារួមផ្ទៃដីនៅខាងឃុំត្រពាំងក្រហម មិនមានជាប់ពាក់ព័ន្ធនឹងទីតាំងគម្រោងអេស ខេ ទេ ហើយអ្នកចូលរួមក្នុងកិច្ចពិភាក្សាក៏មិនមានជំទាស់អ្វីនឹងការ អភិវឌ្ឍរបស់ក្រុមហ៊ុនអេស ខេ ដែរ។ ទោះជាយ៉ាងនេះក្តី សមាជិកនៃអង្គប្រជុំបានស្នើរសុំ ឲ្យក្រុមការងារចុះទៅសិក្សានៅឃុំតាឡាត ជាពិសេសនៅភូមិតាឡាត និងភូមិរំពាត់ នៃខេត្តស្ទឹងត្រែងវិញ ដោយហេតុថាទីតាំងភូមិទាំងពីរមានប្រជាជនរស់នៅជិតតំបន់វិនិយោគរបស់ក្រុមហ៊ុន (ចំងាយប្រមាណតែ ៥ទៅ៦គីឡូម៉ែត្រប៉ុណ្ណោះ) ហើយស្ថិតនៅក្រោមខ្សែទឹកដែលអាចនឹងទទួលរងផលប៉ះពាល់ពីការបំពុលនានា ជាង។ លើសពីនេះលោកមេឃុំ និងសមាជិកអង្គប្រជុំបានជំរុញឲ្យក្រុមការងារយកចិត្តទុកដាក់នឹងករណីជម្លោះរវាង ក្រុមហ៊ុននិងប្រជាជននៅភូមិទាំងពីរ ដោយពួកគាត់បានដឹងថាមានជម្លោះ នឹងការប្តឹងផ្តល់កើតឡើងជាញឹកញាប់ ជាពិសេសជាមួយសហគមន៍ជនជាតិដើមភាគតិច ទាក់ទងនឹងករណីដីសមូហភាពរបស់ពួកគាត់។

### ៦.២.១.៦ កិច្ចពិគ្រោះយោបល់នៅឃុំតាឡាត

#### ➢ កិច្ចពិគ្រោះយោបល់ថ្នាក់ឃុំ

កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង ១០:៣០នាទីរសៀល ក្រុមការងាររបស់ក្រុមហ៊ុន RCBCC Co., Ltd. បានធ្វើការពិភាក្សាជាមួយមេឃុំតាឡាត ជំទប់ទី១ មេប៉ុស្តិ៍ មេភូមិ និងអនុភូមិនានានៅក្នុងឃុំសរុបចំនួន ០៧នាក់ (បញ្ជីវត្តមាន មានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ)។ កិច្ចពិភាក្សាបានបង្ហាញថា ទីតាំងវិនិយោគរបស់

ក្រុមហ៊ុន អេស ខេ ផ្លេនថេសិននេះមានជាប់ពាក់ព័ន្ធជាមួយដីប្រជាជននៅក្នុងឃុំតាឡាត នៃស្រុកសេសាន្ត ខេត្តស្ទឹងត្រែង ជាពិសេសជាមួយដីភូមិចំនួនពីរគឺភូមិរំពាត់និងភូមិតាឡាត។ លោកមេឃុំបានឱ្យដឹងថា នៅក្នុងឃុំតាឡាតនេះកាលពីពេលមុនកាត់ចេញនូវផ្ទៃដីរបស់ប្រជាជនដែលពាក់ព័ន្ធនឹងដីក្រុមហ៊ុន មាន៣០ទៅ៤០គ្រួសារដែលមានដីជាប់នឹងក្រុមហ៊ុន។ លោកបានបន្តថា បន្ទាប់ពីក្រុមនិស្សិតចុះវាស់វែងរួច ប្រជាជនប្រហែល៣០-៤០ គ្រួសារនោះទទួលបានទទួលប្លង់កម្មសិទ្ធសម្រាប់ដីដែលក្រុមនិស្សិតចុះវាស់វែងឲ្យ ប៉ុន្តែនៅតែមានប្រជាជនចំនួន ៧៧គ្រួសារដែលបច្ចុប្បន្ននៅតែបន្តធ្វើស្រែនៅលើដីក្រៅប្លង់ដែលបានវាស់វែងឲ្យ ដោយសារក្រុមហ៊ុនទុកដីទំនេរចោលយូរមិនឃើញមានធ្វើការងារអ្វើលើដីនោះ។ ដោយមានការជាប់ពាក់ព័ន្ធបែបនេះទើបប្រជាជនបានសុំដីដែលកំពុងធ្វើស្រែក្រៅប្លង់នេះមកជាដីសមូហភាពរបស់ជនជាតិដើមភាគតិចគ្រឹងវិញ។ លើសពីនេះ អជ្ញាធម៌មូលដ្ឋាននៅឃុំតាឡាតបានសម្តែងនូវក្តីបារម្ភមួយចំនួនដូចជា៖

- ផលប៉ះពាល់ដល់សុខភាពរបស់ប្រជាជន ដែលអាចបង្កដោយ ថ្នាំគីមីដែលបាញ់ទៅលើដំណាំកៅស៊ូ នៅពេលក្រុមហ៊ុនដំណើរការដាំដុះ
- ការបាត់បង់ដើមជ័រទឹក និងអនុផលព្រៃឈើ នៅពេលក្រុមហ៊ុនធ្វើការឈូសឆាយព្រៃ
- ការបាត់បង់ ឬខូចខាតដល់ជំរកសត្វព្រៃ
- ការប៉ះពាល់ដល់ដីចំការចាស់ដែលប្រជាជនកំពុងធ្វើ។

ដើម្បីកាត់បន្ថយផលប៉ះពាល់ទាំងនេះ អាជ្ញាធរភូមិ-ឃុំបានលើកឡើងនូវសំណូមពរមួយចំនួនដូចខាងក្រោម៖

- សូមក្រុមហ៊ុន និងស្ថាប័នជំនាញកាត់ឱ្យប្រជាជននូវផ្ទៃដីចាស់ដែលគាត់ធ្លាប់ធ្វើជាប្រពៃណី បន្ថែមពីលើដីដែលនិស្សិតចុះវាស់វែងឲ្យ ( សុំព្រំប្រទល់ត្រឹមខ្នារយ៉ាវ៉ ដល់ផ្លូវចិនមកកាន់ទន្លេ )
- សូមក្រុមហ៊ុនចុះវាស់វែងដីជាក់ស្តែងនិងបង្ហាញព្រំប្រទល់ថ្មី កប្រសិនបើដីភូមិរបស់ប្រជាជនមានពាក់ព័ន្ធជាមួយដីក្រុមហ៊ុន ស្នើសូមឱ្យក្រុមហ៊ុនជួយធ្វើការដោះស្រាយក្នុងលក្ខខ័ណ្ឌច្បាស់លាស់មួយ
- សូមផ្តល់ការងារដល់ប្រជាជនក្នុងភូមិពេលក្រុមហ៊ុនដំណើរការ
- សូមជួយធ្វើផ្លូវពីខាងឃុំត្រពាំងក្រហមមកឃុំតាឡាត ដើម្បីងាយស្រួលក្នុងការធ្វើដំណើរទៅមណ្ឌលសុខភាពត្រពាំងក្រហមរាល់ពេលស្វែងរកសេវាសុខភាព។

> **កិច្ចពិគ្រោះយោបល់នៅភូមិរំពាត់**

នាថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ វេលាម៉ោង១០:២០ នៅភូមិរំពាត់ នៃឃុំតាឡាត ស្រុកសេសាន ខេត្តស្ទឹងត្រែងដែលមានព្រំប្រទល់ជាប់នឹងឃុំហាតប៉ក់ ឃុំត្រពាំងក្រហម នៃស្រុកវិនសៃ និងស្រុកកូនមុំនៃខេត្តរតនគិរី ក្រុមការងារនៃក្រុមហ៊ុន RCBCC Co., Ltd បានចុះធ្វើលការពិភាក្សាជាក្រុមជាមួយ លោកមេភូមិរំពាត់ ប្រធានសហគមន៍ជនជាតិដើមភាគតិច និងសមាជិកសហគមន៍ដែលមានបញ្ហាពាក់ព័ន្ធដីធ្លីជាមួយក្រុមហ៊ុនអេស ខេ ផ្លេនថេសិន សរុបចំនួន១៤នាក់(មានភ្ជាប់ជូនក្នុង ឧបសម្ព័ន្ធ)។ កិច្ចពិភាក្សាបានបង្ហាញថា ប្រជាជននៅក្នុងភូមិរំពាត់បានដឹងឮនិងស្គាល់ពីក្រុមហ៊ុនសម្បទានសេដ្ឋកិច្ច អេស ខេ ផ្លេនថេសិន នេះច្បាស់ណាស់ ដោយពួកគាត់បានចោទក្រុមហ៊ុនថាបានរំលោភលើដីសហគមន៍ជនជាតិដើមភាគតិចគ្រឹង ដែលជាដីពួកគាត់កំពុងធ្វើចំការវិលជុំ ។ ពួកគាត់បានអះអាងថាពេលចុះសិក្សាវាយតម្លៃដើម្បីគូសផែនទី ក្រុមហ៊ុនមិនបានសហការជាមួយប្រជាជន និងឃុំទេ ដូច្នេះហើយទើបពួកគាត់មិនបានដឹងឮថាព្រំប្រទល់ក្រុមហ៊ុនវាតទីលើដីចំការរបស់ពួកគាត់។ នៅពេលក្រុមហ៊ុនចុះមកដាក់បង្គោលព្រំប្រទល់ទើបប្រជាជនដឹងថាមានពាក់ព័ន្ធនឹងដីពួកគាត់ ហើយបច្ចុប្បន្នក្រុមហ៊ុននៅតែបន្តដាក់បង្គោលចូលក្នុងដីសហមូលភាពរបស់ជនជាតិដើមភាគតិចនេះដដែល ទោះជាមានការតវ៉ាពីសហគមន៍ក្តី។ បញ្ហា

Draft

នេះធ្វើឱ្យពួកគាត់មិនសប្បាយចិត្ត និងបានមូលមតិគ្នាតវ៉ាដាក់ពាក្យបណ្តឹងទៅអភិបាលស្រុកសេសាន នាថ្ងៃទី៣០ ខែកុម្ភៈ ឆ្នាំ២០១៥ និងបានទៅតវ៉ាជាមួយខាងក្រុមហ៊ុនផ្ទាល់ ដោយមានការចូលរួមពីខាង ប៉ូលីសឃុំតាឡាតនិង អភិបាលស្រុកកូនមុំ ប៉ុន្តែមិនមានដំណោះស្រាយទេ។ អភិបាលស្រុកសេសានបានប្រាប់សហគមន៍ថាដីរបស់ពួក គាត់បានលក់ទៅឱ្យក្រុមហ៊ុនហើយ បន្ទាប់មកក៏ស្ងាត់មិនមានដំណោះស្រាយបន្តទេ គ្រាន់តែមានដំណឹងថាទុកឱ្យ ថ្នាក់ខេត្តជាអ្នកដោះស្រាយ។ សហគមន៍បានបញ្ជាក់ថា នៅតែមិនមានដំណោះស្រាយអំពីបញ្ហាដីនេះមកទល់បច្ចុប្បន្ន។ លើសពីនេះ ពួកគាត់ក៏បានអះអាងថា ការវាតទីកំណត់ព្រំប្រទល់របស់ក្រុមហ៊ុនមិនត្រឹមតែបង្កផលប៉ះពាល់ ដល់ ដីចំការវិលជុំទេ ថែមទាំងប៉ះពាល់ព្រៃអារក្សចុងអ៊ូកំពង់ដំរី និងប្រភពទឹកធម្មជាតិ (អូរតុល)ទៀត។

ទោះជាយ៉ាងណា ការពិភាក្សាក៏បានបញ្ជាក់ដែរថា មិនមានគ្រួសារណា ឬសហគមន៍ណាមានដីកម្មសិទ្ធ ឬ ដីដែលបានចុះបញ្ជីនៅក្នុងភូមិរំពាត់នេះទេ។ ប្រជាជនបានទទូចសុំឱ្យក្រុមហ៊ុនកាត់ដីដែលពាក់ព័ន្ធនោះឱ្យប្រជាជនវិញ ព្រោះដីរបស់សហគមន៍ចាប់មានតាំងពីឆ្នាំ២០០៨មកម្ល៉េះ ក្នុងខណៈដែលក្រុមហ៊ុនទើបចូលមកកំណត់ព្រំ នៅឆ្នាំ២០១១។ បន្ថែមលើនេះ ពួកគាត់បានលើកឡើងនូវក្តីបារម្ភមួយចំនួនដូចជា ការបាត់បង់ដីស្រែចំការ ប្រភព នៃការចិញ្ចឹមជីវិត បាត់បង់អនុផលព្រៃឈើ និងសត្វព្រៃជាដើម។ ពួកគាត់បានប្តេជ្ញាថាទោះជាក្រុមហ៊ុនមិនកាត់ដី នោះមកឱ្យប្រជាជនវិញ ក៏ប្រជាជនមិនព្រមឱ្យដីទៅក្រុមហ៊ុនដែរ ដូច្នេះពួកគាត់សូមសំណូមពរឱ្យមានដំណោះ ស្រាយឱ្យបានឆាប់ និងត្រឹមត្រូវមុនពេលក្រុមហ៊ុនចូលឈូសឆាយ។

- **កិច្ចពិគ្រោះយោបល់នៅភូមិតាឡាត**

នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ វេលាម៉ោង២:៣០នាទីរសៀល ក្រុមការងារនៃក្រុមហ៊ុន RCBCC Co., Ltd បាន រៀបចំកិច្ចពិភាក្សាជាក្រុមជាមួយលោកមេភូមិតាឡាត និងសមាជិកសហគមន៍ដែលមានបញ្ហាពាក់ព័ន្ធដីធ្លី ជាមួយក្រុមហ៊ុនអេស ខេ ផ្លេនថេសិន ដែលមានចំនួនសរុប១១នាក់ (មានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ) នៅភូមិតាឡាត ឃុំតាឡាត ស្រុកសេសាន ខេត្តស្ទឹងត្រែង។ ប្រជាជននៅភូមិតាឡាតបានដឹងឮអំពីក្រុមហ៊ុនអេស ខេ ផ្លេនថេសិន ដោយក្រុមហ៊ុននេះក៏បានបោះបង្គោលកាត់ពាក់កណ្តាលលើដីស្រែរបស់ប្រជាពលរដ្ឋដែលក្នុងនោះមានដីស្រែចំការ ដីបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ និងដីព្រៃអារក្សឃ្លាំងមឿង ដែលមានព្រំប្រទល់ខាងជើងទល់នឹងភ្នំគ្រែ និងជាប់ព្រំប្រទល់ដីសហគមន៍ជនជាតិដើមភាគតិចរំពាត់ រហូតដល់ទល់នឹងចុងអូរតុល។ ពួកគាត់បានអះអាងថា ពេលចុះសិក្សាវាយតម្លៃដើម្បីគូសផែនទី ក្រុមហ៊ុនមិនបានសហការជាមួយប្រជាជនក្នុងភូមិគាត់ទេរហូតដល់ បច្ចុប្បន្ន មានប្រជាជន៣០គ្រួសារដែលមានបញ្ហាពាក់ព័ន្ធនឹងដីក្រុមហ៊ុនដែលមានផ្ទៃដីសរុបប្រហែល៧០០ហិកតា។ ប្រជាជនក៏បានបញ្ជាក់ថាក្រុមហ៊ុនទើបបោះបង្គោលដាក់ផ្លាកនៅឆ្នាំ២០១៥នេះ ដោយពុំមានដំណោះស្រាយ សម្រាប់ ការតវ៉ារបស់ប្រជាជនឡើយ។ ដើម្បីដោះស្រាយបញ្ហានេះ ប្រជាជនសូមធ្វើសំណូមពរដូចខាងក្រោម៖

- សូមក្រុមហ៊ុនកាត់ដីដែលពាក់ពន្ធ័ឱ្យប្រជាជនវិញ
- សូមក្រុមហ៊ុនដកបង្គោលព្រំប្រទល់ចេញពីភូមិតាឡាត ឃុំតាឡាត ស្រុកសេសាន ខេត្តស្ទឹងត្រែង
- សូមជួយសាងសង់ផ្លូវចូលមកពីអូរបញ្ជាន់មកភូមិតាឡាត
- សូមជួយសាងសង់មណ្ឌលសុខភាពនៅក្នុងភូមិ
- សូមឱ្យក្រុមហ៊ុនចុះវាស់វែងធ្វើផែនទីឡើងវិញ ដើម្បីកុំឱ្យមានការពាក់ព័ន្ធជាមួយនឹងដីរបស់ប្រជាជន និង គួរផ្តល់ដំណឹងដល់ប្រជាជននៅពេលធ្វើការវាស់វែងផង
- ពេលក្រុមហ៊ុនដំណើរការ គួរដោះស្រាយឱ្យមានកន្លែងគោ ក្របីដើរ

Draft

- ពេលក្រុមហ៊ុនចុះឈូសឆាយ សូមផ្តល់ដំណឹងឱ្យប្រជាជន និងអាជ្ញាធរបានដឹងឮផង
- នៅពេលចុះមកវាស់វែងម្តងទៀត សុំឱ្យប្រជាជននិងអាជ្ញាធរ ភូមិ ឃុំបានចុះទៅមើលឱ្យបានច្បាស់លាស់នូវព្រំប្រទល់ថ្មីផង។

### ៦.២.១.៧ កិច្ចពិគ្រោះយោបល់នៅឃុំប៉ាកកាឡាន

កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង០៩:៣០ព្រឹក នៅសាលាឃុំប៉ាកកាឡាន ក្រុមការងារនៃក្រុមហ៊ុន RCBCC Co., Ltd បានចុះជួបជាមួយ លោកមេឃុំប៉ាកកាឡាន នៃស្រុកវ៉ឺនសៃ ខេត្តរតនគិរីដើម្បីសាកសួរព័ត៌មានទាក់ទងទៅនឹងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច អេស ខេ ផ្លេនថេសិន។ នៅក្នុងកិច្ចប្រជុំនេះ លោកមេឃុំបានឱ្យដឹងថា ឃុំប៉ាកកាឡានមិនមានការពាក់ព័ន្ធជាមួយក្រុមហ៊ុនវិនិយោគអេស ខេ ផ្លេនថេសិននេះទេ។ ពីព្រោះ ឃុំប៉ាកកាឡានស្ថិតនៅផ្នែកត្រើយម្ខាងនៃទន្លេសេសាន ហើយប្រជាជនដែលរស់នៅក្នុងឃុំប៉ាកកាឡាននេះ ក៏ប្រកបរបររកស៊ីធ្វើស្រែចំការនៅតែផ្នែកត្រើយម្ខាងនៃទន្លេ មិនមានឆ្លងទៅប៉ែកខាងដីក្រុមហ៊ុនទេ។ ទោះជាការអភិវឌ្ឍរបស់ក្រុមហ៊ុននេះ មិនសូវមានផលប្រយោជន៍សម្រាប់ ឃុំប៉ាកាឡាន ក៏លោកមេឃុំយល់ថាការវិនិយោគបែបនេះអាចជួយដល់សេដ្ឋកិច្ចមូលដ្ឋាន និងនាំមកការអភិវឌ្ឍហេត្ថារចនាសម្ព័ន្ធទូទៅសម្រាប់តំបន់។

### ៦.២.១.៨ កិច្ចពិគ្រោះយោបល់នៅឃុំវ៉ឺនសៃ

កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង១០:៣០ព្រឹក នៅសាលាឃុំវ៉ឺនសៃ ក្រុមការងារនៃក្រុមហ៊ុន RCBCC Co., Ltd បានចុះជួបជាមួយ លោកមេឃុំវ៉ឺនសៃ នៃស្រុកវ៉ឺនសៃ ខេត្តរតនគិរី ដើម្បីសាកសួរព័ត៌មានទាក់ទងទៅនឹងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច អេស ខេ ផ្លេនថេសិន។ តាមរយៈ**កិច្ចពិគ្រោះយោបល់** លោកមេឃុំវ៉ឺនសៃបានមានប្រសាសន៍ថា ឃុំវ៉ឺនសៃមិនមានការពាក់ព័ន្ធរវាងដីធ្លីរបស់ប្រជាជន និងក្រុមហ៊ុនទេ។ ចំពោះការរកអនុផលព្រៃឈើវិញ ប្រជាជនក៏មិនបានទៅអាស្រ័យផលនៅក្នុងតំបន់គម្រោងដែរ។ ផ្ទុយទៅវិញ មានតែប្រជាជននៅប៉ែកខាងឃុំប៉ង់ទេ ដែលឆ្លងមករកអនុផលព្រៃឈើនៅខាងឃុំវ៉ឺនសៃ ប៉ុន្តែមិនមានប្រជាជនក្នុងឃុំវ៉ឺនសៃទៅរកអនុផលព្រៃឈើ ឬប្រកបរបរផ្សេងៗនៅត្រើយម្ខាងនៃស្រុកវ៉ឺនសៃទេ។ ជារួមផ្ទៃដីនៅខាងឃុំវ៉ឺនសៃ មិនមានជាប់នឹងទីតាំងគម្រោងអេស ខេ ទេ ព្រោះនៅត្រើយម្ខាងនៃដីក្រុមហ៊ុន។

### ៦.២.១.៩ កិច្ចពិគ្រោះយោបល់នៅឃុំកាចូន

កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង៨:៣០ព្រឹក នៅផ្ទះលោកមេឃុំកាចូន ក្រុមការងារនៃក្រុមហ៊ុន RCBCC Co., Ltd បានចុះជួបជាមួយ លោកមេឃុំកាចូន នៃស្រុកវ៉ឺនសៃ ខេត្តរតនគិរីដើម្បីសាកសួរព័ត៌មានទាក់ទងទៅនឹងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច អេស ខេ ផ្លេនថេសិន។ តាមរយៈការសាកសួរ លោកមេឃុំបានមានប្រសាសន៍ឱ្យដឹងថា នៅក្នុងឃុំកាចូនមិនមានការពាក់ព័ន្ធរវាងដីធ្លីរបស់ប្រជាជន និងក្រុមហ៊ុនទេ។ ចំពោះការរកអនុផលព្រៃឈើវិញ ប្រជាជនក៏មិនបានទៅអាស្រ័យផលនៅក្នុងតំបន់គម្រោងដែរ។

### ៦.២.១.១០ កិច្ចពិគ្រោះយោបល់ជាមួយសហគមន៍ព្រៃឈើកុកព្រៅ

នៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង ០២:៣១ នាទីរសៀល ក្រុមការងាររបស់ក្រុមហ៊ុន RCBCC Co., Ltd. បានធ្វើកិច្ចពិភាក្សាជាមួយលោក **គ្លិម ប៊ិន់** ប្រធានសហគមន៍ព្រៃឈើកុកព្រៅ នៅក្នុងបរិវេណសាលាឃុំ ភ្នំកុក ស្រុកវ៉ឺនសៃ ខេត្តរតនគិរី។ ពាក់ព័ន្ធនឹងវត្តមានគម្រោង លោកបានសំដែងការគាំទ្រចំពោះគម្រោង ព្រោះគម្រោងនេះនាពេលបច្ចុប្បន្ន មិនមានទំនាស់ដីធ្លីជាមួយសហគមន៍របស់គាត់ឡើយ ហើយក្នុងករណីដែលគម្រោងនេះដំណើរការ វាបានចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅក្នុងកម្រិតតំបន់ និងខេត្ត។ លោកក៏មានសំណូមពរ ចំនួនបី ដើម្បីឱ្យក្រុមហ៊ុនជួយដល់សហគមន៍ព្រៃឈើរបស់គាត់ ដូចមានខាងក្រោម៖

Draft

- សុំឱ្យក្រុមហ៊ុនជួយធ្វើផ្លូវចេញពីភូមិភ្នំកុក ទៅដល់ព្រៃសហគមន៍របស់គាត់
- សុំឱ្យក្រុមហ៊ុនជួយជា សម្ភារៈ និងធ្វើថ្នាលបណ្ដុះកូនឈើមួយ សម្រាប់សហគមន៍ព្រៃឈើរបស់គាត់
- ស្នើសុំឱ្យក្រុមហ៊ុនជួយធ្វើប៉ុស្ដិ៍យាម ព្រៃសហគមន៍របស់ពួកគាត់ចំនួនពីកន្លែង (ខាងជើង និងខាងត្បូង)។

### ៦.២.២. ការស្ទង់មតិតាមគ្រួសារ៖ ទស្សនៈ និងសំណូមពរ

ការស្ទង់មតិតាមគ្រួសារ ត្រូវបានធ្វើឡើងជាមួយនឹងការអង្កេតសេដ្ឋកិច្ច-សង្គម (សូមអានវិធីសាស្ត្រស្រាវជ្រាវក្នុងជំពូកទី២) ក្នុងគោលបំណងស្វែងយល់អំពីទស្សនៈរបស់ប្រជាជនមូលដ្ឋានចំពោះគម្រោងវិនិយោគនេះ។ លទ្ធផលនៃការស្ទង់មតិ (ក្រាហ្វិច៦.១) បង្ហាញថា ប្រជាជនក្នុងតំបន់សិក្សាមិនមានជំហររួម ឬទស្សនៈដូចគ្នាអំពីគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន អេស ខេ ផ្លេនថេសិនទេ ដោយអ្នកដែលសម្ដែងការគាំទ្រ (២៦%) គាំទ្រដោយមានលក្ខខណ្ឌ (៣០%) មិនគាំទ្រ (២៤%) និងមិនមានយោបល់ (២០%) មានភាគរយប្រហាក់ប្រហែលគ្នា។ លក្ខខណ្ឌដែលបានលើកឡើងដោយអ្នកគាំទ្រប្រមាណជា៣០%នោះមានដូចជា៖

- ការកំណត់ព្រំប្រទល់ក្រុមហ៊ុនឱ្យបានត្រឹមត្រូវ
- ការផ្ដល់អាទិភាពរបស់ក្រុមហ៊ុនក្នុងការជ្រើសរើសប្រជាជនក្នុងតំបន់មកធ្វើការ
- ការប្ដេជ្ញាចិត្តរបស់ក្រុមហ៊ុនក្នុងការមិនប៉ះពាល់ដីប្រជាជន ដីសហគមន៍ និងដីអារក្សអ្នកតា ជាដើម។

**ក្រាហ្វិច៦.១៖ ទស្សនៈប្រជាជនចំពោះការគាំទ្រ ឬមិនគាំទ្រចំពោះវត្តមានគម្រោង**




ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមក្នុងតំបន់សិក្សា (ខែមិថុនា/ធ្នូ ឆ្នាំ២០១៦)

ប្រជាជនដែលបានចូលរួមការអង្កេតតាមគ្រួសារ បានលើកឡើងនូវសំណូមពរមួយចំនួនដូចបង្ហាញក្នុងក្រាហ្វិច៦.២ខាងក្រោម ដែលជារួមមាន៖មាន

- សូមកុំឲ្យមានការប៉ះពាល់ដីចំការរបស់ប្រជាជន និងផ្ដល់សំណងសមរម្យ ប្រសិនបើមានការប៉ះពាល់ (១៤%),
- ស្នើសុំឲ្យធ្វើមណ្ឌលសុខភាព(១៩%)
- ស្នើសុំផ្លូវពីភូមិ (អ្វី)ទៅឃុំត្រពាំងក្រហម នៃខេត្តរតនគិរី (១២%)
- ស្នើសុំឲ្យក្រុមហ៊ុនកំណត់ព្រំប្រទល់អោយបានត្រឹមត្រូវ និងមានការចូលរួមពីប្រជាជន និងអាជ្ញាធរមូលដ្ឋាន (៥%)

Draft

- ស្នើសុំឲ្យធ្វើសាលារៀន (១២%),
- ស្នើសុំឲ្យធ្វើស្ពាន(១០%)
- ស្នើសុំឲ្យក្រុមហ៊ុនជ្រើសរើសប្រជាជនមូលដ្ឋានជាបុគ្គលិក(៣%)
- ស្នើសុំអណ្តូងទឹក(១៨%),

**ក្រាហ្វិច៦.២៖ សំណូមពររបស់ប្រជាជនក្នុងតំបន់**




ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមក្នុងតំបន់សិក្សា (ខែមិថុនា/ធ្នូ ឆ្នាំ២០១៦)

Draft

## ៦.២.៣. ការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល

### ៦.២.៣.១. កិច្ចពិភាក្សាជាមួយអង្គការ NTFP

បទសម្ភាសន៍ជាមួយ **លោក ជុំ ឈាន** តំណាងអង្គការ NTFP ខេត្តរតនគិរី ត្រូវបានធ្វើឡើងនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ ចាប់ពីម៉ោង២:៤០នាទី ដល់ម៉ោង៣:៣០នាទីរសៀល នៅទីស្នាក់ការអង្គការក្នុងក្រុងបានលុង ខេត្តរតនគិរី។ លោក**ជុំ ឈាន** បានលើកឡើងថា លោកធ្លាប់បានដឹងឮអំពីគម្រោងវិនិយោគដាំដំណាំកៅស៊ូ របស់ក្រុមហ៊ុនអេស ខេ ផ្លេនថេសិនខ្លះដែរ តែមិនច្បាស់លាស់ទេ ព្រោះក្រុមហ៊ុនមិនទាន់បានចាប់ផ្តើមដំណើរការ ។ ទោះជាយ៉ាងណា លោកយល់ថាក្រុមហ៊ុននេះអាចជាគំរូល្អ ព្រោះបានអនុវត្តតាមនិតិវិធី ដោយមិនទាន់ធ្វើការឈូសឆាយ នៅពេលដែលមិនទាន់ទទួលបាននូវអាជ្ញាប័ណ្ណ ដូចក្រុមហ៊ុនខ្លះៗដែលលោកធ្លាប់ឃើញកន្លងមក។ លោកមិនមានការជំទាស់នឹងការអភិវឌ្ឍនេះទេ ប៉ុន្តែសូមឱ្យក្រុមហ៊ុនធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានឱ្យបានត្រឹមត្រូវ និងរកដំណោះស្រាយឱ្យបានច្បាស់លាស់ ដើម្បីបញ្ចៀស ឬកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមានដែលអាចនឹងកើតមាន ចំពោះប្រជាជននៅពេលគម្រោងដំណើរការ ។ក្នុងនាមលោកជាតំណាងអង្គការសង្គមស៊ីវិលមួយនេះ លោកសូមសម្តែងនូវការគាំទ្រចំពោះគម្រោងនេះ ព្រោះលោកយល់ឃើញថា គម្រោងនឹងផ្តល់ផលប្រយោជន៍ជាច្រើនដល់សេដ្ឋកិច្ចជាតិទាំងមូល ប្រសិនបើគម្រោងអនុវត្តបានត្រឹមត្រូវទៅតាមគោលការណ៍ច្បាប់វិនិយោគរបស់រាជរដ្ឋាភិបាល។ ទោះជាយ៉ាងនេះក្តី លោកនៅមានក្តីបារម្ភមួយចំនួនដូចខាងក្រោម៖

- ការប៉ះពាល់ដល់ដីចំការរបស់អ្នកភូមិ ប្រសិនបើក្រុមហ៊ុនធ្វើការឈូសឆាយទៅតាមអំណាចរបស់អជ្ញាប័ណ្ណ
- ការបាត់បង់ប្រពៃណីទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច ក៏ដូចជាការបាត់បង់ចំការពនេចរ ដែលជាមុខរបររបស់ពួកគាត់តាំងពីបុរាណមក។
- ការគំរាមកំហែងចំពោះការអាស្រ័យផលព្រៃឈើរបស់បងប្អូនជនជាតិភាគតិច ដោយក្រុមហ៊ុនមិនបានរក្សាទុកតំបន់ព្រៃសហគមន៍ ដីសមូហភាពរបស់ជនជាតិដើមភាគតិច និងព្រៃបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ។
- ផលប៉ះពាល់ដល់ការរកផល-អនុផលព្រៃឈើ នៅពេលគម្រោងដំណើរការ
- ការប៉ះពាល់ដល់ទីវាលសម្រាប់ ព្រលែងនិងចិញ្ចឹមសត្វ ពាហនៈនានា
- ការខ្វះខាតដីទៅអនាគតសម្រាប់កូនចៅជំនាន់ក្រោយ
- ការធ្វើដំណើរទៅឆ្ងាយជាងមុន ដើម្បីទៅរកអនុផលព្រៃឈើ នៅពេលក្រុមហ៊ុនដំណើរការឈូសឆាយហើយ
- ការប៉ះពាល់ និងបាត់បង់ព្រៃឈើ គុណភាពទឹក (ប្រភពទឹកអូរប្រែប្រួល) គុណភាពបរិស្ថាន និងសុខភាពប្រជាពលរដ្ឋ ដោយសារផលប៉ះពាល់នៃការឈូសឆាយការប្រើប្រាស់ដី ឬថ្នាំគីមីក្នុងបរិមាណច្រើនលើការដាំដុះរបស់ក្រុមហ៊ុន ។

ដើម្បីឱ្យគម្រោងអភិវឌ្ឍន៍នេះ ផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋមូលដ្ឋាន និងសង្គមជាតិទាំងមូល លោកបានលើកឡើងនូវសំណូមពរមួយចំនួនដូចខាងក្រោម៖

- សូមក្រុមហ៊ុនដាក់ពាក្យស្នើសុំសិក្សាអំពីផលប៉ះពាល់ទៅលើប្រជាជនមូលដ្ឋាន ជាពិសេសទៅលើសហគមន៍ជនជាតិដើមភាគតិចជាមុនសិន មុនចាប់ផ្តើមប្រតិបត្តិការ ដើម្បីបញ្ចៀសនូវផលប៉ះពាល់ទៅលើពួកគាត់ និងដើម្បីឱ្យមានការឯកភាពគ្នារវាងក្រុមហ៊ុន ប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាន និងសហគមន៍
- សូមធ្វើការចុះជួបពិភាក្សាជាមួយភូមិ ឃុំ និងអាជ្ញាធរពាក់ព័ន្ធនានា ដើម្បីរកវិធានការបញ្ចៀសផលប៉ះពាល់ដែលអាចកើតមាន
- សូមធ្វើការដោះស្រាយទំនាស់ ដោយឈរលើគោលការណ៍នៃការស្ម័គ្រចិត្តទាំងសងខាង (ដោះស្រាយទំនាស់ដោយផ្ទាល់រវាងតំណាងក្រុមហ៊ុន ជាមួយនឹងប្រជាពលរដ្ឋ-សហគមន៍ ដោយមានអាជ្ញាធរដែនដីជាអ្នកសម្របសម្រួល)
- សូមក្រុមហ៊ុនយកចិត្តទុកដាក់លើការអភិវឌ្ឍនមូលដ្ឋានដូចជា៖ ជីកអណ្តូងទឹក កសាងផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ និងមានទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋាន សហគមន៍ និងប្រជាពលរដ្ឋ
- សូមក្រុមហ៊ុនសិក្សាឱ្យបានច្បាស់លាស់អំពីប្រពៃណីរបស់ជនជាតិភាគតិច និងសូមកាត់ទុកដីសមូហភាព (សម្រាប់សហគមន៍) និងចំការពនេចរ ដើម្បីឱ្យពួកគាត់បានបន្តរក្សាប្រពៃណី និងជួយទ្រទ្រង់ជីវភាពសម្រាប់កូនចៅជំនាន់ក្រោយ។

### ៦.២.៣.២. កិច្ចពិភាក្សាជាមួយអង្គការ SCW

កិច្ចពិភាក្សាជាមួយ **លោក ឌី ប៉ូលុច** តំណាងអង្គការ SCW ត្រូវបានធ្វើឡើងនាថ្ងៃទី០៨ ខែមិថុនា ឆ្នាំ ២០១៦ នៅវេលាម៉ោង០៤:០០រសៀល នៅទីស្នាក់ការអង្គការដែលមានទីតាំងស្ថិតនៅក្នុងក្រុងបានលុង ខេត្តរតនគិរី។ កិច្ចពិភាក្សានេះមានគោលបំណងស្វែងយល់ និងប្រមូលនូវពត៌មានទាក់ទងនឹងក្តីកង្វល់ ក៏ដូចជាអនុសាសន៍

Draft

របស់អង្គការនេះ អំពីគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន នៅក្នុងតំបន់ដែលជាភូមិសាស្ត្រគោលដៅអន្តរាគមន៍របស់អង្គការ។

លោក ឌី ប៉ូលុចបានសម្ដែងការគាំទ្រចំពោះវត្តមានរបស់ក្រុមហ៊ុនវិនិយោគមួយនេះដោយលោកយល់ថាគម្រោងវិនិយោគនេះអាចជួយលើកកម្ពស់សេដ្ឋកិច្ចមូលដ្ឋាន។ ដោយគម្រោងបានបង្កឱ្យមានផលប៉ះពាល់ដល់ជីសហគមន៍ជនជាតិដើមភាគតិច ដែលធ្លាប់អាស្រ័យផលជាយូរលង់មកហើយនោះ លោកបានលើកឡើងនូវក្ដីព្រួយបារម្ភ មួយចំនួនដូចជា៖

- ការប៉ះពាល់ដល់តំបន់ដីព្រៃដែលប្រជាជនប្រើប្រាស់ និងអាស្រ័យផល-អនុផលព្រៃឈើ
- ការមិនបានទទួលការងារតាមការរំពឹងទុក នៅពេលដែលគម្រោងចាប់ដំណើរការ នៅខណៈដែលប្រជាជនបានបាត់បង់នូវព្រៃឈើ និងធនធានធម្មជាតិដែលគាត់ធ្លាប់អាស្រ័យផល

ដើម្បីឱ្យគម្រោងអភិវឌ្ឍន៍នេះ ផ្ដល់ផលប្រយោជន៍ដល់ប្រជាជនមូលដ្ឋាន ក៏ដូចជាសង្គមជាតិទាំងមូល លោកប្រធានអង្គការបានលើកឡើងនូវសំណូមពរមួយចំនួនដូចខាងក្រោម៖

- សូមធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមឱ្យបានច្បាស់លាស់
- សូមរកវិធានការដែលធានាតុល្យភាពរវាងការអភិវឌ្ឍ និងផលប៉ះពាល់អវិជ្ជមាន ក៏ដូចជាការអភិរក្ស
- សូមឱ្យមានការចូលរួមដឹងលឺពីប្រជាជន និងអាជ្ញាធរមូលដ្ឋានអំពីទីតាំងភូមិសាស្ត្រជាក់ស្ដែង មិនមែនទីតាំងនៅលើផែនទីតែម៉្យាងទេ។
- សូមដោះស្រាយបញ្ហាពាក់ពន្ធ័នានាឱ្យបានត្រឹមត្រូវមុនពេលចាប់ផ្ដើមដំណើរការ
- បន្ទាប់ពីធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមហើយ សូមបង្ហាញលទ្ធផលដល់ប្រជាជន និងស្ថាប័នពាក់ព័ន្ធនានាផង
- សូមកំណត់ព្រំប្រទល់ដីរបស់ក្រុមហ៊ុនឱ្យបានច្បាស់លាស់ ជៀសវាងការបៀតបៀន រំលោភដីគ្នាទៅវិញទៅមកទៀត
- សូមប្រើប្រាស់គោលការណ៍ការអភិវឌ្ឍដោយមានការចូលរួម
- សូមអាជ្ញាធម៌ថ្នាក់ខេត្តជួយផ្សព្វផ្សាយដល់ប្រជាជន និងស្ថាប័នពាក់ព័ន្ធ អំពីគម្រោងវិនិយោគនានាក្នុងតំបន់។

Draft

### ៦.២.៣.៣.កិច្ចពិភាក្សាជាមួយអង្គការទន្លេ ៣

កិច្ចពិភាក្សាជាមួយ **លោកស្រី ញុយ ណាងណយ** តំណាងអង្គការទន្លេ៣[1] ត្រូវបានធ្វើឡើងនាថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ នៅម៉ោង១៣:៣០នាទីរសៀល នៅទីស្នាក់ការអង្គការដែលមានទីតាំងស្ថិតនៅក្នុងក្រុងបានលុង ខេត្តរតនគិរី។ កិច្ចពិភាក្សានេះមានគោលបំណងស្វែងយល់ និងប្រមូលនូវព័ត៌មានសំខាន់ៗទាក់ទងនឹងក្ដីកង្វល់ ក៏ដូចជាអនុសាសន៍របស់អង្គការនេះ អំពីគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន នៅក្នុងតំបន់ដែលជាភូមិសាស្ត្រគោលដៅអន្តរាគមន៍របស់អង្គការ។

---

[1] អង្គការនេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០១ ដោយការពង្រីកខ្លួនចេញពីបណ្ដាញអ្នកទទួលរងគ្រោះពីការអភិវឌ្ឍទំនប់វារីអគ្គិសនីក្នុងតំបន់ទន្លេសេសាន។

លោកស្រីបានបង្ហាញថា លោកស្រីសូមសម្តែងនូវការគាំទ្រចំពោះដំណើរការគម្រោងរបស់ក្រុមហ៊ុន ប្រសិនបើគម្រោងនេះមិន ប៉ះពាល់ដល់ប្រជាជន។ លោកស្រីបានបន្ថែមថា លោកស្រីមិនបានដឹងអំពីគម្រោងនេះច្បាស់លាស់ទេទោះជាទីតាំងគោលដៅរបស់អង្គការស្ថិតនៅស្រុកវើនសៃក្តី ដោយអង្គការទន្លេ៣ផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើសម្បទានវារីអគ្គីសនី ប៉ុន្តែតាមការយល់ដឹងជាទូទៅគម្រោងភាគច្រើនបានប៉ះពាល់ដល់ដីស្រែចំការរបស់ប្រជាជន។ ដូច្នេះ លោកស្រីបានលើកឡើងនូវក្តីបារម្ភ មួយចំនួនដូចជា៖

- ការប៉ះពាល់ដល់ការនេសាទរបស់ប្រជាជន
- ការធក់ត្រីខុសច្បាប់នៅតាមទន្លេដោយកម្មករក្រុមហ៊ុន
- ការបំពុលទឹកដោយថ្នាំគីមីពេលក្រុមហ៊ុនដំណើរការ ប្រសិនបើក្រុមហ៊ុនគ្រប់គ្រងកម្មករ និងថ្នាំគីមីមិនបានល្អ
- ជម្លោះរវាងប្រជាជន និងកម្មករដែលអាចកើតឡើងនៅពេលសត្វគោ-ក្របីរបស់អ្នកភូមិចូលក្នុងតំបន់គម្រោង ហើយត្រូវបានកម្មករ-សន្តិសុខរបស់ក្រុមហ៊ុនឃាត់ទុក ដោយមិនប្រគល់ឱ្យម្ចាស់ដើមវិញ
- ការបាត់បង់ទំនៀមទម្លាប់ប្រពៃណី ដែលជាវប្បធម៌រស់របស់ជនជាតិដើមភាគតិច ដោយសារការផ្លាស់ប្តូររបៀបរបបនៃការរស់នៅ ការប្រកបរបរចិញ្ចឹមជីវិត និងធនធានធម្មជាតិដែលប្រជាជនអាស្រ័យផលជាពិសេសមុខរបរប្រចាំថ្ងៃរបស់ស្ត្រី។

ដើម្បីឱ្យគម្រោងនេះ ផ្តល់ផលប្រយោជន៍ដល់ប្រជាជនមូលដ្ឋាន សហគមន៍ជនជាតិដើមភាគតិច ក៏ដូចជាសង្គមជាតិទាំងមូល លោកស្រីបានលើកឡើងនូវសំណូមពរមួយចំនួនដូចខាងក្រោម៖

- សូមក្រុមហ៊ុនធ្វើការដោះស្រាយបញ្ហានានាឱ្យបានរួចរាល់ មុនធ្វើការឈូសឆាយដើម្បីអនុវត្តគម្រោង
- សូមផ្សព្វផ្សាយរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះដល់ប្រជាជននិងស្ថាប័នពាក់ព័ន្ធនានា ដើម្បីទទួលការឯកភាពទាំងអស់គ្នាជាមុនសិន សឹមអនុវត្តគម្រោង
- សូមអាជ្ញាធរ៍ពាក់ពន្ធ័តាមដានត្រួតពិនិត្យការងាររបស់ក្រុមហ៊ុនឱ្យបានហ្មតចត
- សូមស្ថាប័នជំនាញ និងអង្គការពាក់ព័ន្ធនានា ចូលរួមតាមដាននិងត្រួតពិនិត្យការអនុវត្តរបស់គម្រោង
- សូមក្រុមហ៊ុនទុកផ្លូវចេញចូល ឱ្យប្រជាពលរដ្ឋ និងអ្នកដំណើរមកពីចម្ងាយធ្វើដំណើរឆ្លងកាត់ផង។

Draft

### ៦.២.៣.៥. កិច្ចពិភាក្សាជាមួយអង្គការសមាគមន៍ខ្មែរលើ (HA)

កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ វេលាម៉ោង៩:៣០នាទីព្រឹក ក្រុមការងារនៃក្រុមហ៊ុន RCBCC បានចុះជួបពិភាក្សាជាមួយ **លោកស្រី ដាំ ចន្ទី** ប្រធានអង្គការសមាគមខ្មែរលើ នៅស្នាក់ការរបស់អង្គការដែលមាន ទីតាំងស្ថិតនៅក្នុងក្រុងបានលុង ខេត្តរតនគិរី។ លោកស្រីបានឱ្យដឹងថាខាងអង្គការលោកស្រីមិនបានដឹងឮអំពី គម្រោង អេស ខេ ផ្លេនថេសិននេះទេ និងមិនមានធ្វើការពាក់ព័ន្ធនឹងតំបន់គម្រោងផងដែរ។

### ៦.២.៣.៦. កិច្ចពិភាក្សាជាមួយអង្គការ ICSO

កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ វេលាម៉ោង១០:០០នាទីព្រឹក ក្រុមការងារនៃក្រុមហ៊ុន RCBCC បានចុះជួបពិភាក្សាជាមួយ**លោកស្រី ង៉ា ចាន់ថន** នាយកកម្មវិធីរបស់អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច នៅស្នាក់ការរបស់អង្គការដែលមានទីតាំងស្ថិតនៅក្នុងក្រុងបានលុង ខេត្តរតនគិរី។ លោកស្រីបានឱ្យដឹងថាខាងអង្គការ

លោកស្រីមិនបានដឹងឮអំពី គម្រោងអេស ខេ ផ្លេនថេសិននេះទេ និងមិនមានតំបន់ការងារធ្វើការពាក់ព័ន្ធនឹងតំបន់គម្រោងផងដែរ។

#### ៦.២.៣.៧. កិច្ចពិភាក្សាជាមួយអង្គការ DPA

កិច្ចពិភាក្សាជាមួយតំណាងអង្គការ DPA ត្រូវបានធ្វើឡើងនាថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ វេលាម៉ោង ១០:៣០ព្រឹក នៅទីស្នាក់ការអង្គការដែលមានទីតាំងស្ថិតនៅក្នុងទីរួមខេត្តរតនគិរី។ កិច្ចពិភាក្សានេះត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បី ស្វែងយល់ និងប្រមូលនូវព័ត៌មានទាក់ទងនឹងបញ្ហា ក្តីកង្វល់ និងអនុសាសន៍របស់អង្គការនេះ ជុំវិញគម្រោងអភិវឌ្ឍន៍ក្នុងតំបន់ភូមិសាស្ត្រគោលដៅនៃសកម្មភាពប្រតិបត្តិការងាររបស់អង្គការនេះ។

តាមរយៈកិច្ចពិភាក្សា លោកបង្ហាញនូវការសប្បាយចិត្តដែលអង្គការសង្គមស៊ីវិលត្រូវបានផ្តល់ឱកាសចូលរួមផ្តល់យោបល់ក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងអភិវឌ្ឍន៍។ ប៉ុន្តែ ពាក់ព័ន្ធនឹងគម្រោងវិនិយោគដំណាំកសិ-ឧស្សាហកម្មរបស់ក្រុមហ៊ុនអេសខេ មួយនេះខាងអង្គការរបស់លោកមិនមានតំបន់គម្រោងធ្វើការពាក់ព័ន្ធនឹងក្រុមហ៊ុនទេ ហើយលោកក៏មិនបានដឹងឮពីគម្រោងនេះដែរ។

### ៦.២.៤. កិច្ចពិភាក្សាជាមួយស្ថាប័នពាក់ពន្ធ័

### ៦.២.៤.១. កិច្ចពិភាក្សាដាច់ដោយឡែក

➤ **កិច្ចពិភាក្សាជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីខេត្ត**

កិច្ចប្រជុំនេះបានធ្វើឡើងនៅថ្ងៃ០៨ ខែមិថុនា ឆ្នាំ២០១៦ ចាប់ពីម៉ោង៩:០០នាទីព្រឹក នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីខេត្ត ដោយមានការចូលរួមពីសំណាក់អនុប្រធានមន្ទីរ (លោក ទឹម មុនីរតន៍) និងប្រធានការិយាល័យ GIS ១រូប។ កិច្ចប្រជុំផ្តោតសំខាន់ទៅលើដីដែលនៅមានជម្លោះក្រោយការចុះបញ្ជីដីរបស់ក្រុមហ៊ុនអេស ខេ ផ្លេនថេសិនរួចហើយ។ ដីដែលពាក់ពន្ធ័នេះស្ថិតនៅភូមិតាឡាត និងភូមិរំពាត់ ស្ថិតក្នុងឃុំតាឡាត ស្រុកសេសាន ខេត្តស្ទឹងត្រែង ហើយដីនេះត្រូវបានអះអាងថាជាដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ទោះជាដីនេះត្រូវបានចុះបញ្ជីផ្លូវការថាជាដីរបស់ក្រុមហ៊ុនអេស ខេ ផ្លេនថេសិនក្តី។ យោងតាមការសម្ភាស លោកអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានឱ្យដឹងថា ព្រំប្រទល់ដីឃុំតាឡាតនៃស្រុកសេសាន ខេត្តស្ទឹងត្រែងគឺជាប់ទៅនឹងឃុំហាតប៉ក់ និងឃុំត្រពាំងក្រហមនៃខេត្តរតនគិរី ដូច្នេះហើយទើបធ្វើឱ្យមានការជាប់ពាក់ព័ន្ធនេះកើតឡើង។ ប៉ុន្តែ មុននឹងចុះបញ្ជីលើដីឯកជនរបស់រដ្ឋតាមការស្នើសុំរបស់ក្រុមហ៊ុនសម្បទានសេដ្ឋកិច្ច អេស ខេ ផ្លេនថេសិន ក្រុមការងារគ្រប់គ្រងដីរដ្ឋ និងមន្ត្រីជំនាញនៃមន្ទីរគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសុរិយោដីខេត្តរតនគិរីបានចុះធ្វើការកំណត់ព្រំ វាស់វែង និងបំពេញទំរង់បែបបទនៃការប្រមូលទិន្នន័យ និងធ្វើការបិទផ្សាយជាសាធារណៈនូវឯកសារវិនិច្ឆ័យ ដែលមាននិតិវិធីដូចខាងក្រោម៖

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចាត់តំណាង ០១រូប (លោក ជី សុខចិន្តា ក្នុងករណីនេះ) ជានីតិបុគ្គល ដើម្បីដាក់ពាក្យស្នើសុំចុះបញ្ជីដីធ្លីនេះ។

- បន្ទាប់ពីបានទទួលពាក្យស្នើសុំ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីខេត្ត បានចេញសេចក្តីប្រកាសលើកទី១ អំពីកាលបរិច្ឆេទនៃការចុះវាស់វែងដីធ្លី (រយៈពេល ១៤ថ្ងៃបន្ទាប់ពីចេញសេចក្តីប្រកាស)។ សេចក្តីប្រកាសនេះ បានបិទផ្សាយនៅសាលាឃុំ សាលាស្រុក និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដី ដើម្បីជាព័ត៌មានដល់អ្នកពាក់ព័ន្ធ ឱ្យមកចូលរួមក្នុងការវាស់វែងដីធ្លី ចង្អុលបង្ហាញព្រំដី និងធ្វើការជំទាស់ក្នុងករណីការវាស់វែងនោះត្រួតពីលើដីធ្លីពួកគាត់។ ជាក់ស្តែង ការចុះវាស់វែង បានធ្វើឡើងដោយមានការចូលរួមពីតំណាងសាលាខេត្ត មន្ទីរ/ស្ថាប័នពាក់ព័ន្ធ សាលាស្រុកវើនសៃ អាជ្ញាធរឃុំហាត់ប៉ក់ អាជ្ញាធរឃុំភ្នំកុក ឃុំប៉ុង និងមេភូមិពាក់ព័ន្ធ ដែល

មានចំនួនសរុប ៤២នាក់ (បញ្ជីវត្តមានអ្នកចូលរួមមានភ្ជាប់ជូនជាមួយរបាយការណ៍មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្ត ក្នុងឧបសម្ព័ន្ធ)។

- បន្ទាប់ពីវាស់វែងហើយ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្ត បានរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការចុះវាស់វែង (មានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ) និងដាក់របាយការណ៍នោះប្រជុំឆ្លងអន្តរស្ថាប័នពាក់ព័ន្ធមានដូចជា តំណាងមន្ទីរកសិកម្មខេត្ត ខណ្ឌរដ្ឋបាលព្រៃឈើ និងមន្ទីរបរិស្ថានខេត្ត ជាដើម។ បន្ទាប់មកទៀត មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីខេត្ត ចេញសេចក្តីប្រកាសលើកទី២ និងទុករយៈពេល ៣០ថ្ងៃ ជូននីតិបុគ្គល (ដែលជាតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ដើម្បីពិនិត្យ និងវាយតម្លៃឡើងវិញលើផ្ទៃដីដែលត្រូវចុះបញ្ជីជាដីឯកជនរបស់រដ្ឋ មុននឹងមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីខេត្ត ចេញបណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លី។ ផ្ទៃដីដែលអនុញ្ញាតឱ្យចុះបញ្ជីមានទំហំត្រឹមតែ ៦៥០៩.៣១០៤ហិកតាប៉ុណ្ណោះ ទោះជាក្រុមហ៊ុនបានស្នើសុំរហូតដល់ចំនួន ៦៨១៤.៦០១៣ហិកតាក៏ដោយ ហើយក្បាលដី១កន្លែង ដែលមានទំហំ ៣០៥.២៩០៩ហិកតា ពុំអាចចេញបណ្ណកម្មសិទ្ធិឱ្យទេ ដោយហេតុថាដីនេះមានពាក់ព័ន្ធជាមួយដីដែលប្រជាពលរដ្ឋកំពុងតវ៉ា។

ផ្អែកតាមទស្សនៈលោកអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីខេត្ត ការផ្តល់បណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីគឺជាការបញ្ចប់នូវរាល់ទំនាស់ដីធ្លី។ បណ្ណកម្មសិទ្ធិដែលបានចេញបន្ទាប់ពីឆ្លងកាត់ដំណើរការខាងលើគឺជាបណ្ណកម្មសិទ្ធិដែលពុំមាននៅជាប់ដីធ្លីដែលមិនទាន់បានដោះស្រាយនោះទេ។ បណ្ណកម្មសិទ្ធិនេះ ក៏ជាឯកសារផ្លូវច្បាប់ដែលបញ្ជាក់ថា ក្រុមហ៊ុនពុំមានសិទ្ធិឈូសឆាយបន្តទៀតទេ ក្នុងខណៈដែលប្រជាជនក៏មិនអាចចូលទន្ទ្រានដីដែលបានចុះបញ្ជីរួចនេះដែរ។ ការចូលទន្ទ្រានប្រសិនបើមាន គឺជាទង្វើមិនស្របច្បាប់។

Draft

ទន្ទឹមនឹងនេះ លោកអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីខេត្ត ក៏បានបញ្ជាក់ដែរថា បញ្ហាពាក់ពន្ធ័នានាត្រូវបានដោះស្រាយនៅពេលផ្ទៃដីរបស់ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន ត្រូវបានកាត់ចេញឱ្យប្រជាជនរួចនៅពេលចុះវាស់វែង។ ការចុះវាស់វែងគឺបានប្រកាសទូលំទូលាយនិងធ្វើការបោះបង្គោលរួចអស់ហើយដោយមានអាជ្ញាធរពាក់ព័ន្ធចូលរួមផងដែរ។ ចំពោះដីសម្បទានរបស់សហគមន៍ជនជាតិដើមភាគតិចដែលបានតវ៉ានោះ គឺជាដីរបស់ក្រុមហ៊ុន ដោយការបង្កើតសហគមន៍នេះកើតឡើងក្រោយគម្រោងដីសម្បទានរបស់ក្រុមហ៊ុនអេស ខេ ផ្លេនថេសិនបានចុះបញ្ជីដីធ្លីរួចហើយសហគមន៍នេះទៀតសោតគ្រាន់តែបានចងក្រងបង្កើត ប៉ុន្តែមិនទាន់បានទទួលការកាត់ដីជូនពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីទេ។ លោកក៏បានអះអាងបន្តទៀតថា ការពិតទៅប្រជាជនមិនទាន់មានកម្មសិទ្ធិដីធ្លីទេ ព្រោះដីនោះគ្រាន់តែជាដីពួកគាត់ធ្លាប់ធ្វើកសិកម្មពនេចរ ហើយការចូលមកកាន់កាប់ដីរបស់ប្រជាជនគឺនៅក្រោយពេលការកាត់ដីជូនក្រុមហ៊ុនហើយ ។

- **កិច្ចពិភាក្សាជាមួយផ្នែករដ្ឋបាលព្រៃឈើវើនសៃ**

កិច្ចប្រជុំនេះបានធ្វើឡើងនៅថ្ងៃ២៥ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង ១០:០០ ព្រឹក ក្រុមការងាររបស់ក្រុមហ៊ុន RCBCC Co., Ltd. បានចូលជួបពិភាក្សាជាមួយលោក **កង នី** នាយសង្កាត់រដ្ឋបាលព្រៃឈើវើនសៃ ក្នុងបរិវេណសង្កាត់រដ្ឋបាលព្រៃឈើវើនសៃ ស្រុកវើនសៃ ខេត្តរតនគិរី។ ពាក់ព័ន្ធនឹងវត្តមានគម្រោងអេស ខេ ផ្លេនថេសិន លោកបានសំដែងការគាំទ្រ ព្រោះវាបានចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅក្នុងកម្រិតតំបន់ និងកម្រិតខេត្ត។ ទន្ទឹមនឹងនេះ នៅក្នុងកិច្ចពិភាក្សាលោកក៏បានសំដែងនូវក្តីបារម្ភចំពោះគម្រោងនេះផងដែរ ដោយហេតុថា គម្រោងនេះទទួលបានអាជ្ញាបណ្ណពីរដ្ឋាភិបាលយូរណាស់មកហើយ តែគម្រោងនេះមិនទាន់បានចាប់ផ្តើមដំណើរការនៅឡើយ។ ផ្ទុយទៅវិញ គម្រោងអេស ខេ នេះបែរជាមានជម្លោះដីធ្លីជាមួយប្រជាជន ក្នុងន័យនេះផងដែរគាត់ក៏បានផ្តល់អនុសាសន៍ និងសំណូមពរ ចំនួន បីដល់ក្រុមហ៊ុន ដូចខាងក្រោម៖

- សុំឱ្យក្រុមហ៊ុនពន្លឿនដំណើរការ ការអភិវឌ្ឍឱ្យបានឆាប់រហ័ស ដើម្បីធ្វើការបញ្ចៀសជម្លោះដីធ្លីជាមួយប្រជាជន
- ស្នើសុំដីព្រៃឈើដែលមានដំណុះកូនក្រញូងចំនួន ៩៦ ហិចតាដែលមាននៅក្នុងទីតាំងតំបន់គម្រោង ដែលស្ថិតនៅក្នុងភូមិហាតប៉ក់ ឃុំហាតប៉ក់ ស្រុកវ៉ឺនសៃ សម្រាប់ធ្វើការអភិរក្សជាចំការគ្រាប់ពូជ(រាល់លិខិតស្នាម និងផែនទីមាននៅក្នុងឧបសម្ព័ន្ធ)
- នៅពេលដែលក្រុមហ៊ុនដំណើរការ សុំឱ្យក្រុមហ៊ុនជួយឧបត្ថម្ភជា សម្ភារៈ ថវិកា និងមធ្យោបាយសម្រាប់ធ្វើការបណ្តុះកូនឈើព្រៃ នៅក្នុងទីតាំងស្ថានីយ៍បណ្តុះកូនឈើរបស់សង្កាត់រដ្ឋបាលព្រៃឈើវ៉ឺនសៃ និងសម្រាប់ការចូលរួមបង្កើតជាសហគមន៍ព្រៃឈើ នៅក្នុងទីតាំងតំបន់ដែលមានដំណុះកូនក្រញូងទាំងនេះ ព្រមទាំងស្នើសុំឱ្យក្រុមហ៊ុនជួយធ្វើរបង ឬជីកប្រឡាយសម្រាប់ការពារ ដំណុះកូនក្រញូងទាំង ៩៦ ហិចតានេះបន្ថែមទៀត។

> **កិច្ចពិភាក្សាជាមួយផ្នែករដ្ឋបាលជលផលវ៉ឺនសៃ និងទន្លេសេសាន**

កិច្ចប្រជុំនេះបានធ្វើឡើងនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង ១៣: ៥៣ នាទីរសៀល ក្រុមការងារ RCBCC Co. Ltd. បានចូលជួបពិភាក្សាជាមួយលោក **ប៊ិន ធារង្សី** នាយផ្នែកជលផលសេសាន នៅក្នុងបរិវេណ មន្ទីរកសិកម្មខេត្តរតនគិរី។ នៅក្នុងកិច្ចពិភាក្សា លោកបានសំដែងនូវការគាំទ្រនូវវត្តមានរបស់គម្រោងនៅក្នុងតំបន់ ប៉ុន្តែលោកក៏បានបង្ហាញនូវក្តីបារម្ភ ព្រមទាំងផ្តល់នូវអនុសាសន៍មួយចំនួនដើម្បីជៀសវាង ឬ កាត់បន្ថយហេតុប៉ះពាល់បរិស្ថានដែលអាចកើតមាន។ សំណូមពរ និងអនុសាសន៍សំខាន់ ដល់ក្រុមហ៊ុនដែលមានដូចខាងក្រោម៖

- សុំឱ្យក្រុមហ៊ុនប្រើប្រាស់សារធាតុគីមី ឬថ្នាំកសិកម្ម ជីកសិកម្ម ទៅតាមបទដ្ឋានបច្ចេកទេសកសិកម្ម
- ចំពោះកាកសំណល់ផ្សេងៗដែលបន្សល់ទុកពីការប្រើប្រាស់ សុំកុំឱ្យ បុគ្គលិក-កម្មករបោះចូលទៅក្នុងទន្លេ អូរ ឬបឹងត្រពាំងនានា
- នៅពេលដែលក្រុមហ៊ុនចាប់ផ្តើមដំណើរការ សុំកុំឱ្យក្រុមហ៊ុនធ្វើការឈូសឆាយទៅលើព្រៃលិចទឹកដែលដុះនៅតាម អូរ បឹង និងទន្លេ។
- ក្នុងករណីដែលក្រុមហ៊ុនធ្វើការឈូសឆាយ ឬមានការស្តារ បឹង ត្រពាំង អូរ ទន្លេ សូមឱ្យក្រុមហ៊ុនធ្វើការទំនាក់ទំនងជាមួយស្ថាប័ន មានសមត្ថកិច្ចជាមុនសិន(ផ្នែក ឬខណ្ឌរដ្ឋបាលជលផល)ដើម្បីធ្វើការចង្អុល បង្ហាញពីកន្លែងដែលមានវត្តមានប្រភេទមច្ឆជាតិសំខាន់ៗរស់នៅ និងមានគោលបំណងចង់បង្ហាញអំពីព្រំប្រទល់ដែននេសាទ ក៏ដូចជាការជៀសវាងក្នុងការឈូសឆាយលុបបាត់
- នៅពេលដែលក្រុមហ៊ុនដំណើរការ សុំឱ្យក្រុមហ៊ុនជួយឧបត្ថម្ភជា សម្ភារៈ ថវិកា និងមធ្យោបាយទៅដល់សហគន៍នេសាទក្នុងកម្រិតណាមួយ ក្នុងគោលបំណងដើម្បីការពារ និងទប់ស្កាត់បទល្មើសនេសាទខុសច្បាប់ផ្សេងៗ។

### ៦.២.៤.២. កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ខេត្ត

នាថ្ងៃទី១០ ខែមិនា ឆ្នាំ២០១៧ វេលាម៉ោង០៨:៣០នាទីព្រឹក នៅសាលាខេត្តរតនគិរី ក្រុមការងារនៃក្រុមហ៊ុន RCBCC Co.Ltd ដោយមានការសម្របសម្រួលពីមន្ទីរបរិស្ថាន និងសាលាខេត្តរតនគិរី បានរៀបចំកិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់លើគម្រោងវិនិយោគអភិវឌ្ឍន៍លើវិស័យ ដាំដំណាំកសិ-ឧស្សាហកម្មរបស់ក្រុមហ៊ុនអេស ខេ ផ្លេនថេសិន ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់នៃ **ឯកឧត្តម ថង សាវុន** អភិបាលនៃគណៈអភិបាលខេត្តរតន

Draft

គិរី និងអ្នកចូលរួមចំនួន២៣ ដែលជាប្រធាន អនុប្រធាន និងតំណាងនៃមន្ទីរ និងស្ថាប័នជំនាញពាក់ព័ន្ធក្នុងខេត្តរតនគិរីទាំងអស់រួមមាន៖ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលមន្ទីរសុខាភិបាល មន្ទីររ៉ែ និងថាមពល មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ មន្ទីរផែនការ មន្ទីរទេសចរណ៍ មន្ទីរសាធារណៈការ និងដឹកជញ្ជូន មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខណ្ឌរដ្ឋបាលព្រៃឈើ ខណ្ឌរដ្ឋបាលជលផល អង្គការ NTFP តំណាងគណៈអភិបាល ស្រុក វ៉ឺនសៃ (បញ្ជីវត្តមានមានភ្ជាប់ ជូនក្នុងឧបសម្ព័ន្ធ)។ ក្រៅពីតំណាងមន្ទីរមួយចំនួនដូចជា៖ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរសុខាភិបាល មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរផែនការ មន្ទីរទេសចរណ៍ មន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានសម្តែងការគាំទ្រ និងមានមតិយោបល់ខ្លះៗក្នុងអង្គប្រជុំ ដូចរៀបរាប់ខាងក្រោម តំណាងស្ថាប័នផ្សេងៗទៀតបានសម្តែងការគាំទ្រដោយមិនបញ្ចេញយោបល់អ្វីឡើយ។

- **មន្ទីរបរិស្ថាន**

លោកតំណាងមន្ទីរបរិស្ថានមិនមានការជំទាស់ពីគម្រោងវិនិយោគនេះទេ ដោយសារថាក្រុមហ៊ុនបានសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានហើយ ដូច្នេះនឹងអាចមានវិធានការបញ្ចៀស និងកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមានបានត្រឹមត្រូវរួចហើយ។

- **មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

តំណាងមន្ទីរកសិកម្មមិនមានយោបល់ជំទាស់ទេ គ្រាន់តែមានសំណូមពរថា ក្នុងដំណាក់ការឈូសឆាយសាងសង់និងដាំដុះក្នុងកម្មវិធីទី២ គួរមានខាងមន្ទីរដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលចូលរួមផង។ លើសពីនេះ លោកសូមឲ្យបន្ថយការប្រើថ្នាំបាញ់ស្មៅនៅរដូវភ្លៀង ដូច្នេះ ក្រុមហ៊ុនត្រូវមានម៉ាស៊ីនកាត់ស្មៅនៅក្បែរមាត់អូរតូចៗ នឹងគម្លាតឱ្យបាន២០-៣០ម៉ែត្រ ពីមាត់អូរ និងធ្វើប្រឡាយទប់ស្កាត់ការហូរថ្នាំគិមីចូលប្រភពទឹក ជៀសវាងការហូរចូលនៃថ្នាំគីមីទៅតាមប្រភពទឹក។

- **មន្ទីរធនធានទឹក និងឧតុនិយម**

មន្ទីរធនធានទឹកនិងឧតុនិយមមានការគាំទ្រចំពោះ គម្រោងវិនិយោគនេះដោយសារគម្រោងបានសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានបានត្រឹមត្រូវមុនធ្វើការឈូសឆាយ។ លោកមានជាសំណូមពរដែលតម្រូវ ក្រុមហ៊ុនធ្វើការគ្រប់គ្រងដីចំណីរមាត់អូរដែលមានទំហំរហូតដល់១០០ទៅ៥០០ម ឲ្យបានត្រឹមត្រូវ ជៀសវាងការ ទន្ទ្រានពីសំណាក់ប្រជាជន ឬបុគ្គលិក កម្មករ ព្រោះទំហំផ្ទៃដីនេះធំ។

- **មន្ទីរផែនការ**

តំណាងមន្ទីរផែនការក៏មិនមានយោបល់ជំទាស់នឹងគម្រោងវិនិយោគមួយនេះដែរ លោកគ្រាន់តែមាន ជាយោបល់សូមឲ្យមានការគ្រប់គ្រង និងកត់ត្រាឲ្យបានច្បាស់លាស់នូវស្ថិតិប្រជាជនពលរដ្ឋ ដែលជាបុគ្គលិក កម្មករអន្តោរប្រវេសន៍ពីខេត្តផ្សេងៗ ដើម្បីរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម។

- **មន្ទីរសុខាភិបាល**

តំណាងខាងមន្ទីរសុខាភិបាលសម្តែងការគាំទ្រចំពោះគម្រោងវិនិយោគនេះ។ ទន្ទឹមនឹងនេះ លោកមានជាសំណូមពរឲ្យក្រុមហ៊ុនសាងសង់មណ្ឌលសុខភាពមួយនៅក្នុងតំបន់ក្រុមហ៊ុនផ្ទាល់ និងមានរថយន្តសង្គ្រោះបន្ទាន់



Draft

ធ្មប និងបុគ្គលិកពេទ្យឲ្យបានគ្រប់គ្រាន់តាមបទដ្ឋានសុខាភិបាល និងមានសេវាចាក់វ៉ាក់សាំងត្រឹមត្រូវ ជាពិសេសចាប់ពីឆ្នាំ២០២៣ទៅ ដោយតំបន់គម្រោងនឹងមានប្រជាជនដែលជាបុគ្គលិកម្មករចាប់ពី២០០០នាក់ឡើងទៅ រស់នៅ ហើយខេត្តរតនគិរីជាតំបន់ដាច់ស្រយាល និងកំពុងមានការខ្វះខាតផ្នែកសេវាកម្មសុខភាព។

➢ **មន្ទីរទេសចរណ៍**

លោកប្រធានមន្ទីរមានការគាំទ្រចំពោះគម្រោងវិនិយោគនេះ និងមានការកោតសរសើរចំពោះក្រុមហ៊ុន ទីប្រឹក្សាដែលបានសិក្សាលម្អិត។ លោកបានស្នើសូមក្រុមហ៊ុនអេសខេគាំទ្រការអភិរក្សព្រៃមួយចំនួនដែលនៅ សល់ ដោយសារនៅតំបន់គម្របព្រៃនេះមានសត្វស្លាប និងសត្វប្រភេទនានាយ៉ាងសំបូរបែប។ ប្រសិនបើក្រុមហ៊ុន អាចផ្សារភ្ជាប់កសិឧស្សាហកម្មជាមួយនឹងទេសចរណ៍ធម្មជាតិ ឬកសិទេសចរណ៍ នោះនឹងអាចជួយ លើកស្ទួយ ជីវភាពរបស់ប្រជាជន ក៏ដូចជាជួយអភិរក្សសត្វព្រៃ និងសត្វនានាផងដែរ។

➢ **មន្ទីរអភិវឌ្ឍន៍ជនបទ**

តំណាងមន្ទីរអភិវឌ្ឍន៍ជនបទមានការគាំទ្រនឹងគម្រោងវិនិយោគនេះ ហើយសូមឯកភាពតាមរបាយការណ៍របស់ក្រុមហ៊ុនទីប្រឹក្សា។ ប៉ុន្តែ សូមឲ្យក្រុមហ៊ុនម្ចាស់គម្រោងសិក្សាឲ្យបានច្បាស់លាស់ពីបទដ្ឋានរបស់មន្ទីរ និងក្រសួងអភិវឌ្ឍន៍ជនបទទាក់ទងនឹង៖ ការសាងសង់ផ្លូវលំ លូកាត់ថ្នល់ ផ្លូវកាត់ថ្នល់ និងអណ្តូងទឹកស្អាត។

➢ **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

តំណាងមន្ទីរក៏មិនមានការជំទាស់នឹងគម្រោងវិនិយោគមួយនេះដែរ ដោយគ្រាន់តែមានសំណូមពរដល់ក្រុមហ៊ុនឲ្យសាងសង់បន្ទប់សង្គ្រោះបឋម បន្ថែមពីលើការមានមណ្ឌលសុខភាព ដូចការស្នើសុំរបស់មន្ទីរ សុខាភិបាល។ លើសពីនេះ ដោយកម្មករភាគច្រើនមានគ្រួសារតាមមកជាមួយ ក្រុមហ៊ុនត្រូវមានសាលារៀននៅក្នុង តំបន់គម្រោងសម្រាប់កុមារដែលជាកូនៗបុគ្គលិក កម្មករ ប្រសិនបើទីតាំងសាលារៀននៅឆ្ងាយពីភូមិ ក៏ដូចជាមាន វត្តអារាមសម្រាប់ពេលបុណ្យទាន ដោយពួកគាត់អាចមិនបាច់ត្រលប់ទៅស្រុកកំណើត។

➢ **តំណាងគណៈអភិបាលខេត្ត**

ជារួម ឯកឧត្តមអភិបាលបានសម្តែងនូវការស្វាគមន៍ចំពោះគម្រោងវិនិយោគរបស់ក្រុមហ៊ុនអេសខេ និងគាំទ្រឲ្យមានការអភិវឌ្ឍកសិឧស្សាហកម្មនៅក្នុងខេត្តរតនគិរីដែលជាខេត្តគោលដៅ ដើម្បីប្រើប្រាស់ដីឲ្យអស់លទ្ធភាព ក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ កាត់បន្ថយភាពក្រីក្រ ក៏ដូចជាលើកកម្ពស់ជីវភាព ប្រជាជន និងសេដ្ឋកិច្ចមូលដ្ឋាន។ ឯកឧត្តមបានបញ្ជាក់ថា គម្រោងវិនិយោគរបស់ក្រុមហ៊ុនអេសខេនេះបានពន្យាពេលប្រតិបត្តិការយូរហើយដើម្បីរៀបចំកសាងផែនការមេ និងធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញនេះ ដូច្នេះ ឯកឧត្តមសង្ឃឹមថាក្រុមហ៊ុននឹងចាប់ផ្តើមដំណើរការក្នុងពេលឆាប់ៗខាងមុខនេះ បន្ទាប់ពីរបាយការការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញនេះត្រូវបានឯកភាព។ លើសពីនេះ ឯកឧត្តមបានជំរុញឲ្យ អ្នកចូលរួម ដែលជាតំណាងនៃមន្ទីរ និងស្ថាប័នជំនាញពាក់ព័ន្ធនានាក្នុងខេត្តរតនគិរីទាំងអស់ ចូលរួមពិនិត្យរបាយការឲ្យបានគ្រប់ជ្រុងជ្រោយ ផ្តល់យោបល់ឲ្យបានហ្មត់ចត់ល្អិតល្អន់ ដើម្បីឲ្យក្រុមហ៊ុនអាច សម្រេចគោលបំណងក្នុងការ

ចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ក៏ដូចជាលើកកម្ពស់ជីវភាពមូលដ្ឋាន និងចូល រួមអភិរក្សបរិស្ថាន និងគ្រប់គ្រងផលប៉ះពាល់ឲ្យមានប្រសិទ្ធភាពបំផុត។ មុននិងបញ្ចប់កិច្ចប្រជុំពិគ្រោះ យោបល់នេះ ឯកឧត្តមអភិបាលបានស្នើរនូវសំណូមពរពី គម្រោងនេះដូចខាងក្រោម៖

- ក្រុមហ៊ុនបានចុះកិច្ចសន្យាជាមួយរដ្ឋាភិបាលរួចហើយ ដូច្នេះក្រុមហ៊ុនត្រូវសិក្សាឲ្យបានហ្មត់ចត់អំពី បញ្ហាដីធ្លីជាមួយប្រជាជន ហើយពិនិត្យលទ្ធភាពរកវិធានការដោះស្រាយបញ្ហាដីធ្លីជាមួយប្រជាជន ឲ្យបាន ចប់សព្វគ្រប់ និងធ្វើការអភិវឌ្ឍឲ្យបានឆាប់រហ័សទាន់ពេលវេលា។
- បញ្ហាគឺនៅខាងឃុំតាឡាត មានការលំបាកដោះស្រាយដោយជាបញ្ហាឆ្លងខេត្ត ដូច្នេះទាមទារឲ្យមានការរាយការណ៍ពីខាងអាជ្ញាធរស្រុក និងឃុំតាឡាតផ្តល់យោបល់ មុននឹងអាចធ្វើការដោះស្រាយបាន។
- គម្រោងមិនទាន់ចាប់ផ្តើមសាងសង់ហេដ្ឋារចនាសម្ព័ន្ធពេញលេញនៅឡើយ ដូច្នេះមន្ទីរសាធារណៈការ និងដឹកជញ្ជូន និងមន្ទីរអភិវឌ្ឍន៍ជនបទត្រូវចូលរួមសិក្សារួមគ្នាដើម្បីតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ជាមួយហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោង ឲ្យមានសុខដុមនីយកម្ម។
- សូមមន្ទីរជំនាញចូលរួមត្រួតពិនិត្យនៅពេលធ្វើការឈូសឆាយ និងតម្រូវឲ្យមានឯកសណ្ឋានច្បាស់លាស់សម្រាប់កម្មករ ដើម្បីឲ្យប្រជាជនដឹងឮ និងជៀសវាងការភាន់ច្រឡំ។
- ក្រុមហ៊ុនត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការ គ្រប់គ្រងបុគ្គលិក កម្មករ ជៀសវាងការទន្ទ្រានយកដីចំណីអូរ ឬការកាប់ឆ្ការព្រៃមាត់អូរ។
- ប្រសិនបើអាច ពិនិត្យលទ្ធភាពបង្កើតទេសចរណ៍ធម្មជាតិ ឬកសិទេសចរណ៍ក្នុងតំបន់គម្រោង ដោយសារតំបន់គម្រោងសំបូរទៅដោយសត្វនិងព្រៃឈើ ក៏ដូចជាមានសង្វាក់ផលិតកម្មកសិផលប្លែកៗដែលអាចទាក់ទាញឲ្យភ្ញៀវទេសចរចាប់អារម្មណ៍មកកំសាន្ត និងបង្កើនសកម្មភាពសេដ្ឋកិច្ចក្នុងតំបន់បន្ថែម។
- គ្រប់គ្រងប្រជាពលរដ្ឋដែលជាកម្មករឲ្យបានត្រឹមត្រូវ ជៀសវាងការបង្កជំលោះជាមួយប្រជាពលរដ្ឋក្នុងស្រុក និងគ្រប់គ្រងទិន្នន័យ ស្ថិតិកម្មករ ចំណូលថ្មី ទាំងនោះឲ្យបានច្បាស់លាស់។
- លើកផែនការនិងទិសដៅយូរអង្វែងរបស់ក្រុមហ៊ុនឱ្យបានច្បាស់លាស់ ងាយស្រួលក្នុងការព្យាករណ៍ នូវបញ្ហាដែលអាចកើតមាន និងជៀសវាងបញ្ហាណាដែលទាក់ទងនឹងនយោបាយ។
- ផ្តល់អាទិភាពប្រជាពលរដ្ឋមូលដ្ឋាន ក្នុងការផ្តល់ឱកាសការងារជាបុគ្គលិក កម្មកររបស់ក្រុមហ៊ុនវិនិយោគដំណាំកសិ-ឧស្សាហកម្មនេះ។
- ចំពោះគ្រឿងចក្រដែលក្រុមហ៊ុនវិនិយោគនាំចូលមក ត្រូវរៀបបញ្ជីឲ្យបានច្បាស់ជាមួយស្ថាប័នជំនាញ ពាក់ព័ន្ធ ជៀសវាងការនាំចូលគ្រឿងចក្រដែលមិនត្រឹមត្រូវ។
- សូមក្រុមហ៊ុនទីប្រឹក្សាធ្វើការកែសម្រួលលើខ្លឹមសារនៃរបាយការណ៍ ជាពិសេសលើទិន្នន័យ និងតួលេខតាមការផ្តល់យោបល់ពីមន្ទីរជំនាញនានា។

Draft

## ៦.៣. សន្និដ្ឋាន

លទ្ធផលនៃការពិគ្រោះយោបល់ជាសាធារណៈ និងការស្ទង់មតិប្រជាជនដែលរស់នៅក្បែរតំបន់គម្រោង បង្ហាញថា ទោះជាគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុនមិនទាន់បានដំណើរការក្តី ក៏គម្រោងនេះមានបញ្ហាពាក់ព័ន្ធទៅនឹងដីស្រែចំការ (ពិសេសចំការវិលជុំ) ដីព្រៃសហគមន៍ដែលប្រជាជនអាស្រ័យផល ដីព្រៃបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ ព្រៃអារក្ស និងផ្នូរដូនតារបស់ជនជាតិដើមភាគតិចមួយចំនួន។ កិច្ចពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន បានបង្ហាញថា មូលហេតុចំបងដែលនាំឱ្យមានបញ្ហាទំនាស់ដីធ្លីរវាងប្រជាជននិងក្រុមហ៊ុនរួមមាន៖ (១) ការមិនទាន់មានកម្មសិទ្ធិដីធ្លីស្របច្បាប់ច្បាស់លាស់របស់ប្រជាជន សម្រាប់ប្រភេទដីខ្លះដែលពួកគាត់ធ្លាប់អាស្រ័យផលដូចជា ដីចំការវិលជុំ ដីផ្នូរដូនតា ព្រៃអារក្ខ និងដីបំរុងទុកសម្រាប់កូនចៅជំនាន់ក្រោយ ខណៈដែលក្រុមហ៊ុនបានទទួលសិទ្ធិពីរាជរដ្ឋាភិបាលសម្រាប់វិនិយោគលើដីទាំងនោះ និង(២)ក្រុមហ៊ុននៅមិនទាន់ចាប់ផ្តើមដំណើរការទើបដីរបស់ក្រុមហ៊ុននៅទំនេរ ក្នុងខណៈដែលប្រជាជនមួយចំនួនពុំមានដីធ្លីសម្រាប់ធ្វើស្រែចំការ ដូច្នេះទើបពួកគាត់ចូលរុករានដើម្បីប្រកបរបរចិញ្ចឹមជីវិត។ បញ្ហាប្រឈមដែលមិនគួរមើលរំលង គឺកង្វះខាតដីធ្លីសម្រាប់ធ្វើស្រែចំការនាពេលបច្ចុប្បន្ន និង ដីបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយនាពេលអនាគត ដែលជាក្តីបារម្ភដ៏ធំធេងរបស់ប្រជាជន។

ការព្រួយបារម្ភនេះបានពញ្ជាក់បន្ថែមទៀតតាមរយៈលទ្ធផលនៃការសិក្សាស្ទង់មតិ និងទស្សនៈប្រជាជនចំពោះគម្រោង។ ប្រជាជនភាគច្រើនបានបង្ហាញនូវការគាំទ្រចំពោះសកម្មភាពគម្រោង ប្រសិនបើគម្រោងមិនបំពានលើដីរបស់ពួកគាត់ ឬផ្តល់សំណងសមរម្យដល់គាត់ក្នុងករណីមានការប៉ះពាល់ និងចូលរំចំណែកក្នុងការកសាងហេត្ថារចនាសម្ព័ន្ធសម្រាប់ប្រជាជនមូលដ្ឋានដែលមានដូចជា៖ មណ្ឌលសុខភាព ផ្លូវ ស្ពាន សាលារៀន និងអណ្តូងទឹកជាដើម។

Draft

អាជ្ញាធរមូលដ្ឋាន ស្ថាប័នជំនាញនានា និងអង្គការសង្គមស៊ីវិល ដែលបានចូលរួមក្នុងការពិភាក្សាយោបល់នេះ ក៏បានសម្តែងនូវការគាំទ្រចំពោះគម្រោង ប៉ុន្តែព្រួយបារម្ភដូចដែលបានលើកឡើងដោយប្រជាជនដែរ។ កង្វះខាតដីធ្លីសម្រាប់ប្រជាពលរដ្ឋធ្វើស្រែចំការ ការបាត់បង់ផល-អនុផលព្រៃឈើ ការបំពានលើព្រៃអារក្ខអ្នកតា ផ្នូរដូនតារបស់សហគមន៍ជនជាតិដើមភាគតិច ការខូចគុណភាពទឹកនិងដីជាដើម គឺជាបញ្ហាដែលត្រូវដោះស្រាយជាចាំបាច់ មុនពេលដំណើរការគម្រោងចាប់ផ្តើម។ ទាំងប្រជាជន អាជ្ញាធរមូលដ្ឋាន និងអង្គការសង្គមស៊ីវិល បានស្នើសូមឲ្យក្រុមហ៊ុន សហការជាមួយភាគីពាក់ព័ន្ធ ជាពិសេសអាជ្ញាធរមូលដ្ឋាន និងអង្គការសង្គមស៊ីវិល ក្នុងការរៀបចំអនុវត្តកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន និងផែនការគ្រប់គ្រងបរិស្ថាន ដើម្បីកាត់បន្ថយផលប៉ះពាល់ដែលអាចកើតឡើងនៅពេលគម្រោងចាប់ផ្តើមដំណើរការ (កម្មវិធីទាំងនេះត្រូវបានដាក់បញ្ចូលក្នុងផែនការគ្រប់គ្រងបរិស្ថាន ក្នុងជំពូកទី៨) ។ នៅពេលដំណើរការអនុវត្តគម្រោង ក្រុមហ៊ុនត្រូវធានាថាមិនមានផលប៉ះពាល់ជាអវិជ្ជមានដល់ប្រជាជនមូលដ្ឋានឡើយ។ ទន្ទឹមនឹងនេះដែរ ការដោះស្រាយផលប៉ះពាល់ដីធ្លីជាលក្ខណៈបុគ្គល និងសមូហភាពក្តី ការជួយអភិវឌ្ឍន៍មូលដ្ឋាន និងការស្តារបរិស្ថានឡើងវិញ អាចបង្កើតឱកាសដល់ក្រុមហ៊ុន ក្នុងការកសាងភាពជាដៃគូជាមួយប្រជាជន និងសហគមន៍មូលដ្ឋាន។

# ជំពូកទី៧

# ហេតុប៉ះពាល់បរិស្ថាន

# និង

# វិធានការកាត់បន្ថយ

Draft

# ជំពូកទី៧៖ ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

## ៧.១. សេចក្ដីផ្ដើម

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបានធ្វើឡើងដើម្បីស្វែងយល់ឱ្យបានច្បាស់ពីបុព្វហេតុ ព្រមទាំងទំហំនៃផលប៉ះពាល់នានាដែលនឹងអាចកើតមានឡើងចំពោះធនធានបរិស្ថានធម្មជាតិ (ធនធានរូបសាស្ត្រ និងធនធានជីវសាស្ត្រ) និងសេដ្ឋកិច្ច-សង្គមនៃតំបន់គម្រោង ដោយសារតែសកម្មភាពគម្រោង។ ហេតុប៉ះពាល់ទាំងនោះ អាចនឹងកើតមានឡើងដោយផ្ទាល់ ឬប្រយោល និងជាវិជ្ជមាន ឬអវិជ្ជមាន។ ការស្វែងយល់ពីហេតុប៉ះពាល់ទាំងនោះ នឹងជួយឱ្យក្រុមហ៊ុនម្ចាស់គម្រោងអាចធ្វើការសម្រេចចិត្តបានត្រឹមត្រូវ ក្នុងការរៀបចំផែនការកាត់បន្ថយផលប៉ះពាល់ និងផែនការគ្រប់គ្រងបរិស្ថានឱ្យបានសមស្រប។ ដើម្បីឱ្យការវាយតម្លៃនេះមានភាពត្រឹមត្រូវ និងច្បាស់លាស់ ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយបែងចែកទៅតាមតំណាក់កាលនីមួយៗនៃគម្រោង រួមមាន៖

- **ដំណាក់កាលមុនប្រតិបត្តិគម្រោង៖** ចែកចេញជាពីរគឺ ទី០១-ដំណាក់កាលមុនសាងសង់ សំដៅដល់ដំណាក់កាលរៀបចំសំណុំឯកសារដែលជាតម្រូវការផ្លូវច្បាប់ ដើម្បីគាំទ្រដល់កិច្ចដំណើរការគម្រោង រួមទាំងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនេះ និងទី០២-ដំណាក់កាលសាងសង់ សំដៅដល់ដំណាក់កាលសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ការឈូសឆាយដីដើម្បីរៀបចំព្រំប្រទល់ ប្រព័ន្ធផ្លូវចេញ-ចូលតំបន់គម្រោង ប្រព័ន្ធផ្លូវធ្វើដំណើរក្នុងតំបន់គម្រោង ការកាប់ឆ្ការព្រៃ ការសាងសង់ទីស្នាក់ការការិយាល័យ កន្លែងស្នាក់នៅរបស់បុគ្គលិក-កម្មករ ប៉ុស្តិ៍យាម ការបែងចែកអនុតំបន់ និងសំណង់ផ្សេងៗទៀត)
- **ដំណាក់កាលប្រតិបត្តិគម្រោង៖** ជាដំណាក់កាលចាប់ផ្ដើមប្រតិបត្តិសកម្មភាពចម្បងៗនៃគម្រោងដែលរួមមាន ការឈូសឆាយរៀបចំដីដាំដុះ ការរៀបចំថ្នាលបណ្ដុះ ការដាំដំណាំ ការថែទាំដំណាំ ការប្រមូលផល ការកែច្នៃកសិផល និងការដឹកជញ្ជូនចូលនូវធាតុចូលកសិកម្ម និងដឹកជញ្ជូនចេញនូវកសិផល។
- **ដំណាក់កាលបញ្ចប់គម្រោង៖** សំដៅដល់ដំណាក់កាលចុងក្រោយនៃគម្រោង នៅពេលដែលរាល់សកម្មភាពទាំងអស់នៃគម្រោងត្រូវបញ្ឈប់ ហើយតំបន់គម្រោងនឹងត្រូវប្រគល់ជូនរាជរដ្ឋាភិបាលកម្ពុជាវិញ។

Draft

ការកំណត់កេបញ្ហាសំខាន់ៗដែលជាកត្តាចង្អុលបង្ហាញសម្រាប់វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនៅតាមដំណាក់កាលនីមួយៗខាងលើ ត្រូវបានធ្វើឡើងដូចខាងក្រោយ៖

**ក. ពត៌មានលម្អិតដែលទាក់ទងនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន-សង្គម៖** ប្រើប្រាស់ព័ត៌មានលម្អិតដែលបានរៀបរាប់នៅជំពូកផ្សេងៗ ជាពិសេសនៅជំពូកទី៤ (ការពិពណ៌នាអំពីគម្រោង) និងជំពូកទី៥ (ធនធានបរិស្ថានដែលមានស្រាប់) ដើម្បីធ្វើការវាយតម្លៃពីហេតុប៉ះពាល់ចំពោះបរិស្ថាន និងសង្គម។

**ខ. ការកំណត់ន័យនៃហេតុប៉ះពាល់បរិស្ថាន និងសង្គម**

ខ១. បរិវេណដែលទទួលរងការប៉ះពាល់

- ក្នុងបរិវេណគម្រោង៖ ជាការប៉ះពាល់ដោយផ្ទាល់ដែលកើតឡើងនៅក្នុងបរិវេណគម្រោង
- ក្រៅបរិវេណគម្រោង៖ ជាការប៉ះពាល់ដែលពង្រីក ឬជះឥទ្ធិពលទៅតំបន់ជុំវិញទីតាំងគម្រោង

ខ២. រយៈពេលនៃការទទួលរងការប៉ះពាល់

- រយៈពេលខ្លី៖ ជាការប៉ះពាល់ដែលកើតឡើងតែក្នុងរយៈពេលកសាង ឬខ្លីជាងនេះ

- រយៈពេលវែង៖ ជាការប៉ះពាល់ដែលកើតឡើងក្នុងរយៈពេលវែងជាង ៣ ឆ្នាំ (តាមការសន្មត់) ឬកើតឡើងរហូតដល់ចប់កិច្ចសន្យាគម្រោង

**គ. កម្រិតនៃហេតុប៉ះពាល់**

- កម្រិតខ្លាំង៖ ជាហេតុប៉ះពាល់ដែលអាចបង្កឡើងដោយសកម្មភាពគម្រោង និងធ្វើឲ្យមានការប្រែប្រួលខ្លាំងដល់ធនធានបរិស្ថានដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន និងអនាគត
- កម្រិតមធ្យម៖ ជាហេតុប៉ះពាល់ដែលបង្កឡើងដោយសកម្មភាពគម្រោង និងធ្វើឲ្យមានការប្រែប្រួលជាមធ្យមដល់ធនធានបរិស្ថានដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន និងអនាគត
- កម្រិតតិចតួច៖ ជាហេតុប៉ះពាល់ដែលបង្កឡើងដោយសកម្មភាពគម្រោង និងធ្វើឲ្យមានការប្រែប្រួលក្នុងកម្រិតទាបដល់ធនធានបរិស្ថានដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន និងអនាគត
- មិនប៉ះពាល់៖ ជាសកម្មភាពគម្រោង ដែលមិនមានការប៉ះពាល់ដល់ធនធានបរិស្ថានដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន និងអនាគត។

តារាង៧.១៖ តារាងម៉ាទ្រីសសម្រាប់កំណត់សក្តានុពលហេតុប៉ះពាល់បរិស្ថាន និងសង្គមពីសកម្មភាពគម្រោង

| ធនធានបរិស្ថាន និងសង្គម | ដំណាក់កាលមុនប្រតិបត្តិ | | | | ដំណាក់កាលប្រតិបត្តិ | | | | ដំណាក់កាលបញ្ចប់គម្រោង | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | អវិជ្ជមាន | គ្មាន | វិជ្ជមាន | កម្រិត | អវិជ្ជមាន | គ្មាន | វិជ្ជមាន | កម្រិត | អវិជ្ជមាន | គ្មាន | វិជ្ជមាន | កម្រិត |
| **ធនធានរូបសាស្ត្រ** | | | | | | | | | √ | | | **ខ្លាំង** |
| ការប្រែប្រួលបរិយាកាស | √ | | | តិចតួច | | | | | | | | |
| ការប្រែប្រួលសណ្ឋានដី | √ | | | មធ្យម | | | | | | | | |
| ការប្រែប្រួលទេសភាព | √ | | | មធ្យម | | | | | | | | |
| គុណភាពដី | √ | | | តិចតួច-មធ្យម | √ | | | មធ្យម | | | | |
| គុណភាពខ្យល់ | √ | | | តិចតួច-មធ្យម | √ | | | តិចតួច-មធ្យម | | | | |
| កម្រិតសំឡេង និងរំញ័រ | √ | | | មធ្យម | √ | | | តិចតួច | | | | |
| គុណភាពទឹកលើដី និងក្រោមដី | √ | | | តិចតួច-មធ្យម | √ | | | តិចតួច-មធ្យម | | | | |
| **ធនធានជីវសាស្ត្រ** | | | | | | | | | √ | | | **មធ្យម** |
| ធនធានព្រៃឈើ | √ | | | មធ្យម | | √ | | | | | | |
| ធនធានសត្វព្រៃ | √ | | | មធ្យម | √ | | | តិច | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | តូច | | | | |
| ព្រៃលិចទឹក និងព្រៃកោងកាង | √ | | | មធ្យម | | | | | | | | |
| ធនធានមច្ឆជាតិ | √ | | | តិច តូច-មធ្យម | √ | | | តិច តូច-មធ្យម | | | | |
| **ធនធានសេដ្ឋកិច្ច-សង្គម** | | | | | | | | | √ | | | **ខ្លាំង** |
| សុវត្ថិភាពការងារ និងសុខភាពបុគ្គលិក/កម្មករ | √ | | | តិច តូច | √ | | | តិច តូច | | | | |
| សុវត្ថិភាពក្នុងមូលដ្ឋាន | √ | | | តិច តូច | √ | | | តិច តូច | | | | |
| ស្ថានភាពសេដ្ឋកិច្ចប្រជាជនមូលដ្ឋាន | √ | | | តិច តូច-មធ្យម | √ | | | តិច តូច | | | | |
| ផ្លូវគមនាគមន៍ | √ | | | តិច តូច | | | | | | | | |
| បញ្ហាទេសចរណ៍ | √ | | | តិច តូច | | | | | | | | |
| ការរំខានដល់ការធ្វើចរាចរណ៍របស់ប្រជាជន | | | | | √ | | | តិច តូច | | | | |
| សិទ្ធការងាររបស់កម្មករ និងឱកាសការងាររបស់ប្រជាជនមូលដ្ឋាន | | | | | √ | | | តិច តូច | | | | |

Draft

## ៧.២. ហេតុប៉ះពាល់អវិជ្ជមាន និងវិធានការកាត់បន្ថយ ក្នុងដំណាក់កាលមុនប្រតិបត្តិ

### ៧.២.១. ធនធានរូបសាស្ត្រ

### ក. សណ្ឋានដី និងថានលេខា

<u>**ហេតុប៉ះពាល់៖**</u> យោងតាមផែនទី JICA ឆ្នាំ២០០២ រយៈកម្ពស់ដីក្នុងតំបន់គម្រោង (ជំពូកទី៥) បង្ហាញថា តំបន់គម្រោងជាតំបន់ខ្ពង់រាប ដែលមានរយៈកម្ពស់ប្រែប្រួលចន្លោះពី ៨០ម. ទៅ ២០០ម. ធៀបនឹងនីវ៉ូទឹកសមុទ្រ។ នៅក្នុងដំណាក់កាលសាងសង់គម្រោង លក្ខណៈសណ្ឋានដីនៃតបន់គម្រោងអាចមានការប្រែប្រួលក្នុងកម្រិតតិចតួច ដោយសារសកម្មភាពឈូសឆាយពង្រាបដីឲ្យរាបស្មើនៅតាមតំបន់ដែលមានទួល និងដំបូកខ្ពស់ៗ ក្នុងគោលបំណងធ្វើផ្លូវក្រវ៉ាត់ព្រំ ប្រព័ន្ធផ្លូវប្រើប្រាស់ក្នុងតំបន់គម្រោង ផ្លូវបែងចែកឡូតិ៍ និងអនុ

តំបន់ ផ្ទះកម្មករ និងសំណង់ហេដ្ឋារចនាសម្ព័នផ្សេងៗទៀត។ ផ្ទៃដីសំណង់ហេដ្ឋារចនាសម្ព័ន្ធ ដែលប្រឈមនឹងការប្រែប្រួលសណ្ឋានដី និងឋានលេខា មានទំហំសរុបប្រមាណ ៣៨៣ ហិកតា ៥,៩% នៃផ្ទៃដីគម្រោងសរុប) ឬច្រើនជាងនេះ អាស្រ័យនឹងការប្រតិបត្តិក្នុងពេលសាងសង់។

**__វិធានការកាត់បន្ថយ៖__** ដើម្បីកាត់បន្ថយការប៉ះពាល់ដល់សណ្ឋានដីនេះឲ្យស្ថិតនៅកម្រិតទាបបំផុត ក្រុមហ៊ុនត្រូវអនុវត្តនូវវិធានការមួយចំនួនដូចខាងក្រោម៖

- ធ្វើការឈូសឆាយដីរៀបចំដីទៅតាមលក្ខណៈសណ្ឋានដី និងទៅតាមទំហំដូចដែលបានគ្រោងក្នុងផែនការមេគម្រោង ដោយសហការជាមួយមន្ត្រីជំនាញមានសមត្ថកិច្ច ដើម្បីវាយតម្លៃឲ្យបានត្រឹមត្រូវ។ បន្ថែមលើនេះទៀត តំបន់ភ្នំ ឬតំបន់ដែលមានរយៈកម្ពស់ខ្ពស់ដែលស្ថាប័នជំនាញតម្រូវឲ្យរក្សាទុក គឺក្រុមហ៊ុនត្រូវតែរក្សាទុក។
- រៀបចំសាងសង់ផ្លូវឆ្លងកាត់នានាក្នុងតំបន់គម្រោង (optimum road size) ឱ្យមានទំហំសមស្រប ដើម្បីជានាប្រសិទ្ធភាព និងសុវត្ថិភាពការងារ សំដៅជៀសវាងការអូសបន្លាយពេលពេលសាងសង់ (ឬទុកដីនៅទំនេរ) ដែលអាចនឹងបង្កឲ្យមានការហូរច្រោះដីកើតឡើង។

### ខ. គុណភាពដី

**__ហេតុប៉ះពាល់៖__** ទីតាំងដីសម្បទានដែលក្រុមហ៊ុនទទួលបានសម្រាប់គម្រោងអភិវឌ្ឍន៍នេះ ជាដីផលិតកម្មដំបូង (Primary Industry) ដោយសារវាគ្របដណ្តប់ទៅដោយព្រៃឈើ។ ដីផលិតកម្មដំបូងនេះ នឹងត្រូវប្រែក្លាយទៅដីហេដ្ឋារចនាសម្ព័ន្ធគម្រោង ចំនួន ៣៨៣ ហិកតា (៥,៩% នៃផ្ទៃដីគម្រោងសរុប) ឬច្រើនជាងនេះ អាស្រ័យនឹងការប្រតិបត្តិក្នុងពេលសាងសង់។ តាមបទពិសោធន៍ ដីដែលបានប្រែក្លាយទៅជាដីហេដ្ឋារចនាសម្ព័ន្ធ មិនអាចប្រើក្លាយទៅជាដីផលិតកម្មដំបូងវិញនោះទេ។

**__វិធានការកាត់បន្ថយ៖__** ដើម្បីកាត់បន្ថយការប៉ះពាល់ដល់គុណភាពដីឲ្យស្ថិតនៅកម្រិតទាបបំផុត ក្រុមហ៊ុននឹងអនុវត្តនូវវិធានការមួយចំនួនដូចខាងក្រោម៖

- សាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅលើប្រភេទដីដែលមានគុណភាពទាប (Plinthite podzols) ឱ្យបានច្រើនជាអតិបរិមា ដើម្បីកាត់បន្ថយការបាត់បង់ប្រភេទដីដែលមានគុណភាពខ្ពស់ (Gray hydromorphics)
- ធ្វើការឈូសឆាយដីរៀបចំដីទៅតាមទំហំដីដូចដែលបានគ្រោងក្នុងផែនការមេគម្រោង ដើម្បីជៀសវាងការបាត់បង់ដីផលិតកម្មដំបូងលើសពីផ្ទៃដីហេដ្ឋារចនាសម្ព័ន្ធគម្រោង។
- បកយកដីស្រទាប់លើដែលមានជីជាតិ ដើម្បីចាក់គ្របលើទីតាំងជុំវិញសំណង់អគារ និងរៀបចំទីតាំងទាំងនោះទៅជាសួនច្បារ ឬដាំរុក្ខជាតិ ដើមឈើលម្អនៅជុំវិញសំណង់អគារទាំងនោះ។
- រៀបចំ និងអនុវត្តឱ្យបានត្រឹមត្រូវតាម ផែនការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេង។

Draft

**គ. ប្រព័ន្ធជលសាស្ត្រ (ទំហំ ជម្រៅ និងលំហូរទឹក)**

**ហេតុប៉ះពាល់៖** យោងតាមផែនទី JICA ឆ្នាំ២០០២ និងការចុះពិនិត្យជាក់ស្តែងក្នុងកំពេលសិក្សា ក្រៅពីមានទីតាំងជាប់ទន្លេសេសាន នៅក្នុងតំបន់គម្រោង មានអូរសំខាន់ចំនួន ០៧គឺ៖ អូរភ្នំ អូរតាង ពាមមាត់អូរ អូរតាឡាត អូរជរិក អូរកន្សែង និងអូរស្វាយរៀង ដែលហូរកាត់ ឬមានប្រភពនៅក្នុងទីតាំងគម្រោងរួចហើយ ឆ្ពោះទៅទន្លេសេសាន។ អូរទាំងនេះតភ្ជាប់ជាមួយដៃអូរតូចៗជាច្រើនទៀត ដែលមិនមានឈ្មោះ។ នៅដំណាក់កាលនេះ ស្ថានភាពប្រព័ន្ធជលសាស្ត្រ ដែលបានរៀបរាប់ខាងលើ អាចនឹងមានការប្រែប្រួលក្នុងកម្រិតតិចតួចដោយសារ៖

- ការឈូសឆាយដីព្រៃ ធ្វើប្រព័ន្ធផ្លូវ ផ្លូវក្រវ៉ាត់ព្រំ អាចនឹងលុបប្រព័ន្ធអូរ និងដៃអូរមួយចំនួនដូចមានរៀបរាប់ខាងលើ។
- ការឈូសឆាយដីព្រៃនៅតាមមាត់អូរ ដើម្បីសាងសង់ផ្ទះស្នាក់នៅ ឬការដ្ឋានក្រុមហ៊ុន ឬសំណង់អគារផ្សេងៗទៀត ក៏នឹងអាចធ្វើឲ្យប្រព័ន្ធអូរទាំងនោះ កកស្ទះមិនមានទឹកហូរ ដោយសារការហូរច្រោះកករដី ឬការហូរចូលមែកឈើ ស្លឹកឈើ។ល។
- នៅរដូវប្រាំងប្រព័ន្ធអូរ ដៃអូរ និងត្រពាំងមួយចំនួនមានសភាពគោកដោយកន្លែង ពោលគឺមានទឹកដក់តិចៗនៅតាមអន្លង់ ដូច្នេះក្រុមហ៊ុនអាចនឹងធ្វើការស្ទាក់ ឬធ្វើទំនប់ទប់ទឹក សម្រាប់ទុកទឹកប្រើប្រាស់ក្នុងតំបន់គម្រោង។

**វិធានការកាត់បន្ថយ៖** ដើម្បីកាត់បន្ថយការប៉ះពាល់នេះឲ្យនៅកម្រិតទាបបំផុត ក្រុមហ៊ុននឹងអនុវត្តនូវវិធានការមួយចំនួនដូចខាងក្រោម៖

- ក្នុងករណីសាងសង់ហេដ្ឋារចនាសម្ព័ន្ធឆ្លងកាត់ប្រព័ន្ធផ្លូវទឹក ក្រុមហ៊ុននឹងសាងសង់ស្ពានឆ្លងកាត់ ឬរៀបចំប្រព័ន្ធលូបង្ហូរឱ្យបានត្រឹមត្រូវ។
- ដើម្បីការពារមិនឲ្យប៉ះពាល់ដល់ចរន្តទឹក និងបរិមាណទឹក ក្នុងករណីដែលក្រុមហ៊ុនធ្វើទំនប់ស្ទាក់ទឹក គឺក្រុមហ៊ុននឹងសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញមានសមត្ថកិច្ច ជាពិសេសមន្ទីរធនធានទឹក និងឧតុនិយមខេត្ត ដើម្បីវាយតម្លៃ និងផ្តល់អនុសាសន៍បច្ចេកទេស។
- ក្រុមហ៊ុននឹងសាងសង់សំណង់ផ្សេងៗនៅចម្ងាយយ៉ាងហោចណាស់ ១០០ម. ទៅ១៥០ម. ពីអូរ និងប្រព័ន្ធផ្លូវទឹកនានា ដើម្បីការពារការហូរច្រោះដី និងកំទេចកំទីមែកឈើ ស្លឹកឈើ ចូលទៅក្នុងប្រព័ន្ធផ្លូវទឹកទាំងនោះ។

**ឃ. គុណភាពទឹក (ទឹកក្រោមដី និងលើដី)**

**ហេតុប៉ះពាល់៖** នៅក្នុងដំណាក់ការនេះ គុណភាពទឹកលើដីទាំង ០៧កន្លែង និងក្រោមដី ០៣ កន្លែង (ជំពូកទី៥.១.២.៣) អាចធ្លាក់ចុះក្នុងកម្រិតតិចតួចដោយសារ៖

- ការឈូសឆាយព្រៃឈើតាមមាត់អូរដោយចេតនា ឬអចេតនា ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ
- ការគ្រប់គ្រងសំណល់រឹងមិនបានល្អ ដូចជាសំណល់ផ្ទះបាយ សំណល់ថង់ប្លាស្ទិក សំបកដប សំបកកំប៉ុង និង លាមកមនុស្ស ឬ សត្វជាដើម

Draft

- ការគ្រប់គ្រងសំណល់រាវមិនបានល្អ ដូចជាសំណល់រាវចេញពីការប្រើប្រាស់ទូទៅរបស់បុគ្គលិក-កម្មករ និងបង្គន់អនាម័យជាដើម។
- ការគ្រប់គ្រងសំណល់ប្រេងមិនបានល្អ ដោយធ្វើឱ្យមានការលេចជ្រាបពីម៉ាស៊ីន គ្រឿងចក្រ និងកន្លែងជួសជុលគ្រឿងចក្ររបស់ក្រុមហ៊ុន។

<u>**វិធានការកាត់បន្ថយ៖**</u> ដើម្បីកាត់បន្ថយការប៉ះពាល់ដល់គុណភាពទឹកឲ្យនៅកម្រិតទាបបំផុត ក្រុមហ៊ុននឹងអនុវត្តវិធានការដូចខាងក្រោម៖

- រាល់ការឈូសឆាយទាំងអស់ គឺក្រុមហ៊ុននឹងអនុវត្តតែក្នុងរដូវប្រាំងតែប៉ុណ្ណោះ ដើម្បីកាត់បន្ថយទំហំនៃការហូរច្រោះ។ (គួរកត់សម្គាល់ផងដែរថា តាមរយៈផែនទីទីជម្រាល និងការសិក្សាលើការហូរច្រោះនៅក្នុងជំពូកទី៥ កម្រិតជម្រាល និងសំណឹកដីនៅក្នុងតំបន់គម្រោង មានការប្រែប្រួលតិចតួចប៉ុណ្ណោះ ដែលមិនអាចធ្វើឲ្យមានការហូរច្រោះខ្លាំងនោះទេ។)
- រក្សាទុកព្រៃតាមទ្រនាប់ដងអូរ និងតំបន់មាត់ទឹកនានា យ៉ាងហោចណាស់ចម្ងាយពី ១០០ម. ទៅ ១៥០ម. សងខាងមាត់អូរទៅតាមស្ថានភាពជាក់ស្តែង ដើម្បីការពារការហូរច្រោះដី និងការហូរនាំនូវសំណល់ផ្សេងៗចូលទៅក្នុងប្រភពទឹក។
- រៀបចំ និងអនុវត្តឱ្យបានត្រឹមត្រូវតាម ផែនការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេង
- តាមដានគុណភាពទឹកក្នុងតំបន់គម្រោង តាមរយៈការយកសំណាកទឹកទៅពិនិត្យនៅមន្ទីរពិសោធន៍ឱ្យបានទៀងទាត់ (២ដង/ឆ្នាំ) ព្រមទាំងសហការជាមួយស្ថាប័នមានសមត្ថកិច្ច ក្នុងការស្វែងរក និងអនុវត្តវិធានការចាំបាច់នានា ក្នុងករណីពិនិត្យឃើញថាគុណភាពទឹកមានបម្រែបម្រួលជាអវិជ្ជមាន ដើម្បីកែលម្អ ឬស្តារគុណភាពទឹកឲ្យបានល្អប្រសើរឡើងវិញ។

**ង. គុណភាពខ្យល់**

<u>**ហេតុប៉ះពាល់៖**</u> នៅដំណាក់កាលនេះ គុណភាពខ្យល់ នឹងអាចមានការធ្លាក់ចុះក្នុងកម្រិតតិចតួច ដោយសារការសាយភាយធូលី ផ្សែង និងឧស្ម័នផ្សេងៗចូលទៅក្នុងបរិយាកាស តាមរយៈសកម្មភាពឈូសឆាយ ឬការដឹកជញ្ជូនសម្ភារសំណង់ ដោយប្រើប្រាស់គ្រឿងចក្រ គ្រឿងម៉ាស៊ីនផ្សេងៗ ការដុតសំណល់រឹង និងសំណល់កំទេចកំទីមែកឈើ ជាដើម។

<u>**វិធានការកាត់បន្ថយ៖**</u> ដើម្បីកាត់បន្ថយការប៉ះពាល់នេះឲ្យស្ថិតនៅកម្រិតទាបបំផុត ក្រុមហ៊ុននឹងអនុវត្តនូវវិធានការមួយចំនួនដូចខាងក្រោម៖

- រាល់ការឈូសឆាយដីព្រៃដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ គឺត្រូវអនុវត្តតាមដំណាក់កាលដែលបានកំណត់ក្នុងផែនការមេ រួចធ្វើការសាងសង់ និងបង្ហាប់ដីភ្លាមដោយដោយមិនទុកដីឲ្យនៅទំនេរចោល។
- ការសាងសង់សំណង់ផ្សេងៗ នឹងត្រូវធ្វើឡើងនៅចម្ងាយយ៉ាងហោចណាស់ ១០០ម. ទៅ ១៥០ម. ពីអូរ ដើម្បីរក្សាទុកព្រៃមាត់អូរឲ្យជួយទប់ស្កាត់ការហុយធូលីទៅតំបន់ផ្សេង និងជួយបន្សុទ្ធខ្យល់។
- នឹងធ្វើការស្រោចទឹក និងបង្ហាប់ដីឲ្យអស់លទ្ធភាព នៅពេលឈូសឆាយស្លាបនាផ្លូវនានា។

Draft

- នឹងធ្វើការគ្រប់គ្រង និងថែទាំគ្រឿងចក្រ យាន្តជំនិះឱ្យបានល្អ និងឱ្យបានទៀងទាត់ (ដូចជាការប្តូរប្រេងរំអិលតាមកាលកំណត់ និងមិនធ្វើការដោះចេញនូវតម្រងចម្រោះឧស្ម័នពុលដែលមានស្រាប់លើគ្រប់គ្រឿងចក្រ និងយាន្តជំនិះ) ដើម្បីកាត់បន្ថយបរិមាណឧស្ម័នបំភាយចូលបរិយាកាស។
- អប់រំ-ណែនាំឱ្យប្រើប្រាស់គ្រឿងចក្រ និងគ្រឿងម៉ាស៊ីន ឲ្យមានប្រសិទ្ធិភាព ដោយជៀសវាងនូវការបញ្ឆេះម៉ាស៊ីនទុកចោលនៅពេលដែលមិនចាំបាច់ ឬពេទ៍ខ្លាំងពេក
- ពិនិត្យតាមដានកម្រិតនៃការបញ្ចេញឧស្ម័នបំពុលពីគ្រឿងចក្រ និងយាន្តយន្តដែលប្រើប្រាស់ក្នុងដំណើរការគម្រោង ព្រមទាំងធ្វើការជួសជុល ឬផ្លាស់ប្តូរថ្មីនូវគ្រឿងចក្រ ឬយានយន្តណាដែលបញ្ចេញឧស្ម័នបំពុលលើសកម្រិតស្តង់ដារដែលអនុញ្ញាតឱ្យបញ្ចេញសម្រាប់ប្រភពចល័ត ដូចមានកំណត់នៅក្នុងអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងសំឡេង (ឆ្នាំ២០០០)។
- កំណត់ល្បឿនបើកបរក្នុងការដឹកជញ្ជូនសម្ភារសំណង់ និងបរិក្ខាផ្សេងៗចេញ-ចូលក្នុងតំបន់គម្រោង ជាពិសេសតំបន់ទីប្រជុំជន មន្ទីរពេទ្យ និងសាលារៀន ជាដើម។
- ជៀសវាងការដុតសំណល់ថង់ផ្លាស្ទិក និងសំណល់រឹងផ្សេងទៀតនៅទីវាល។
- ដាំដើមឈើឡើងវិញនៅតាមការដ្ឋាន និងដងផ្លូវក្នុងទីតាំងគម្រោង ព្រមទាំងនៅតាមតំបន់ដែលយានយន្តរបស់ក្រុមហ៊ុនឆ្លងកាត់ បន្ថែមលើការរក្សាទុកព្រៃតាមទ្រនាប់ដងអូរ ដើម្បីជួយទប់ស្កាត់ការហុយធូលីទៅតំបន់ផ្សេង និងជួយបន្សុទខ្យល់។

### ច. សំឡេង-រំញ័រ

**<u>ហេតុប៉ះពាល់៖</u>** នៅដំណាក់កាលនេះ សំឡេងរំខានចេញពីសកម្មភាពគម្រោង នឹងអាចកើតមានក្នុងកម្រិតតិចតួចបំផុត ចំណែកឯរំញ័រនឹងមិនបង្កឱ្យមានការរំខាននោះទេ។ សំឡេងរំខាន អាចនឹងកើតចេញពី ដំណើរការរណាយន្តអារឈើមុនធ្វើការឈូសឆាយ គ្រឿងចក្រឈូសឆាយ ម៉ាស៊ីនភ្លើង និងម៉ាស៊ីនផ្សេងៗទៀត ក្នុងអំឡុងពេលឈូសឆាយ ឬសាងសង់ ព្រមទាំងសំឡេងចេញពីរថយន្តដឹកជញ្ជូនសម្ភារសំណង់ និងសម្ភារបរិក្ខាផ្សេងៗ។

**<u>វិធានការកាត់បន្ថយ៖</u>** ដើម្បីកាត់បន្ថយការប៉ះពាល់នេះឲ្យស្ថិតនៅកម្រិតទាបបំផុត ក្រុមហ៊ុននឹងអនុវត្តនូវវិធានការមួយចំនួនដូចខាងក្រោម៖

- អនុវត្តការងារដឹងជញ្ជូន ឈូសឆាយ និងសាងសង់ តែពេលថ្ងៃ ដោយជៀសវាងអនុវត្តការងារនៅពេលយប់។
- ប្រើប្រាស់គ្រឿងចក្រ និងយានយន្ត ដែលមានបំពាក់ឧបករណ៍កាត់បន្ថយសំឡេង ឬដែលមានការបញ្ចេញសំឡេងគោរពតាមស្តង់ដារអនុញ្ញាតសម្រាប់ប្រភពចល័ត ដូចមានកំណត់ក្នុងអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេងសាងសង់បន្ទប់សម្រាប់ដាក់ម៉ាស៊ីនភ្លើង ដោយបំពាក់នូវស៊ីម៉ាំងដែលមានសំឡេងតិច។
- កំណត់ល្បឿនបើកបរក្នុងការដឹកជញ្ជូនសម្ភារសំណង់ និងបរិក្ខាផ្សេងៗចេញ-ចូលក្នុងតំបន់គម្រោង ជាពិសេសតំបន់ទីប្រជុំជន មន្ទីរពេទ្យ និងសាលារៀន ជាដើម។

Draft

### ៧.២.២. ធនធានជីវសាស្ត្រ

#### ក. ព្រៃឈើ និងសារពើរុក្ខជាតិ

**ហេតុប៉ះពាល់៖** សកម្មភាពឈូសឆាយ និងកាប់ឆ្ការព្រៃ ដើម្បីរៀបចំថ្នាល និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានាក្នុងតំបន់គម្រោង នឹងធ្វើឱ្យបាត់បង់ធនធានព្រៃឈើរហូតដល់ ៣៨៣ ហិកតា (៥,៩% នៃផ្ទៃដីគម្រោងសរុប) អាស្រ័យនឹងការប្រតិបត្តិក្នុងពេលសាងសង់ដែលមាននៅក្នុងទីតាំងគម្រោង។ គួរកត់សម្គាល់ថា នៅក្នុងទីតាំងគម្រោង មានផ្ទៃដីមួយចំនួនជាផ្ទៃដីគ្មានគម្របព្រៃស្រាប់ ឬព្រៃឈើនៅតំបន់នោះត្រូវបានកាប់ទន្រ្ទានធ្វើស្រែ-ចំការដោយជនឆ្លៀតឱកាសមួយចំនួនរួចទៅហើយ។

**វិធានការកាត់បន្ថយ៖**

ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ដល់ធនធានព្រៃឈើដែលមាននៅក្នុងទីតាំងតំបន់គម្រោង ក្រុមហ៊ុននឹងអនុវត្តនូវវិធានការដូចខាងក្រោម៖

- ក្រុមហ៊ុននឹងធ្វើការឈូសឆាយព្រៃឈើសម្រាប់រៀបចំហេដ្ឋារចនាសម្ព័ន្ធគម្រោង តែទៅតាមទំហំផ្ទៃដីដូចកំណត់នៅផែនការមេ ដែលបានឯកភាពដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រុមហ៊ុន នឹងដាំឡើងវិញនូវដើមឈើលម្អ នៅតាមដងផ្លូវក្នុងតំបន់គម្រោង និងនៅជុំវិញសំណង់អគារនានាក្នុងទីតាំងគម្រោង។

#### ខ. ធនធានសត្វព្រៃ

**ហេតុប៉ះពាល់៖**

លទ្ធផលនៃសិក្សាពីធនធានសត្វព្រៃ ក្នុងជំពូក៥ បានបង្ហាញថា នៅក្នុងតំបន់គម្រោងមានប្រភេទសត្វព្រៃទាំងអស់ប្រមាណ ៣៥១ប្រភេទ។ វត្តមាននៃគម្រោង នឹងបណ្តាលឲ្យមានផលប៉ះពាល់ក្នុងកម្រិតមធ្យមចំពោះធនធានសត្វព្រៃ ដែលផលប៉ះពាល់នេះអាចនឹងកើតឡើងដោយផ្ទាល់ ឬដោយប្រយោល ព្រមទាំងកើតឡើងក្នុងរយៈពេលយូរអង្វែង។ បុព្វហេតុនៃផលប៉ះពាល់ទាំងនោះមាន៖

- បាត់បង់ជម្រក និងប្រភពចំណីដោយសារការកាប់ឆ្ការព្រៃដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធគម្រោង
- ការរំខានដែលបង្កដោយសម្លេងគ្រឿងចក្រ និងយានយន្ត ក្នុងកិច្ចដំណើរការសាងសង់នានា
- ការគំរាមកំហែងដោយសារសកម្មភាពបរបាញ់ខុសច្បាប់ពីសំណាក់បុគ្គលិក-កម្មករគម្រោងក្នុងករណីដែលមានការអប់រំ-ណែនាំ និងវិន័យតឹងរឹងក្នុងក្រុមហ៊ុន បន្ថែមលើកត្តាគំរាមកំហែងដោយសារសកម្មភាពបរបាញ់ខុសច្បាប់ដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន។

**វិធានការកាត់បន្ថយ៖**

ដើម្បីកាត់បន្ថយ ឬជៀសវាងនូវផលប៉ះពាល់ដូចបានរៀបរាប់ខាងលើ ក្រុមហ៊ុននឹងអនុវត្តនូវវិធានការដូចខាងក្រោម៖

- ធ្វើការឈូសឆាយព្រៃឈើជាតំណាក់ៗតាមទីតាំងដែលត្រូវការសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធគម្រោង ដើម្បីទុកផ្លូវ និងពេលវេលាឲ្យសត្វព្រៃធ្វើការភៀសខ្លួនទៅកាន់តំបន់ផ្សេងៗ។
- កាត់បន្ថយឲ្យអស់លទ្ធភាពនូវការរំខានដោយសំឡេង-រំញ័រ ដែលកើតចេញពីសកម្មភាពឈូសឆាយ និងសាងសង់ តាមរយៈការប្រើប្រាស់គ្រឿងចក្រ ឬយានយន្តដែលបញ្ចេញសម្លេង-រំញ័រតិច។

- អប់រំ និងហាមឃាត់បុគ្គលិក-កម្មករគម្រោង និងបុគ្គលិក-កម្មកររបស់អ្នកម៉ៅការ (ឈូសឆាយ និងសាងសង់) មិនឱ្យធ្វើការបរបាញ់ប្រភេទសត្វព្រៃដែលមាននៅក្នុងតំបន់ដោយខុសច្បាប់ ព្រមទាំងធ្វើការផ្សព្វផ្សាយឱ្យពួកគាត់បានដឹងពីអត្ថប្រយោជន៍សត្វព្រៃ
- ដាក់បំរាមមិនឲ្យបុគ្គលិក-កម្មករ បរិភោគសាច់សត្វព្រៃ និងមិនអនុញ្ញាឱ្យទិញសាច់ ឬសត្វព្រៃពីអ្នកលក់ ឬពីប្រជាពលរដ្ឋមូលដ្ឋាន។
- លើកទឹកចិត្តដល់បុគ្គលិក-កម្មករ (ផ្តល់ជារង្វាន់) ឱ្យចូលរួមរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ចក្នុងករណីសង្កេតឃើញមានការលួចបរបាញ់ខុសច្បាប់។ធ្វើការផាកពិន័យតឹងរឹង (ឧ. ព្រមាន ឬបញ្ឈប់ពីការងារ) ក្នុងការណីបុគ្គលិក-កម្មករណាមួយប្រព្រឹត្តិបទល្មើស និងនិងបំរាមពាក់ព័ន្ធនឹងការបរបាញ់ និងបរិភោគសត្វព្រៃ។

**គ. ធនធានមច្ឆជាតិ**

**<u>ហេតុប៉ះពាល់៖</u>**

លទ្ធផលនៃការសិក្សាវាយតម្លៃអំពីធនធានមច្ឆជាតិ បានបង្ហាញថានៅក្នុង និងក្បែរទីតាំងតំបន់គម្រោងមានវត្តមានមច្ឆជាតិទាំងអស់ប្រមាណ ២៤៣ប្រភេទ។ ប្រភេទមច្ឆជាតិទាំងនេះអាចនឹងរងផលប៉ះពាល់ក្នុងកម្រិតតិចតួច ដោយសាកត្តាដូចខាងក្រោម៖

- ការធ្លាក់ចុះនៃគុណភាពទឹកក្នុងអូរ ដោយសារតែការហូរច្រោះដីល្បាប់ពីទីតាំងការដ្ឋានសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ចូលទៅក្នុងអូរ និងការបំពុលទឹកដែលកើតឡើងដោយសារការគ្រប់គ្រងកាកសំណល់រឹងរាវមិនបានត្រឹមត្រូវតាមបច្ចេកទេស។
- ការស្តារឡើងវិញនូវប្រព័ន្ធផ្លូវទឹក និងការសាសង់ស្រះ ឬអាងស្តុកទឹកដែលនឹងធ្វើឱ្យមានការប្រែប្រួលចរន្តទឹក។
- ការនេសាទខុសច្បាប់ពីសំណាក់បុគ្គលិក-កម្មករគម្រោង ដែលនឹងជាសម្ពាធមួយទៀតបន្ថែមលើសម្ពាធនៃការនេសាទខុសច្បាប់ដែលកំពុងកើតមានឡើងនៅក្នុងតំបន់។

**<u>វិធានការកាត់បន្ថយ៖</u>**

ដើម្បីកាត់បន្ថយផលប៉ះពាល់ទៅលើធនធានមច្ឆជាតិដូចបានរៀបរាប់ខាងលើ ក្រុមហ៊ុននឹងអនុវត្តនូវវិធានការដូចខាងក្រោម៖

- សហការជាមួយស្ថាប័នមានសមត្ថកិច្ច ដើម្បីជៀសវាងការរំខានដល់កន្លែង ឬតំបន់ដែលជម្រកមច្ឆជាតិសំខាន់ៗ ក្នុងករណីដែលក្រុមហ៊ុនស្តារប្រព័ន្ធផ្លូវទឹកទោះជាក្នុងគោលបំណងអ្វីក៏ដោយ។
- ធ្វើការលែងកូនមច្ឆជាតិនៅតាមប្រព័ន្ធផ្លូវទឹក ដែលមាននៅក្នុង និងក្បែរទីតាំងតំបន់គម្រោងក្នុងរយៈពេល១ឆ្នាំម្តង។
- ដាក់ពិន័យ ចំពោះបុគ្គលិក-កម្មករ ដែលបានលួចនេសាទត្រីខុសច្បាប់ និងលើកទឹកចិត្តដល់បុគ្គលិក-កម្មករឱ្យចូលរួមរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ច ក្នុងករណីសង្កេតឃើញមានសកម្មភាពលួចធ្វើការនេសាទត្រីខុសច្បាប់។
- រៀបចំ និងអនុវត្តឱ្យបានត្រឹមត្រូវតាម ផែនការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេង

### ៧.២.៣ ធនធានសេដ្ឋកិច្ច និងសង្គម

#### ក. កម្មសិទ្ធិដីធ្លី និងការប្រើប្រាស់ដី

ក១. ហេតុ/ផលប៉ះពាល់៖

នៅក្នុងដំណាក់កាលនេះ គម្រោងបានបង្កការបារម្ភដល់ប្រជាជនដែលរស់នៅក្នុងនិងក្បែរតំបន់គម្រោង ដោយសារសកម្មភាពសិក្សាវាយតម្លៃ និងការកំណត់ព្រំដីពីសំណាក់ក្រុមហ៊ុននិងស្ថាប័នជំនាញពាក់ព័ន្ធនានា ដែលបានចុះទៅសិក្សាពីស្ថានភាពដីធ្លី ព្រៃឈើ នៅតំបន់ដីសម្បទានសេដ្ឋកិច្ច។ ដោយមិនបានដឹងឮ និងយល់ច្បាស់លាស់អំពីសកម្មភាពទាំងនេះ ពួកគាត់មានការព្រួយបារម្ភពីការបាត់បង់ និងការរំលោភយកដីស្រែ-ចម្ការ ដីចម្ការវិលជុំ ដីបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ ដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច និងដីលែងសត្វរបស់ពួកគាត់ពីសំណាក់ក្រុមហ៊ុន។

ជាក់ស្តែង ទោះបីគម្រោងមិនទាន់ដំណើរការដាំដុះ ប៉ុន្តែវត្តមានគម្រោងក្នុងតំបន់ និងដំណើរការកំណត់ព្រំប្រទល់ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន បានប៉ះពាល់ដល់ព្រៃសហគមន៍ ព្រៃបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ ព្រៃអារក្ស ផ្នូរដូនតា ប្រភពទឹកធម្មជាតិ ដីស្រែ-ចម្ការ ជាពិសេសចម្ការវិលជុំរបស់គ្រួសារជនជាតិដើមភាគតិចនិងគ្រួសារខ្មែរមួយចំនួន។ ជារួមក្នុងដំណាក់កាលដំបូង ក្រុមហ៊ុនបានស្នើសុំសម្បទានដីសេដ្ឋកិច្ច ចំនួន ១៧.០១៤ ហិកតា ប៉ុន្តែរាជរដ្ឋាភិបាលបានសម្រេចផ្តល់ជូនតែ ៨.០០០ ហិកតា ប៉ុណ្ណោះ។ បន្ទាប់មក គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តរតនគិរី បានចុះធ្វើការអង្កេតវាស់វែង និងធ្វើអត្តសញ្ញាណកម្មដីម្តងទៀត។ លទ្ធផលបង្ហាញថា ផ្ទៃដីសរុបមានចំនួនតែ **<u>១៦.៩៩០,៦៧៨ហិកតា</u>** ដែលក្នុងនោះមានដីដែលបានកាត់ចេញ និងត្រូវរក្សាទុកសរុបចំនួន **<u>១០.៩៩០ហិកតា</u>** ដែលរួមមានផ្ទៃដីតំបន់ទ្រនាប់ដងអូរ (៥០០ម និង១០០) ចំនួន ២.២៤៨ហិកតា ផ្ទៃដីតំបន់សហគមន៍ព្រៃឈើចំនួន ១៧៣ ហិកតា តំបន់រក្សាទុកចំនួន ២.២២៤ ហិកតា ផ្ទៃដីជាន់ព្រៃគុហ៍ក្នុងស្រុកចំនួន ២៨៧ហិកតា ផ្ទៃដីត្រៀមបម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋនៅពេលអនាគត១០% ចំនួន ៨៥៧ ហិកតា ផ្ទៃដីត្រៀមបម្រុងទុកសម្រាប់សម្បទានដីសង្គមកិច្ចចំនួន ៥៩៨ហិកតា និងផ្ទៃដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋចំនួន ២.៦២៧ ហិកតា។ ដូច្នេះផ្ទៃដីដែលនៅសល់សម្រាប់ការវិនិយោគរបស់ក្រុមហ៊ុន ហើយដែលត្រូវបានចុះបញ្ជីដីរដ្ឋរួចរាល់ មានចំនួនត្រឹមតែ **<u>៦.៥០៩,២៧ ហិកតា</u>**ប៉ុណ្ណោះ។

ក២. វិធានការកាត់បន្ថយ៖

ដើម្បីបញ្ចៀស និងដោះស្រាយចំពោះការបារម្ភរបស់ប្រជាជនមូលដ្ឋាន ក្រុមហ៊ុនរៀបចំនូវវិធានការមួយចំនួនដូចខាងក្រោម៖

- ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធ ដើម្បីរៀបចំ និងផ្សព្វផ្សាយអំពីគោលការណ៍ក្នុងការដោះស្រាយទំនាស់ដល់ប្រជាពលរដ្ឋ
- ក្រុមហ៊ុននឹងធ្វើការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ និងប្រជាពលរដ្ឋដែលមានដីធ្លីជាប់ព្រំទីតាំងគម្រោង ដើម្បីផ្តល់ជាព័ត៌មានលម្អិតស្តីពីព្រំប្រទល់គម្រោង។
- ក្រុមហ៊ុននឹងធ្វើការបង្ហាញដល់ប្រជាជន នូវដំណើរការវិនិយោគដីសម្បទានសេដ្ឋកិច្ច តាំងពីដំណាក់កាលស្នើសុំរាជរដ្ឋាភិបាល រហូតដល់ដំណាក់កាលវិនិយោគ និងបញ្ចប់គម្រោង ព្រមទាំងលើកឡើងនូវរាល់វិធានការកាត់បន្ថយ ដើម្បីបញ្ចៀសនូវហេតុប៉ះពាល់អវិជ្ជមាននានា (រួមទាំងការកាត់ចេញនូវផ្ទៃដីពាក់ព័ន្ធនានាដែលបានធ្វើឡើងកន្លងមក)។

Draft

- ក្រុមហ៊ុននឹងមិនឈូសឆាយហួសពីព្រំដីដែលទទួលបានពីរដ្ឋាភិបាល
- ក្រុមហ៊ុននឹងគាំទ្រអាជ្ញាធរមូលដ្ឋានក្នុងការរៀបចំផែនការប្រើប្រាស់ដីក្នុងតំបន់ឲ្យបានសមរម្យ។

**ខ. មុខរបរ និងប្រាក់ចំណូល**

**ខ១. ហេតុប៉ះពាល់៖**

ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគម្រោងលើផ្ទៃដីប្រមាណ ៣៨៣ ហិកតា (៥,៩% នៃផ្ទៃដីវិនិយោគសរុប) ដែលជាដីព្រៃ នឹងមិនអាចធ្វើឱ្យប៉ះពាល់ដល់សកម្មភាពប្រកបរបរចិញ្ចឹមជីវិត (រកផល-អនុផលព្រៃឈើ) របស់ប្រជាជនមូលដ្ឋាននោះទេ។

**ខ២. វិធានការកាត់បន្ថយ៖** មិនចាំបាច់

**គ. ការប្រើប្រាស់ទឹក សុខនាព និងអនាម័យក្នុងការរស់នៅ របស់ប្រជាជនមូលដ្ឋាន**

គ១. ហេតុប៉ះពាល់៖

ការប្រើប្រាស់ទឹករបស់ប្រជាជននៅតំបន់គម្រោង បច្ចុប្បន្នប្រជាជនបានប្រើប្រាស់ទឹកទន្លេ និងទឹកអណ្តូង ជាប្រភពទឹកចម្បងសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ។ ប្រជាជនមានចំនួនច្រើនបានប្រើប្រាស់ទឹកភ្លៀងសម្រាប់ធ្វើស្រែចម្ការ។ ប្រភពទឹកអូរ ស្ទឹង ព្រែក ប្រឡាយមិនត្រូវបានប្រជាជននិយមប្រើប្រាស់ទេ ដោយពួកគាត់យល់ថាមិនស្អាតកខ្វក់ដែលនេះមកពីមូលហេតុនៃការបំពុលពីសំរាម និងរួមផ្សំនឹងសារធាតុគីមីពីដំណាំកសិ-ឧស្សាហកម្មរបស់ក្រុមហ៊ុនផ្សេងៗដែលមាននៅក្នុងតំបន់ (មិនមែនក្រុមហ៊ុន SK)។ ករណីនេះ អាចស្នើបានថានៅពេលដែលគម្រោងចាប់ផ្តើមដំណើរការសាងសង់ អាចនឹងមានការបំពុលប្រភពទឹកទាំងនេះបន្ថែមទៀត ប្រសិនបើមិនមានវិធានការទប់ស្កាត់ការបំពុល។ ការឈូសឆាយលុបប្រភពទឹកអូរ អាចនឹងកើតមាន និងបង្កឲ្យមានការរំខានដល់ការប្រើប្រាស់ទឹករបស់ប្រជាជនសម្រាប់ជីវភាពប្រចាំថ្ងៃ និងសម្រាប់ការងារកសិកម្ម ជាពិសេសនៅរដូវប្រាំង។ សកម្មភាពឈូសឆាយដី អាចនឹងធ្វើឲ្យមានការហូរច្រោះដី កករល្បាប់ ហើយការបោះចោលសំណល់រឹង និងបង្ហូរសំណល់រាវចូលទៅក្នុងប្រភពទឹក ក៏អាចនឹងធ្វើឲ្យមានការបំពុលប្រភពទឹកប្រើប្រាស់របស់មនុស្ស និងសត្វ។ល។ ប្រសិនបើមិនបានអនុវត្តតាមវិធានការត្រឹមត្រូវ។

គ២. វិធានការកាត់បន្ថយ៖

- មិនឈូសឆាយលុបប្រភពទឹកដែលធ្វើឲ្យប៉ះពាល់ដល់បរិមាណធារទឹក និងការប្រើប្រាស់ទឹករបស់ប្រជាជននៅខ្សែទឹកខាងក្រោម
- ជីកស្រះស្តុកទឹកភ្លៀងសម្រាប់ប្រើប្រាស់ ដើម្បីកាត់បន្ថយសម្ពាធលើការប្រើប្រាស់ទឹកពីប្រព័ន្ធផ្លូវទឹកធម្មជាតិ និងទឹកក្រោម
- រៀបចំ និងអនុវត្តឱ្យបានត្រឹមត្រូវតាម ផែនការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេង ដើម្បីការពារការបំពុលប្រភពទឹក។

ឃ. ប្រពៃណី ទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច

**ឃ១. ហេតុប៉ះពាល់៖**

កិច្ចពិភាក្សាជាមួយមន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន បានឲ្យដឹងថា ដីពាក់ពន្ធ័នានាដូចជា ដីកប់សព ទីទួលសុវត្ថិភាព ព្រៃអារក្ស គឺត្រូវបានកាត់ចេញឱ្យប្រជាជនវិញអស់ហើយ។ ក្នុងករណីការប៉ះពាល់ទៅលើទំនៀមទម្លាប់ប្រពៃណីដូនតានៅក្នុងគម្រោងសម្បទានមួយនេះ ហាក់មិនមានបញ្ហាចោទធ្ងន់ធ្ងរនោះទេ។ បច្ចុប្បន្ន តាមរយៈការ

Draft

សម្ភាសន៍ជាមួយប្រជាជនក្នុងខែឧសភា និងខែធ្នូ ឆ្នាំ២០១៦ បានឱ្យដឹងថា ការកំណត់ព្រំដីរបស់គម្រោងនៅមានប៉ះពាល់សម្បត្តិវប្បធម៌របស់ជនជាតិដើមភាគតិចក្នុងភូមិពាក់ព័ន្ធមួយចំនួនតូច។ កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០១៧ ក្រុមហ៊ុនបានសហការជាមួយអាជ្ញាធរខេត្តរតនគិរី អាជ្ញាធរខេត្តស្ទឹងត្រែង និងសហគមន៍ជនជាតិដើមភាគតិចភូមិរំពាត់ ក្នុងការចុះធ្វើការផ្ទៀងផ្ទាត់ និងបោះបង្គោលព្រំ ដើម្បីបញ្ចប់បញ្ហាទំនាស់ដីធ្លីដែលកើតមានឡើងដោយសារភាពមិនច្បាស់លាស់នៃព្រំប្រទល់ខេត្តទាំងពីរ ក៏ដូចជាព្រំប្រទល់ដីសហគមន៍ជនជាតិដើមភាគតិចភូមិរំពាត់ដែលស្ថិតនៅក្នុងខេត្តស្ទឹងត្រែង (ទីតាំងគម្រោងស្ថិតនៅក្នុងខេត្តរតនគិរី)។ សូមមើលកំណត់ហេតុស្តីពីការប្រជុំត្រួតពិនិត្យបោះបង្គោលព្រំប្រទល់រវាង ភូមិបីត្រពាំងក្រហម ឃុំត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគិរី និងភូមិរំពាត់ ឃុំតាឡាត ស្រុកសេសាន ខេត្តស្ទឹងត្រែង ក្នុងឧបសម្ព័ន្ធ។ ផ្ទៃដីដែលគ្រោងសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដូចកំណត់ក្នុងផែនការមេគម្រោង មិនប៉ះពាល់នឹងផ្ទៃដីពាក់ព័ន្ធទាំងនេះទេ។ ទោះជាយ៉ាងនេះក្តី ទំនៀមទម្លាប់ ប្រពៃណីរបស់ជនជាតិដើមភាគតិច ជាពិសេសសហគមន៍ដែលនៅជាប់នឹងទីតាំងគម្រោង អាចនឹងទទួលរងនូវឥទ្ធិពលពីវប្បធម៌ថ្មី ដែលនាំចូលមកជាមួយនឹងបុគ្គលិក-កម្មករដែលជាជនចំណូលថ្មី។

**ឃ២. វិធានការកាត់បន្ថយ៖**

- ផ្សព្វផ្សាយអំពីទំនៀមទម្លាប់ ប្រពៃណី (ជាពិសេសតំណមនានា) របស់ជនជាតិដើមភាគតិច ដល់បុគ្គលិក-កម្មករ និងដាក់បំរាមមិនឱ្យបុគ្គលិក-កម្មករធ្វើសកម្មភាពអ្វីដែលអាចប៉ះពាល់ដល់ទំនៀមទម្លាប់ ប្រពៃណីទាំងនោះ។
- សហការជាមួយអាជ្ញាធរ និងសហគមន៍មូលដ្ឋាន ដើម្បីរៀបចំពិធីបុណ្យតាមបែបប្រពៃណីរបស់ជនជាតិដើមភាគតិច។

ង. សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋាន

**ង១. ហេតុប៉ះពាល់៖**

សកម្មភាពគម្រោង អាចនឹងបង្កបញ្ហាមួយចំនួនពាក់ព័ន្ធនឹងសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋាន ដូចជា៖

- យានយន្តរបស់ក្រុមហ៊ុនដែលបើកឆ្លងកាត់ភូមិដ្ឋានប្រជាជន អាចនឹងបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ ដោយសារការបើកលឿនពេក ការធ្វេសប្រហែសរបស់អ្នកបើកបរ និងភាពមានកម្រិតនៃចំណេះដឹងអំពីច្បាប់ចរាចរណ៍របស់ប្រជាជនមូលដ្ឋាន
- បុគ្គលិក-កម្មករគម្រោងដែលជាជនចំណូលថ្មី អាចរស់នៅមិនចុះសម្រុងនឹងប្រជាជនមូលដ្ឋានដែលជាជនជាតិដើមភាគតិច ដែលអាចនឹងឈានទៅបង្កជាជម្លោះ និងអំពើហឹង្សានានា
- បុគ្គលិក-កម្មករគម្រោងដែលជាជនចំណូលថ្មី អាចនាំមកនូវវប្បធម៌មិនល្អ ដូចជាការសេពគ្រឿងញៀន ការលេងល្បែងស៊ីសង ចោរកម្ម ជម្ងឺឆ្លង ពេស្យាចារ និងករណីរំលោភសេពសន្ថវៈ (ពីបុគ្គលិក-កម្មករលើប្រជាជន និង/ឬពីប្រជាជនលើបុគ្គលិក-កម្មករ)។

**ង២. វិធានការកាត់បន្ថយ**

- ធ្វើការផ្សព្វផ្សាយជាដំណឹងឲ្យបានមុនទៅកាន់អាជ្ញាធរមូលដ្ឋាន អំពីការចល័តគ្រឿងចក្រ ឬគ្រឿងម៉ាស៊ីនដែលត្រូវប្រើក្នុងពេលដំណើរការគម្រោង
- ណែនាំឱ្យអ្នកបើកបរគោរពច្បាប់ចរាចរណ៍ និងពិន័យធ្ងន់ធ្ងរ ប្រសិនបើមិនគោរពច្បាប់ ហើយការមិនគោរពច្បាប់ធ្វើឱ្យមានគ្រោះថ្នាក់ចរាចរណ៍
- ធ្វើការផ្សព្វផ្សាយជាចំណេះដឹងបន្ថែមដល់ប្រជាជនមូលដ្ឋាន ទាក់ទងនឹងសុវត្ថិភាពចរាចរណ៍

Draft

- ជ្រើសរើសបុគ្គលិក-កម្មករក្នុងមូលដ្ឋាន ឲ្យអស់លទ្ធភាពមុននឹងសម្រេចជ្រើសរើសអ្នកតំបន់ផ្សេង
- បញ្ចូលក្នុងបទបញ្ជាផ្ទៃក្នុងនូវបំរាមពាក់ព័ន្ធនឹងគ្រឿងញៀន អំពើហឹង្សាជាមួយប្រជាជនមូលដ្ឋាន និង ករណីចោរកម្ម ពេស្យាចារ រំលោភសេពសន្ថវៈ
- សហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការត្រួតពិនិត្យ និងតាមដានបុគ្គលិក-កម្មករ ដែលជាជនចំណូលថ្មី ដើម្បីធានាថាពួកគេមិនពាក់ព័ន្ធនឹងគ្រឿងញៀន បង្កហឹង្សាជាមួយប្រជាជនមូលដ្ឋាន និងបង្កឲ្យមានករណីចោរកម្ម ពេស្យាចារ សេពសន្ថវៈ
- មានផែនការត្រួតពិនិត្យសុខភាពបុគ្គលិក-កម្មករជាប្រចាំ និងបណ្តុះបណ្តាលពួកគាត់អំពីបញ្ហានៃជម្ងឺឆ្លង ការបង្ការជម្ងឺឆ្លងនានា និងផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន ។ល។
- គាំទ្រដល់បេសកកម្មរបស់ប្រជាការពារឃុំ ដើម្បីពង្រឹងសុវត្ថិភាព និងសន្តិសុខមូលដ្ឋាន។

### ច. សុខភាព សុវត្ថិភាព និងសុខមាលភាពបុគ្គលិក និងកម្មករគម្រោង

**ច១. ហេតុប៉ះពាល់៖**

នៅពេលគម្រោងចាប់ផ្តើមដំណើរការឈូសឆាយ និងសាងសង់ នឹងមានបុគ្គលិក កម្មករមួយចំនួនមកស្នាក់នៅក្នុងតំបន់គម្រោងដែលនឹងតម្រូវឲ្យមានការសាងសង់លំនៅដ្ឋានសម្រាប់ពួកគាត់។ ស្ថានភាពលំនៅដ្ឋានរបស់កម្មករប្រសិនបើពុំមានស្តង់ដារល្អ (មិនមានការផ្គត់ផ្គង់ទឹកស្អាតគ្រប់គ្រាន់ មិនមានបង្គន់អនាម័យប្រើប្រាស់ត្រឹមត្រូវ និងមិនមានការគ្រប់គ្រងឲ្យបានល្អ) នឹងបង្កនូវផលប៉ះពាល់ដល់សុខភាព និងសុខមាលភាពពួកគាត់ធ្ងន់ធ្ងរ។ លើសពីនេះទៀត ការរស់នៅច្រើនគ្នាក្នុងលំនៅដ្ឋានតូចចង្អៀត ឬរស់នៅក្នុងជំរុំប្រក់តង់កៅស៊ូ ដូចធ្លាប់មានក្នុងគម្រោងផ្សេងៗទៀតពីមុនមក នឹងបង្កនូវផលប៉ះពាល់ដល់សុខភាពដោយអាចងាយឆ្លងមេរោគនានា។ ដោយសារតំបន់គម្រោងស្ថិតនៅក្នុងតំបន់ព្រៃ និងមានប្រជាជនមូលដ្ឋានភាគច្រើនធ្លាប់កើតជម្ងឺគ្រុនចាញ់កន្លងមក បុគ្គលិក និងកម្មករគម្រោង ក៏នឹងប្រឈមមុខខ្លាំងនឹងជំងឺគ្រុនចាញ់នេះផងដែរ ប្រសិនណាមិនមានការថែរក្សាសុខភាព និងមិនមានវិធានការសុវត្ថិភាពត្រឹមត្រូវនោះទេ។

ការបញ្ជាគ្រឿងចក្រក្នុងការឈូសឆាយ រៀបចំដី និងសាងសង់ ដោយគ្មានបច្ចេកទេស អាចនឹងបង្កគ្រោះថ្នាក់ដល់អ្នករួមការងារ និងខ្លួនឯង។ គ្រោះថ្នាក់ដែលធ្លាប់កើតមានកន្លងមក មានដូចជា៖ ការប៉ះទង្គិចជាមួយគ្រឿងចក្រដែលធ្វើឱ្យគ្រាំក្នុង ឬដាច់រលាត់លើសារពាង្គកាយ ការប៉ះពាល់ដល់ប្រព័ន្ធប្រសាទដោយសារការប្រើប្រាស់រណាយន្ត ជាដើម។

**ច២. វិធានការកាត់បន្ថយ៖**

- ផ្តល់លំនៅដ្ឋានសម្រាប់ស្នាក់នៅ ក្នុងកម្រិតស្តង់ដារកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ស្របតាមច្បាប់ស្តីពីការងារ (មាត្រា ២០៤ ដល់ ២០៦ និង មាត្រានានាក្នុងជំពូក៧ និងជំពូក៨)។
- ផ្តល់នូវការបណ្តុះបណ្តាលអំពីការទប់ស្កាត់ការកើតជម្ងឺគ្រុនចាញ់ និងផ្តល់មុងជ្រលក់ថ្នាំដល់បុគ្គលិក-កម្មករ។
- ផ្តល់ការបណ្តុះបណ្តាលអំពីបច្ចេកទេសបញ្ជាគ្រឿងចក្រ និងវិធានសុវត្ថិភាពក្នុងការការពារគ្រោះថ្នាក់ក្នុងពេលបំពេញការងារ
- អនុវត្តកម្មវិធីត្រួតពិនិត្យ និងថែទាំសុខភាព ជាពិសេសពាក់ព័ន្ធនឹងជម្ងឺគ្រុនចាញ់
- ផ្តល់នូវបរិក្ខាសង្គ្រោះបឋម និងណែនាំអំពីវិធីសាស្ត្រសង្គ្រោះបឋម ដល់បុគ្គលិក-កម្មករ មុនពេលចាប់ផ្តើមបំពេញការងារ។

Draft

ផ្តល់ការធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់ការងារដល់គ្រប់បុគ្គលិក-កម្មករ ក្រោមរូបភាពបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)។

## ៧.៣. ហេតុប៉ះពាល់អវិជ្ជមាន និងវិធានការកាត់បន្ថយ ក្នុងដំណាក់កាលប្រតិបត្តិ

### ៧.៣.១ ធនធានរូបសាស្ត្រ

#### ក. សណ្ឋានដី និងថានលេខា

**ហេតុប៉ះពាល់៖** យោងតាមផែនទីរយៈកម្ពស់ដីក្នុងតំបន់គម្រោង នៅក្នុងជំពូកទី៥ ចំណុច៥.១.១.២ បង្ហាញថាតំបន់គម្រោងជាតំបន់ខ្ពង់រាប ដែលមានរយៈកម្ពស់ប្រែប្រួលចន្លោះពី ៨០ម. ទៅ ២០០ម. ធៀបនឹងនីវ៉ូទឹកសមុទ្រ។ ក្នុងដំណាក់កាលប្រតិបត្តិគម្រោង បម្រែបម្រួលសណ្ឋានដីអាចនឹងកើតមានឡើង ដែលអាចកើតឡើងក្នុងកម្រិតតិចតួច ដោយសារសកម្មភាពឈូសឆាយពង្រាបដីឲ្យរាបស្មើនៅតាមតំបន់ទួល និងដំបូកខ្ពស់ៗ ដើម្បីដាំដុះដំណាំកសិ-ឧស្សាហកម្មដែលជាមុខព្រួញនៃគម្រោងវិនិយោគនេះ។ ជាមួយគ្នានេះ ការឈូសឆាយព្រៃដោយរក្សាទុកដីឲ្យនៅទំនេរ នឹងបង្កើតឲ្យមានការហូរច្រោះដីនៅរដូវវស្សា ហើយជាលទ្ធផលអាចធ្វើឲ្យសណ្ឋានដីមានការប្រែប្រួល។

**វិធានការកាត់បន្ថយ៖** ដើម្បីកាត់បន្ថយផលប៉ះពាល់ដល់សណ្ឋានដី និងការហូរច្រោះដីនេះឲ្យស្ថិតនៅកម្រិតទាបបំផុត ក្រុមហ៊ុននឹងអនុវត្តនូវវិធានការមួយចំនួនដូចខាងក្រោម៖

- ធ្វើការឈូសឆាយតែក្នុងរដូវប្រាំង និងរៀបចំដាំដំណាំភ្លាមៗក្រោយពីឈូសឆាយរួច ដើម្បីកាត់បន្ថយកម្រិត និងរយៈពេលនៃការហូរច្រោះ។
- ធ្វើការឈូសឆាយដីតាមលក្ខណៈសណ្ឋានដី និងតាមលក្ខណៈបច្ចេកទេស។ បន្ថែមពីលើនេះ តំបន់ភ្នំ ឬតំបន់ដែលមានរយៈកម្ពស់ខ្ពស់ដែលស្ថាប័នជំនាញតម្រូវឲ្យរក្សាទុក គឺក្រុមហ៊ុននឹងរក្សាទុក។
- មិនឈូសឆាយឬ កាប់ឆ្ការព្រៃនៅតាមតំបន់ទ្រនាប់អូរ ឬក្បែរមាត់ទឹកដើម្បីពង្រីកផ្ទៃដីដាំដុះ ដោយរក្សាគម្របព្រៃឱ្យបានពី ១០០ម ទៅ ១៥០ម ពីប្រភពទឹក ព្រមទាំងជួយគាំពារព្រៃទ្រនាប់នានាដែលមាននៅក្នុងទីតាំងគម្រោង ដើម្បីការពារទីជម្រាល និងទប់ស្កាត់ការហូរច្រោះដី និងបាក់ច្រាំង។
- កាប់ឆ្ការព្រៃ ឈូសឆាយដី និងរៀបចំថ្នាលដំណាំ ជាដំណាក់កាលនៅត្រង់តំបន់ដែលមានជម្រាលខ្លាំង ហើយចាប់ផ្តើមធ្វើពីតំបន់ដែលមានរយៈកម្ពស់ខ្ពស់មុន ដើម្បីជៀសវាងការបាក់ដី។
- រៀបចំផ្លូវឆ្លងកាត់នានាក្នុងតំបន់គម្រោង (optimum road size) ឱ្យមានទំហំសមស្រប ដើម្បីធានាប្រសិទ្ធភាព និងសុវត្ថិភាពការងារ សំដៅជៀសវាងការអូសបន្លាយពេលដាំដុះ (ឬទុកដីនៅទំនេរ) ដែលអាចនឹងបង្កឲ្យមានការហូច្រោះដីកើតឡើង។
- ជៀសវាងការដឹកជញ្ជូនលើសទម្ងន់ ដែលនាំឱ្យមានការបាក់ខូចផ្លូវ និងការហូរដីចេញពីផ្លូវជាពិសេសនៅរដូវវស្សា។

#### ខ. គុណភាពដី

**ហេតុប៉ះពាល់៖** នៅក្នុងដំណាក់កាលនេះ សកម្មភាពគម្រោងអាចធ្វើឲ្យប៉ះពាល់ដល់គុណភាពដីក្នុងកម្រិតតិចតួចដោយសារ៖

- ការគ្រប់គ្រងសំណល់រឹង រាវ មិនបានល្អ ដូចជាសំណល់ផ្ទះបាយ សំណល់ថង់ប្លាស្ទិក សំបកដបសំណល់រាវចេញពីបន្ទប់ទឹក និងបង្គន់ ជាដើម។

- ការគ្រប់គ្រងសំណល់ប្រេងមិនបានល្អ តាមរយៈការលេចជ្រាបពីម៉ាស៊ីន គ្រឿងចក្រ និងកន្លែងជួសជុលគ្រឿងចក្ររបស់ក្រុមហ៊ុន។
- ការប្រើប្រាស់មិនបានត្រឹមត្រូវតាមបច្ចេកទេស និងលើសពីតម្រូវការ នូវជីគីមី ថ្នាំសម្លាប់សត្វល្អិត ឬស្មៅ ដើម្បីជួយជំរុញដល់ការលូតលាស់របស់ដំណាំកៅស៊ូ និងដំណាំផ្សេងៗទៀត។
- ការទុកដីទំនេរចោល ក្រោយពីការឈូសឆាយដីព្រៃរួច ដែលទីតាំងទាំងនោះនឹងទទួលឥទ្ធិពលមិនល្អពីអាកាសធាតុដូចជា ខ្យល់ កំដៅថ្ងៃ និងពន្លឺ ជាដើម ឬការហូរច្រោះដីមានជីជាតិនៅផ្នែកខាងលើ ជាហេតុធ្វើឲ្យដីបាត់បង់ជីជាតិ និងសឹករេចរឹល។

**<u>វិធានការកាត់បន្ថយ៖</u>** ដើម្បីកាត់បន្ថយកម្រិតនៃការប៉ះពាល់ដល់គុណភាពដីឲ្យនៅកម្រិតទាបបំផុត ក្រុមហ៊ុន នឹងអនុវត្តនូវវិធានការមួយចំនួនដូចខាងក្រោម៖

- រៀបចំ និងអនុវត្តឱ្យបានត្រឹមត្រូវតាម ផែនការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេង។
- រាល់ការឈូសឆាយទាំងអស់ គឺក្រុមហ៊ុន នឹងអនុវត្តតែកំឡុងរដូវប្រាំងតែប៉ុណ្ណោះ ហើយនឹងធ្វើការដាំដុះភ្លាមៗដោយមិនទុកដីឲ្យនៅទំនេរចោល ដែលនាំឲ្យមានការហូរច្រោះនោះទេ។
- កំណត់ទំហំសមស្របនៃផ្លូវឆ្លងកាត់នានាក្នុងតំបន់គម្រោង (optimum road size) ដើម្បីធានាប្រសិទ្ធភាព និងសុវត្ថិភាពការងារ ជៀសវាងការអូសបន្លាយពេលដាំដុះ (ឬទុកដីនៅទំនេរ) ដែលអាចនឹងបង្កឲ្យមានការហូរច្រោះដីកើតឡើង។
- រៀបចំទីតាំងចម្ការដំណាំដោយសាងសង់ប្រព័ន្ធបង្ហូរទឹកឲ្យបានត្រឹមត្រូវ និងអនុវត្តន៍ការភ្ជួររាស់តាមបច្ចេកទេសដែលមានមេត្រីភាពបរិស្ថាន (ឧ. មិនភ្ជួររាស់ជ្រៅពេក ភ្ជួររាស់ជាលក្ខណៈកាំជណ្ដើរ)។
- ប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវកំទេចកំទីមែក ឬស្លឹករុក្ខជាតិដែលបានកាប់ឆ្ការ ជាគម្របដី ដើម្បីកាត់បន្ថយការហូរច្រោះ និងរំហួត និងផ្តល់ជីជាតិដល់ដី។
- ប្រើប្រាស់តែជីគីមីកសិកម្ម ថ្នាំសម្លាប់សត្វល្អិត ឬស្មៅ ដែលមានចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រៀបចំផែនការប្រើប្រាស់ដីឱ្យបានច្បាស់លាស់ និងអនុវត្តតាមផែនការនេះឲ្យបានខ្ជាប់ខ្ជួន ដើម្បីជៀសវាងការប្រើប្រាស់ជីគីមីលើសកម្រិតដែលបណ្តាលឲ្យខូចគុណភាពដី។
- កាត់បន្ថយការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ដោយការរៀបចំ និងអនុវត្តផែនការត្រៀមដើម្បីទប់ស្កាត់កំណើនលើសលប់នៃចំនួនសត្វល្អិត (avoid the outbreak occurs)។
- ដាំដុះបន្ថែមនូវប្រភេទដំណាំបន្ទាប់បន្សំ ដូចជាពោត សណ្តែក ឬពពួកបន្លែបង្ការនានា (នៅតាមចន្លោះរង ឬនៅក្នុងចន្លោះពេលសម្អាតថ្នាលបន្ទាប់ពីពេលប្រមូលផលដំណាំចម្បងរួច) ធ្វើជាគម្របដីដើម្បីកាត់បន្ថយការហូរច្រោះដីស្រទាប់លើ និងបាត់បង់ជីជាតិដី។

**គ. ប្រព័ន្ធជលសាស្ត្រ (ទំហំ ជម្រៅ និងលំហូរទឹក)**

**<u>ហេតុប៉ះពាល់៖</u>** នៅដំណាក់កាលនេះ ប្រព័ន្ធជលសាស្ត្រ អាចនឹងមានការប្រែប្រួលក្នុងកម្រិតតិចតួចដោយសារ៖

- ការឈូសឆាយដីព្រៃដើម្បីដាំដំណាំកៅស៊ូ និងដំណាំផ្សេងៗទៀត ដែលអាចនឹងលុបប្រព័ន្ធអូរ និងដៃអូរមួយចំនួន។
- ការឈូសឆាយដីព្រៃនៅតាមមាត់អូរ ក៏នឹងធ្វើឲ្យប្រព័ន្ធអូរទាំងនោះ កកស្ទះមិនមានទឹកហូរ ដោយសារការហូរច្រោះកករដី មែកឈើ ឬស្លឹកឈើហូរចូល។

- ដោយសារនៅរដូវប្រាំងប្រព័ន្ធអូរ ដៃអូរ និងត្រពាំងមានសភាពគោក ប៉ុន្តែមានទឹកដក់តិចៗនៅតាមអន្លង់ ដូច្នេះក្រុមហ៊ុនអាចនឹងធ្វើការស្ទាក់ ឬធ្វើទំនប់ទប់ទឹក ឬស្តារឡើងវិញនូវប្រព័ន្ធផ្លូវទឹកមួយចំនួនដែលជាកត្តាធ្វើឲ្យមានបម្រែបម្រួលទ្រង់ទ្រាយអូរ និងចរន្តទឹក។

**<u>វិធានការកាត់បន្ថយ៖</u>** ដើម្បីកាត់បន្ថយការប៉ះពាល់នេះឲ្យនៅកម្រិតទាបបំផុត ក្រុមហ៊ុននឹងអនុវត្តនូវវិធានការមួយចំនួនដូចខាងក្រោម៖

- រក្សាគម្របព្រៃពី ១០០ម ទៅ ១៥០ម ពីប្រភពទឹក និងជួយគាំពារព្រៃទ្រនាប់នានាដែលមាននៅក្នុងទីតាំងគម្រោង ដើម្បីការពារទីជម្រាល និងទប់ស្កាត់ការហូរច្រោះដីចូលប្រភពទឹក។
- ដើម្បីការពារមិនឲ្យប៉ះពាល់ខ្លាំងដល់ចរន្តទឹក និងបរិមាណទឹក ក្នុងករណីដែលក្រុមហ៊ុនធ្វើទំនប់ស្ទាក់ទឹក ឬស្តារឡើងវិញនូវប្រព័ន្ធផ្លូវទឹកណាមួយ ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញមានសមត្ថកិច្ច (ជាពិសេសមន្ទីរធនធានទឹក និងឧតុនិយមខេត្ត) ដើម្បីធ្វើការវាយតម្លៃ និងផ្តល់អនុសាសន៍បច្ចេកទេស។
- សិក្សាពីស្ថានភាពសមតុល្យទឹកក្រោមដីឲ្យបានច្បាស់លាស់ មុននឹងធ្វើការខួង ឬបូមយកទឹកពីប្រភពទឹកក្រោមដី មកប្រើប្រាស់។

**ឃ. គុណភាពទឹក (ទឹកក្រោមដី និងលើដី)**

**<u>ហេតុប៉ះពាល់៖</u>** នៅក្នុងដំណាក់ការនេះ គុណភាពទឹកទាំងលើដី និងក្រោមដី អាចធ្លាក់ចុះក្នុងកម្រិតមធ្យមដោយសារ៖

- ការឈូសឆាយព្រៃឈើតាមមាត់អូរដោយចេតនា ឬអចេតនា ដើម្បីយកដីដាំដុះ បណ្តាលឲ្យបាត់បង់ទ្រនាប់ធម្មជាតិ និងបង្កឲ្យមានការហូរច្រោះដី និងកំទេចកំទីនានាចូលទៅក្នុងប្រភពទឹក។
- ការគ្រប់គ្រងសំណល់រឹង មិនបានល្អ ដូចជាសំណល់ផ្ទះបាយ សំណល់ថង់ប្លាស្ទិក សំបកដប និងសំបកកំប៉ុង ជាដើម។
- ការគ្រប់គ្រងសំណល់រាវមិនបានល្អ ដូចជាសំណល់រាវចេញពីការប្រើប្រាស់ទូទៅរបស់បុគ្គលិក-កម្មករ និងកាកសំណល់ចេញពីបង្គន់ ជាដើម។
- ការគ្រប់គ្រងសំណល់ប្រេងមិនបានល្អ តាមរយៈការលេចជ្រាបពីម៉ាស៊ីន គ្រឿងចក្រ និងកន្លែងជួសជុលគ្រឿងចក្ររបស់ក្រុមហ៊ុន។
- ការហូរជ្រាបនៃជីគីមី ថ្នាំសម្លាប់សត្វល្អិតនិងស្មៅ ដោយសារការប្រើប្រាស់ខុសបច្ចេកទេស ការប្រើប្រាស់លើសតម្រូវការ និងការបោលកាកសំណល់សំបកកំប៉ុងថ្នាំពាសវាលពាសកាល។

(**ចំណាំ៖** សំណល់ដែលចេញពីសកម្មភាពទាំងអស់ខាងលើ នឹងហូរចូលទៅក្នុងប្រភពទឹក ប្រសិនបើមិនបានគ្រប់គ្រងត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស)។

**<u>វិធានការកាត់បន្ថយ៖</u>** ដើម្បីកាត់បន្ថយការប៉ះពាល់ដល់គុណភាពទឹកឲ្យនៅកម្រិតទាបបំផុត ក្រុមហ៊ុននឹងអនុវត្តនូវវិធានការមួយចំនួនដូចខាងក្រោម៖

- រាល់ការឈូសឆាយទាំងអស់ គឺក្រុមហ៊ុន នឹងអនុវត្តក្នុងកំឡុងរដូវប្រាំងតែប៉ុណ្ណោះ ហើយនឹងធ្វើការដាំដុះភ្លាមៗដោយមិនទុកដីឲ្យនៅទំនេរចោល ដើម្បីការពារ ឬកាត់បន្ថយការហូរច្រោះដីចូលទៅក្នុងប្រភពទឹក។
- រៀបចំ និងអនុវត្តឱ្យបានត្រឹមត្រូវតាម ផែនការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេង។

Draft

- រក្សាគម្របព្រៃពី ១០០ម ទៅ ១៥០ម ពីប្រភពទឹក និងជួយគាំពារព្រៃទ្រនាប់នានាដែលមាននៅក្នុងទីតាំងគម្រោង ដើម្បីធ្វើជារនាំងទប់ស្កាត់ ឬកាត់បន្ថយ កកជី និងសំណល់ផ្សេងៗដែលហូរនាំជាមួយទឹកភ្លៀងចូលទៅក្នុងប្រភពទឹក។
- ជៀសវាងការដាក់ជី ឬបាញ់ថ្នាំសម្លាប់សត្វល្អិត និងស្មៅ មុនពេលដែលទំនងជាមានភ្លៀងធ្លាក់ ដើម្បីកាត់បន្ថយការហូរនាំសារធាតុទាំងនេះចូលទៅក្នុងប្រភពទឹក។
- តាមដានគុណភាពទឹកក្នុងតំបន់គម្រោង តាមរយៈការយកសំណាកទឹកទៅពិនិត្យនៅមន្ទីរពិសោធន៍ឱ្យបានទៀងទាត់ (២ដង/ឆ្នាំ) ព្រមទាំងសហការជាមួយស្ថាប័នមានសមត្ថកិច្ច ក្នុងការស្វែងរក និងអនុវត្តវិធានការចាំបាច់នានា ក្នុងករណីពិនិត្យឃើញថាគុណភាពទឹកមានបម្រែបម្រួលជាអវិជ្ជមាន ដើម្បីកែលម្អ ឬស្តារគុណភាពទឹកឲ្យបានល្អប្រសើរឡើងវិញ។

**ង. គុណភាពខ្យល់**

__ហេតុប៉ះពាល់៖__ គុណភាពខ្យល់ក្នុងតំបន់នៅមិនទាន់មានការបំពុលនៅឡើយ ក្នុងពេលបច្ចុប្បន្ន។ នៅដំណាក់កាលប្រតិបត្តិគម្រោង គុណភាពខ្យល់នឹងអាចមានការធ្លាក់ចុះក្នុងកម្រិតតិចតួច ដោយសារការសាយភាយធូលី ផ្សែង និងឧស្ម័នបំពុលផ្សេងៗ ចេញពីគ្រឿងចក្រ និងគ្រឿងម៉ាស៊ីននានាដែលប្រើប្រាស់ក្នុងសកម្មភាពឈូសឆាយ ការដឹកជញ្ជូនកសិផល ព្រមទាំងការដុតសំណល់រឹង កំទេចកំទីមែកឈើ សំណល់កសិកម្ម ជាដើម។ ទោះជាយ៉ាងនេះក្តី គម្រោងអភិវឌ្ឍដំណាំកសិ-ឧស្សាហកម្មបែបនេះ (ដោយមិនគិតបញ្ចូលរោងចក្រកែច្នៃ) មិនអាចធ្វើឱ្យមានការបំពុលខ្យល់ដែលនឹងនាំឱ្យលើសកម្រិតស្តង់ដារកំណត់ ឬប៉ះពាល់ដល់សុខភាពសាធារណៈនោះទេ។

__វិធានការកាត់បន្ថយ៖__ ដើម្បីកាត់បន្ថយការប៉ះពាល់នេះឲ្យស្ថិតនៅកម្រិតទាបបំផុត ក្រុមហ៊ុននឹងអនុវត្តនូវវិធានការមួយចំនួនដូចខាងក្រោម៖

- ធ្វើការគ្រប់គ្រង និងថែទាំគ្រឿងចក្រ និងយានយន្តនានាយ៉ាងទៀងទាត់ ដូចជាប្តូរប្រេងរំអិលតាមកាលកំណត់ និងបំពាក់តម្រងចម្រោះឧស្ម័នបំពុល ដើម្បីកាត់បន្ថយការបំភាយឧស្ម័ន។
- ពិនិត្យតាមដានកម្រិតនៃការបញ្ចេញឧស្ម័នបំពុលពីគ្រឿងចក្រ និងយាន្តយន្តដែលប្រើប្រាស់ក្នុងដំណើរការគម្រោង ព្រមទាំងធ្វើការជួសជុល ឬផ្លាស់ប្តូរថ្មីនូវគ្រឿងចក្រ ឬយានយន្តណាដែលបញ្ចេញឧស្ម័នបំពុលលើសកម្រិតស្តង់ដារដែលអនុញ្ញាតឱ្យបញ្ចេញសម្រាប់ប្រភពចល័ត ដូចមានកំណត់នៅក្នុងអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងសំឡេង (ឆ្នាំ២០០០)។
- ជៀសវាងការដុតសំណល់គ្រប់ប្រភេទ ដោយអនុវត្តទៅតាមផែនការគ្រប់គ្រងសំណល់រឹង និងប្រើប្រាស់ឱ្យអស់លទ្ធភាពនូវកំទេចកំទីមែកឈើ និងសំណល់កសិកម្ម ក្នុងដំណើរការដាំដុះ (ឧ. យកទៅធ្វើជាជីកំប៉ុស និងគ្របលើដីដែលមិនទាន់ដាំដំណាំដើម្បីកាត់បន្ថយការហូរច្រោះ និងរំហួត)។
- កំណត់ល្បឿនបើកបរក្នុងការដឹកជញ្ជូនកសិផល និងបរិក្ខាផ្សេងៗចេញចូលក្នុងតំបន់គម្រោង ជាពិសេសតំបន់ទីប្រជុំជន មន្ទីរពេទ្យ និងសាលារៀន ជាដើម។
- អប់រំ-ណែនាំឱ្យប្រើប្រាស់គ្រឿងចក្រ និងគ្រឿងម៉ាស៊ីន ឲ្យមានប្រសិទ្ធិភាព ដោយជៀសវាងនូវការបញ្ឆេះម៉ាស៊ីនទុកចោលនៅពេលដែលមិនចាំបាច់ ឬពេទ័ខ្លាំងពេក។
- រក្សាទុកដើមឈើនៅតាមព្រំទីតាំងគម្រោងដើម្បីដើម្បីជួយទប់ស្កាត់ការហុយធូលីទៅតំបន់ផ្សេង និងជួយបន្សុទខ្យល់។

**ច. កម្រិតសំឡេង**

**<u>ហេតុប៉ះពាល់៖</u>** កម្រិតសំឡេងនៅក្នុងតំបន់នាពេលបច្ចុប្បន្ន មិនមានបង្កការរំខាននោះទេ។ ប៉ុន្តែក្នុងដំណាក់កាលប្រតិបត្តិគម្រោង សំឡេងរំខានចេញពីសកម្មភាពគម្រោង នឹងអាចកើតមានក្នុងកម្រិតតិចតួច ដោយសារ៖

- សំឡេងចេញពីរណារយន្តអារឈើមុនធ្វើការឈូសឆាយ គ្រឿងចក្រឈូសឆាយ ម៉ាស៊ីនភ្លើង និងម៉ាស៊ីនផ្សេងៗទៀតដែលគាំទ្រដល់ដំណើរការប្រតិបត្តិគម្រោង។
- សំឡេងចេញពីរថយន្តដឹកជញ្ជូនសម្ភារសំណង់ និងសម្ភារបរិក្ខាផ្សេងៗ ។ល។

**<u>វិធានការកាត់បន្ថយ៖</u>** ដើម្បីកាត់បន្ថយការប៉ះពាល់ឲ្យស្ថិតនៅកម្រិតទាបបំផុត ក្រុមហ៊ុននឹងអនុវត្តនូវវិធានការមួយចំនួនដូចខាងក្រោម៖

- អនុវត្តការងារដឹងជញ្ជូន ឈូសឆាយ និងដាំដុះ តែពេលថ្ងៃ ដោយជៀសវាងអនុវត្តការងារនៅពេលយប់។
- ប្រើប្រាស់គ្រឿងចក្រ និងយានយន្ត ដែលមានបំពាក់ឧបករណ៍កាត់បន្ថយសំឡេង ឬដែលមានការបញ្ចេញសំឡេងគោរពតាមស្តង់ដារអនុញ្ញាតសម្រាប់ប្រភពចល័ត ដូចមានកំណត់ក្នុងអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង។
- ពិនិត្យតាមដានកម្រិតនៃការបញ្ចេញសំឡេងរំខានពីគ្រឿងចក្រ និងយាន្តយន្តដែលប្រើប្រាស់ក្នុងដំណើរការគម្រោង ព្រមទាំងធ្វើការជួសជុលគ្រឿងចក្រ ឬយានយន្តណាដែលបញ្ចេញសំឡេងលើសកម្រិតស្តង់ដារដែលអនុញ្ញាតឱ្យបញ្ចេញសម្រាប់ប្រភពចល័ត ដូចមានកំណត់នៅក្នុងអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងសំឡេង (ឆ្នាំ២០០០)។
- អនុវត្តការងារដឹកជញ្ជូន ឈូសឆាយ និងសាងសង់ តែពេលថ្ងៃ ដោយចៀសវាងអនុវត្តការងារនៅពេលយប់។
- កំណត់ល្បឿនបើកបរក្នុងការដឹកជញ្ជូនកសិផល និងបរិក្ខាផ្សេងៗចេញ-ចូលក្នុងតំបន់គម្រោង ជាពិសេសតំបន់ទីប្រជុំជន មន្ទីរពេទ្យ និងសាសារៀន ជាដើម។
- អប់រំ-ណែនាំឱ្យប្រើប្រាស់គ្រឿងចក្រ និងគ្រឿងម៉ាស៊ីន ឲ្យមានប្រសិទ្ធិភាព ដោយជៀសវាងនូវការបញ្ឆេះម៉ាស៊ីនទុកចោលនៅពេលដែលមិនចាំបាច់ ឬរេវខ្លាំងពេក។

**៧.៣.២. ធនធានជីវសាស្ត្រ**

**ក. ព្រៃឈើ និងសារព័ន្ធរុក្ខជាតិ**

<u>ហេតុប៉ះពាល់៖</u>

ព្រៃឈើ និងសារព័ន្ធរុក្ខជាតិដែលមាននៅក្នុងទីតាំងគម្រោង នឹងត្រូវបាត់បង់ទាំងស្រុង។ ជារួមដំណើរការប្រតិបត្តិគម្រោង (ឈូសឆាយ ដាំដុះ) គួបផ្សំនឹងដំណើរការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដូចរៀបរាប់ខាងដើម នឹងធ្វើឱ្យបាត់បង់ផ្ទៃដីព្រៃឈើសរុបប្រមាណ ៦.១៥៨ ហិកតា (ដែលក្នុងនោះមានព្រៃស្រោងចំនួន ៥៤៩ហិកតា, ព្រៃពាក់កណ្តាលស្រោងចំនួន ៣៩៣ហិកតា, និងព្រៃល្បោះចំនួន ៥២១៦ហិកតា បើផ្អែកតាមលទ្ធផលនៃការធ្វើសារពើភ័ណ្ឌព្រៃឈើក្នុងជំពូកទី៥)។ ក្នុងករណីដែលព្រៃឈើដែលមាននៅក្រៅទីតាំងគម្រោងមិនមានការប្រែប្រួល នោះផ្ទៃដីព្រៃឈើក្នុងរង្វង់ ៥គ.ម. ជុំវិញទីតាំងគម្រោង នឹងនៅសល់ប្រមាណ ៥១.៧២៧ហិកតា (ដែលក្នុងនោះមានព្រៃស្រោងចំនួន ១៥.៧៧០ហិកតា, ព្រៃពាក់កណ្តាលស្រោងចំនួន ៥.៤៦៦ ហិកតា, ព្រៃល្បោះចំនួន

២៨.៨៦០ ហិកតា, និងព្រៃប្រភេទផ្សេងទៀតចំនួន ១៦៣០ ហិកតា) ស្មើនឹង ៧៥% នៃផ្ទៃដីសរុប (៦៩.០៤៦ ហិកតា)។ ដូច្នេះ ផ្ទៃដីព្រៃឈើដែលនឹងបាត់បង់ដោយសារគម្រោងនេះ (ដោយមិនគិតពីគម្រោងអភិវឌ្ឍន៍ និងកត្តាផ្សេងទៀត) គឺមានចំនួនប្រមាណតែ ១០,៧% នៃផ្ទៃដីព្រៃឈើដែលមាននៅក្នុងរង្វង់ ៥គ.ម. ជុំវិញទីតាំងគម្រោង (៥៧.៦៣៩)។

**វិធានការកាត់បន្ថយ៖**

ការបាត់បង់ផ្ទៃដីព្រៃឈើក្នុងទីតាំងគម្រោង គឺជាជម្រើសមួយដែលមិនអាចជៀសវាងបាន ដើម្បីទទួលបានគម្រោងវិនិយោគនេះ។ ទោះជាយ៉ាងណា ផ្ទៃដីដែលត្រូវបាត់បង់នេះ បានកាត់ចេញនូវព្រៃឈើមួយចំនួនរួចហើយ ដូចជាផ្ទៃដីទ្រនាប់ដងអូរចំនួន ២.១៤៤ ហិកតា, ផ្ទៃដីតំបន់សហគមន៍ព្រៃឈើចំនួន ១៧៣ហិកតា, ផ្ទៃដីតំបន់រក្សាទុកចំនួន ២.២២៤ ហិកតា ផ្ទៃដីតំបន់ជាន់គ្នាជាមួយព្រៃគុបក្នុងស្រុកចំនួន ២៨៧ ហិកតា ជាដើម (សូមអានជំពូកទី៤)។ ដើម្បីជាការប៉ះប៉ូវដល់ការបាត់បង់ព្រៃឈើក្នុងដំណើរការគម្រោងនេះ ក្រុមហ៊ុននឹងអនុវត្តនូវវិធានការដូចខាងក្រោម៖

- ចូលរួមឧបត្ថម្ភគាំទ្រសម្រាប់ការអភិរក្សព្រៃគុបក្នុងស្រុក ការគ្រប់គ្រងសហគមន៍ព្រៃឈើកុកព្រៅ ការអភិរក្សចំការពូជឈើ ការដាក់បញ្ចូលបន្ថែមនូវធនធានព្រៃឈើដែលនៅសេសសល់ជាដីអភិរក្ស ឬសហគមន៍ព្រៃឈើ ការការពារព្រៃទ្រនាប់អូរ ជាដើម។
- ចូលរួមដាំ និងស្តារឡើងវិញ នូវប្រភេទឈើក្នុងស្រុកឬមានដោយកម្រ នៅតាមព្រៃទ្រនាប់អូរដែលបានកាត់ចេញ ព្រៃសហគមន៍ ដងផ្លូវ និងតំបន់សាធារណៈផ្សេងទៀត។
- ចូលរួមឧបត្ថម្ភគាំទ្រដល់សកម្មភាពរបស់ស្ថានីយ៍បណ្តុះកូនឈើ របស់ផ្នែករដ្ឋបាលព្រៃឈើរ៉ែនសែ ដើម្បីផ្គត់ផ្គង់កូនឈើសម្រាប់ការដាំដុះក្នុងតំបន់។

**ខ. ធនធានសត្វព្រៃ**

**ហេតុប៉ះពាល់៖**

ធនធានសត្វព្រៃដែលមាននៅក្នុងព្រៃក្នុងទីតាំងគម្រោង នឹងទទួលរងផលប៉ះពាល់ដោយផ្ទាល់ និងប្រយោលដូចខាងក្រោម៖

- បាត់បង់ទីជម្រកដោយសារការបាត់បង់ព្រៃឈើក្នុងដំណើការអភិវឌ្ឍគម្រោង (សត្វមួយចំនួនអាចភៀសខ្លួនទៅតំបន់ព្រៃឈើដែលនៅក្បែរនោះ)។
- ការរំខានដែលកើតចេញពីសកម្មភាពឈូសឆាយ ដាំដុះ (ជាពិសេសការរំខានដែលបង្កដោយសំឡេងត្រាក់ទ័រ និងគ្រឿងចក្រផ្សេងៗទៀត) រួមទាំងសកម្មភាពនានារបស់បុគ្គលិក-កម្មករផងដែរ។
- ការគំរាមកំហែង ដោយសារសកម្មភាពលួចបរបាញ់ខុសច្បាប់ពីសំណាក់បុគ្គលិក-កម្មករគម្រោង បន្ថែមលើសម្ពាធនៃការបរបាញ់ខុសច្បាប់ដែលមានក្នុងពេលបច្ចុប្បន្ន។

**វិធានការកាត់បន្ថយ៖**

ដើម្បីកាត់បន្ថយ ឬជៀសវាងនូវផលប៉ះពាល់ដូចបានរៀបរាប់ខាងលើ ក្រុមហ៊ុននឹងអនុវត្តនូវវិធានការដូចខាងក្រោម៖

- ធ្វើការឈូសឆាយព្រៃឈើ និងដាំដុះ ជាដំណាក់ៗតាមអនុតំបន់ដូចមានក្នុងផែនការមេរបស់គម្រោង ដើម្បីទុកផ្លូវ និងពេលវេលាឲ្យសត្វព្រៃធ្វើការភៀសខ្លួនទៅកាន់តំបន់ផ្សេងៗ
- ពន្លឿនការដាំដំណាំឡើងវិញនៅក្នុងអនុតំបន់របស់គម្រោងឱ្យបានឆាប់រហ័ស ដើម្បីបង្កើតជាជម្រកថ្មីដល់ប្រភេទសត្វព្រៃមួយចំនួន

- ចូលរួមធ្វើការដាំដើមឈើនៅក្នុងព្រៃសហគមន៍ និងព្រៃឈើរក្សាទុក ដើម្បីជាជម្រកនៃប្រភេទសត្វព្រៃ
- កាត់បន្ថយឲ្យដល់កម្រិតតិចបំផុតនូវការរំខានដោយសំឡេងដែលកើតចេញពីសកម្មភាពគម្រោង
- អប់រំ និងហាមឃាត់បុគ្គលិក-កម្មករ និងប្រជាជនមូលដ្ឋាន មិនឱ្យធ្វើការបរបាញ់ប្រភេទសត្វព្រៃដែលមាននៅក្នុងតំបន់ដោយខុសច្បាប់ ព្រមទាំងផ្សព្វផ្សាយអំពីអត្ថផលប្រយោជន៍សត្វព្រៃ
- ដាក់បំរាមមិនឲ្យបុគ្គលិក-កម្មករបរិភោគសាច់សត្វព្រៃ និងមិនអនុញ្ញាឱ្យទិញសាច់ ឬសត្វព្រៃពីអ្នកលក់ ឬពីប្រជាពលរដ្ឋមូលដ្ឋាន។
- លើកទឹកចិត្តដល់បុគ្គលិក-កម្មករ (ផ្តល់ជារង្វាន់) ឱ្យចូលរួមរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ចក្នុងករណីសង្កេតឃើញមានការលួចបរបាញ់ខុសច្បាប់។
- ធ្វើការផាកពិន័យតឹងរឹង (ឧ. ព្រមាន ឬបញ្ឈប់ពីការងារ) ក្នុងការណីបុគ្គលិក-កម្មករណាមួយប្រព្រឹត្តិបទល្មើសនឹងបំរាមពាក់ព័ន្ធនឹងការបរបាញ់ និងបរិភោគសត្វព្រៃ។

**ង. ធនធានមច្ឆជាតិ**

**<u>ហេតុប៉ះពាល់៖</u>**

ហេតុប៉ះពាល់ដែលអាចកើតមានទៅលើធនធានមច្ឆជាតិមានដូចខាងក្រោម៖

- ការធ្លាក់ចុះនៃគុណភាពទឹកក្នុងអូរ ដោយសារតែការហូរច្រោះដីល្បាប់ចូលទៅក្នុងអូរ និងការបំពុលទឹកដែលកើតឡើងដោយសារការគ្រប់គ្រងកាកសំណល់រឹង រាវមិនបានត្រឹមត្រូវតាមបច្ចេកទេស។
- ការស្តារឡើងវិញនូវប្រព័ន្ធផ្លូវទឹក និងការសាសង់ស្រះ ឬអាងស្តុកទឹកដែលនឹងធ្វើឱ្យមានការប្រែប្រួលចរន្តទឹក។
- ការនេសាទខុសច្បាប់ពីសំណាក់បុគ្គលិក-កម្មករគម្រោង បន្ថែមលើសម្ពាធនៃការនេសាទខុសច្បាប់ដែលបាននិងកំពុងកើតមាននៅក្នុងតំបន់។

**<u>វិធានការកាត់បន្ថយ៖</u>**

ដើម្បីកាត់បន្ថយ ឬជៀសវាងនូវផលប៉ះពាល់ខាងលើ ក្រុមហ៊ុននឹងអនុវត្តនូវវិធានការដូចខាងក្រោម៖

- សហការជាមួយស្ថាប័នមានសមត្ថកិច្ច ដើម្បីជៀសវាងការរំខានដល់កន្លែង ឬតំបន់ដែលជម្រកមច្ឆជាតិសំខាន់ៗ ក្នុងករណីដែលក្រុមហ៊ុនស្តារប្រព័ន្ធផ្លូវទឹកទោះជាក្នុងគោលបំណងអ្វីក៏ដោយ។
- ធ្វើការលែងកូនមច្ឆជាតិនៅតាមប្រព័ន្ធផ្លូវទឹក ដែលមាននៅក្នុងនិងក្បែរទីតាំងគម្រោងក្នុងរយៈពេល១ឆ្នាំម្តង។
- ដាក់ពិន័យ ចំពោះបុគ្គលិក-កម្មករ ដែលបានលួចនេសាទត្រីខុសច្បាប់ និងលើកទឹកចិត្តដល់បុគ្គលិក-កម្មករឱ្យចូលរួមរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ច ក្នុងករណីសង្កេតឃើញមានសកម្មភាពលួចធ្វើការនេសាទត្រីខុសច្បាប់។
- រៀបចំ និងអនុវត្តឱ្យបានត្រឹមត្រូវតាម ផែនការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេង។

**៧.៣.៣. ធនធានសេដ្ឋកិច្ច និងសង្គម**

ក. កម្មសិទ្ធិដីធ្លី និងការប្រើប្រាស់ដី

<u>ក១. ហេតុ/ផលប៉ះពាល់៖</u>

ទោះបីគម្រោងមិនទាន់ដំណើរការដាំដុះ ប៉ុន្តែវត្តមានគម្រោងក្នុងតំបន់ បានបង្កការរំខានដល់ការប្រើប្រាស់ដីធ្លី របស់គ្រួសារជនជាតិដើមភាគតិចនិងគ្រួសារខ្មែរមួយចំនួនរួចទៅហើយ។ ដូច្នេះក្នុងដំណាក់កាលឈូសឆាយ ប្រសិនបើមិនអនុវត្តទៅតាមវិធានការច្បាស់លាស់ គម្រោងអាចនឹងបង្កផលប៉ះពាល់ទៅដល់ប្រជាជនថែមទៀត។

ក្នុងកិច្ចពិគ្រោះយោបល់ជាសាធារណៈ (សូមអានជំពូកទី៦) ប្រជាជននិងអាជ្ញាធរភូមិ-ឃុំនៅតែអះអាងថាមានដីធ្លីប្រជាជនមួយចំនួននៅមិនទាន់បានដោះស្រាយនៅឡើយ ទោះជាគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តរតនគិរី បានចុះធ្វើការអង្កេតវាស់វែង និងធ្វើអត្តសញ្ញាណកម្មដីម្តងទៀត ហើយបានកាត់ចេញ និងត្រូវរក្សាទុកនូវផ្ទៃដីសរុបរហូតដល់ចំនួន **១០.៩៩០ហិកតា** ដូចមានបង្ហាញខាងលើក្តី (តារាង5.29)។ ជាក់ស្តែង តាមការអះអាងរបស់លោកមេឃុំប៉ង់ មេភូមិហ្វាំង មេភូមិប៉ុង និងប្រជាជន ទីតាំងដីរបស់ក្រុមហ៊ុនបានកាត់ចំក្បាលដីស្រែរបស់ប្រជាជនចំនួន១០០០ហិកតា ដោយក្នុងនោះបានវាស់ចំក្បាលដីស្រែរបស់ប្រជាជនក្នុងភូមិប៉ុង និងភូមិហ្វាំងចំនួនជាង ៣០០ហិកតា ហើយក្រុមហ៊ុនក៏បានកាត់ចេញប្រហែល៩០% តែនៅ១០%ទៀតមិនទាន់ដោះស្រាយរួច។ ចំណែកឯនៅឃុំតាឡាតដែលមានភូមិរំពាត់ និងភូមិតាឡាតក៏មានប្រជាជនបានអះអាងថា ដីរបស់ក្រុមហ៊ុនបានប៉ះពាល់ទៅលើដីសហគមន៍សម្ភូហាភាពរំពាត់ និងតាឡាត និងដីបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយផងដែរ។

បន្ថែមពីនេះ វត្តមានគម្រោង នៅក្នុងភូមិសាស្ត្រ ឃុំប៉ង់ ឃុំភ្នំកុក ឃុំហាតប៉ក់ និងឃុំតាឡាត បានធ្វើឲ្យផ្ទៃដីសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាននៅក្នុងឃុំទាំងនេះថយចុះ ស្របពេលដែលតម្រូវការប្រើប្រាស់ដីកើនឡើងជាមួយនឹងកំណើនប្រជាជនក្នុងតំបន់ (៥,២%ក្នុងឃុំភ្នំកុក និង២,៨%ក្នុងឃុំតាឡាត)។ ដូច្នេះ ការថយចុះនៃផ្ទៃដីដែលនៅសេសសល់សម្រាប់អភិវឌ្ឍន៍ក្នុងមូលដ្ឋាន នឹងក្លាយជាកត្តាគំរាមកំហែងដល់លទ្ធភាពប្រើប្រាស់ដីនាពេលអនាគត ជាពិសេសក្នុងវិស័យកសិកម្ម (ធ្វើស្រែវស្សា ចម្ការដំឡូងមី និងស្វាយចន្ទី)។ ហេតុនេះ កូនចៅជំនាន់ក្រោយនឹងមានលទ្ធភាពកាន់តែតិចក្នុងការជ្រើសរើសមុខរបរក្នុងវិស័យកសិកម្មដើម្បីចិញ្ចឹមជីវិត។ លើសពីនេះ កង្វះខាតការរៀបចំផែនការច្បាស់លាស់ក្នុងការប្រើប្រាស់ដីក្នុងតំបន់របស់អាជ្ញាធរមូលដ្ឋាន ជាកត្តាគំរាមកំហែងដល់ការបែងចែកដី ដើម្បីប្រើប្រាស់ក្នុងពេលអនាគត ដែលនឹងអាចប៉ះពាល់ដល់សុខមាលភាពប្រជាជនក្នុងតំបន់។

<u>ក២. វិធានការកាត់បន្ថយ៖</u>

- ក្រុមហ៊ុននឹងមិនឈូសឆាយដីហួសពីព្រំដីដែលទទួលបានពីរដ្ឋាភិបាល
- ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាដីធ្លីដែលប្រជាជននៅតែអះអាងថាមិនទាន់បានដោះស្រាយ

ខ. មុខរបរ និងប្រាក់ចំណូល

<u>ខ១. ហេតុប៉ះពាល់៖</u>

ផ្អែកលើស្ថានភាពបច្ចុប្បន្ន ការបាត់បង់ដីធ្លីសម្រាប់ប្រកបរបរកសិកម្មនឹងធ្វើឲ្យប្រជាជនបាត់បង់ ឬថយចុះនូវប្រភពចំណូលសំខាន់សម្រាប់គ្រួសារ។ តាមរយៈការសិក្សាជាក់ស្តែង គ្រួសារដែលមានមុខរបរចម្បងធ្វើស្រូវចម្ការ ឬស្រូវវស្សា (ដែលមានចំនួនសរុបប្រមាណ ៥៨%) មានប្រាក់ចំណូលទាបជាមធ្យមបានប្រមាណ ៥០៨-១៤២៥ ដុល្លារ/ឆ្នាំប៉ុណ្ណោះ ហើយគ្រួសារដែលមានមុខរបរចម្បងដាំដំឡូងមី (ដែលមានចំនួន ៤០%) និងគ្រួសារដែលមានមុខរបរចម្បងដាំស្វាយចន្ទី (៤១%) មានប្រាក់ចំណូលខ្ពស់ជាមធ្យមអាចរកបានរហូតដល់ ៥០០០ដុល្លារ/ឆ្នាំ (ប៉ុន្តែច្រើនជាងគ្រួសារអ្នកធ្វើស្រូវចម្ការ ឬស្រូវវស្សា)។ យើងសង្កេតឃើញថា ក្នុងកំឡុងពេលធ្វើអង្កេតនេះគ្រួសារអ្នកដាំដំឡូងមីមានផ្ទៃដីតិចតួចសម្រាប់ដាំដំណាំនេះ ហើយដំណាំស្វាយចន្ទីដែលបានដាំដុះរួចនោះភាគច្រើនមិនទាន់បានទទួលផលពេញលេញនៅឡើយ ដូច្នេះគ្រួសារទាំងនេះអាចនឹងរកប្រាក់ចំណូលបានច្រើនក្នុងពេលដ៏ខ្លីខាងមុខ គឺនៅពេលដែលដំណាំស្វាយចន្ទីរបស់ពួកគាត់ផ្តល់ផលពេញលេញ។ ហេតុនេះ គ្រួសារដែលបាត់បង់ដីចម្ការ ឬដែលនឹងបាត់បង់ឱកាសមានដីធ្លីសម្រាប់ធ្វើស្រែចំការដោយសារវត្តមានក្រុមហ៊ុននោះ នឹងអាចបាត់បង់លទ្ធភាពរកប្រាក់ចំណូលពីរបរទាំងនេះក្នុងកម្រិតប្រហាក់ប្រហែលនឹងលទ្ធផលនៃការសិក្សានេះ។

ការបាត់បង់ចំណូលដែលអាចទទួលបានពីផលអនុផលព្រៃឈើជាក្តីបារម្ភដ៏សំខាន់មួយ។ ការសិក្សាស្ថានភាពសេដ្ឋកិច្ច និងសង្គមក្នុងតំបន់បង្ហាញថា មុខរបរចម្បងរបស់ប្រជាជន គឺពឹងផ្អែកទៅលើវិស័យកសិកម្មដែលមានអត្រាខ្ពស់រហូតដល់៨៥% ដោយក្នុងនោះមុខរបរដែលជាសេវាកម្មមានត្រឹម១០%ប៉ុណ្ណោះ និងការងារបានប្រាក់កម្រៃមានត្រឹម៥% ។ លទ្ធផលនេះបង្ហាញច្បាស់ថា ប្រជាជនក្នុងតំបន់ពឹងផ្អែកទៅលើវិស័យកសិកម្មយ៉ាងខ្លាំងសម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគាត់។ ហេតុនេះ ការបាត់បង់ផលអនុផលព្រៃឈើនៅពេលគម្រោងចាប់ផ្តើមដំណើរការ អាចនឹងបង្កផលប៉ះពាល់ដល់ជីវភាពរបស់ប្រជាជនក្នុងកម្រិតមួយគួរឲ្យបារម្ភ ព្រោះប្រជាជនក្នុងតំបន់នេះតែងតែប្រើប្រាស់ផលអនុផលព្រៃឈើសម្រាប់ធ្វើជាគ្រឿងសំណង់សម្រាប់សង់ផ្ទះ ឧបករណ៍កសិកម្ម ធ្វើជារបង ឈើថាមពល និងចំណីអាហារ ជាដើម។

លើសពីនេះ ការបាត់បង់ធនធានព្រៃឈើទ្រង់ទ្រាយធំ រួមចំណែកធ្វើឲ្យមានបម្រែបម្រួលប្រព័ន្ធជលសាស្ត្រ និងគុណភាពទឹកអូរធម្មជាតិដែលជាទីជម្រកមច្ឆជាតិ ដូច្នេះវាអាចមានផលប៉ះពាល់ដល់ប្រភពចំណូល និងបង្កើនខ្ទង់ចំណាយនៅក្នុងគ្រួសារ។ ស្ថានភាពបែបនេះនឹងធ្វើឲ្យការរស់នៅរបស់ប្រជាជនកាន់តែលំបាកជាងមុន ជាពិសេសដោយពួកគាត់មានបានការអប់រំតិចតួច ឱកាសទទួលបានការងារថ្មីសមស្របក៏មានកាន់តែតិច ហើយភាពងាយរងគ្រោះនេះនឹងមានកម្រិតកាន់តែធ្ងន់ធ្ងរចំពោះជនជាតិដើមភាគតិច ស្ត្រី កុមារ និងជនពិការជាដើម។

ទោះជាយ៉ាងណា ការបង្កើតយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាព និងវិធានការសមស្របសម្រាប់លើកកម្ពស់សេដ្ឋកិច្ចមូលដ្ឋាន ជីវភាពប្រជាជន និងសុខុមាលភាពសង្គម នឹងអាចជួយកាត់បន្ថយភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ដែលអាចកើតឡើងទាំងនេះ។ ជាក់ស្តែងការអង្កេតតាមគ្រួសារបានបង្ហាញថា បម្រែបម្រួលយុទ្ធសាស្ត្រនៃការប្រកបរបរចិញ្ចឹមជីវិតដើម្បីឆ្លើយតបនឹងស្ថានភាពនៃការអភិវឌ្ឍក្នុងតំបន់បានធ្វើឲ្យគ្រួសារក្នុងតំបន់សិក្សាប្រមាណ ៥១% មានកម្រិតជីវភាពកើនឡើង, គ្រួសារប្រមាណតែ២០% មានកម្រិតជីវភាពថយចុះ និងគ្រួសារប្រមាណ ២៣% មានកម្រិតជីវភាពនៅដដែល។

**ខ២. វិធានការកាត់បន្ថយ៖**

- ក្រុមហ៊ុននឹងរៀបចំ និងអនុវត្តគម្រោងកសិកម្មបែបកិច្ចសន្យា (គាំទ្របច្ចេកទេសដាំដុះ និងទិញយកកសិផល) ចំពោះមុខដំណាំដែលជាមុខព្រួញនៃគម្រោងវិនិយោគនេះ (ដូចជា កាកាវ ដូង អាកាស្យាសេណេហ្គាល់ សណ្តែកសៀង)។
- ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបណ្តុះបណ្តាលចំណេះដឹង ជំនាញចិញ្ចឹមសត្វ និងជំនាញឯកទេសផ្សេងទៀតដល់ប្រជាជនមូលដ្ឋាន។
- ក្រុមហ៊ុននឹងផ្តល់ឱកាសសមស្របដល់ប្រជាជនអាចបម្រើការងារនៅក្នុងតំបន់គម្រោង ដោយមានប្រាក់បៀវត្សសមរម្យអាចទទួលយកបានពីសំណាក់ពួកគាត់ ដើម្បីអាចចូលរួមស្តារស្ថានភាពជីវភាពឡើងវិញ។
- ក្រុមហ៊ុន នឹងផ្តល់លទ្ធភាពដល់ប្រជាជនមូលដ្ឋានក្នុងការចូលរក និងប្រមូលអនុផលព្រៃឈើជាលក្ខណៈប្រពៃណី (ដូចបានចែងនៅក្នុងច្បាប់ស្តីពីព្រៃឈើ) ក្នុងព្រៃរក្សាទុក ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់។

## គ. ការប្រើប្រាស់ទឹក សុខភាព និងអនាម័យក្នុងការរស់នៅ របស់ប្រជាជនមូលដ្ឋាន

គ១. ហេតុប៉ះពាល់៖

ការប្រើប្រាស់ទឹករបស់ប្រជាជននៅតំបន់គម្រោង បច្ចុប្បន្នប្រជាជនបានប្រើប្រាស់ទឹកទន្លេ និងទឹកអណ្តូងជាប្រភពទឹកចម្បងសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ។ ប្រជាជនមានចំនួនច្រើនបានប្រើប្រាស់ទឹកភ្លៀងសម្រាប់ធ្វើស្រែ



Draft

ចម្ការ។ ប្រភពទឹកអូរ ស្ទឹង ព្រែក ប្រឡាយមិនត្រូវបានប្រជាជននិយមប្រើប្រាស់ទេ ដោយពួកគាត់យល់ថាមិនស្អាត កខ្វក់ដែលនេះមកពីមូលហេតុនៃការបំពុលពីសំរាម និងរួមផ្សំនឹងសារធាតុគីមីពីដំណាំកសិ-ឧស្សាហកម្មរបស់ក្រុមហ៊ុនផ្សេងៗដែលនៅក្នុងតំបន់។ ករណីនេះ អាចស្មើបានថានៅពេលដែលគម្រោងចាប់ផ្តើមដំណើរការដាំដុះអាចនឹងមានការបំពុលប្រភពទឹកទាំងនេះបន្ថែមទៀត ប្រសិនបើមិនមានវិធានការទប់ស្កាត់ការបំពុលត្រឹមត្រូវ។ ថ្នាំគីមីដែលបាញ់ដំណាំកៅស៊ូអាចនឹងប៉ះពាល់ដល់ទឹកទន្លេដែលជាប្រភពចម្បងរបស់ប្រជាជន និងការបំពុលទឹកក្រោមដីអាចប៉ះពាល់ដល់ប្រភពទឹកអណ្តូងផងដែរ ដែលជាបញ្ហាមួយត្រូវយកចិត្តទុកដាក់បញ្ចៀសនៅពេលដែលបច្ចុប្បន្នប្រភពទឹកអូរ ស្ទឹង ព្រែក ឬប្រឡាយត្រូវបានចាត់ទុកថាមានគុណភាពមិនល្អ(៤១%) និងប្រជាជនយល់ឃើញថាមានស្ថានភាពល្អក់កករដែលមានអត្រាខ្ពស់រហូតដល់៤៣%។ ដូច្នេះ ផលប៉ះពាល់ដល់សុខភាពរបស់ប្រជាជនដោយសារទឹកអូរទាំងនោះរងការបំពុលដោយសារថ្នាំពុលកសិកម្ម និងសកម្មភាពផ្សេងៗទៀតរបស់គម្រោង។

លើសពីនេះទៅទៀត ការគ្រោងស្ទាក់ទប់ទឹកយ៉ាងច្រើនទុកប្រើតែនៅក្នុងតំបន់គម្រោង និងលទ្ធភាពនៃការឈូសឆាយលុបប្រភពទឹកអូររបស់ក្រុមហ៊ុន អាចនឹងធ្វើឲ្យមានការរំខានដល់ការប្រើប្រាស់ទឹករបស់ប្រជាជនសម្រាប់ជីវភាពប្រចាំថ្ងៃ និងសម្រាប់ការងារកសិកម្ម ជាពិសេសនៅរដូវប្រាំង។ ដោយឡែក សកម្មភាពឈូសឆាយដីអាចនឹងធ្វើឲ្យមានការហូរច្រោះដី កករល្បាប់ និងការបោះចោលសំណល់រឹង និងបង្ហូរសំណល់រាវចូលទៅក្នុងប្រភពទឹក អាចនឹងធ្វើឲ្យមានការបំពុលប្រភពទឹកប្រើប្រាស់របស់មនុស្សនិងសត្វ។ល។ ប្រសិនបើមិនបានអនុវត្តតាមវិធានការត្រឹមត្រូវ។

ការបាត់បង់/ថយចុះប្រភពចំណីអាហារពីធម្មជាតិ (ដូចជា បន្លែ សត្វព្រៃ ត្រី) អាចនឹងត្រូវបានជំនួសដោយចំណីអាហារពីទីផ្សារដែលអាចមានសារធាតុគីមីនឹងធ្វើឲ្យប៉ះពាល់ដល់សុខភាព។ ការកើនឡើងនូវចំណាយលើចំណីអាហារ គួបផ្សំនឹងថ្លៃព្យាបាលជម្ងឺ អាចនឹងធ្វើឲ្យសុខមាលភាពប្រជាជនធ្លាក់ចុះ។

<u>គ២. វិធានការកាត់បន្ថយ៖</u>

- មិនធ្វើទំនប់ស្ទាក់ទឹក ឬឈូសឆាយលប់ប្រភពទឹកដែលធ្វើឲ្យប៉ះពាល់ដល់បរិមាណធារទឹក និងការប្រើប្រាស់ទឹករបស់ប្រជាជននៅខ្សែទឹកខាងក្រោម
- ជីកស្រះស្តុកទឹកភ្លៀងសម្រាប់ប្រើប្រាស់ ដើម្បីកាត់បន្ថយសម្ពាធលើការប្រើប្រាស់ទឹកពីប្រព័ន្ធផ្លូវទឹកធម្មជាតិ និងទឹកក្រោម
- រៀបចំ និងអនុវត្តឱ្យបានត្រឹមត្រូវតាម ផែនការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេង ដើម្បីការពារការបំពុលប្រភពទឹក
- ធ្វើការដាំដើមឈើនៅតាមដងអូរដែលគ្មានគម្របព្រៃ ឬមានព្រៃរចរឹលឲ្យបានចម្ងាយពី ១០០ ម៉ែត្រ ទៅ ១៥០ម៉ែត្រ ដើម្បីបង្កើតជារនាំងចម្រោះទឹកធម្មជាតិ
- គាំទ្រការបង្កើនសួនបន្លែធម្មជាតិ និងកសិដ្ឋានចិញ្ចឹមសត្វប្រចាំគ្រួសារ ដើម្បីកាត់បន្ថយការទិញចំណីអាហារពីទីផ្សារ
- គាំទ្រដល់កម្មវិធីអប់រំ ផ្សព្វផ្សាយអំពីសុខភាព អនាម័យក្នុងការរស់នៅ (ជាពិសេសរៀបចំ និងចែកចាយនូវផ្ទាំងផ្សព្វផ្សាយអំពីបំរាមក្នុងការប្រើប្រាស់ធុងថ្នាំគីមីកសិកម្មសម្រាប់ស្តុកម្ហូបអាហារ និងទឹកបរិភោគ)
- គាំទ្រដល់ដំណើរការមណ្ឌលសុខភាពដែលមានស្រាប់ក្នុងតំបន់ (មណ្ឌលសុខភាពភ្នំកុក និងមណ្ឌលសុខភាពរ៉ូនសៃ)

Draft

- គាំទ្រដល់ដំណើរការបង្កើតមណ្ឌលសុខភាពក្នុងភូមិតាឡាត ឬភូមិរំពាត់ នៃឃុំតាឡាត (ភូមិទាំងពីរនេះនៅដាច់ស្រយាលពីទីប្រជុំឃុំ និងស្ថិតនៅក្រោមខ្សែទឹកនៃទីតាំងគម្រោង)

**ឃ. ប្រពៃណី ទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច**

**<u>ឃ១. ហេតុប៉ះពាល់៖</u>**

ប្រពៃណីធ្វើកសិកម្មពនេចររបស់ប្រជាជនជនជាតិដើមអាចនឹងត្រូវបានកម្រិត ក្រោយផ្ទៃដីព្រៃឈើក្នុងតំបន់មួយភាគធំត្រូវបានប្រគល់ឲ្យក្រុមហ៊ុនដើម្បីដំណើរការគម្រោងនាពេលដ៏ខ្លីខាងមុខ។ ការបាត់បង់ព្រៃឈើអាចនឹងធ្វើឲប្រពៃណីទំនៀមទម្លាប់មួយចំនួនដូចជា៖ ការកប់សព ការសែនព្រេនអារក្សអ្នកតា ការប្រកបរបរបណ្ដើរឆ្កែដេញសត្វ ការដេងជ័រ និងរកអនុផលព្រៃឈើផ្សេងៗក៏ត្រូវបានកម្រិត និងផ្លាស់ប្តូរដែរ។

កិច្ចពិភាក្សាជាមួយមន្ទីរពាក់ពន្ធ័និងអជ្ញាធម៌មូលដ្ឋាន បានឲ្យដឹងថាដីពាក់ពន្ធ័នានាដូចជា ដីកប់សព ទីទួលសុវត្ថិភាព ព្រៃអារក្ស គឺត្រូវបានកាត់ចេញឲប្រជាជនវិញអស់ហើយ។ ក្នុងករណីការប៉ះពាល់ទៅលើវប្បធម៌ប្រពៃណីជូនតានៅក្នុងគម្រោងសម្បទានមួយនេះ ហាក់មិនមានបញ្ហាចោទធ្ងន់ធ្ងរនោះទេ។ បច្ចុប្បន្ន តាមរយៈការសម្ភាសន៍ជាមួយប្រជាជនក្នុងខែឧសភា និងខែធ្នូ ឆ្នាំ២០១៦ បានឲដឹងថា ការកំណត់ព្រំដីរបស់គម្រោងនៅមានប៉ះពាល់សម្បត្តិវប្បធម៌របស់ជនជាតិដើមភាគតិចក្នុងភូមិពាក់ព័ន្ធមួយចំនួនតូចដូចខាងក្រោម៖

ហេតុនេះ សិទ្ធិដូចមានចែងក្នុង **មាត្រា ៤០**នៃច្បាប់ព្រៃឈើ ដែលថា "ចំពោះសហគមន៍មូលដ្ឋានរស់នៅក្នុង ឬក្បែរដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ រដ្ឋត្រូវទទួលស្គាល់ និងធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍មូលដ្ឋាននោះសម្រាប់គោលបំណងទំនៀមទម្លាប់ ជំនឿ សាសនា និងការរស់នៅដូចមានចែងក្នុងមាត្រានេះ" ត្រូវបានរំលោភបំពាន។

លើសពីនេះ ទំនៀមទម្លាប់ ប្រពៃណីរបស់ជនជាតិដើមភាគតិច ជាពិសេសសហគមន៍ដែលនៅជាប់នឹងទីតាំងគម្រោង (៧.១) នឹងទទួលរងនូវឥទ្ធិពលពីវប្បធម៌ថ្មី ដែលនាំចូលមកជាមួយនឹងបុគ្គលិក-កម្មករដែលជាជនចំណូលថ្មី។

<u>ឃ២. វិធានការកាត់បន្ថយ៖</u>

- ផ្តល់លទ្ធភាពដល់ប្រជាជនមូលដ្ឋានក្នុងការអនុវត្តនូវប្រពៃណីនៃការប្រមូលអនុផលព្រៃឈើ ដោយមិនហាមឃាត់ពួកគាត់មិនឱ្យចូលព្រៃរក្សាទុក។
- ផ្សព្វផ្សាយអំពីទំនៀមទម្លាប់ ប្រពៃណី (ជាពិសេសតំណមនានា) របស់ជនជាតិដើមភាគតិច ដល់បុគ្គលិក-កម្មករ និងដាក់បំរាមមិនឱ្យបុគ្គលិក-កម្មករធ្វើសកម្មភាពអ្វីដែលអាចប៉ះពាល់ដល់ទំនៀមទម្លាប់ ប្រពៃណីទាំងនោះ។
- សហការជាមួយអាជ្ញាធរ និងសហគមន៍មូលដ្ឋាន ដើម្បីរៀបចំពិធីបុណ្យតាមបែបប្រពៃណីរបស់ជនជាតិដើមភាគតិច។
- សហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាដីធ្លីដែលប្រជាជននៅតែអះអាងថាមិនទាន់បានដោះស្រាយ។

**ង. សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋាន**

**<u>ង១. ហេតុប៉ះពាល់៖</u>**

សកម្មភាពគម្រោង អាចនឹងបង្កបញ្ហាមួយចំនួនពាក់ព័ន្ធនឹងសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋាន ដូចជា៖

Draft

- យានយន្តរបស់ក្រុមហ៊ុនដែលបើកឆ្លងកាត់ភូមិដ្ឋានប្រជាជន អាចនឹងបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ ដោយសារការបើកលឿនពេក ការធ្វេសប្រហែសរបស់អ្នកបើកបរ និងភាពមានកម្រិតនៃចំណេះដឹងអំពីច្បាប់ចរាចរណ៍របស់ប្រជាជនមូលដ្ឋាន
- បុគ្គលិក-កម្មករគម្រោងដែលជាជនចំណូលថ្មី អាចរស់នៅមិនចុះសម្រុងនឹងប្រជាជនមូលដ្ឋានដែលជាជនជាតិដើមភាគតិច ដែលអាចនឹងឈានទៅបង្កជាជម្លោះ និងអំពើហឹង្សានានា
- បុគ្គលិក-កម្មករគម្រោងដែលជាជនចំណូលថ្មី អាចនាំមកនូវវប្បធម៌មិនល្អ ដូចជាការសេពគ្រឿងញៀន ការលេងល្បែងស៊ីសង ចោរកម្ម ជម្ងឺឆ្លង ពេស្យាចារ និងករណីរំលោភសេពសន្ថវៈ (ពីបុគ្គលិក-កម្មករលើប្រជាជន និង/ឬពីប្រជាជនលើបុគ្គលិក-កម្មករ)។

**ង២. វិធានការកាត់បន្ថយ**

- ណែនាំឱ្យអ្នកបើកបរគោរពច្បាប់ចរាចរណ៍ និងពិន័យធ្ងន់ធ្ងរ ប្រសិនបើមិនគោរពច្បាប់ ហើយការមិនគោរពច្បាប់ធ្វើឱ្យមានគ្រោះថ្នាក់ចរាចរណ៍
- ធ្វើការផ្សព្វផ្សាយជាចំណេះដឹងបន្ថែមដល់ប្រជាជនមូលដ្ឋាន ទាក់ទងនឹងសុវត្ថិភាពចរាចរណ៍
- ជ្រើសរើសបុគ្គលិក-កម្មករក្នុងមូលដ្ឋាន ឲ្យអស់លទ្ធភាពមុននឹងសម្រេចជ្រើសរើសអ្នកតំបន់ផ្សេង
- បញ្ចូលក្នុងបទបញ្ជាផ្ទៃក្នុងនូវបំរាមពាក់ព័ន្ធនឹងគ្រឿងញៀន អំពើហឹង្សាជាមួយប្រជាជនមូលដ្ឋាន និងករណីចោរកម្ម ពេស្យាចារ រំលោភសេពសន្ថវៈ
- សហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការត្រួតពិនិត្យ និងតាមដានបុគ្គលិក-កម្មករ ដែលជាជនចំណូលថ្មី ដើម្បីធានាថាពួកគេមិនពាក់ព័ន្ធនឹងគ្រឿងញៀន បង្កហឹង្សាជាមួយប្រជាជនមូលដ្ឋាន និងបង្កឲ្យមានករណីចោរកម្ម ពេស្យាចារ សេពសន្ថវៈ
- មានផែនការត្រួតពិនិត្យសុខភាពបុគ្គលិក-កម្មករជាប្រចាំ និងបណ្តុះបណ្តាលពួកគាត់អំពីបញ្ហានៃជម្ងឺឆ្លង ការបង្ការជម្ងឺឆ្លងនានា និងផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន ។ល។
- គាំទ្រដល់បេសកកម្មរបស់ប្រជាការពារឃុំ ដើម្បីពង្រឹងសុវត្ថិភាព និងសន្តិសុខមូលដ្ឋាន

ច. សុខភាព សុវត្ថិភាព និងសុខមាលភាពបុគ្គលិក និងកម្មករគម្រោង

**ច១. ហេតុប៉ះពាល់៖**

នៅពេលគម្រោងចាប់ផ្តើមដំណើរការឈូសឆាយ និងដាំដុះនឹងមានបុគ្គលិក កម្មករមួយចំនួនមកស្នាក់នៅក្នុងតំបន់គម្រោងដែលនឹងតម្រូវឲ្យមានការសាងសង់លំនៅដ្ឋានសម្រាប់ពួកគាត់។ ស្ថានភាពលំនៅដ្ឋានរបស់កម្មករប្រសិនបើពុំមានស្តង់ដារល្អ (មិនមានការផ្គត់ផ្គង់ទឹកស្អាតគ្រប់គ្រាន់ មិនមានបង្គន់អនាម័យប្រើប្រាស់ត្រឹមត្រូវ និងមិនមាន ការគ្រប់គ្រងឲ្យបានល្អ) នឹងបង្កនូវផលប៉ះពាល់ដល់សុខភាព និងសុខមាលភាពពួកគាត់ធ្ងន់ធ្ងរ។ លើសពីនេះទៀតការរស់នៅច្រើនគ្នាក្នុងលំនៅដ្ឋានតូចចង្អៀត ឬរស់នៅក្នុងជំរុំប្រក់តង់កៅស៊ូ ដូចធ្លាប់មានក្នុងគម្រោងផ្សេងៗទៀតពីមុនមក នឹងបង្កនូវផលប៉ះពាល់ដល់សុខភាពដោយអាចងាយឆ្លងមេរោគនានា។ដោយសារតំបន់គម្រោងស្ថិតនៅក្បែរតំបន់ព្រៃ និងមានប្រជាជនមូលដ្ឋានភាគច្រើនធ្លាប់កើតជម្ងឺគ្រុនចាញ់កន្លងមក បុគ្គលិក និងកម្មករគម្រោងនឹងប្រឈមមុខខ្លាំងនឹងជំងឺគ្រុនចាញ់នេះផងដែរ ប្រសិនណាមិនមានការថែរក្សាសុខភាព និងមិនមានវិធានការសុវត្ថិភាពត្រឹមត្រូវនោះទេ។

ការបញ្ជាគ្រឿងចក្រក្នុងការឈូសឆាយ រៀបចំដីដាំដុះ និងថែទាំដំណាំ ដោយគ្មានបច្ចេកទេស អាចនឹងបង្កគ្រោះថ្នាក់ដល់អ្នករួមការងារ និងខ្លួនឯង។ គ្រោះថ្នាក់ដែលធ្លាប់កើតមានកន្លងមក មានដូចជា៖ ការប៉ះទង្គិចជាមួយ

Draft

គ្រឿងចក្រដែលធ្វើឱ្យគ្រាំក្នុង ឬដាច់រលាត់លើសារពាង្គកាយ ការប៉ះពាល់ដល់ប្រព័ន្ធប្រសាទដោយសារការប្រើប្រាស់រណារយន្ត ជាដើម។

ការប្រើប្រាស់ថ្នាំពុលកសិកម្មដោយធ្វេសប្រហែស ដោយគ្មានការអនុវត្តយន្តការសុវត្ថិភាព (ការបំពាក់សម្ភារ និងឧបករណ៍ការពារ) ពុំមានការណែនាំឲ្យយល់អំពីហានិភ័យបណ្តាលមកពីសារធាតុគីមី ពិសេសថ្នាំពុលកសិកម្ម (ថ្នាំសម្លាប់ស្មៅ) និងជីគីមី ពុំមានការបណ្តុះបណ្តាលអំពីសុវត្ថិភាពក្នុងការប្រើប្រាស់សារធាតុគីមី នឹងបង្កនូវផលប៉ះពាល់ដល់សុខភាពបុគ្គលិក និងកម្មករគម្រោង។

**ច២. វិធានការកាត់បន្ថយ៖**

- ផ្តល់លំនៅដ្ឋានសម្រាប់ស្នាក់នៅ ក្នុងកម្រិតស្តង់ដារកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ស្របតាមច្បាប់ស្តីពីការងារ (មាត្រា ២០៤ ដល់ ២០៦ និង មាត្រានានាក្នុងជំពូក៧ និងជំពូក៨)។
- ផ្តល់នូវការបណ្តុះបណ្តាលអំពីការទប់ស្កាត់ការកើតជម្ងឺគ្រុនចាញ់ និងផ្តល់មុងជ្រលក់ថ្នាំដល់បុគ្គលិក-កម្មករ។
- ផ្តល់ការបណ្តុះបណ្តាលអំពីបច្ចេកទេសបញ្ជាគ្រឿងចក្រ និងវិធានសុវត្ថិភាពក្នុងការការពារគ្រោះថ្នាក់ក្នុងពេលបំពេញការងារ និងការពារផលប៉ះពាល់ពីថ្នាំគីមីកសិកម្ម
- ផ្តល់ឱ្យបុគ្គលិក-កម្មករនូវឧបករណ៍សុវត្ថិភាពស្របតាមបទដ្ឋានកំណត់ (ដូចជា ស្បែកជើងកវែង ម៉ាស់ការពារមុខ ស្រោមដៃ ខោអាវសម្រាប់ស្លៀកពាក់ពេលបាញ់ថ្នាំ)
- អនុវត្តកម្មវិធីត្រួតពិនិត្យ និងថែទាំសុខភាព ជាពិសេសពាក់ព័ន្ធនឹងជម្ងឺគ្រុនចាញ់ និងជម្ងឺដែលបង្កឡើងដោយសារផលប៉ះពាល់នៃថ្នាំគីមីកសិកម្ម។
- រៀបចំឱ្យមានស្លាកសញ្ញាបង្ហាញ និងណែនាំនៅទីតាំងស្តុកថ្នាំពុលកសិកម្ម អំពីគ្រោះថ្នាក់ដែលអាចបណ្តាលមកពីថ្នាំពុលកសិកម្ម និងវិធីសាស្ត្រណែនាំអំពីការលាយថ្នាំ។
- មិនអនុញ្ញាតឲ្យបុគ្គលិក-កម្មករដែលគ្មានភារកិច្ច ឬដែលមិនពាក់ឧបករណ៍ការពារ ចូលទីតាំងស្តុកថ្នាំគីមីកសិកម្ម និងជីកសិកម្ម
- រៀបចំទីតាំងស្តុកថ្នាំគីមីកសិកម្ម និងជីកសិកម្ម ទៅតាមលក្ខណៈបច្ចេកទេស ដោយការពារមិនឲ្យប៉ះពាល់ទឹក លេចជ្រាបចូលក្នុងដី ហុយតាមខ្យល់ ឬត្រូវកំដៅ និងត្រូវមានឧបករណ៍ការពារអគ្គិភ័យ និងខ្យល់ចេញចូលល្អ។
- លាយតាមស្តង់ដារបច្ចេកទេសនូវថ្នាំពុលកសិកម្ម តាមការណែនាំនៅលើសំបកថ្នាំ នៅទីតាំងរួមមួយក្បែរទីតាំងស្តុកថ្នាំ ដែលធានានូវសុវត្ថិភាពមិនប៉ះពាល់ដល់បរិស្ថាន និងសុខភាពមនុស្ស មុនចែកចាយបន្តឲ្យកម្មករប្រើប្រាស់។
- ប្រមូលមកវិញនូវធុងបាញ់ថ្នាំរបស់កម្មករ ដើម្បីរក្សាទុកនៅតាមទីតាំងរួម ដោយមិនអនុញ្ញាតឲ្យកម្មករយកទៅរក្សាទុកតាមផ្ទះរបស់ខ្លួន ដែលអាចធ្វើឲ្យប៉ះពាល់ដល់សុខភាពសមាជិកគ្រួសារ និងខ្លួនឯង។
- មានបន្ទប់ព្យាបាលបឋមសម្រាប់ជួយសង្គ្រោះបុគ្គលិក-កម្មករ នៅពេលមានកើតជម្ងឺ ឬមានគ្រោះថ្នាក់ក្នុងពេលបំពេញការងារ។
- ផ្តល់ការធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់ការងារដល់គ្រប់បុគ្គលិក-កម្មករ ក្រោមរូបភាពបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)។

## ៧.៤. ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ ក្នុងដំណាក់កាលបញ្ចប់គម្រោង

នៅពេលបញ្ចប់គម្រោងវិនិយោគនេះ (ឆ្នាំទី៥០) ដំណាំកសិ-ឧស្សាហកម្មដែលបានដាំដុះក្នុងដំណើរការគម្រោងវិនិយោគនេះ នឹងស្ថិតនៅក្នុងពេលផ្តល់ផល។ ក្រុមហ៊ុននឹងផ្ទេរទីតាំងគម្រោង (រួមទាំងចំការកាកាវ ដូង អាកាស្យាសេណេហ្គាល់ កៅស៊ូ និងដំណាំកសិ-ឧស្សាហកម្មផ្សេងទៀត) ទៅឱ្យរាជរដ្ឋាភិបាលកម្ពុជាវិញ។ ដូច្នេះ ថ្វីត្បិតតែសិទ្ធិវិនិយោគរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់ ដំណើរការគម្រោង (ការប្រមូលផល) នឹងនៅតែបន្ត។ ទោះជាយ៉ាងនេះក្តី ក្រុមហ៊ុនម្ចាស់គម្រោង នឹងសហការជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ច ដើម្បីធ្វើការសម្អាតបរិស្ថានឱ្យស្របតាមច្បាប់ដែលមានជាធរមាន មុននឹងផ្ទេរទីតាំងទៅឱ្យរាជរដ្ឋាភិបាលវិញ។ រាជរដ្ឋាភិបាល អាចប្រគល់សិទ្ធិក្នុងលក្ខខណ្ឌវិនិយោគសមស្របទៅឱ្យក្រុមហ៊ុនមួយផ្សេងទៀត ដើម្បីប្រមូលផលបន្ត។ ការរៀបចំផែនការបិទគម្រោង និងស្តារបរិស្ថានឡើងវិញ ជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនដែលទទួលសិទ្ធប្រមូលផលបន្តនោះ។

ខាងក្រោមនេះជាការបរិយាយពីហេតុប៉ះពាល់បរិស្ថានចម្បងៗ និងវិធានការកាត់បន្ថយ នៅក្នុងដំណាក់កាលបញ្ចប់គម្រោង៖

### ក. ការតាំងទីលំនៅ

**<u>ហេតុប៉ះពាល់៖</u>** អាចនឹងមានប្រជាជនចាបយកដីចំការ និង/ឬ តាំងទីលំនៅបែបអនាធិបតេយ្យ នៅលើដីដែលជាទីតាំងគម្រោងនៅពេលក្រុមហ៊ុនចាកចេញ។

**<u>វិធានការកាត់បន្ថយ៖</u>** ក្រុមហ៊ុននឹងធ្វើផ្ទេរទីតាំងគម្រោងទៅរដ្ឋាភិបាលជាគ្រប់គ្រងវិញស្របតាមនីតិវិធីដែលមានជាធរមាន (ក្នុងករណីរដ្ឋាភិបាលមិនអនុញ្ញាតឱ្យវិនិយោគបន្ត)។

### ខ. ស្ថានភាពសេដ្ឋកិច្ច

**<u>ហេតុប៉ះពាល់៖</u>**

- ប្រជាពលរដ្ឋដែលជាបុគ្គលិក-កម្មករគម្រោង នឹងត្រូវបាត់បង់ការងារ
- វិស័យឯកជនមួយចំនួនធំ (ឧ. អ្នកលក់ជី ថ្នាំសម្លាប់សត្វល្អិត និងថ្នាំកំចាត់ស្មៅចង្រៃ) ត្រូវបាត់បង់ផលប្រយោជន៍ពីគម្រោង
- ប្រជាពលរដ្ឋក្បែរខាងអាចបាត់បង់ចំណូលបន្ថែមពីសេវាកម្មមួយចំនួន (ឧ. លក់ដូរ)

**<u>វិធានការកាត់បន្ថយ៖</u>**

- ធ្វើការផ្សព្វផ្សាយ និងបិទប្រកាសយ៉ាងតិច ០៣ខែ មុនបិទគម្រោង ដើម្បីឲ្យបុគ្គលិក-កម្មករបានដឹង និងមានពេលវេលាគ្រប់គ្រាន់សម្រាប់ស្វែងរកការងារថ្មី
- ក្រុមហ៊ុនមានថវិកាសម្រាប់ពេលបិទគម្រោងជូនបុគ្គលិក-កម្មករ ដោយគោរពតាមច្បាប់ការងារ និងទៅតាមរយៈពេលធ្វើការ និងស្នាដៃការងារ
- បើសិនមានការអភិវឌ្ឍថ្មីរបស់ក្រុមហ៊ុន នោះក្រុមហ៊ុននឹងផ្តល់អត្តិភាពការងារជាចម្បងដល់បុគ្គលិក-កម្មករ ចាស់ធ្លាប់បម្រើការងារឲ្យក្រុមហ៊ុន។

### គ. ការបំពុលដី ទឹកលើដី និងទឹកក្រោមដី

**<u>ហេតុប៉ះពាល់៖</u>** សំណល់គ្រប់ប្រភេទដែលនៅបន្សល់ទុកក្នុងទីតាំងគម្រោង ក្រោយពេលក្រុមហ៊ុនចាកចេញ៖

- អាចធ្វើឱ្យប៉ះពាល់ដល់គុណភាពដី

- អាចហូរចូលទៅក្នុងប្រភពទឹក/អូរធម្មជាតិ ដែលធ្វើឱ្យប្រភពទឹកទាំងនោះរងការបំពុល និងធ្វើឱ្យប៉ះពាល់ដល់ធនធានជីវៈចម្រុះក្នុងទឹក និងសុខភាពមនុស្ស ដែលប្រើប្រាស់ទឹកពីប្រភពទាំងនោះ
- អាចហូរជ្រាបទឹកបំពុលចេញពីសំរាម (leachate) ចូលទៅក្នុងប្រភពទឹកក្រោមដី ដែលធ្វើឱ្យប៉ះពាល់គុណភាពទឹក។

**<u>វិធានការកាត់បន្ថយ៖</u>**

- ក្រុមហ៊ុននឹងរៀបចំផែនការបិទគម្រោង និងស្តារបរិស្ថានឡើងវិញឱ្យបានត្រឹមត្រូវរយៈពេល ០១ឆ្នាំមុនគម្រោងបញ្ចប់
- ក្រុមហ៊ុនមានថវិកាបម្រុងប្រមាណ ៣.០០០ដុល្លារសម្រាប់សម្អាតអនាម័យបរិស្ថានក្នុងទីតាំងគម្រោងមុនពេលបញ្ចប់ការវិនិយោគ។

Draft

តារាង៧.២៖ សង្ខេបហេតុ/ផលប៉ះពាល់បរិស្ថាន និងសង្គមអវិជ្ជមាន និងវិធានការកាត់បន្ថយ

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ តិច | មធ្យម | ខ្លាំង | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| **១.ដំណាក់កាលសាងសង់** | | | | | |
| **១.១. ធនធានបរិស្ថានរូបសាស្ត្រ** | | | | | |
| ក.សណ្ឋានដី/ឋានលេខា | – ការឈូសឆាយពង្រាបដីឲ្យរាបស្មើនៅតាមតំបន់ដែលមានទួល និងដំបូកខ្ពស់ៗ ដើម្បីសាងសង់ផ្លូវ ផ្ទះកម្មករ និងហេដ្ឋារចនាសម្ព័នផ្សេងៗទៀត | √ | | | • សិក្សាប្លង់លម្អិតជាមុន មុននឹងធ្វើការឈូសឆាយ<br>• ធ្វើការឈូសឆាយដីរៀបចំដីទៅតាមលក្ខណៈសណ្ឋានដី<br>• រក្សាទុកនូវតំបន់ភ្នំ ឬតំបន់ដែលមានរយៈកម្ពស់ខ្ពស់តាមការណែនាំរបស់ស្ថាប័នជំនាញ |
| ខ.ប្រព័ន្ធជលសាស្ត្រ | – ការឈូសឆាយដីព្រៃ ធ្វើប្រព័ន្ធផ្លូវ<br>– ការលុបប្រព័ន្ធអូរ និងដៃអូរមួយចំនួន<br>– ការហូរច្រោះកករដី មែកឈើ ឬស្លឹកឈើហូរចូលក្នុងអូរ ឬប្រឡាយ<br>– ការសាងសង់អាងស្តុកទឹក និងការស្តារឡើងវិញនូវអូរ និងដៃអូរមួយចំនួន | √ | | | • ករណីសាងសង់ហេដ្ឋរចនាសម្ព័នឆ្លងកាត់ប្រព័ន្ធផ្លូវទឹក ក្រុមហ៊ុនត្រូវសាងសង់ស្ពានឆ្លងកាត់ ឬរៀបចំប្រព័ន្ធលូបង្ហូរអោយបានត្រឹមត្រូវ<br>• ក្នុងករណីដែលក្រុមហ៊ុនធ្វើទំនប់ស្ទាក់ទឹក ឬស្តារប្រឡាយឡើងវិញ ក្រុមហ៊ុនត្រូវសហការណ៍ស្ថាប័នជំនាញជាមុនសិន<br>• ត្រូវសាងសង់សំណង់ផ្សេងៗនៅចម្ងាយយ៉ាងហោចណាស់ ១០០ម. ទៅ១៥០ម. ពីអូរ និងប្រព័ន្ធផ្លូវទឹកនានា |
| គ.គុណភាពទឹក(ទឹកក្រោដី និងលើដី) | – ការឈូសឆាយព្រៃឈើតាមមាត់អូរ<br>– ការគ្រប់គ្រងសំណល់រឹងមិនបានល្អ (សំណល់ផ្ទះបាយ សំណល់ថង់ប្លាស្ទិក សំបកដប សំបកកំប៉ុង និងលាមកមនុស្ស ឬ សត្វជាដើម)<br>– ការគ្រប់គ្រងសំណល់រាវមិនបានល្អ (សំណល់រាវចេញពីការប្រើប្រាស់ទូទៅរបស់បុគ្គលិក-កម្មករ និងបង្គន់អនាម័យ)<br>– ការលេចជ្រាបប្រេងពីម៉ាស៊ីន គ្រឿងចក្រ និងកន្លែងជួសជុលគ្រឿងចក្ររបស់ក្រុមហ៊ុន | √ | | | • រាល់ការឈូសឆាយទាំងអស់ គឺក្រុមហ៊ុន ត្រូវតែអនុវត្តតែក្នុងកំឡុងរដូវប្រាំង<br>• រក្សាទុកព្រៃតាមច្រាំងទន្លេដងអូរ និងតំបន់មាត់ទឹកនានា យ៉ាងហោចណាស់ចម្ងាយពី ១០០ម. ទៅ១៥០ម<br>• ត្រូវគ្រប់គ្រងសំណល់រឹង និងរាវ ឲបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស<br>• ណែនាំ និងអប់រំបុគ្គលិក-កម្មករ មិនឲ្យបោះចោលសំណល់រឹងពាសវាលពាសកាល<br>• ត្រូវរៀបចំឲមានការពិនិត្យដានគុណភាពទឹកក្នុងតំបន់គម្រោងជាប្រចាំ |

Draft

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| ឃ.គុណភាពខ្យល់ | – ការសាយភាយធូលី ផ្សែង និងឧស្ម័នផ្សេងៗពីសកម្មភាពឈូសឆាយ ឬការដឹកជញ្ជូនសម្ភារៈ និង ការប្រើប្រាស់គ្រឿងចក្រផ្សេងៗ<br>– ការដុតសំណល់រឹង និងសំណល់ កំទេចកំទីមែកឈើដាដើម | | | | • រាល់ការឈូសឆាយ សាងសាង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ត្រូវអនុវត្តតាមដំណាក់កាលដែលបានកំណត់ក្នុងផែនការមេ និងធ្វើការសាងសង់ភ្លាម<br>• ការសាងសង់សំណង់ផ្សេងៗ ត្រូវធ្វើឡើងនៅចម្ងាយយ៉ាងហោចណាស់១០០ម. ទៅ ១៥០ម. ពីអូរ<br>• ស្រោចទឹក និងបង្ហាប់ដីឲ្យអស់លទ្ធភាព នៅពេលឈូសឆាយស្ពាបនាផ្លូវនានា<br>• ថែទាំគ្រឿងចក្រ យាន្តជំនិះឲបានល្អ និងឲបានទៀងទាត់ដើម្បីកាត់បន្ថយបរិមាណឧស្ម័នដែលភាយចូលបរិយាកាស<br>• ប្រើប្រាស់គ្រឿងចាក់ដែលប្រើប្រាស់បច្ចេកទេសថ្មីៗ ឬដែលមិនមានអាយុកាលលើសកំនត់ប្រើប្រាស់ដើម្បីកាត់បន្ថយបរិមាណឧស្ម័នដែលភាយចេញ<br>• កំណត់ល្បឿនបើកបរក្នុងការដឹកជញ្ជូនសម្ភារៈសំណង់ និងបរិក្ខាផ្សេងៗចេញ-ចូលក្នុងតំបន់គម្រោង<br>• គ្រប់គ្រងសំនល់រឹងឲបានត្រឹមត្រូវតាមបច្ចេកទេស |
| ង.ការរំខានដោយសំលេង | – សំឡេងចេញពីរណាយន្តអារឈើមុនធ្វើការឈូសឆាយ គ្រឿងចក្រឈូសឆាយ ម៉ាស៊ីនភ្លើង និងម៉ាស៊ីនផ្សេងៗទៀតដែលដំណើរការក្នុងអំឡុងពេលឈូសឆាយ ឬសាងសង់<br>– សំឡេងចេញពីរថយន្តដឹកជញ្ជូនសម្ភារៈសំណង់ និងសម្ភារៈបរិក្ខាផ្សេងៗ | √ | | | • អនុវត្តការងារដឹងជញ្ជូន ឈូសឆាយ និងសាងសង់ តែពេលថ្ងៃ ដោយចៀសវាងអនុវត្តការងារនៅពេលយប់។<br>• ត្រូវប្រើប្រាស់គ្រឿងចក្រឈូសឆាយដែលមានលក្ខណៈសមស្របតាមស្តង់ដារ ដូចជាប្រើប្រាស់គ្រឿងចក្រ និងគ្រឿងម៉ាស៊ីនដែលមានបំពាក់ឧបករណ៍កាត់បន្ថយសំឡេង ដូចជាស៊ីម៉ាំង។<br>• ត្រូវមានផែនការប្រើប្រាស់គ្រឿងចក្រ និងគ្រឿងម៉ាស៊ីនឲ្យមានប្រសិទ្ធិភាព ដោយចៀសវាងនូវការបញ្ឆេះម៉ាស៊ីនទុកចោលនៅពេលដែលមិនចាំបាច់<br>• សាងសង់បន្ទប់សម្រាប់ដាក់ម៉ាស៊ីនភ្លើង ដោយបំពាក់នូវស៊ីម៉ាំងដែលមានសំឡេងតិច។<br>• កំណត់ល្បឿនបើកបរក្នុងការដឹកជញ្ជូនសម្ភារៈសំណង់ និងបរិក្ខាផ្សេងៗចេញ-ចូលក្នុងតំបន់គម្រោង ។ |

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| **១.២ ធនធានជីវសាស្ត្រ** | | | | | |
| ក.ព្រៃឈើ និងសារពើន្ធរុក្ខជាតិ | – សកម្មភាពឈូសឆាយ កាប់ឆ្ការព្រៃ<br>– ការរៀបចំថ្នាល<br>– សកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានាក្នុងតំបន់គម្រោង | | | √ | • ក្រុមហ៊ុនត្រូវធ្វើការឈូសឆាយព្រៃឈើតែទៅតាមផែនការមេ ដែលរាជរដ្ឋាភិបាលបានអនុម័តផ្តល់ឲ្យតែប៉ុនោះ។<br>• ក្រុមហ៊ុនត្រូវចូលរួមដាំ និងស្តារឡើងវិញ នូវប្រភេទព្រៃនៅក្បែរមាត់ទឹក និងនៅតាមដងអូរ(អោយបានយ៉ាងតិចចម្ងាយ ១០០ម ទៅ១៥០ម សងខាងអូរ)។<br>• ក្រុមហ៊ុនត្រូវចូលរួមឧបត្ថម្ភគាំទ្រដល់សកម្មភាពដាំ និងបណ្តុះកូនឈើនៅតាមសហគមន៍ព្រៃឈើ តំបន់ព្រៃរក្សាទុកដែលមាននៅក្នុងតំបន់(ឧ.សហគមន៍ព្រៃឈើកុកព្រៅ) និងជាពិសេសត្រូវចូលរួមឧបត្ថម្ភគាំទ្រដល់សកម្មភាពអភិរក្ស ស្តារ ដាំ និងបណ្តុះកូនឈើរបស់ផ្នែករដ្ឋបាលព្រៃឈើវីនសៃដែលនៅក្បែរទីតាំងគម្រោង។<br>• នៅត្រង់ទីតាំងដែលមានជម្រាលខ្ពស់ ឬរយៈកម្ពស់ខ្ពស់ខ្លាំងដែលតម្រូវអោយរក្សាទុក ក្រុមហ៊ុនត្រូវធ្វើការថែរក្សានូវធនធានដែលមានស្រាប់អោយបានល្អ និងធ្វើការដាំដើមឈើបន្ថែមប្រសិនបើចាំបាច់។ |
| ខ.ផល-អនុផលព្រៃឈើ | – ការឈូសឆាយ កាប់ឆ្ការព្រៃ រៀបចំថ្នាល និងការសាងសង់ហេដ្ឋារចនាសម្ព័ននានាដែលធ្វើអោយបាត់បង់គម្របព្រៃ | | | √ | • ធ្វើការឈូសឆាយព្រៃឈើតែទៅតាមផែនការមេ ដែលរាជរដ្ឋាភិបាលបានអនុម័តផ្តល់ឲ្យតែប៉ុនោះ។<br>• ក្រុមហ៊ុនត្រូវចូលរួមដាំ និងស្តារឡើងវិញ នូវប្រភេទព្រៃនៅក្បែរមាត់ទឹក និងនៅតាមដងអូរ(អោយបានយ៉ាងតិចចម្ងាយ ១០០ម ទៅ១៥០ម សងខាងអូរ)។<br>• ក្រុមហ៊ុនត្រូវចូលរួមឧបត្ថម្ភគាំទ្រដល់សកម្មភាពដាំ និងបណ្តុះកូនឈើនៅតាមសហគមន៍ព្រៃឈើ តំបន់ព្រៃរក្សាទុកដែលមាននៅក្នុងតំបន់(ឧ.សហគមន៍ព្រៃឈើកុកព្រៅ) និងជាពិសេសត្រូវចូលរួមឧបត្ថម្ភគាំទ្រដល់សកម្មភាពអភិរក្ស ស្តារ ដាំ និងបណ្តុះកូនឈើរបស់ផ្នែករដ្ឋបាលព្រៃឈើវីនសៃដែលនៅក្បែរទីតាំងគម្រោង។<br>• នៅត្រង់ទីតាំងដែលមានជម្រាលខ្ពស់ ឬរយៈកម្ពស់ខ្ពស់ខ្លាំងដែលតម្រូវអោយរក្សាទុក ក្រុមហ៊ុនត្រូវធ្វើការថែរក្សានូវធនធានដែលមានស្រាប់អោយបានល្អ និងធ្វើការដាំដើមឈើបន្ថែមប្រសិនបើចាំបាច់។ |

Draft

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| | | | | | • ក្រុមហ៊ុនត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពីបច្ចេកទេសកសិកម្មដល់ប្រជាពលរដ្ឋមូលដ្ឋាន នឹងជម្រុញលើកទឹកចិត្ត ព្រមទាំផ្តល់អាទិភាពអោយប្រជាពលរដ្ឋមូលដ្ឋានបានចូលបម្រើការងារគម្រោង។<br>• ក្រុមហ៊ុនត្រូវអនុវត្តតាមការស្នើសុំរបស់ប្រជាជនដូចមាននៅក្នុង ជំពូក៥.៣(ធនធានសេដ្ឋកិច្ច សង្គម) និងអនុសាសន៍របស់សាធារណៈជននៅជំពូក៦(ការចូលរួមពីសាធារណៈជន)។ |
| ឃ. ធនធានសត្វព្រៃ | – បាត់បង់ជម្រក និងប្រភពចំនីដោយសារការកាប់ឆ្ការព្រៃដើម្បីយកដីដាំដំណាំ។<br>– ការរំខានដែលបង្កដោយសម្លេងគ្រឿងចក្រ និងយានយន្ត។<br>– ការគំរាមកំហែង ដោយសារសកម្មភាពបរបាញ់ខុសច្បាប់ពីសំណាក់ប្រជាជន បុគ្គលិក-កម្មករក្នុង-ក្រៅតំបន់គម្រោង។ | | | √ | • ពន្លឿនការដាំដំណាំឡើងវិញនៅក្នុងតំបន់គម្រោងឱ្យបានឆាប់រហ័ស ដូចបានបង្ហាញក្នុងផែនការមេ ដើម្បីបង្កើតជាជម្រកថ្មីដល់ប្រភេទសត្វព្រៃទាំងអស់ដែលមានវត្តមាន និងបង្កើនជាទេសភាពធម្មជាតិទៅដល់ប្រភេទសត្វព្រៃទាំងនោះ។<br>• ត្រូវធ្វើការឈូសឆាយព្រៃឈើជាតំណាក់ៗតាមអនុតំបន់និមួយៗឆ្លាស់គ្នា ដើម្បីទុកផ្លូវនិងពេលវេលាឲ្យសត្វព្រៃធ្វើការភៀសខ្លួនទៅកាន់តំបន់ផ្សេងៗ ។<br>• កាត់បន្ថយឲ្យអស់លទ្ធភាពនូវការរំខានដោយសំឡេង-រំញ័រ ដែលកើតចេញពីសកម្មភាពគម្រោងតាមរយៈការប្រើប្រាស់គ្រឿងចក្រ ឬយានយន្តដែលបញ្ចេញសម្លេងតិច។<br>• អប់រំ និងហាមឃាត់ បុគ្គលិក-កម្មករ និងប្រជាជនក្នុងតំបន់ មិនឱ្យធ្វើការបរបាញ់ប្រភេទសត្វព្រៃដែលមាននៅក្នុងតំបន់ដោយខុសច្បាប់។<br>• អប់រំ និងផ្សព្វផ្សាយពីអត្ថផលប្រយោជន៍សត្វព្រៃ និងដាក់បំរាមមិនឲ្យបរិភោគសាច់សត្វព្រៃ។<br>• ដាក់ពិន័យ ចំពោះបុគ្គលិក-កម្មករ ដែលបរបាញ់សត្វព្រៃខុសច្បាប់ និងរាយការជូនស្ថាប័នមានសមត្ថកិច្ច ក្នុងករណីសង្កេតឃើញមានការលួចបរបាញ់ខុសច្បាប់<br>• មិនត្រូវទិញសាច់ ឬសត្វព្រៃពីអ្នកលក់ ឬពីប្រជាពលរដ្ឋមូលដ្ឋាន។<br>• ត្រូវធ្វើការផាកពិន័យឲ្យបានតឹងរឹង (ឧ.ព្រមាន ឬបញ្ឈប់ពីការងារ) ក្នុងករណីបុគ្គលិក-កម្មករណាមួយប្រព្រឹត្តិបទល្មើស និងបទបញ្ញាខាងលើ។<br>• ទាំងម្ចាស់ក្រុមហ៊ុន ទាំងបុគ្គលិក-កម្មករ ត្រូវចូលរួមអភិរក្សសត្វព្រៃទាំងអស់គ្នា ក្នុង |

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| | | | | | ករណីប្រព្រឹត្តិបទល្មើសសត្វព្រៃខុសច្បាប់ និងត្រូវអនុវត្តទៅតាមច្បាប់ព្រៃឈើដែលមានចែងនៅក្នុង ជំពូកទី១៥ មានត្រា៩៨ ចំណុចទី១១ និង១២។ |
| ង.វត្តមាន និងប្រភេទមច្ឆជាតិ | – ការធ្លាក់ចុះនៃគុណភាពទឹកក្នុងអូរ ដោយសារតែការហូរច្រោះដីល្បាប់ចូលទៅក្នុងអូរ និងការបំពុលទឹកដែលកើតឡើងដោយសារការគ្រប់គ្រងកាកសំណល់រឹង រាវមិនបានត្រឹមត្រូវតាមបច្ចេកទេស។<br>– ការស្ថាបនាឡើងវិញនូវប្រព័ន្ធផ្លូវទឹក និងការសាងសង់ស្រះឬអាងស្តុកទឹកដែលនឹងធ្វើអោយមានការប្រែប្រួលចរន្តទឹក។<br>– ការនេសាទខុសច្បាប់ពីសំនាក់ជនខិលខូចមួយចំនួន។ | | √ | | • មុនពេលក្រុមហ៊ុនចាប់ផ្តើមការឈូសឆាយ ឬស្ថាបនាប្រព័ន្ធផ្លូវទឹកនៅកន្លែងណាមួយ(ទន្លេ អូរ ត្រពាំង) ត្រូវធ្វើការទំនាក់ទំនងជាមួយស្ថាប័នមានសមត្ថកិច្ច(ផ្នែករដ្ឋបាលជលផលរ៉ូនសែ) ដើម្បីធ្វើការចង្អុលបង្ហាញអំពីកន្លែង ឬតំបន់ដែលមានវត្តមានមច្ឆជាតិសំខាន់ៗរស់នៅ។<br>• ធ្វើការលែងកូនមច្ឆជាតិនៅតាមប្រព័ន្ធផ្លូវទឹក ដែលមាននៅក្នុងនិងក្បែរទីតាំងតំបន់គម្រោងក្នុងរយៈពេល១ឆ្នាំម្តង។<br>• ដាក់ពិន័យ ចំពោះបុគ្គលិក-កម្មករ ដែលបានលួចនេសាទត្រីខុសច្បាប់ និងរាយការជូនស្ថាប័នមានសមត្ថកិច្ច ក្នុងករណីសង្កេតឃើញមានសកម្មភាពលួចធ្វើការនេសាទត្រីខុសច្បាប់។<br>• ទាំងម្ចាស់ក្រុមហ៊ុន ទាំងបុគ្គលិក-កម្មករ ត្រូវចូលរួមអភិរក្សមច្ឆជាតិទាំងអស់គ្នា ក្នុងករណីប្រព្រឹត្តិបទល្មើសខុសច្បាប់ និងត្រូវអនុវត្តទៅតាម ច្បាប់ជលផល ដូចដែលមានចែងនៅក្នុង ជំពូកទី១៥ មានត្រា៩៩។ |
| **១.៣. ធនធានសេដ្ឋកិច្ចសង្គម** | | | | | |
| ក. កម្មសិទ្ធិដីធ្លី និងការប្រើប្រាស់ដី | - វត្តមានគម្រោងក្នុងតំបន់ និងដំណើរការកំណត់ព្រំប្រទល់ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន បានប៉ះពាល់ដល់ព្រៃសហគមន៍ ព្រៃបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ ព្រៃអារក្ស ផ្នូរដូនតា ប្រភពទឹកធម្មជាតិ ដីស្រែ-ចម្ការ ជាពិសេសចម្ការវិលជុំរបស់គ្រួសារជនជាតិដើមភាគតិចនិងគ្រួសារខ្មែរមួយចំនួន។ | | | √ | • ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធ ដើម្បីរៀបចំ និងផ្សព្វផ្សាយអំពីគោលការណ៍ក្នុងការដោះស្រាយទំនាស់ដល់ប្រជាពលរដ្ឋ<br>• ក្រុមហ៊ុននឹងធ្វើការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ និងប្រជាពលរដ្ឋដែលមានដីធ្លីជាប់ព្រំទីតាំងគម្រោង ដើម្បីផ្តល់ជាព័ត៌មានលម្អិតស្តីពីព្រំប្រទល់គម្រោង<br>• ក្រុមហ៊ុននឹងធ្វើការបង្ហាញដល់ប្រជាជន នូវដំណើរការវិនិយោគដីសម្បទានសេដ្ឋកិច្ចតាំងពីដំណាក់កាលស្នើសុំរាជរដ្ឋាភិបាល រហូតដល់ដំណាក់កាលវិនិយោគ និងបញ្ចប់គម្រោង ព្រមទាំងលើកឡើងនូវរាល់វិធានការកាត់បន្ថយ ដើម្បីបញ្ចៀសនូវហេតុប៉ះពាល់អវិជ្ជមាននានា (រួមទាំងការកាត់ចេញនូវផ្ទៃដីពាក់ព័ន្ធនានាដែលបានធ្វើឡើងកន្លងមក) |

Draft

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់: តិច | ទំហំនៃការប៉ះពាល់: មធ្យម | ទំហំនៃការប៉ះពាល់: ខ្លាំង | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | | | | ។<br>• ក្រុមហ៊ុននឹងមិនឈូសឆាយហួសពីព្រំដីដែលទទួលបានពីរដ្ឋាភិបាល<br>• ក្រុមហ៊ុននឹងគាំទ្រអាជ្ញាធរមូលដ្ឋានក្នុងការរៀបចំផែនការប្រើប្រាស់ដីក្នុងតំបន់ឲ្យបានសមរម្យ។ |
| ខ. មុខរបរ និងប្រាក់ចំណូល | - ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគម្រោងលើផ្ទៃដីប្រមាណ ៣៨៣ ហិកតា (៥,៩% នៃផ្ទៃដីវិនិយោគសរុប) ដែលជាដីព្រៃនឹងមិនអាចធ្វើឱ្យប៉ះពាល់ដល់សកម្មភាពប្រកបរបរចិញ្ចឹមជីវិត (រកផល-អនុផលព្រៃឈើ) របស់ប្រជាជនមូលដ្ឋាននោះទេ។ | √ | | | • មិនចាំបាច់ |
| គ. ការប្រើប្រាស់ទឹក សុខភាព និងអនាម័យក្នុងការរស់នៅរបស់ប្រជាជនមូលដ្ឋាន | - ប្រភពទឹកអូរ ស្ទឹង ព្រែក ប្រឡាយទទួលរងការបំពុលពីសំរាម និងរូមផ្សំនឹងសារជាតុគីមីពីដំណាំកសិ-ឧស្សាហកម្មរបស់ក្រុមហ៊ុនផ្សេងៗដែលមាននៅក្នុងតំបន់ (មិនមែនក្រុមហ៊ុន SK)។ ពេលគម្រោងSKចាប់ផ្តើមដំណើរការសាងសង់ អាចនឹងមានការបំពុលប្រភពទឹកទាំងនេះបន្ថែមទៀត។<br>- ការឈូសឆាយលុបប្រភពទឹកអូរ អាចនឹងកើតមាន<br>- សកម្មភាពឈូសឆាយដី អាចនឹងធ្វើឲ្យមានការហូរច្រោះដី កករល្បាប់<br>- ការបោះចោលសំណល់រឹង និងបង្ហូរសំណល់រាវចូលទៅក្នុងប្រភពទឹក ក៏អាចនឹងធ្វើឲ្យមានការបំពុលប្រភពទឹកប្រើប្រាស់របស់មនុស្ស និងសត្វ។ល។ ប្រសិនបើមិនបានអនុវត្តតាមវិធានការត្រឹមត្រូវ។ | | √ | | • មិនឈូសឆាយលុបប្រភពទឹកដែលធ្វើឲ្យប៉ះពាល់ដល់បរិមាណជាទឹក និងការប្រើប្រាស់ទឹករបស់ប្រជាជននៅខ្សែទឹកខាងក្រោម<br>• ជីកស្រះស្តុកទឹកភ្លៀងសម្រាប់ប្រើប្រាស់ ដើម្បីកាត់បន្ថយសម្ពាធលើការប្រើប្រាស់ទឹកពីប្រព័ន្ធផ្លូវទឹកធម្មជាតិ និងទឹកក្រោម<br>• រៀបចំ និងអនុវត្តឱ្យបានត្រឹមត្រូវតាម ផែនការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេង ដើម្បីការពារការបំពុលប្រភពទឹក។ |

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| ឃ. ប្រពៃណីទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច | - ការកំណត់ព្រំដីរបស់គម្រោងនៅមានប៉ះពាល់សម្បត្តិវប្បធម៌របស់ជនជាតិដើមភាគតិចក្នុងភូមិពាក់ព័ន្ធមួយចំនួនតូច។<br>- ផ្ទៃដីដែលគ្រោងសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធដូចកំណត់ក្នុងផែនការមេគម្រោង មិនប៉ះពាល់នឹងផ្ទៃដីពាក់ព័ន្ធទាំងនេះទេ។ ទោះជាយ៉ាងនេះក្តី ទំនៀមទម្លាប់ប្រពៃណីរបស់ជនជាតិដើមភាគតិច ជាពិសេសសហគមន៍ដែលនៅជាប់នឹងទីតាំងគម្រោង អាចនឹងទទួលរងនូវឥទ្ធិពលពីវប្បធម៌ថ្មី ដែលនាំចូលមកជាមួយនឹងបុគ្គលិក-កម្មករដែលជាជនចំណូលថ្មី។ | | √ | | • ផ្សព្វផ្សាយអំពីទំនៀមទម្លាប់ ប្រពៃណី (ជាពិសេសតំណមនានា) របស់ជនជាតិដើមភាគតិច ដល់ បុគ្គលិក-កម្មករ និងដាក់បំរាមមិនឱ្យបុគ្គលិក-កម្មករធ្វើសកម្មភាពអ្វីដែលអាចប៉ះពាល់ដល់ទំនៀមទម្លាប់ ប្រពៃណីទាំងនោះ។<br>• សហការជាមួយអាជ្ញាធរ និងសហគមន៍មូលដ្ឋាន ដើម្បីរៀបចំពិធីបុណ្យតាមបែបប្រពៃណីរបស់ជនជាតិដើមភាគតិច។ |
| ង. សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋាន | - ការបើកលឿនពេក ការធ្វេសប្រហែសរបស់អ្នកបើកបរយានយន្តរបស់ក្រុមហ៊ុន និងភាពមានកម្រិតនៃចំណេះដឹងអំពីច្បាប់ចរាចរណ៍របស់ប្រជាជនមូលដ្ឋានអាចបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ទៅដល់ប្រជាជនមូលដ្ឋាន<br>- បុគ្គលិក-កម្មករគម្រោងដែលជាជនចំណូលថ្មីអាចរស់នៅមិនចុះសម្រុងនឹងប្រជាជនមូលដ្ឋានដែលជាជនជាតិដើមភាគតិច ដែលអាចនឹងឈានទៅបង្កជាជម្លោះ និងអំពើហឹង្សានានា<br>- បុគ្គលិក-កម្មករគម្រោងដែលជាជនចំណូលថ្មី អាចនាំមកនូវវប្បធម៌មិនល្អ ដូចជាការសេពគ្រឿងញៀន ការលេងល្បែងស៊ីសង ចោរកម្ម ជម្ងឺឆ្លង ពេស្យាចារ និងករណីរំលោភសេពសន្ថវៈ (ពីបុគ្គលិក-កម្មករលើប្រជាជន និង/ឬពីប្រជាជនលើបុគ្គលិក-កម្មករ)។ | | √ | | • ធ្វើការផ្សព្វផ្សាយជាដំណឹងឲ្យបានមុនទៅកាន់អាជ្ញាធរមូលដ្ឋាន អំពីការចល័តគ្រឿងចក្រ ឬគ្រឿងម៉ាស៊ីនដែលត្រូវប្រើក្នុងពេលដំណើរការគម្រោង<br>• ណែនាំឱ្យអ្នកបើកបរគោរពច្បាប់ចរាចរណ៍ និងពិន័យធ្ងន់ធ្ងរ ប្រសិនបើមិនគោរពច្បាប់ ហើយការមិនគោរពច្បាប់ធ្វើឱ្យមានគ្រោះថ្នាក់ចរាចរណ៍<br>• ធ្វើការផ្សព្វផ្សាយជាចំណេះដឹងបន្ថែមដល់ប្រជាជនមូលដ្ឋាន ទាក់ទងនឹងសុវត្ថិភាពចរាចរណ៍<br>• ជ្រើសរើសបុគ្គលិក-កម្មករក្នុងមូលដ្ឋាន ឲ្យអស់លទ្ធភាពមុននឹងសម្រេចជ្រើសរើសអ្នកតំបន់ផ្សេង<br>• បញ្ចូលក្នុងបទបញ្ជាផ្ទៃក្នុងនូវបំរាមពាក់ព័ន្ធនឹងគ្រឿងញៀន អំពើហឹង្សាជាមួយប្រជាជនមូលដ្ឋាន និង ករណីចោរកម្ម ពេស្យាចារ រំលោភសេពសន្ថវៈ<br>• សហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការត្រួតពិនិត្យ និងតាមដានបុគ្គលិក-កម្មករ ដែលជាជនចំណូលថ្មី ដើម្បីធានាថាពួកគេមិនពាក់ព័ន្ធនឹងគ្រឿងញៀន បង្កហឹង្សាជាមួយប្រជាជនមូលដ្ឋាន និងបង្កឲ្យមានករណីចោរកម្ម ពេស្យាចារ សេពសន្ថវៈ |

Draft

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| | | | | | • មានផែនការត្រួតពិនិត្យសុខភាពបុគ្គលិក-កម្មករជាប្រចាំ និងបណ្តុះបណ្តាលពួកគាត់អំពីបញ្ហានៃជម្ងឺឆ្លង ការបង្ការជម្ងឺឆ្លងនានា និងផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន។ល។<br>• គាំទ្រដល់បេសកកម្មរបស់ប្រជាការពារឃុំ ដើម្បីពង្រឹងសុវត្ថិភាព និងសន្តិសុខមូលដ្ឋាន។ |
| ច. សុខភាព សុវត្ថិភាព និងសុខមាលភាពបុគ្គលិក និងកម្មករគម្រោង | - ការរស់នៅច្រើនគ្នាក្នុងលំនៅដ្ឋានតូចចង្អៀត ឬរស់នៅក្នុងជំរុំប្រក់តង់កៅស៊ូ ដូចធ្លាប់មានក្នុងគម្រោងផ្សេងៗទៀតពីមុនមកនឹងបង្កនូវផលប៉ះពាល់ដល់សុខភាពដោយអាចងាយឆ្លងមេរោគនានា<br>- ដោយសារតំបន់គម្រោងស្ថិតនៅក្នុងតំបន់ព្រៃ និងមានប្រជាជនមូលដ្ឋានភាគច្រើនធ្លាប់កើតជម្ងឺគ្រុនចាញ់កន្លងមក បុគ្គលិកនិងកម្មករគម្រោង ក៏នឹងប្រឈមមុខខ្លាំងនឹងជំងឺគ្រុនចាញ់នេះផងដែរ<br>- ការបញ្ជាគ្រឿងចក្រក្នុងការឈូសឆាយ រៀបចំដី និងសាងសង់ ដោយគ្មានបច្ចេកទេស អាចនឹងបង្កគ្រោះថ្នាក់ដល់អ្នករួមការងារ និងខ្លួនឯង | | | √ | • ផ្តល់លំនៅដ្ឋានសម្រាប់ស្នាក់នៅ ក្នុងកម្រិតស្តង់ដារកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ស្របតាមច្បាប់ស្តីពីការងារ (មាត្រា ២០៤ ដល់ ២០៦ និង មាត្រានានាក្នុងជំពូក៧ និងជំពូក៨)។<br>• ផ្តល់នូវការបណ្តុះបណ្តាលអំពីការទប់ស្កាត់ការកើតជម្ងឺគ្រុនចាញ់ និងផ្តល់មុងជ្រលក់ថ្នាំដល់បុគ្គលិក-កម្មករ។<br>• ផ្តល់ការបណ្តុះបណ្តាលអំពីបច្ចេកទេសបញ្ជាគ្រឿងចក្រ និងវិធានសុវត្ថិភាពក្នុងការការពារគ្រោះថ្នាក់ក្នុងពេលបំពេញការងារ<br>• អនុវត្តកម្មវិធីត្រួតពិនិត្យ និងថែទាំសុខភាព ជាពិសេសពាក់ព័ន្ធនឹងជម្ងឺគ្រុនចាញ់<br>• ផ្តល់នូវបរិក្ខាសង្គ្រោះបឋម និងណែនាំអំពីវិធីសាស្រ្តសង្គ្រោះបឋម ដល់បុគ្គលិក-កម្មករ មុនពេលចាប់ផ្តើមបំពេញការងារ។<br>• ផ្តល់ការធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់ការងារដល់គ្រប់បុគ្គលិក-កម្មករ ក្រោមរូបភាពបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)។ |
| ២.ដំណាក់កាលប្រតិបត្តិគម្រោង | | | | | |
| ២.១. ធនធានបរិស្ថានរូបសាស្ត្រ | | | | | |
| ក. សណ្ឋានដី និងការហូរ | – សកម្មភាពឈូសឆាយពង្រាបដីឲ្យរាបស្មើនៅតាមតំបន់ទួល និងជំបូកខ្ពស់ៗ ដើម្បីដាំដុះដំណាំកៅស៊ូ និង | | | | • រាល់ការឈូសឆាយទាំងអស់ ត្រូវអនុវត្តតែកំឡុងរដូវប្រាំងតែប៉ុណ្ណោះ<br>• ការឈូសឆាយដីត្រូវធ្វើឡើងតាមលក្ខណៈសណ្ឋានដី និងតាមលក្ខណៈបច្ចេកទេស |

Draft

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| ច្រោះដី | ដំណាំកសិ-ឧស្សាហកម្មផ្សេងៗទៀត។<br>– ការឈូសឆាយព្រៃដោយរក្សាទុកដីឲ្យនៅទំនេរ នឹងបង្កើតឲ្យមានការហូរច្រោះដីនៅរដូវវស្សា ហើយជាលទ្ធផលអាចធ្វើឲ្យសណ្ឋានដីមានការប្រែប្រួល | √ | | | • តំបន់ភ្នំ ឬតំបន់ដែលមានរយៈកម្ពស់ខ្ពស់ដែលស្ថាប័នជំនាញតម្រូវឲ្យរក្សាទុក គឺក្រុមហ៊ុនត្រូវតែរក្សាទុក<br>• ជៀសវាងការដឹកជញ្ជូនលើសទម្ងន់ ដែលនាំអោយមានការបាក់ខូចផ្លូវ និងការហូរដីចេញពីផ្លូវជាពិសេសនៅរដូវវស្សា<br>• ក្រុមហ៊ុនត្រូវរក្សាគម្របព្រៃពី ១០០ម ទៅ១៥០ម ពីប្រភពទឹកដើម្បីការពារទីជម្រាល និងទប់ស្កាត់ការហូរច្រោះដី និងបាក់ច្រាំង<br>• ត្រូវរៀបចំទីតាំងចម្ការដំណាំដោយសាងសង់ប្រព័ន្ធបង្ហូរទឹកឲបានត្រឹមត្រូវ និងអនុវត្តន៍ការភ្ជួររាស់ឲត្រឹមត្រូវតាមបច្ចេកទេស។<br>• ត្រូវប្រើប្រាស់ឲអស់ពីលទ្ធភាពនូវកំទេចកំទីមែក ឬស្លឹករុក្ខជាតិដែលបានកាប់ឆ្ការ ដូចជាការយកទៅធ្វើជាជីកំប៉ុស និងគ្របលើដីដែលមិនទាន់ដាំដំណាំដើម្បីកាត់បន្ថយការហូរច្រោះ និងហួតដែលធ្វើឲដីឡើងរឹង<br>• ការកាប់ឆ្ការព្រៃ ការឈូសឆាយដី នឹងការរៀបចំថ្នាលដំណាំត្រូវធ្វើឡើងជាដំណាក់កាលនៅត្រង់តំបន់ដែលមានជម្រាលខ្លាំង ត្រូវចាប់ផ្តើមធ្វើពីតំបន់ដែលមានរយៈកំពស់ខ្ពស់មុន ដើម្បីជៀសវាងការបាក់ដី។<br>• ត្រូវរៀបចំដាំដំណាំភ្លាមៗក្រោយពីឈូសឆាយរួច ដើម្បីកាត់បន្ថយកម្រិត និង រយៈពេលនៃការហូរច្រោះ។<br>• ត្រូវដាំដុះបន្ថែមនូវប្រភេទដំណាំបន្ទាប់បន្សំ ដូចជាពោត សណ្តែក ឬពពួកបន្លែបង្ការនានា នៅតាមចន្លោះរង ឬនៅក្នុងចន្លោះពេលសំអាតថ្នាលបន្ទាប់ពីពេលប្រមូលផលដំណាំចំបងរួច ធ្វើជាគម្របដីដើម្បីកាត់បន្ថយការហូរច្រោះ និងជួយរក្សារលំនឹងគុណភាពដី។<br>• កំនត់ទំហំសមស្របនៃផ្លូវឆ្លងកាត់នានាក្នុងតំបន់គម្រោង (optimum road size) ដើម្បីធានាប្រសិទ្ធភាព និងសុវត្ថិភាពការងារ ជៀសវាងការអូសប្រឡាយសកម្មភាពនានាដែលអាចនឹងបង្ករអោយមានការហូរច្រោះកើតឡើង។ |

Draft

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| ខ.គុណភាពដី | – ការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេងមិនបានល្អ<br>– ការប្រើប្រាស់មិនបានត្រឹមត្រូវតាមបច្ចេកទេស និងលើសពីតម្រូវការ នូវជីគីមី ថ្នាំសំលាប់សត្វល្អិត ឬស្មៅ<br>– ការទុកដីទំនេរចោល ក្រោយពីការឈូសឆាយដីព្រៃរួច | √ | | | • រាល់រាល់ការឈូសឆាយទាំងអស់ គឺក្រុមហ៊ុន នឹងអនុវត្តតែកំឡុងរដូវប្រាំងតែប៉ុណ្ណោះ<br>• ធ្វើការដាំដុះភ្លាមៗបន្ទាប់ពីរៀបចំដីរួចដោយមិនទុកដីឲ្យនៅទំនេរចោល ដែលនាំឲ្យមានការហូរច្រោះនោះទេ<br>• ចំពោះការគ្រប់គ្រងសំណល់រឹង ត្រូវអនុវត្តទៅតាមផែនការគ្រប់គ្រងសំណល់រឹងឲបានត្រឹមត្រូវ ដោយការជីករណ្ដៅកប់ ឬដុតចោលជាដើម។<br>• ធ្វើការណែនាំ និងអប់រំដល់បុគ្គលិក-កម្មករ មិនឲ្យមានការបោះចោលសំណល់រឹងពាសវាលពាសកាល និងមិនឲបោះចោលទៅក្នុងប្រភពទឹក។<br>• ចំពោះការគ្រប់គ្រងសំណល់រាវ ដូចជាសំណល់រាវចេញពីផ្ទះបាយ បង្គន់អនាម័យនិងបន្ទប់ទឹក គ្រឿងចក្រនិងគ្រឿងម៉ាស៊ីន ក្រុមហ៊ុនត្រូវរៀបចំផែនការគ្រប់គ្រងអោយបានសមស្រប តាមការនែនាំរបស់អ្នកជំនាញ។<br>• ជៀសវាងការប្រើប្រាស់មិនបានត្រឹមត្រូវតាមបច្ចេកទេសនូវជីគីមីកសិកម្ម ថ្នាំពុលសំលាប់សត្វល្អិត ឬស្មៅ<br>• មិនត្រូវឈូសឆាយដីតាមដងអូរ និងក្បែរប្រភពទឹក ដោយរក្សាតម្របព្រៃដែលមាក្នុងចម្ងាយពី ១០០ម ទៅ ១៥០ម។<br>• ត្រូវរៀបចំអោយមានប្រព័ន្ធសម្អាតទឹកកខ្វក់ ដើម្បីសម្អាតទឹកកខ្វក់ដែលចេញពីសកម្មភាពនានានៃគម្រោង ជាពិសេសកាកសំនល់ចេញពីរោងចក្រកែច្នៃផលិតផល ឲបានត្រឹមត្រូវតាមស្តង់ដាមុនបង្ហូរចូលទៅក្នុងបរិស្ថាន។<br>• ត្រូវរៀបចំផែនការ គ្រប់គ្រងការប្រើប្រាស់ ការគ្រប់គ្រងកាកសំណល់ប្រេង និងរៀបចំកន្លែងទុកដាក់ប្រេងឥន្ធនៈអោយបានត្រឹមត្រូវដើម្បីជៀសវាងការហៀរហូរទៅលើដី ឬចូលទៅក្នុងប្រភពទឹក។<br>• ត្រូវជម្រុញឲមានការប្រើប្រាស់ជីធម្មជាតិឲបានច្រើនបំផុតតាមដែលអាចធ្វើបាន<br>• ត្រូវប្រើប្រាស់តែជីគីមី ឬថ្នាំសម្លាប់កត្តាចង្រៃទាំងឡាយណាដែលបានទទួលការអនុញ្ញាតិពីក្រសួងកសិកម្មតែប៉ុនោះ។ |



Draft

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| | | | | | • រៀបចំផែនការប្រើប្រាស់ដីឲបានច្បាស់លាស់ និងអនុវត្តតាមផែនការឲបានខ្ជាប់ខ្ជួន ដើម្បីជៀសវាងការប្រើប្រាស់លើសកម្រិតដែលបណ្តាលឲមានការហូរជ្រាបចូលទៅក្នុងដី ធ្វើឲខូចគុណភាពដី និងទឹកនៅក្នុងតំបន់។<br>• កាត់បន្ថយការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ដោយការរៀបចំផែនការត្រៀមដើម្បីទប់ស្កាត់កំណើនលើសលប់នៃចំនួនសត្វល្អិត (avoid the outbreak occurs)។<br>• ត្រូវដាំដុះបន្ថែមនូវប្រភេទដំណាំបន្ទាប់បន្សំ ដូចជាពោត សណ្តែក ឬពពួកបន្លែបង្ការនានា (នៅតាមចន្លោះរង ឬនៅក្នុងចន្លោះពេលសំអាតថ្នាលបន្ទាប់ពីពេលប្រមូលផលដំណាំចំបងរួច) ធ្វើជាគម្របដីដើម្បីកាត់បន្ថយការហូរច្រោះ និងជួយរក្សាលំនឹងគុណភាពដី។ |
| គ.ប្រព័ន្ធជលសាស្ត្រ | – ការឈូសឆាយដីព្រៃដើម្បីដាំដំណាំកៅស៊ូ និងដំណាំផ្សេងៗទៀត ដែលអាចនឹងលុបប្រព័ន្ធអូរ និងដៃអូរមួយចំនួន។<br>– ការឈូសឆាយដីព្រៃនៅតាមមាត់អូរ ក៏នឹងធ្វើឲ្យប្រព័ន្ធអូរទាំងនោះ កកស្ទះមិនមានទឹកហូរ ដោយសារការហូរច្រោះកករដី មែកឈើ ឬស្លឹកឈើហូរចូល។<br>– ការសង់ទំនប់ស្ទាក់ ឬទប់ទឹក ឬស្តារឡើងវិញនូវប្រព័ន្ធផ្លូវទឹកមួយចំនួន ដែលជាកត្តាធ្វើឲមានបម្រែបម្រួលទ្រង់ទ្រាយអូរ និងចរន្តទឹក។ | √ | | | • រក្សាទុកព្រៃតាមទ្រនាប់ដងអូរដែលមានក្នុងតំបន់គម្រោងចម្ងាយពី ១០០ម. ទៅ១៥០ម.សងខាងអូរទៅតាមស្ថានភាពអូរ។<br>• ដើម្បីការពារមិនឲ្យប៉ះពាល់ខ្លាំងដល់ចរន្តទឹក និងបរិមាណទឹក ក្នុងករណីដែលក្រុមហ៊ុនធ្វើទំនប់ស្ទាក់ទឹក ឬស្តារឡើងវិញនូវប្រព័ន្ធផ្លូវទឹកណាមួយ ក្រុមហ៊ុនត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញ ជាពិសេសគឺមន្ទីរធនធានទឹក និងឧតុនិយមខេត្ត ដើម្បីធ្វើការវាយតម្លៃ និងផ្តល់អនុសាសន៍បច្ចេកទេស។ (សម្គាល់៖ ប្រភពទឹកដែលបុគ្គលិក-កម្មករប្រើប្រាស់ គឺទឹកអណ្តូងស្នប់ និងទឹកស្រះដែលក្រុមហ៊ុនបានជីក។)<br>• ត្រូវសិក្សាពីស្ថានភាពសមតុល្យទឹកក្រោមដីអោយបានច្បាស់លាស់ មុននឹងធ្វើការខួង ឬបូមយកទឹកពីប្រភពទឹកក្រោមដី។<br>• មិនត្រូវបូមទឹកក្រោមដី អោយហួសពីកម្រិតនៃការបំពេញឡើងវិញ (Recharge rate) ឡើយ ដើម្បីជៀសវាងការស្រុតចុះនៃកំពស់ដី (land subsidence) ការប្រែប្រួលនៃខ្សែទឹក (ទាំងលើដី និងក្រោមដី)។ |
| ឃ.គុណភាពទឹក | – ការឈូសឆាយព្រៃឈើតាមមាត់អូរដោយចេតនា ឬអចេតនា | | √ | | • រាល់ការឈូសឆាយទាំងអស់ គឺក្រុមហ៊ុន នឹងអនុវត្តតែកំឡុងរដូវប្រាំងតែប៉ុណ្ណោះ ហើយនឹងធ្វើការដាំដុះភ្លាមៗដោយមិនទុកដីឲ្យនៅទំនេរចោល ដែលនាំឲ្យមានការហូរច្រោះ |



Draft

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| | – ការគ្រប់គ្រងសំណល់រឹង រាវ មិនបាន<br>– ការគ្រប់គ្រងសំណល់ប្រេងមិនបានល្អ តាមរយៈការលេចជ្រាបពីម៉ាស៊ីន គ្រឿងចក្រ និងកន្លែងជួសជុលគ្រឿងចក្ររបស់ក្រុមហ៊ុន។<br>– ការហូរជ្រាបនៃជីគីមី និងកាកសំនល់ថ្នាំសម្លាប់សត្វល្អិតនានាដោយសារការប្រើប្រាស់ខុសបច្ចេកទេស ការប្រាស់លើសតម្រូវការ និងការចោលកាកសំនល់សំបកកំប៉ុងថ្នាំពាសវាលពាសកាល | | | | នោះទេ។<br>• គ្រប់គ្រងកាកសំនល់រឹង រាវឲបានត្រឹមត្រូវតាមបច្ចេកទេស<br>• ក្រុមហ៊ុនត្រូវរៀបចំទីលានចោលសម្រាមអោយបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងនៅឆ្ងាយពីប្រភពទឹកដើម្បីជៀសវាងការហូរ Leakage ពីគំនរសម្រាមចូលទៅក្នុងប្រភពទឹក។<br>• ធ្វើការណែនាំ និងអប់រំដល់បុគ្គលិក-កម្មករ មិនឲ្យមានការបោះចោលសំណល់រឹងពាសវាលពាសកាល និងមិនឲបោះចោលទៅក្នុងប្រភពទឹក។<br>• ចំពោះការគ្រប់គ្រងសំណល់រាវ ដូចជាសំណល់រាវចេញពីផ្ទះបាយ បង្គន់អនាម័យនិងបន្ទប់ទឹក គ្រឿងចក្រនិងគ្រឿងម៉ាស៊ីន គឺក្រុមហ៊ុនព្យាយាមអនុវត្តទៅតាមផែនការគ្រប់គ្រងសំណល់រាវរបស់ខ្លួន។<br>• ជៀសវាងការប្រើប្រាស់មិនបានត្រឹមត្រូវតាមបច្ចេកទេសនូវជីគីមីកសិកម្ម ថ្នាំពុលសំលាប់សត្វល្អិត ឬស្មៅក្នុងការជួយជម្រុញដល់ការលូតលាស់របស់ដំណាំកៅស៊ូ និងដំណាំផ្សេងៗទៀត ដោយសហការណ៍ជាមួយក្រសួងកសិកម្ម និងស្ថាប័នដែលពាក់ព័ន្ធ។<br>• មិនត្រូវឈូសឆាយដីតាមដងអូរ និងក្បែរប្រភពទឹក។<br>• ត្រូវរៀបចំអោយមានប្រព័ន្ធសម្អាតទឹកកខ្វក់ ដើម្បីសម្អាតទឹកកខ្វក់ដែលចេញពីសកម្មភាពនានានៃគម្រោងឲបានត្រឹមត្រូវតាមស្តង់ដារមុនបង្ហូរចូលទៅក្នុងបរិស្ថាន។<br>• ត្រូវរៀបចំផែនការ គ្រប់គ្រងការប្រើប្រាស់ ការគ្រប់គ្រងកាកសំណល់ប្រេង និងរៀបចំកន្លែងទុកដាក់ប្រេងឥន្ទនៈអោយបានត្រឹមត្រូវដើម្បីជៀសវាងការហៀរហូរទៅលើដី ឬចូលទៅក្នុងប្រភពទឹក។<br>• ត្រូវជម្រុញឲមានការប្រើប្រាស់ជីធម្មជាតិឲបានច្រើនបំផុតតាមដែលអាចធ្វើបាន។<br>• ត្រូវប្រើប្រាស់តែជីគីមី ឬថ្នាំសម្លាប់កត្តាចង្រៃទាំងឡាយណាដែលបានទទួលការអនុញ្ញាត្តិពីក្រសួងកសិកម្មតែប៉ុនោះ។<br>• ត្រូវធ្វើការពិនិត្យតាមដានគុណភាពទឹកក្នុងតំបន់គម្រោងជាប្រចាំ តាមរយៈការយក |

Draft

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| | | | | | សំណាកទឹកទៅពិនិត្យនៅមន្ទីរពិសោធន៍នៃក្រសួងបរិស្ថាន តាមពេលវេលាជាក់ស្តែងដែលបានកំណត់ក្នុងផែនការគ្រប់គ្រងបរិស្ថាន នៅជំពូក៨។ |
| ង.គុណភាពខ្យល់ | – ការសាយភាយធូលី ផ្សែង និងឧស្ម័នផ្សេងៗចូលទៅក្នុងបរិយាកាស តាមរយៈសកម្មភាពឈូសឆាយ ឬការដឹកជញ្ជូនកសិផល និងសត្វព្រៃ ដោយប្រើប្រាស់គ្រឿងចក្រ គ្រឿងម៉ាស៊ីនផ្សេងៗ ការដុតសំណល់រឹង និងសំណល់កំទេចកំទីមែកឈើជាដើម | √ | | | • ការឈូសឆាយដីព្រៃដើម្បីដាំដំណាំកៅស៊ូ គឺអនុវត្តតាមដំណាក់កាលដែលបានកំណត់ក្នុងផែនការមេ រួចធ្វើដាំដុះភ្លាមៗដោយមិនឲ្យទុកដីទំនេរចោល<br>• រក្សាទុកព្រៃតាមទ្រនាប់ដងអូរដែលមានក្នុងតំបន់គម្រោងចម្ងាយពី ១០០ម. ទៅ១៥០ម.សងខាងអូរទៅតាមស្ថានភាពអូរ ដើម្បីជួយទប់ស្កាត់ការហុយធូលីទៅតំបន់ផ្សេង និងជួយបន្សុទ្ធខ្យល់។<br>• ធ្វើការគ្រប់គ្រង និងថែទាំគ្រឿងចក្រ យានដ្ឋានជំនិះយ៉ាងទៀងទាត់ ដូចជាការប្តូរប្រេងរំអិលតាមកាលកំណត់ និងមិនធ្វើការដោះចេញនូវតម្រងចម្រោះឧស្ម័នពុលដែលមានស្រាប់លើគ្រប់គ្រឿងចក្រ និងយានដ្ឋានជំនិះ ដើម្បីកាត់បន្ថយឧស្ម័នបំភាយចូលបរិយាកាស។<br>• កំណត់ល្បឿនបើកបរក្នុងការដឹកជញ្ជូនកសិផល និងបរិក្ខាផ្សេងៗចេញចូលក្នុងតំបន់គម្រោង ជាពិសេសតំបន់ទីប្រជុំជន មន្ទីរពេទ្យ និងសាលារៀនជាដើម។<br>• ចំពោះសំណល់កំទេចកំទីមែកឈើដែលមិនមានតម្លៃសេដ្ឋកិច្ច និងថង់ផ្លាស្ទិក គឺក្រុមហ៊ុននឹងអនុវត្តរៀបចំផែនការគ្រប់គ្រងឲបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។<br>• ត្រូវធ្វើការពិនិត្យតាមដានគុណភាពខ្យល់ក្នុងតំបន់ជាប្រចាំ តាមពេលវេលាជាក់ស្តែងដែលបានកំណត់ក្នុងផែនការគ្រប់គ្រងបរិស្ថាន នៅជំពូក៨។ |
| ច. សំឡេងរំខាន | – សំឡេងចេញពីរណារយន្តអារឈើមុនធ្វើការឈូសឆាយ គ្រឿងចក្រឈូសឆាយ ម៉ាស៊ីនភ្លើង និងម៉ាស៊ីនផ្សេងៗទៀតដែលដំណើរការក្នុងអំឡុងពេលឈូសឆាយ ឬសាងសង់។<br>– សំឡេងចេញពីរថយន្តដឹកជញ្ជូនសម្ភារៈសំណង់ និងសម្ភារៈបរិក្ខាផ្សេងៗ ។ល។ | √ | | | • អនុវត្តការងារដឹកជញ្ជូន ឈូសឆាយ និងសាងសង់ តែពេលថ្ងៃ ដោយចៀសវាងអនុវត្តការងារនៅពេលយប់។<br>• ត្រូវប្រើប្រាស់គ្រឿងចក្រឈូសឆាយ ដែលមានការអនុញ្ញាតឲ្យប្រើប្រាស់ និងដែលមានលក្ខណៈត្រឹមត្រូវស្តង់ដារបច្ចេកទេស ដូចជាប្រើប្រាស់គ្រឿងចក្រ និងគ្រឿងម៉ាស៊ីនដែលមានបំពាក់ឧបករណ៍កាត់បន្ថយសំឡេង។<br>• ត្រូវរៀបចំផែនការប្រើប្រាស់គ្រឿងចក្រ និងគ្រឿងម៉ាស៊ីនឲ្យមានប្រសិទ្ធិភាព ដោយចៀសវាងនូវការបញ្ឆេះម៉ាស៊ីនទុកចោលនៅពេលដែលមិនចាំបាច់។ |

Draft

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| | | | | | • សាងសង់បន្ទប់សម្រាប់ដាក់ម៉ាស៊ីនភ្លើង ដោយបំពាក់នូវស៊ីម៉ាំងដែលមានសំឡេងតិច។<br>• កំណត់ល្បឿនបើកបរក្នុងការដឹកជញ្ជូនសម្ភារៈសំណង់ និងបរិក្ខាផ្សេងៗចេញ-ចូលក្នុងតំបន់គម្រោង ជាពិសេសតំបន់ទីប្រជុំជន មន្ទីរពេទ្យ និងសាលារៀនជាដើម។ |
| **២.២ ធនធានជីវសាស្ត្រ** | | | | | |
| ក. ព្រៃឈើ និងសារព័ន្ធរុក្ខជាតិ | – សកម្មភាពដាំដុះ និងការឈូសឆាយនៅកំឡុងពេលសាងសង់ | √ | | | • ចូលរួមដាំ និងស្តារឡើងវិញ នូវប្រភេទព្រៃនៅក្បែរមាត់ទឹកនៅតាមបណ្តោយដងអូរយ៉ាងតិច ១០០-១៥០ ម៉ែត្រ សង់ខាងអូរ<br>• ក្រុមហ៊ុនត្រូវចូលរួមឧបត្ថម្ភគាំទ្រដល់សកម្មភាពដាំ និងបណ្តុះកូនឈើនៅតាមសហគមន៍ព្រៃឈើដែលមាននៅក្នុងតំបន់(ឧ.សហគមន៍ព្រៃឈើកុកព្រៅ) ព្រៃរក្សាទុក និងជាពិសេសរួមឧបត្ថម្ភគាំទ្រដល់សកម្មភាពអភិរក្ស ស្តារ ដាំ និងបណ្តុះកូនឈើនៅផ្នែករដ្ឋបាលព្រៃឈើវ៉ឺនសៃ ដើម្បីជាការប៉ះពៅដល់ទៅព្រៃឈើដែលបានបាត់បង់។ |
| ខ.ផល-អនុផលព្រៃឈើ | – សកម្មភាពដាំដុះ និងការឈូសឆាយនៅកំឡុងពេលសាងសង់ | √ | | | • ក្រុមហ៊ុនត្រូវចូលរួមដាំ និងស្តារឡើងវិញ នូវប្រភេទព្រៃនៅក្បែរមាត់ទឹក និងនៅតាមដងអូរ(អោយបានយ៉ាងតិចចម្ងាយ ១០០ម ទៅ១៥០ម សងខាងអូរ)។<br>• ក្រុមហ៊ុនត្រូវចូលរួមឧបត្ថម្ភគាំទ្រដល់សកម្មភាពដាំ និងបណ្តុះកូនឈើនៅតាមសហគមន៍ព្រៃឈើ តំបន់ព្រៃរក្សាទុកដែលមាននៅក្នុងតំបន់(ឧ.សហគមន៍ព្រៃឈើកុកព្រៅ) និងជាពិសេសត្រូវចូលរួមឧបត្ថម្ភគាំទ្រដល់សកម្មភាពអភិរក្ស ស្តារ ដាំ និងបណ្តុះកូនឈើរបស់ផ្នែករដ្ឋបាលព្រៃឈើវ៉ឺនសៃដែលនៅក្បែរទីតាំងគម្រោង ដើម្បីជាការប៉ះប៉ូវចំពោះការបាត់បង់គម្របព្រៃដែលបង្កដោយសារសកម្មភាពគម្រោង។<br>• នៅត្រង់ទីតាំងដែលមានជម្រាលខ្ពស់ ឬរយៈកម្ពស់ខ្ពស់ខ្លាំងដែលតម្រូវអោយរក្សាទុក ក្រុមហ៊ុនត្រូវធ្វើការថែរក្សានូវធនធានដែលមានស្រាប់អោយបានល្អ និងធ្វើការដាំដើមឈើបន្ថែមប្រសិនបើចាំបាច់។<br>• ក្រុមហ៊ុនត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពីបច្ចេកទេសកសិកម្មដល់ប្រជាពលរដ្ឋមូលដ្ឋាន និងជម្រុញលើកទឹកចិត្ត ព្រមទាំផ្តល់អាទិភាពអោយប្រជាពលរដ្ឋមូលដ្ឋានបានចូលបម្រើការងារគម្រោង។ |

Draft

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| | | | | | • ក្រុមហ៊ុនត្រូវអនុវត្តតាមការស្នើសុំរបស់ប្រជាជនដូចមាននៅក្នុង ជំពូក៥.៣(ធនធានសេដ្ឋកិច្ច សង្គម) និងអនុសាសន៍របស់សាធារណៈជននៅជំពូក៦(ការចូលរួមពីសាធារណៈជន)។ |
| គ.ប្រភេទ និងវត្តមានសត្វព្រៃ | – ការរំខានដែលកើតចេញពីសកម្មភាពដាំដុះ(ជាពិសេសការរំខានដែលបង្ករដោយសម្លេងគ្រាក់ទ័រនិងគ្រឿងចក្រផ្សេងៗទៀត) រួមទាំងសកម្មភាពនានារបស់បុគ្គលិក-កម្មករផងដែរ។<br>– ការគំរាមកំហែង ដោយសារសកម្មភាពលួចបរបាញ់ខុសច្បាប់ពីសំណាក់ប្រជាជន បុគ្គលិក-កម្មករ ក្នុង និងក្រៅទីតាំងគម្រោង។ | √ | | | • ចូលរួមធ្វើការដាំដើមឈើនៅក្នុងព្រៃសហគមន៍ និងព្រៃឈើដែលរក្សាទុក ដើម្បីជាជម្រកនៃប្រភេទសត្វព្រៃ ទាំងនោះ<br>• កាត់បន្ថយឲ្យដល់កម្រិតតូចបំផុតនូវការរំខានដោយសំឡេង-រំញ័រ ដែលកើតចេញពីសកម្មភាពគម្រោង។<br>• អប់រំ និងហាមឃាត់ បុគ្គលិក-កម្មករ និងប្រជាជនក្នុងតំបន់ មិនឱ្យធ្វើការបរបាញ់ប្រភេទសត្វព្រៃដែលមាននៅក្នុងតំបន់ដោយខុសច្បាប់។<br>• អប់រំ និងផ្សព្វផ្សាយពីអត្ថផលប្រយោជន៍សត្វព្រៃ និងជម្រុញមិនឲ្យបុគ្គលិក កម្មករ ធ្វើការជួញដូរឬបរិភោគសាច់សត្វព្រៃ។<br>• ដាក់ពិន័យ ចំពោះបុគ្គលិក-កម្មករ ដែលបរបាញ់ប្រភេទសត្វព្រៃខុសច្បាប់ និងរាយការជូនស្ថាប័នមានសមត្ថកិច្ច ក្នុងករណីសង្កេតឃើញមានការលួចបរបាញ់ខុសច្បាប់។<br>• ធ្វើការហាមប្រាមមិនឲមានការទិញសាច់ ឬសត្វព្រៃ ជាពិសេសពីសំណាក់ប្រជាពលរដ្ឋមូលដ្ឋាន។<br>• ត្រូវដាក់ពិន័យឲ្យបានតឹងរឹង (ឧ.ព្រមាន ឬបញ្ឈប់ពីការងារ) ក្នុងករណីមានបុគ្គលិក-កម្មករណាមួយប្រព្រឹត្តិបទល្មើស និងបទបញ្ញាខាងលើ។<br>• ទាំងម្ចាស់ក្រុមហ៊ុន ទាំងបុគ្គលិក-កម្មករ ត្រូវចូលរួមអភិរក្សសត្វព្រៃទាំងអស់គ្នា ក្នុងករណីប្រព្រឹត្តិបទល្មើសសត្វព្រៃខុសច្បាប់ និងត្រូវអនុវត្តទៅតាម ច្បាប់ព្រៃឈើដែលមានចែងនៅក្នុង ជំពូកទី១៥ មានត្រា៩៨ ចំណុចទី១១ និង១២។ |
| ឃ.វត្តមាន និងប្រភេទមច្ឆជាតិ | – ការធ្លាក់ចុះនៃគុណភាពទឹកក្នុងអូរ ដោយសារតែការហូរច្រោះដីល្បាប់ចូលទៅក្នុងអូរ និងការបំពុលទឹកដែលកើតឡើងដោយសារការគ្រប់គ្រងកាកសំណល់ | | √ | | • មុនពេលក្រុមហ៊ុនចាប់ផ្ដើមការឈូសឆាយ ឬស្ថាប្រព័ន្ធផ្លូវទឹកនៅកន្លែងណាមួយ(ទន្លេ អូរ ត្រពាំង) ត្រូវធ្វើការទំនាក់ទំនងជាមួយស្ថាប័នមានសមត្ថកិច្ច(ផ្នែករដ្ឋបាលជលផលរ៉ូនសែ) ដើម្បីធ្វើការចង្អុលបង្ហាញអំពីកន្លែង ឬតំបន់ដែលមានវត្តមានមច្ឆជាតិសំខាន់ៗ |

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| | រឹង រាវមិនបានត្រឹមត្រូវតាមបច្ចេកទេស។<br>- ការស្តារឡើងវិញនូវប្រព័ន្ធផ្លូវទឹក និងការសាសង់ស្រះ ឬអាងស្តុកទឹកដែលនឹងធ្វើអោយមានការប្រែប្រួលចរន្តទឹក។<br>- ការនេសាទខុសច្បាប់ពីសំនាក់ជនខិលខូចមួយចំនួន។ | | | | រស់នៅ។<br>• ធ្វើការលែងកូនមច្ឆជាតិនៅតាមប្រព័ន្ធផ្លូវទឹក ដែលមាននៅក្នុងនិងក្បែរទីតាំងតំបន់គម្រោងក្នុងរយៈពេល១ឆ្នាំម្តង។<br>• ដាក់ពិន័យ ចំពោះបុគ្គលិក-កម្មករ ដែលបានលួចនេសាទត្រីខុសច្បាប់ និងរាយការជូនស្ថាប័នមានសមត្ថកិច្ច ក្នុងករណីសង្កេតឃើញមានសកម្មភាពលួចធ្វើការនេសាទត្រីខុសច្បាប់។<br>• ទាំងម្ចាស់ក្រុមហ៊ុន ទាំងបុគ្គលិក-កម្មករ ត្រូវចូលរួមអភិរក្សមច្ឆជាតិទាំងអស់គ្នា ក្នុងករណីប្រព្រឹត្តិបទល្មើសខុសច្បាប់ និងត្រូវអនុវត្តទៅតាម ច្បាប់ជលផល ដូចដែលមានចែងនៅក្នុង ជំពូកទី១៥ មានត្រា៩៩។<br>• ត្រូវធ្វើការគ្រប់គ្រងសំណល់ រឹង រាវ ឱ្យបានល្អ ដោយអនុវត្តតាមផែនការកាត់បន្ថយផលប៉ះពាល់ក្នុងចំនុច រូបសាស្ត្រ និងអនុសាសន៍ក្នុងជំពូក ៨។ |
| **២.៣. ធនធានសេដ្ឋកិច្ចសង្គម** | | | | | |
| ក. កម្មសិទ្ធិដីធ្លី និងការប្រើប្រាស់ដី | - ទោះបីគម្រោងមិនទាន់ដំណើរការដាំដុះ ប៉ុន្តែវត្តមានគម្រោងក្នុងតំបន់ បានបង្កការរំខានដល់ការប្រើប្រាស់ដីធ្លី របស់គ្រួសារជនជាតិដើមភាគតិចនិងគ្រួសារខ្មែរមួយចំនួនរួចទៅហើយ (ឃុំប៉ង់ ឃុំភ្នំកុក ឃុំហាតប៉ក់ និងឃុំតាឡាត)។ | | | √ | • ក្រុមហ៊ុននឹងមិនឈូសឆាយដីហួសពីព្រំដីដែលទទួលបានពីរដ្ឋាភិបាល<br>• ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាដីធ្លីដែលប្រជាជននៅតែអះអាងថាមិនទាន់បានដោះស្រាយ |
| ខ. មុខរបរ និងប្រាក់ចំណូល | - អាចនឹងបាត់បង់ឱកាសបង្កើនដីធ្លីសម្រាប់ធ្វើស្រែចំការដោយសារវត្តមានក្រុមហ៊ុន ហើយនឹងអាចបាត់បង់លទ្ធភាពរកប្រាក់ចំណូល។<br>- ការបាត់បង់ផលអនុផលព្រៃឈើនៅពេលគម្រោងចាប់ផ្តើមដំណើរការ | | √ | | • ក្រុមហ៊ុននឹងរៀបចំ និងអនុវត្តគម្រោងកសិកម្មបែបកិច្ចសន្យា (គាំទ្របច្ចេកទេសដាំដុះ និងទិញយកកសិផល) ចំពោះមុខដំណាំដែលជាមុខព្រួញនៃគម្រោងវិនិយោគនេះ (ដូចជា កាកាវ ដូង អាកាស្យាសេណេហ្គាល់ សណ្តែកសៀង)។<br>• ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបណ្តុះបណ្តាលចំណេះដឹង ជំនាញចិញ្ចឹមសត្វ និងជំនាញឯកទេសផ្សេងទៀតដល់ប្រជាជនមូលដ្ឋាន។ |



Draft

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| | | | | | • ក្រុមហ៊ុននឹងផ្តល់ឱកាសសមស្របដល់ប្រជាជនអាចបម្រើការងារនៅក្នុងតំបន់គម្រោង ដោយមានប្រាក់បៀវត្សសមរម្យអាចទទួលយកបានពីសំណាក់ពួកគាត់ ដើម្បីអាចចូលរួមស្តារស្ថានភាពជីវភាព ឡើងវិញ។<br>• ក្រុមហ៊ុន នឹងផ្តល់លទ្ធភាពដល់ប្រជាជនមូលដ្ឋានក្នុងការចូលរក និងប្រមូលអនុផលព្រៃឈើជាលក្ខណៈប្រពៃណី (ដូចបានចែងនៅក្នុងច្បាប់ស្តីពីព្រៃឈើ) ក្នុងព្រៃរក្សាទុក ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់។ |
| គ. ការប្រើប្រាស់ទឹក សុខភាព និងអនាម័យក្នុងការរស់នៅរបស់ប្រជាជនមូលដ្ឋាន | - អាចនឹងមានការបំពុលប្រភពទឹក<br>- ការគ្រោងស្ទាក់ទប់ទឹកទុកប្រើតែនៅក្នុងតំបន់គម្រោង និងសកម្មភាពនៃការឈូសឆាយលុបប្រភពទឹកអូររបស់ក្រុមហ៊ុនអាចនឹងធ្វើឲ្យមានការរំខានដល់ការប្រើប្រាស់ទឹករបស់ប្រជាជនសម្រាប់ជីវភាពប្រចាំថ្ងៃ និងសម្រាប់ការងារកសិកម្ម ជាពិសេសនៅរដូវប្រាំង។<br>- សកម្មភាពឈូសឆាយដីអាចនឹងធ្វើឲ្យមានការហូរច្រោះដី កករល្បាប់<br>- ការបោះចោលសំណល់រឹងនិងបង្ហូរសំណល់រាវចូលទៅក្នុងប្រភពទឹក អាចនឹងធ្វើឲ្យមានការបំពុលប្រភពទឹកប្រើប្រាស់ | | √ | | • មិនធ្វើទំនប់ស្ទាក់ទឹក ឬឈូសឆាយលប់ប្រភពទឹកដែលធ្វើឲ្យប៉ះពាល់ដល់បរិមាណធារទឹក និងការប្រើប្រាស់ទឹករបស់ប្រជាជននៅខ្សែទឹកខាងក្រោម<br>• ជីកស្រះស្តុកទឹកភ្លៀងសម្រាប់ប្រើប្រាស់ ដើម្បីកាត់បន្ថយសម្ពាធលើការប្រើប្រាស់ទឹកពីប្រព័ន្ធផ្លូវទឹកធម្មជាតិ និងទឹកក្រោម<br>• រៀបចំ និងអនុវត្តឱ្យបានត្រឹមត្រូវតាម ផែនការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេង ដើម្បីការពារការបំពុលប្រភពទឹក<br>• ធ្វើការដាំដើមឈើនៅតាមដងអូរដែលគ្មានគម្របព្រៃ ឬមានព្រៃរេចរឹលឲ្យបានចម្ងាយពី ១០០ ម៉ែត្រ ទៅ ១៥០ម៉ែត្រ ដើម្បីបង្កើតជារនាំងចម្រោះទឹកធម្មជាតិ<br>• គាំទ្រការបង្កើនសួនបន្លែធម្មជាតិ និងកសិដ្ឋានចិញ្ចឹមសត្វប្រចាំគ្រួសារ ដើម្បីកាត់បន្ថយការទិញចំណីអាហារពីទីផ្សារ<br>• គាំទ្រដល់កម្មវិធីអប់រំ ផ្សព្វផ្សាយអំពីសុខភាព អនាម័យក្នុងការរស់នៅ (ជាពិសេសរៀបចំ និងចែកចាយនូវផ្ទាំងផ្សព្វផ្សាយអំពីបំរាមក្នុងការប្រើប្រាស់ធុងថ្នាំគីមីកសិកម្មសម្រាប់ស្តុកម្ហូបអាហារ និងទឹកបរិភោគ)<br>• គាំទ្រដល់ដំណើរការមណ្ឌលសុខភាពដែលមានស្រាប់ក្នុងតំបន់ (មណ្ឌលសុខភាពភ្នំកុក និងមណ្ឌលសុខភាពរនីសែ)<br>• គាំទ្រដល់ដំណើរការបង្កើតមណ្ឌលសុខភាពក្នុងភូមិតាឡាត ឬភូមិរំពាត់ នៃឃុំតាឡាត (ភូមិទាំងពីរនេះនៅដាច់ស្រយាលពីទីប្រជុំឃុំ និងស្ថិតនៅក្រោមខ្សែទឹកនៃទីតាំង |

Draft

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| | | | | | គម្រោង ) |
| ឃ. ប្រពៃណី ទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច | - កសិកម្មពនេចររបស់ប្រជាជនជនជាតិដើមអាចនឹងត្រូវបានកម្រិត ក្រោយផ្ទៃដីព្រៃឈើក្នុងតំបន់មួយភាគធំត្រូវបានប្រគល់ឲ្យក្រុមហ៊ុនដើម្បីដំណើរការគម្រោង<br>- ការបាត់បង់ព្រៃឈើអាចនឹងធ្វើឲ្យប្រពៃណីទំនៀមទម្លាប់មួយចំនួនដូចជា៖ ការកប់សព ការសែនព្រេន អារក្សអ្នកតា ការប្រកបរបរបណ្តើរផ្លែដេញសត្វ ការដងជ័រ និងរកអនុផលព្រៃឈើផ្សេងៗ<br>- ទំនៀមទម្លាប់ ប្រពៃណីរបស់ជនជាតិដើមភាគតិច ជាពិសេសសហគមន៍ដែលនៅជាប់នឹងទីតាំងគម្រោង នឹងទទួលរងនូវឥទ្ធិពលពីវប្បធម៌ថ្មី ដែលនាំចូលមកជាមួយនឹងបុគ្គលិក-កម្មករដែលជាជនចំណូលថ្មី។<br>- | √ | | | • ផ្តល់លទ្ធភាពដល់ប្រជាជនមូលដ្ឋានក្នុងការអនុវត្តនូវប្រពៃណីនៃការប្រមូលអនុផលព្រៃឈើ ដោយមិនហាមឃាត់ពួកគាត់មិនឱ្យចូលព្រៃរក្សាទុក។<br>• ផ្សព្វផ្សាយអំពីទំនៀមទម្លាប់ ប្រពៃណី (ជាពិសេសតំណមនានា) របស់ជនជាតិដើមភាគតិច ដល់ បុគ្គលិក-កម្មករ និងដាក់បំរាមមិនឱ្យបុគ្គលិក-កម្មករធ្វើសកម្មភាពអ្វីដែលអាចប៉ះពាល់ដល់ទំនៀមទម្លាប់ ប្រពៃណីទាំងនោះ។<br>• សហការជាមួយអាជ្ញាធរ និងសហគមន៍មូលដ្ឋាន ដើម្បីរៀបចំពិធីបុណ្យតាមបែបប្រពៃណីរបស់ជនជាតិដើមភាគតិច។<br>• សហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាដីធ្លីដែលប្រជាជននៅតែអះអាងថាមិនទាន់បានដោះស្រាយ |
| ង. សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋាន | - ការធ្វើចរាចរណ៍យានយន្តនានារបស់គម្រោងអាចបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ទៅដល់ប្រជាជនមូលដ្ឋាន<br>- អាចមានជម្លោះ និងអំពើហិង្សាកើតឡើងរវាងបុគ្គលិក-កម្មករគម្រោងនឹងប្រជាជនមូលដ្ឋាន ជាពិសេសជនជាតិដើមភាគតិច<br>- អាចកើតមាននូវវប្បធម៌មិនល្អ ដូចជាការសេពគ្រឿងញៀន ការលេងល្បែងស៊ីសង ចោរកម្ម ជម្ងឺឆ្លង ពេស្យាចារ និងករណីរំលោភសេពសន្ថវៈ (ពីបុគ្គលិក-កម្មករលើប្រជាជន និង/ឬពីប្រជាជនលើបុគ្គលិក-កម្មករ)។ | | √ | | • ណែនាំឱ្យអ្នកបើកបរគោរពច្បាប់ចរាចរណ៍ និងពិន័យធ្ងន់ធ្ងរ ប្រសិនបើមិនគោរពច្បាប់ ហើយការមិនគោរពច្បាប់ធ្វើឱ្យមានគ្រោះថ្នាក់ចរាចរណ៍<br>• ធ្វើការផ្សព្វផ្សាយជាចំណេះដឹងបន្ថែមដល់ប្រជាជនមូលដ្ឋាន ទាក់ទងនឹងសុវត្ថិភាពចរាចរណ៍<br>• ជ្រើសរើសបុគ្គលិក-កម្មករក្នុងមូលដ្ឋាន ឲ្យអស់លទ្ធភាពមុននឹងសម្រេចជ្រើសរើសអ្នកតំបន់ផ្សេង<br>• បញ្ចូលក្នុងបទបញ្ជាផ្ទៃក្នុងនូវបំរាមពាក់ព័ន្ធនឹងគ្រឿងញៀន អំពើហិង្សាជាមួយប្រជាជនមូលដ្ឋាន និង ករណីចោរកម្ម ពេស្យាចារ រំលោភសេពសន្ថវៈ<br>• សហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការត្រួតពិនិត្យ និងតាមដានបុគ្គលិក-កម្មករ ដែលជាជនចំណូលថ្មី ដើម្បីធានាថាពួកគេមិនពាក់ព័ន្ធនឹងគ្រឿងញៀន បង្កហិង្សាជាមួយ |

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| | | | | | ប្រជាជនមូលដ្ឋាន និងបង្កឲ្យមានករណីចោរកម្ម ពេស្យាចារ សេពសន្ថវៈ<br>• មានផែនការត្រួតពិនិត្យសុខភាពបុគ្គលិក-កម្មករជាប្រចាំ និងបណ្តុះបណ្តាលពួកគាត់អំពីបញ្ហានៃជម្ងឺឆ្លង ការបង្ការជម្ងឺឆ្លងនានា និងផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន ។ល។<br>• គាំទ្រដល់បេសកកម្មរបស់ប្រជាការពារឃុំ ដើម្បីពង្រឹងសុវត្ថិភាព និងសន្តិសុខមូលដ្ឋាន |
| ច. សុខភាព សុវត្ថិភាព និងសុខមាលភាពបុគ្គលិក និងកម្មករគម្រោង | - ការរស់នៅច្រើនគ្នាក្នុងលំនៅដ្ឋានមិនមានស្តង់ដាត្រឹមត្រូវអាចនឹងបង្កនូវផលប៉ះពាល់ដល់សុខភាពដោយអាចងាយឆ្លងមេរោគនានា<br>- បុគ្គលិកនិងកម្មករគម្រោង ក៏នឹងប្រឈមមុខខ្លាំងនឹងជំងឺគ្រុនចាញ់<br>- ការបញ្ជាគ្រឿងចក្រ និងរៀបចំដីដាំដុះ និងថែទាំដំណាំដោយគ្មានបច្ចេកទេស អាចនឹងបង្កគ្រោះថ្នាក់ដល់បុគ្គលិកនិងកម្មករគម្រោង។<br>- ការប្រើប្រាស់ថ្នាំពុលកសិកម្ម ដោយគ្មានការអនុវត្តយន្តការសុវត្ថិភាព និងកង្វះការណែនាំអំពីហានិភ័យ អាចនឹងបង្កនូវផលប៉ះពាល់ដល់សុខភាពបុគ្គលិក និងកម្មករគម្រោង។ | | √ | | • ផ្តល់លំនៅដ្ឋានសម្រាប់ស្នាក់នៅ ក្នុងកម្រិតស្តង់ដាកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ស្របតាមច្បាប់ស្តីពីការងារ (មាត្រា ២០៤ ដល់ ២០៦ និង មាត្រានានាក្នុងជំពូក ៧ និងជំពូក៨)។<br>• ផ្តល់នូវការបណ្តុះបណ្តាលអំពីការទប់ស្កាត់ការកើតជម្ងឺគ្រុនចាញ់ និងផ្តល់មុងជ្រលក់ថ្នាំដល់បុគ្គលិក-កម្មករ។<br>• ផ្តល់ការបណ្តុះបណ្តាលអំពីបច្ចេកទេសបញ្ជាគ្រឿងចក្រ និងវិធានសុវត្ថិភាពក្នុងការការពារគ្រោះថ្នាក់ក្នុងពេលបំពេញការងារ និងការពារផលប៉ះពាល់ពីថ្នាំគីមីកសិកម្ម<br>• ផ្តល់ឱ្យបុគ្គលិក-កម្មករនូវឧបករណ៍សុវត្ថិភាពស្របតាមបទដ្ឋានកំណត់ (ដូចជាស្បែកជើងកវែង ម៉ាស់ការពារមុខ ស្រោមដៃ ខោអាវសម្រាប់ស្លៀកពាក់ពេលបាញ់ថ្នាំ)<br>• អនុវត្តកម្មវិធីត្រួតពិនិត្យ និងថែទាំសុខភាព ជាពិសេសពាក់ព័ន្ធនឹងជម្ងឺគ្រុនចាញ់ និងជម្ងឺដែលបង្កឡើងដោយសារផលប៉ះពាល់នៃថ្នាំគីមីកសិកម្ម។<br>• រៀបចំឱ្យមានស្លាកសញ្ញាបង្ហាញ និងណែនាំនៅទីតាំងស្តុកថ្នាំពុលកសិកម្ម អំពីគ្រោះថ្នាក់ដែលអាចបណ្តាលមកពីថ្នាំពុលកសិកម្ម និងវិធីសាស្ត្រណែនាំអំពីការលាយថ្នាំ។<br>• មិនអនុញ្ញាតឲ្យបុគ្គលិក-កម្មករដែលគ្មានភារកិច្ច ឬដែលមិនពាក់ឧបករណ៍ការពារ ចូលទីតាំងស្តុកថ្នាំគីមីកសិកម្ម និងជីកសិកម្ម<br>• រៀបចំទីតាំងស្តុកថ្នាំគីមីកសិកម្ម និងជីកសិកម្ម ទៅតាមលក្ខណៈបច្ចេកទេស ដោយការពារមិនឲ្យប៉ះពាល់ទឹក លេចជ្រាបចូលក្នុងដី ហុយតាមខ្យល់ ឬត្រូវកំដៅ និងត្រូវមានឧបករណ៍ការពារអគ្គិភ័យ និងខ្យល់ចេញចូលល្អ។ |

Draft

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| | | | | | • លាយតាមស្តង់ដារបច្ចេកទេសនូវថ្នាំពុលកសិកម្ម តាមការណែនាំនៅលើសំបកថ្នាំ នៅទីតាំងរួមមួយក្បែរទីតាំងស្តុកថ្នាំ ដែលធានានូវសុវត្ថិភាពមិនប៉ះពាល់ដល់បរិស្ថាន និងសុខភាពមនុស្ស មុនចែកចាយបន្តឲ្យកម្មករប្រើប្រាស់។<br>• ប្រមូលមកវិញនូវធុងបាញ់ថ្នាំរបស់កម្មករ ដើម្បីរក្សាទុកនៅតាមទីតាំងរួម ដោយមិនអនុញ្ញាតឲ្យកម្មករយកទៅរក្សាទុកតាមផ្ទះរបស់ខ្លួន ដែលអាចធ្វើឲ្យប៉ះពាល់ដល់សុខភាពសមាជិកគ្រួសារ និងខ្លួនឯង។<br>• មានបន្ទប់ព្យាបាលបឋមសម្រាប់ជួយសង្គ្រោះបុគ្គលិក-កម្មករ នៅពេលមានកើតជម្ងឺ ឬមានគ្រោះថ្នាក់ក្នុងពេលបំពេញការងារ។<br>• ផ្តល់ការធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់ការងារដល់គ្រប់បុគ្គលិក-កម្មករ ក្រោមរូបភាពបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)។ |
| **៣.ដំណាក់កាលបញ្ចប់គម្រោង** | | | | | |
| **៣.១. ធនធានបរិស្ថានរូបសាស្ត្រ** | | | | | |
| ក. សណ្ឋានដី ការហូរច្រោះដី និងគុណភាពទឹក | – ការរុះរើ និងការប្រមូលផលដើមឈើទាំងអស់នេះ ដែលនាំឲ្យដីទំនេរចោលគ្មានគម្របដើមឈើ<br>– ការហូរច្រោះនាំសំណល់រឹង-រាវ សំណល់ប្រេងដែលសម្អាតមិនបានល្អ | | √ | | • ត្រូវបញ្ចប់គម្រោង និងប្រគល់ទីតាំងទាំងមូលជូនរាជរដ្ឋាភិបាលវិញតាមកាលកំណត់ និងគោរពតាមគោលការណ៍នៃនាំរបស់រាជរដ្ឋាភិបាល។<br>• ត្រូវធ្វើការរុះរើប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៅតាមតម្រូវការរបស់រដ្ឋាភិបាល ឲ្យបានមុនពេលបញ្ចប់គម្រោងជាស្ថាពរ។<br>• ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការប្រមូលផលដើមឈើដែលបានដាំដុះ និងមិនត្រូវកាប់ឆ្ការនូវធនធានព្រៃឈើដែលបានដាំក្នុងដំណាក់កាលសាងសង់គម្រោងឡើយ។<br>• ធ្វើការសំអាតសំណល់រឹង-រាវដែលមាននៅក្នុងតំបន់គម្រោង ឲ្យបានត្រឹមត្រូវតាមលក្ខណៈ បច្ចេកទេសដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងបរិស្ថាន ឲ្យជួយពិនិត្យឲ្យបានត្រឹមត្រូវមុននឹងធ្វើការបិទគម្រោង។<br>• ត្រូវបន្តជួយជ្រោមជ្រែងដល់សកម្មភាពស្តារបរិស្ថានឡើងវិញ ដោយបន្តផ្តល់មូលនិធិប |



Draft

| ធនធានបរិស្ថាន-សង្គម | ហេតុប៉ះពាល់អវិជ្ជមាន | ទំហំនៃការប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | |
| | | | | | វិស្ថានតាមការនែនាំក្នុងជំពូក ៨។ |
| ៣.២. ធនធានជីវសាស្ត្រ | | | | | |
| ក. ធនធានជីវសាស្ត្រ | – ការរុះរើ និងការប្រមូលផលដើមឈើទាំងអស់នេះដែលនាំឲ្យដីទំនេរចោលគ្មានគម្របដើមឈើ<br>– ការហូរច្រោះនាំសំណល់រឹង-រាវ សំណល់ប្រេងដែលសម្អាតមិនបានល្អ | | √ | | • មុននឹងបញ្ចប់គម្រោង ក្រុមហ៊ុនត្រូវធ្វើការលុបបំពេញឲជិតនូវកន្លែងចាក់សម្រាម ឬកន្លែងស្តុកកាកសំនល់រឹង រាវទាំងអស់ឲបានត្រឹមត្រូវតាមបច្ចេកទេស<br>• ក្រុមហ៊ុននឹងពិភាក្សាជាមួយស្ថាប័នមានជំនាញដើម្បីផ្ទេរការគ្រប់គ្រង ឬបន្តវិធានការនានាអោយបានត្រឹមត្រូវក្នុងដំណាក់កាលបិទគម្រោង។<br>• ក្រុមហ៊ុនត្រូវរក្សារាល់ប្រភេទព្រៃឈើដែលបានដាំនៅក្នុងដំណាក់កាលប្រតិបត្តិ។<br>• ក្រុមហ៊ុនត្រូវបន្តជួយជ្រោមជ្រែងដល់សកម្មភាពស្តារបរិស្ថានឡើងវិញ ដោយបន្តផ្តល់មូលនិធិបរិស្ថានតាមការនែនាំក្នុងជំពូក ៨។ |

Draft

## ៧.៥. បណ្តុំនៃហេតុប៉ះពាល់

បណ្តុំនៃហេតុប៉ះពាល់ ជាការសិក្សាអំពីបម្រែបម្រួលធនធានបរិស្ថាន ដែលបង្កឡើងដោយសកម្មភាពគម្រោង និងសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចផ្សេងទៀត។ បណ្តុំនៃហេតុប៉ះពាល់ចម្បងបំផុតដែលគួរឱ្យព្រួយបារម្ភ គឺការបាត់បង់ធនធានព្រៃឈើ និងបម្រែបម្រួលអវិជ្ជមាននៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី។

ការបាត់បង់ធនធានព្រៃឈើ បានកើតមានឡើងក្នុងតំបន់គម្រោងតាំងពីមិនទាន់មានវត្តមានគម្រោងមកម្ល៉េះ និងកើតឡើងព្រមគ្នានៅទីតាំងផ្សេងទៀតនៅក្នុងខេត្តរតនគិរី។ ក្នុងកម្រិតនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងអភិវឌ្ឍន៍តែមួយនេះ យើងមិនអាចវាយតម្លៃដោយជាក់លាក់ថា ព្រៃឈើដែលបាននិងកំពុងបាត់បង់សរុបនៅក្បែរតំបន់គម្រោងមានទំហំប៉ុណ្ណានោះទេ។ ប៉ុន្តែតាមរយៈផែនទី៧.១ យើងអាចសន្និដ្ឋានបឋមបានថា ធនធានព្រៃឈើនៅក្នុងស្រុកវើនសៃ និងស្រុកកូនមុំ (ដែលជាទីតាំងអភិវឌ្ឍន៍របស់គម្រោង) បាននិងកំពុងទទួលការគម្រាមកំហែង សឹករេចរឹល និងបាត់បង់ដោយសារសកម្មភាពសេដ្ឋកិច្ចក្នុងមូលដ្ឋាន និងគម្រោងអភិវឌ្ឍន៍ជាច្រើនក្នុងវិស័យដីសម្បទានសេដ្ឋកិច្ច និងវារីអគ្គិសនី។ ការវិភាគភាពត្រួតស៊ីគ្នារវាងគម្របព្រៃឈើឆ្នាំ២០១០ (រដ្ឋបាលព្រៃឈើ) និងគម្របព្រៃឈើឆ្នាំ២០១៦ (Landsat 8)[1] ផ្ទៃដីគម្របព្រៃឈើបានធ្លាក់ចុះប្រមាណ ២៦.៣០៦ ហិកតា។ ផ្ទៃដីព្រៃឈើដែលមានក្នុងទីតាំង គម្រោង SK (៦.១៥៨ ហិកតា) និងគម្រោងអភិវឌ្ឍន៍ដីសម្បទានសេដ្ឋកិច្ចផ្សេងទៀតដូចបង្ហាញក្នុងផែនទី៧.២ (៧៨.២៩៥ ហិកតា) ក៏នឹងត្រូវបាត់បង់បន្ថែមតាមរយៈសកម្មភាពនៃការអភិវឌ្ឍព្រមគ្នារបស់គម្រោងនីមួយៗ។ ជាបណ្តុំនៃផលប៉ះពាល់ ធនធានព្រៃឈើសរុបប្រមាណ ១១០.៧៥៩ ហិកតា (ស្មើនឹង ៣២,៨% នៃផ្ទៃដីគម្របព្រៃឈើដែលមានក្នុងឆ្នាំ២០១០ ក្នុងស្រុកវើនសៃ និងស្រុកកូនមុំ) នឹងត្រូវបាត់បង់។ ផ្អែកលើលទ្ធផលនៃការវិភាគនេះ ផ្ទៃដីព្រៃឈើដែលនឹងបាត់បង់ដោយសារគម្រោង SK (៦.១៥៨ ហិកតា) គ្រាន់តែជាចំណែកតូចមួយ (ប្រមាណ ៥,៦%) នៃផ្ទៃដីព្រៃឈើដែលនឹងបាត់បង់សរុបចាប់ពីឆ្នាំ២០១០មក (តារាង៧.៤)។ ទោះជាយ៉ាងនេះក្តី ព្រៃឈើដែលនឹងបាត់បង់ដោយសារគម្រោង SK និងគម្រោងអភិវឌ្ឍន៍ផ្សេងទៀតក្នុងតំបន់ គួបផ្សំនឹងព្រៃឈើដែលបាននិងកំពុងបាត់បង់ដោយសារការទន្ទ្រានយកដីពីសំណាកប្រជាជនក្នុងមូលដ្ឋាន និងជនឆ្លៀតឱកាសមួយចំនួន ពិតជាមានទំហំធំធេងគួរឱ្យព្រួយបារម្ភ។

តារាង៧.៣៖ លទ្ធផលនៃវិភាគបម្រែបម្រួលគម្របព្រៃឈើក្នុងស្រុកវើនសៃ និងស្រុកកូនមុំ ខេត្តរតនគិរី

| | ផ្ទៃដី (ហ.ត) | បណ្តុំនៃផ្ទៃដីព្រៃបាត់បង់ (ហ.ត) |
|---|---|---|
| គម្របព្រៃឆ្នាំ២០១០ ក្នុងស្រុកវើនសៃ និងកូនមុំ | 337,762 | |
| គម្របព្រៃឆ្នាំ២០១៦ ក្នុងស្រុកវើនសៃ និងកូនមុំ | 311,456 | -26306 |
| គម្របព្រៃឆ្នាំ២០១៦ ក្នុងទីតាំងគម្រោង SK | 6,158 | -32464 |
| គម្របព្រៃឆ្នាំ២០១៦ ក្នុងទីតាំងគម្រោងអភិវឌ្ឍន៍ផ្សេងទៀត | 78,295 | -110759 |

វិធានការកាត់បន្ថយបណ្តុំនៃហេតុប៉ះពាល់ ហួសពីដែនសមត្ថភាពរបស់ក្រុមហ៊ុន ក្នុងការដោះស្រាយតែឯកឯង។ រដ្ឋាភិបាលអាចប្រើប្រាស់ឧបករណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ (Strategic Environmental Assessment – SEA) ដើម្បីរៀបចំ/កែសម្រួលផែនការប្រើប្រាស់ដី ឬវិធានការកាត់បន្ថយការបាត់បង់ធនធានព្រៃឈើ ដែលមានសារៈសំខាន់សម្រាប់ការអភិរក្សជីវៈចម្រុះ និងអាចធានាបាននូវលំហូរសេវាកម្មប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ ជាពិសេសសេវាកម្មការពារទីជំរាល និងប្រភពទឹកស្អាត។ ក្នុងកម្រិតអប្បបរិមា រាជរដ្ឋាភិបាលគួរចៀសវាងការអភិវឌ្ឍនៅក្នុងតំបន់ជីវៈចម្រុះ និងទីជម្រកសំខាន់ដូចបង្ហាញក្នុងផែនទី៧.៣ និងអនុវត្តយន្តការចាំបាច់នានាដើម្បីជំរុញការអភិរក្សជីវៈចម្រុះក្នុងតំបន់ទាំងនោះ។

[1] www.glovis.usgs.gov, Type of Land sat 8 OLI, Code: 125-50 and 125-51 (Date 14/04/2016)

ផែនទី៧.១ ៖ ការគម្រាមកំហែងធនធានព្រៃឈើដោយសារគម្រោងអភិវឌ្ឍន៍ក្នុងស្រុករវៀងសែ និងស្រុកកូនមុំ



ផែនទី៧.២៖ គម្រោងអភិវឌ្ឍន៍នៅក្នុងស្រុកវើនសៃ និងស្រុកកូនមុំ ខេត្តរតនគិរី



## ផែនទី៧.៣ ៖ តំបន់ជីវៈចម្រុះ និងទីជម្រកសំខាន់ៗក្នុងខេត្តរតនគិរី



## ៧.៦. ហេតុប៉ះពាល់បរិស្ថាន-សង្គមវិជ្ជមាន

វត្តមានគម្រោងមិនមែនសុទ្ធតែនាំមកនូវផលប៉ះពាល់អវិជ្ជមាននោះទេ។ ការផ្តល់ដីសម្បទានសេដ្ឋកិច្ចតាមរយៈគម្រោងវិនិយោគនេះ គឺក្នុងគោលបំណងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមក្នុងតំបន់ ខេត្ត ក៏ដូចជាប្រទេសជាតិទាំងមូល។ ផលវិជ្ជមានដែលទទួលបានពីគម្រោងប្រភេទនេះ រួមមាន៖

- ជំរុញនូវសកម្មភាពផលិតកម្មនិងការនាំចេញផលិតផលជ័រកៅស៊ូ។ កិច្ចដំណើរគម្រោងនេះជាចលករមួយនាំឲមានផលចំណេញសេដ្ឋកិច្ចសុទ្ធប្រមាណ ៩,៦៣២លានដុល្លារ ក្នុងរយៈពេល ៥០ឆ្នាំនៃការវិនិយោគនេះ ស្មើនឹង ១៩២.៦៤៨ដុល្លារ ជាមធ្យមក្នុង០១ឆ្នាំ។
- បង្កើតការងារដល់ប្រជាជនទាំងក្នុងតំបន់ និងក្រៅតំបន់ និងការងារពាក់ព័ន្ធផ្សេងទៀត តាមរយៈការប្រើប្រាស់ និងទិញទំនិញដែលផលិតដោយសហគ្រាសនៅក្នុងស្រុក។ ក្រុមហ៊ុនគួរពិចារណាជម្រើសក្នុងការបណ្តុះបណ្តាលដល់ប្រជាជនមូលដ្ឋាន ដែលមានសក្តានុពល ដើម្បីឲ្យពួកគាត់អាចក្លាយជាមេការក្នុងកិច្ចដំណើរការគម្រោង។ ធ្វើបែបនេះ យើងអាចជំរុញផលវិជ្ជមាននៃគម្រោងវិនិយោគនេះឲរិតតែប្រសើរឡើង។
- ផ្តល់ចំណូលដល់រដ្ឋតាមរយៈពន្ធលើប្រាក់ចំណូលរបស់ក្រុមហ៊ុន ពន្ធលើប្រាក់បៀវត្សរបស់បុគ្គលិក និងកម្មករគម្រោង។
- លើកកម្ពស់ការយល់ដឹងរបស់បុគ្គលិក និងកម្មករខ្មែរ អំពីបច្ចេកទេសក្នុងការដាំដុះ ថែទាំ ប្រមូលផល និងកែច្នៃផលិតផលជ័រកៅស៊ូ។
- គម្រោងវិនិយោគអាចនឹងមានការសាងសង់ផ្លូវគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធជាច្រើននៅក្នុងតំបន់គម្រោងដូចជា ផ្លូវ ផ្ទះកម្មករ អណ្តូងទឹក ស្រះទឹកជាដើម។ ប្រការនេះបានជំរុញឲមានការឈានទៅមុខមួយជំហ៊ានទៀតនូវការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់ដាច់ស្រយាល។
- ក្រុមហ៊ុនបានជួយតំបន់ដាច់ស្រយាលនេះឲក្លាយជាតំបន់កសិ-ឧស្សាហកម្មមួយដែលបង្កើនមុខរបរ និងប្រាក់ចំណូលបន្ថែម។
- វត្តមានរបស់គម្រោងនៅក្នុងតំបន់ បានធ្វើឲមានការកើនឡើងនូវការប្រើប្រាស់ដីឲ្យកាន់តែអស់លទ្ធភាពនៅក្នុងតំបន់ជាជាងទុកដីទំនេរចោល
- វត្តមានរបស់គម្រោងនៅក្នុងតំបន់ បានរួមចំណែកជួយលុបបំបាត់សកម្មភាពអនាធិបតេយ្យរបស់ជនឆ្លៀតឱកាសមួយចំនួនដូចជា ការរានដីព្រៃ ការកាប់ឈើ និងការបរបាញ់សត្វ។ល។ ក្រុមហ៊ុននឹងជួយស្តារឡើងវិញនូវតំបន់ដីព្រៃដែលរេចរឹល តាមរយៈផែនការដាំដើមឈើឡើងវិញរបស់គម្រោងនៅតំបន់ដីព្រៃរេចរឹល។

ក្រុមហ៊ុននឹងជួយគាំទ្រដល់សកម្មភាពអភិវឌ្ឍន៍មូលដ្ឋាន (ដូចរៀបរាប់ក្នុងកម្មវិធីគ្រប់គ្រង និងត្រួតពិនិត្យបរិស្ថាន ក្នុងជំពូកទី៨) បន្ថែមទៀត។ ការគាំទ្រដល់សកម្មភាពអភិវឌ្ឍន៍មូលដ្ឋានទាំងនេះ គួបផ្សំនឹងការអនុញ្ញាតឲ្យប្រជាជនប្រើប្រាស់ផ្លូវគមនាគមន៍ក្នុងទីតាំងគម្រោង អាចជួយសម្រួលដល់ដំណើរសេដ្ឋកិច្ចក្នុងតំបន់ដែលយើងរំពឹងថានឹងមានការកើនឡើងនៅពេលអនាគត។

Draft

# ជំពូកទី៨

# ផែនការគ្រប់គ្រងបរិស្ថាន

Draft

Draft

# ជំពូកទី៨៖ ផែនការគ្រប់គ្រងបរិស្ថាន

## ៨.១. សេចក្តីផ្តើម

ផែនការគ្រប់គ្រងបរិស្ថាន ត្រូវបានរៀបចំឡើងជាផែនការគ្រប់គ្រង កម្មវិធីអប់រំ-បណ្តុះបណ្តាល និងកម្មវិធីត្រួតពិនិត្យបរិស្ថានលម្អិតមួយ ដោយកំណត់យ៉ាងច្បាស់លាស់នូវគោលបំណង សកម្មភាពការងារ អ្នកទទួលខុសត្រូវ ពេលវេលា/ខួបអនុវត្តន៍ និងតម្រូវការថវិកា សំដៅធ្វើយ៉ាងណាធានាបាននូវការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលមានចែងក្នុងជំពូកទី៧ នៃរបាយការណ៍នេះ។ នៅក្នុងផែនការគ្រប់គ្រងបរិស្ថាននេះ យន្តការត្រួតពិនិត្យ/តាមដានការអនុវត្តសកម្មភាពការងារ ក៏ត្រូវបានកំណត់។

ផែនការសកម្មភាពលម្អិត តម្រូវការថវិកា និងពេលវេលានៃការអនុវត្ត ត្រូវបានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាននេះ ដោយឈរលើមូលដ្ឋានសំខាន់ចំនួន៥៖ ហេតុប៉ះពាល់បរិស្ថាន-សង្គមដែលបានស្រាវជ្រាវរកឃើញ, ភាពអាចស្តារ ឬមិនអាចស្តារឡើងវិញបាននៃផលប៉ះពាល់ដែលអាចនឹងកើតឡើង, ទម្លាប់ល្អៗនៃការអនុវត្តវិធានការកាត់បន្ថយ, តម្រូវការដាក់ស្តែងនៅមូលដ្ឋាន, និងភាពអាចផ្គត់ផ្គង់/គាំទ្រជាថវិកាបានរបស់ក្រុមហ៊ុនម្ចាស់គម្រោង។

## ៨.២. សមាសភាពស្ថាប័នត្រួតពិនិត្យ

ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន នឹងត្រូវបានធ្វើឡើងដោយម្ចាស់គម្រោងផ្ទាល់ ដែលម្ចាស់គម្រោងត្រូវជ្រើសរើសបុគ្គលិកដែលមានជំនាញ និងចំណេះដឹងផ្នែកបរិស្ថាន ដើម្បីជួយក្នុងការអនុវត្តការងារនេះ។ ក្នុងការអនុវត្តផែនការគ្រប់គ្រងបរិស្ថាននេះដែរ ក៏តម្រូវឱ្យមានការចុះត្រួតពិនិត្យជាទៀតទាត់ពីសំណាក់ស្ថាប័នមានសមត្ថកិច្ចដើម្បីធានានូវការអនុវត្តវិធានការកាត់បន្ថយ ឬផែនការគ្រប់គ្រងស្របតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវ និងដើម្បីធ្វើការកែតម្រូវនូវការអនុវត្តដែលមិនទាន់បានល្អ។

ជារួម សមាសភាពនៃក្រុមការងារអនុវត្តផែនការគ្រប់គ្រងបរិស្ថាន មានដូចជា៖

- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថាប័នថ្នាក់ក្រោមជាតិ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងអភិវឌ្ឍន៍ជនបទខេត្ត
- មន្ទីរបរិស្ថានខេត្ត
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តខេត្ត
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្ត
- មន្ទីរធនធានទឹក និងឧតុនិយមខេត្ត
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត
- មន្ទីរសុខាភិបាលខេត្ត
- អាជ្ញាធរដែនដី (ខេត្ត ស្រុក ឃុំ)

Draft

## ៨.៣. ផែនការគ្រប់គ្រងបរិស្ថាន

### ៨.៣.១. វិធានការការពារបរិស្ថាន

វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន-សង្គមសំខាន់ៗ ដូចមានបង្ហាញក្នុងជំពូកទី៧ ត្រូវបានលើកយកមកសង្ខេបឡើងវិញដូចតទៅ៖

#### ក. ដំណាក់កាលមុនប្រតិបត្តិ

- ធ្វើការឈូសឆាយ និងរៀបចំដីទៅតាមលក្ខណៈសណ្ឋានដី និងទៅតាមទំហំដូចដែលបានគ្រោងក្នុងផែនការ
- រៀបចំផ្លូវឆ្លងកាត់នានាក្នុងតំបន់គម្រោងឱ្យមានទំហំសមស្រប ដើម្បីធានាប្រសិទ្ធភាព និងសុវត្ថិភាពការងារ សំដៅជៀសវាងការអូសបន្លាយពេលសាងសង់ និងដាំដុះ (ឬទុកដីនៅទំនេរ) ដែលអាចនឹងបង្កឲ្យមានការហូរច្រោះដីកើតឡើង
- សាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅលើប្រភេទដីដែលមានគុណភាពទាប ឱ្យបានច្រើនជាអតិបរមា
- ធ្វើការឈូសឆាយរៀបចំដីទៅតាមទំហំដីដូចដែលបានគ្រោង ដើម្បីជៀសវាងការបាត់បង់ដីផលិតកម្មដំបូងលើសពីផ្ទៃដីហេដ្ឋារចនាសម្ព័ន្ធគម្រោង
- បកយកដីស្រទាប់លើដែលមានជីជាតិ ដើម្បីចាកគ្របលើទីតាំងជុំវិញសំណង់អគារ និងរៀបចំទីតាំងទាំងនោះទៅជាសួនច្បារ ឬដាំរុក្ខជាតិ ដើមឈើលម្អនៅជុំវិញសំណង់អគារទាំងនោះ
- រៀបចំ និងអនុវត្តឱ្យបានត្រឹមត្រូវតាម ផែនការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេង
- ធ្វើការឈូសឆាយតែក្នុងរដូវប្រាំង និងរៀបចំដាំណាំភ្លាមៗក្រោយពីឈូសឆាយរួច ដើម្បីកាត់បន្ថយកម្រិត និងរយៈពេលនៃការហូរច្រោះ
- សាងសង់ស្ពានឆ្លងកាត់ ឬរៀបចំប្រព័ន្ធលូបង្ហូរឱ្យបានត្រឹមត្រូវ ក្នុងករណីសាងសង់ហេដ្ឋរចនាសម្ព័នឆ្លងកាត់ប្រព័ន្ធផ្លូវទឹក
- សហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញមានសមត្ថកិច្ច ដើម្បីវាយតម្លៃ និងផ្តល់អនុសាសន៍បច្ចេកទេស ក្នុងករណីដែលក្រុមហ៊ុនធ្វើទំនប់ស្ទាក់ទឹក
- សាងសង់សំណង់ផ្សេងៗនៅចម្ងាយយ៉ាងហោចណាស់ ១០០ម. ទៅ១៥០ម. ពីអូរ និងប្រព័ន្ធផ្លូវទឹកនានា ដើម្បីការពារការហូរច្រោះដី និងកំទេចកំទីមែកឈើ ស្លឹកឈើ ចូលទៅក្នុងប្រព័ន្ធផ្លូវទឹកទាំងនោះ
- ធ្វើការឈូសឆាយតែក្នុងរដូវប្រាំង និងសាងសង់ ដាំដុះភ្លាមៗដោយមិនទុកដីឲ្យនៅទំនេរចោល ដើម្បីការពារ ឬកាត់បន្ថយការហូរច្រោះដីចូលទៅក្នុងប្រភពទឹក
- រក្សាទុកព្រៃតាមច្រទនាប់ដងអូរ និងតំបន់មាត់ទឹក ក្នុងចម្ងាយពី ១០០ម. ទៅ១៥០ម. សងខាង ដើម្បីការពារការហូរច្រោះដី និងការហូរនាំនូវសំណល់ផ្សេងៗចូលទៅក្នុងប្រភពទឹក
- តាមដានគុណភាពទឹកតាមរយៈការយកសំណាកទឹកទៅពិនិត្យនៅមន្ទីរពិសោធន៍ឱ្យបានទៀងទាត់ (៤ដង/ឆ្នាំ) និងសហការជាមួយស្ថាប័នមានសមត្ថកិច្ច ក្នុងការស្វែងរក និងអនុវត្ត វិធានការចាំបាច់នានា ក្នុងករណីពិនិត្យឃើញថាគុណភាពទឹកមានបម្រែបម្រួលជាអវិជ្ជមាន ដើម្បីកែលម្អ ឬស្តារគុណភាពទឹកឲ្យបានល្អប្រសើរឡើងវិញ
- ធ្វើការឈូសឆាយដីព្រៃដើម្បីសាងសាង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ តាមដំណាក់កាលដែលបានកំណត់ក្នុងផែនការមេ រួចធ្វើការបង្ហាប់ដីភ្លាម និងសាងសង់ ដោយដោយមិនទុកដីឲ្យនៅទំនេរចោល
- ជៀសវាងការដុតសំណល់គ្រប់ប្រភេទ ដោយអនុវត្តទៅតាមផែនការគ្រប់គ្រងសំណល់រឹង និងប្រើប្រាស់ឱ្យអស់លទ្ធភាពនូវកំទេចកំទីមែកឈើ និងសំណល់កសិកម្មក្នុងដំណើរការដាំដុះ

Draft

- សាងសង់សំណាង់ផ្សេងៗនៅចម្ងាយពី ១០០ម. ទៅ ១៥០ម. ពីអូរ ដើម្បីរក្សាទុកព្រៃមាត់អូរឲ្យជួយទប់ស្កាត់ការហុយធូលីទៅតំបន់ផ្សេង និងជួយបន្សុទ្ធខ្យល់
- ធ្វើការស្រោចទឹក និងបង្ហាប់ដីឲ្យអស់លទ្ធភាព នៅពេលឈូសឆាយស្ថាបនាផ្លូវនានា
- គ្រប់គ្រង និងថែទាំគ្រឿងចក្រ យាន្តជំនិះឱ្យបានល្អ និងទៀងទាត់ (ឧ. ប្តូរប្រេងរំអិល បំពាក់តម្រងចម្រោះឧស្ម័នពុល) ដើម្បីកាត់បន្ថយបរិមាណឧស្ម័នបំភាយចូលបរិយាកាស
- អប់រំ-ណែនាំឱ្យប្រើប្រាស់គ្រឿងចក្រ និងគ្រឿងម៉ាស៊ីន ឲ្យមានប្រសិទ្ធិភាព ដោយជៀសវាងនូវការបញ្ឆេះម៉ាស៊ីនទុកចោលនៅពេលដែលមិនចាំបាច់ ឬរាទ័ខ្លាំងពេក
- ពិនិត្យតាមដានកម្រិតនៃការបញ្ចេញឧស្ម័នបំពុលពីគ្រឿងចក្រ និងយាន្តយន្តដែលប្រើប្រាស់ក្នុងដំណើរការគម្រោង ព្រមទាំងធ្វើការជួសជុល ឬផ្លាស់ប្តូរថ្មីនូវគ្រឿងចក្រ ឬយានយន្តណាដែលបញ្ចេញឧស្ម័នបំពុលលើសកម្រិតស្តង់ដារ
- ដាំដើមឈើឡើងវិញនៅតាមការដ្ឋាន និងដងផ្លូវក្នុងទីតាំងគម្រោង ព្រមទាំងនៅតាមតំបន់ដែលយានយន្តរបស់ក្រុមហ៊ុនឆ្លងកាត់ ដើម្បីជួយទប់ស្កាត់ការហុយធូលី និងបន្សុទ្ធខ្យល់
- អនុវត្តការងារដឹកជញ្ជូន ឈូសឆាយ សាងសង់ និងដាំដុះ តែពេលថ្ងៃ ដោយជៀសវាងអនុវត្តការងារនៅពេលយប់
- ប្រើប្រាស់គ្រឿងចក្រ និងយានយន្ត ដែលមានបំពាក់ឧបករណ៍កាត់បន្ថយសំឡេង ឬមានការបញ្ចេញសំឡេងគោរពតាមស្តង់ដារកំណត់
- ពិនិត្យតាមដានកម្រិតនៃការបញ្ចេញសំឡេងរំខានពីគ្រឿងចក្រ និងយាន្តយន្ត ព្រមទាំងធ្វើការជួសជុលគ្រឿងចក្រ ឬយានយន្តណាដែលបញ្ចេញសំឡេង លើសកម្រិតស្តង់ដារកំណត់
- កំណត់ល្បឿនបើកបរក្នុងការដឹកជញ្ជូនសម្ភារសំណង់ បរិក្ខាផ្សេងៗ និងកសិផល ចេញ-ចូលក្នុងតំបន់គម្រោង ជាពិសេសតំបន់ទីប្រជុំជន មន្ទីរពេទ្យ និងសាលារៀន ជាដើម
- ធ្វើការឈូសឆាយព្រៃឈើសម្រាប់រៀបចំហេដ្ឋារចនាសម្ព័ន្ធគម្រោង តែទៅតាមទំហំផ្ទៃដីដូចកំណត់នៅផែនការមេ
- ដាំឡើងវិញនូវដើមឈើលម្អ នៅតាមដងផ្លូវក្នុងតំបន់គម្រោង និងនៅជុំវិញសំណង់អគារនានាក្នុងទីតាំងគម្រោង
- ចូលរួមឧបត្ថម្ភគាំទ្រសម្រាប់ការអភិរក្សព្រៃគុបក្នុងស្រុក ការគ្រប់គ្រងសហគមន៍ព្រៃឈើកុកព្រៅ ការអភិរក្សចំការពូជឈើ ការដាក់បញ្ចូលបន្ថែមនូវធនធានព្រៃឈើដែលនៅសេសសល់ជាដីអភិរក្ស ឬសហគមន៍ព្រៃឈើ ការការពារព្រៃទ្រនាប់អូរ ជាដើម
- ចូលរួមដាំ និងស្តារឡើងវិញ នូវប្រភេទឈើក្នុងស្រុកឬមានដោយកម្រ នៅតាមព្រៃទ្រនាប់អូរដែលបានកាត់ចេញ ព្រៃសហគមន៍ ដងផ្លូវ និងតំបន់សាធារណៈផ្សេងទៀត
- ចូលរួមឧបត្ថម្ភគាំទ្រដល់សកម្មភាពរបស់ស្ថានីយ៍បណ្តុះកូនឈើ របស់ផ្នែករដ្ឋបាលព្រៃឈើរ៉ូនសែ ដើម្បីផ្គត់ផ្គង់កូនឈើសម្រាប់ការដាំដុះក្នុងតំបន់
- ធ្វើការឈូសឆាយ សាងសង់ និងដាំដុះ ជាដំណាក់ៗតាមអនុតំបន់ដូចមានក្នុងផែនការមេរបស់គម្រោង ដើម្បីទុកផ្លូវ និងពេលវេលាឲ្យសត្វព្រៃធ្វើការភៀសខ្លួនទៅកាន់តំបន់ផ្សេងៗ
- កាត់បន្ថយឲ្យអស់លទ្ធភាពនូវការរំខានដោយសំឡេង-រំញ័រ តាមរយៈការប្រើប្រាស់គ្រឿងចក្រ ឬយានយន្តដែលបញ្ចេញសំឡេង-រំញ័រតិច

- អប់រំ និងហាមឃាត់បុគ្គលិក-កម្មករគម្រោង និងបុគ្គលិក-កម្មកររបស់អ្នកម៉ៅការ (ឈូសឆាយ សាងសង់ និងដាំដុះ) មិនឱ្យធ្វើការបរបាញ់ប្រភេទសត្វព្រៃដែលមាននៅក្នុងតំបន់ដោយខុសច្បាប់ ព្រមទាំងធ្វើការផ្សព្វផ្សាយឱ្យពួកគាត់បានដឹងពីអត្ថប្រយោជន៍សត្វព្រៃ
- ដាក់បំរាមមិនឲ្យបុគ្គលិក-កម្មករ បរិភោគសាច់សត្វព្រៃ និងមិនអនុញ្ញាឱ្យទិញសាច់ ឬសត្វព្រៃពីអ្នកលក់ ឬពីប្រជាពលរដ្ឋមូលដ្ឋាន
- លើកទឹកចិត្តដល់បុគ្គលិក-កម្មករ (ផ្តល់ជារង្វាន់) ឱ្យចូលរួមរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ចក្នុងករណីសង្កេតឃើញមានការលួចបរបាញ់ខុសច្បាប់
- ធ្វើការដាក់ពិន័យតឹងរឹង (ឧ. ព្រមាន ឬបញ្ឈប់ពីការងារ) ក្នុងករណីបុគ្គលិក-កម្មករណាមួយប្រព្រឹត្តិបទល្មើសនឹងបំរាមពាក់ព័ន្ធនឹងការបរបាញ់ និងបរិភោគសត្វព្រៃ
- សហការជាមួយស្ថាប័នមានសមត្ថកិច្ច ដើម្បីជៀសវាងការរំខានដល់កន្លែង ឬតំបន់ដែលជាជម្រកមច្ឆជាតិសំខាន់ៗ ក្នុងករណីដែលក្រុមហ៊ុនស្តារប្រព័ន្ធផ្លូវទឹកទោះជាក្នុងគោលបំណងអ្វីក៏ដោយ
- ធ្វើការលែងកូនមច្ឆជាតិនៅតាមប្រព័ន្ធផ្លូវទឹក ដែលមាននៅក្នុង និងក្បែរទីតាំងតំបន់គម្រោងក្នុងរយៈពេល១ឆ្នាំម្តង
- ដាក់ពិន័យ ចំពោះបុគ្គលិក-កម្មករ ដែលបានលួចនេសាទត្រីខុសច្បាប់ និងលើកទឹកចិត្តដល់បុគ្គលិក-កម្មករឱ្យចូលរួមរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ច ក្នុងករណីសង្កេតឃើញមានសកម្មភាពលួចធ្វើការនេសាទត្រីខុសច្បាប់
- សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធ ដើម្បីរៀបចំ និងផ្សព្វផ្សាយអំពីគោលការណ៍ក្នុងការដោះស្រាយទំនាស់ដល់ប្រជាពលរដ្ឋ
- ធ្វើការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ និងប្រជាពលរដ្ឋដែលមានដីធ្លីជាប់ព្រំទីតាំងគម្រោងដើម្បីផ្តល់ជាព័ត៌មានលម្អិតស្តីពីព្រំប្រទល់គម្រោង
- ធ្វើការបង្ហាញដល់ប្រជាជន នូវដំណើរការវិនិយោគនេះ តាំងពីដំណាក់កាលស្នើសុំរាជរដ្ឋាភិបាល រហូតដល់ដំណាក់កាលវិនិយោគ និងបញ្ចប់គម្រោង ព្រមទាំងលើកឡើងនូវរាល់វិធានការកាត់បន្ថយដើម្បីបញ្ចៀសនូវការប៉ះពាល់អវិជ្ជមាននានា (រួមទាំងការកាត់ចេញនូវផ្ទៃដីពាក់ព័ន្ធនានាដែលបានធ្វើឡើងកន្លងមក)
- មិនឈូសឆាយដីហួសពីព្រំដីដែលទទួលបានពីរដ្ឋាភិបាល
- គាំទ្រអាជ្ញាធរមូលដ្ឋានក្នុងការរៀបចំផែនការប្រើប្រាស់ដីក្នុងតំបន់ឲ្យបានសមរម្យ
- មិនធ្វើទំនប់ស្ទាក់ទឹក ឬឈូសឆាយលុបប្រភពទឹកដែលធ្វើឲ្យប៉ះពាល់ដល់បរិមាណធារទឹក និងការប្រើប្រាស់ទឹករបស់ប្រជាជននៅខ្សែទឹកខាងក្រោម
- ជីកស្រះស្តុកទឹកភ្លៀងសម្រាប់ប្រើប្រាស់ ដើម្បីកាត់បន្ថយសម្ពាធលើការប្រើប្រាស់ទឹកពីប្រព័ន្ធផ្លូវទឹកធម្មជាតិ និងទឹកក្រោម
- ផ្សព្វផ្សាយអំពីទំនៀមទម្លាប់ ប្រពៃណី (ជាពិសេសតំណមនានា) របស់ជនជាតិដើមភាគតិច ដល់បុគ្គលិក-កម្មករ និងដាក់បំរាមមិនឱ្យបុគ្គលិក-កម្មករធ្វើសកម្មភាពអ្វីដែលអាចប៉ះពាល់ដល់ទំនៀមទម្លាប់ ប្រពៃណីទាំងនោះ
- សហការជាមួយអាជ្ញាធរ និងសហគមន៍មូលដ្ឋាន ដើម្បីរៀបចំពិធីបុណ្យតាមបែបប្រពៃណីរបស់ជនជាតិដើមភាគតិច

Draft

- ធ្វើការផ្សព្វផ្សាយជាដំណឹងឲ្យបានមុនទៅកាន់អាជ្ញាធរមូលដ្ឋាន អំពីការចល័តគ្រឿងចក្រ ឬគ្រឿងម៉ាស៊ីនដែលត្រូវប្រើក្នុងពេលដំណើរការគម្រោង
- ណែនាំឱ្យអ្នកបើកបរគោរពច្បាប់ចរាចរណ៍ និងពិន័យធ្ងន់ធ្ងរ ប្រសិនបើមិនគោរពច្បាប់ ហើយការមិនគោរពច្បាប់ធ្វើឱ្យមានគ្រោះថ្នាក់ចរាចរណ៍
- ធ្វើការផ្សព្វផ្សាយជាចំណេះដឹងបន្ថែមដល់ប្រជាជនមូលដ្ឋាន ទាក់ទងនឹងសុវត្ថិភាពចរាចរណ៍
- ជ្រើសរើសបុគ្គលិក-កម្មករក្នុងមូលដ្ឋាន ឲ្យអស់លទ្ធភាពមុននឹងសម្រេចជ្រើសរើសអ្នកតំបន់ផ្សេង
- បញ្ចូលក្នុងបទបញ្ជាផ្ទៃក្នុងនូវបំរាមពាក់ព័ន្ធនឹងគ្រឿងញៀន អំពើហឹង្សាជាមួយប្រជាជនមូលដ្ឋាន និងករណីចោរកម្ម ពេស្យាចារ រំលោភសេពសន្ថវៈ
- សហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការត្រួតពិនិត្យ និងតាមដានបុគ្គលិក-កម្មករ ដែលជាជនចំណូលថ្មី ដើម្បីធានាថាពួកគេមិនពាក់ព័ន្ធនឹងគ្រឿងញៀន បង្កហឹង្សាជាមួយប្រជាជនមូលដ្ឋាន និងបង្កឲ្យមានករណីចោរកម្ម ពេស្យាចារ សេពសន្ថវៈ
- មានផែនការត្រួតពិនិត្យសុខភាពបុគ្គលិក-កម្មករជាប្រចាំ និងបណ្តុះបណ្តាលពួកគាត់អំពីបញ្ហានៃជម្ងឺឆ្លង ការបង្ការជម្ងឺឆ្លងនានា និងផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន ។ល។
- គាំទ្រដល់បេសកកម្មរបស់ប្រជាការពារឃុំ ដើម្បីពង្រឹងសុវត្ថិភាព និងសន្តិសុខមូលដ្ឋាន
- ផ្តល់លំនៅដ្ឋានសម្រាប់ស្នាក់នៅ ក្នុងកម្រិតស្តង់ដារកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ស្របតាមច្បាប់ស្តីពីការងារ
- ផ្តល់នូវការបណ្តុះបណ្តាលអំពីការទប់ស្កាត់ការកើតជម្ងឺគ្រុនចាញ់ និងផ្តល់មុងជ្រលក់ថ្នាំដល់បុគ្គលិក-កម្មករ
- ផ្តល់ការបណ្តុះបណ្តាលអំពីបច្ចេកទេសបញ្ជាគ្រឿងចក្រ និងវិធានសុវត្ថិភាពក្នុងការការពារគ្រោះថ្នាក់ក្នុងពេលបំពេញការងារ និងការពារផលប៉ះពាល់ពីថ្នាំគីមីកសិកម្ម
- ផ្តល់នូវបរិក្ខាសង្គ្រោះបឋម និងណែនាំអំពីវិធីសាស្ត្រសង្គ្រោះបឋម ដល់បុគ្គលិក-កម្មករ មុនពេលចាប់ផ្តើមបំពេញការងារ
- ផ្តល់ការធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់ការងារដល់គ្រប់បុគ្គលិក-កម្មករ ក្រោមរូបភាពបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ។

## ខ. ដំណាក់កាលប្រតិបត្តិ

- ធ្វើការឈូសឆាយ និងរៀបចំដីទៅតាមលក្ខណៈសណ្ឋានដី និងទៅតាមទំហំដូចដែលបានគ្រោងក្នុងផែនការ
- ធ្វើការឈូសឆាយតែក្នុងរដូវប្រាំង និងរៀបចំដាំណាំភ្លាមៗក្រោយពីឈូសឆាយរួច ដើម្បីកាត់បន្ថយកម្រិត និងរយៈពេលនៃការហូរច្រោះ
- មិនឈូសឆាយ ឬកាប់ឆ្ការព្រៃនៅតាមតំបន់ទ្រនាប់អូរ ឬក្បែរមាត់ទឹកដើម្បីពង្រីកផ្ទៃដីដាំដុះ ដោយរក្សាគម្របព្រៃឱ្យបានពី ១០០ម ទៅ ១៥០ម ពីប្រភពទឹក
- ជួយគាំពារព្រៃទ្រនាប់អូរនានាដែលមាននៅក្នុងទីតាំងគម្រោង ដើម្បីការពារទីជម្រាល និងទប់ស្កាត់ការហូរច្រោះដី និងបាក់ច្រាំង
- កាប់ឆ្ការព្រៃ ឈូសឆាយដី និងរៀបចំថ្នាលដំណាំ ជាដំណាក់កាលនៅត្រង់តំបន់ដែលមានជម្រាលខ្លាំង ហើយចាប់ផ្តើមធ្វើពីតំបន់ដែលមានរយៈកម្ពស់ខ្ពស់មុន ដើម្បីជៀសវាងការបាក់ដី

Draft

- រៀបចំផ្លូវឆ្លងកាត់នានាក្នុងតំបន់គម្រោងឱ្យមានទំហំសមស្រប ដើម្បីជានាប្រសិទ្ធភាព និងសុវត្ថិភាពការងារ សំដៅជៀសវាងការអូសបន្លាយពេលសាងសង់ និងដាំដុះ (ឬទុកដីនៅទំនេរ) ដែលអាចនឹងបង្កឲ្យមានការហូរច្រោះដីកើតឡើង
- ណែនាំអ្នកបើកបរមិនឱ្យដឹកជញ្ជូនលើសទម្ងន់ ដែលនាំឱ្យមានការបាក់ខូចផ្លូវ និងការហូរដីចេញពីផ្លូវ ជាពិសេសនៅរដូវវស្សា
- រៀបចំ និងអនុវត្តឱ្យបានត្រឹមត្រូវតាម ផែនការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់ប្រេង
- រៀបចំទីតាំងចម្ការដំណាំឱ្យមានប្រព័ន្ធបង្ហូរទឹកត្រឹមត្រូវ និងអនុវត្តការភ្ជួររាស់តាមបច្ចេកទេសដែលមានមេត្រីភាពបរិស្ថាន (ឧ. មិនភ្ជួររាស់ជ្រៅពេក ភ្ជួររាស់ជាលក្ខណៈកាំជណ្ដើរ ជាពិសេសនៅទីតាំងដែលមានជម្រាលខ្ពស់)
- ប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវកំទេចកំទីមែក ឬស្លឹករុក្ខជាតិដែលបានកាប់ឆ្ការ ជាគម្របដី ដើម្បី កាត់បន្ថយការហូរច្រោះ និងរំហួត និងផ្តល់ជីជាតិដល់ដី
- ប្រើប្រាស់តែជីគីមីកសិកម្ម ថ្នាំសម្លាប់សត្វល្អិត ឬស្មៅ ដែលមានចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រៀបចំផែនការប្រើប្រាស់ជីឱ្យបានច្បាស់លាស់ និងអនុវត្តតាមផែនការនេះឲ្យបានខ្ជាប់ខ្ជួន ដើម្បីជៀសវាងការប្រើប្រាស់ជីគីមីលើសកម្រិតដែលបណ្តាលឲ្យខូចគុណភាពដី
- កាត់បន្ថយការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ដោយការរៀបចំ និងអនុវត្តផែនការត្រៀមដើម្បីទប់ស្កាត់កំណើនលើសលប់នៃចំនួនសត្វល្អិត (avoid the outbreak occurs)
- ដាំដុះបន្ថែមនូវប្រភេទដំណាំបន្ទាប់បន្សំ ដូចជាពោត សណ្តែក ឬពពួកបន្លែបង្ការនានា នៅតាមចន្លោះរង ឬនៅក្នុងចន្លោះពេលសម្អាតថ្នាលបន្ទាប់ពីពេលប្រមូលផលដំណាំចម្បងរួច ធ្វើជាគម្របដីដើម្បីកាត់បន្ថយការហូរច្រោះ និងបាត់បង់ជីជាតិដី
- សហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញមានសមត្ថកិច្ច ដើម្បីវាយតម្លៃ និងផ្តល់អនុសាសន៍បច្ចេកទេស ក្នុងករណីដែលក្រុមហ៊ុនធ្វើទំនប់ស្ទាក់ទឹក
- សិក្សាពីស្ថានភាពសមតុល្យទឹកក្រោមដីឲ្យបានច្បាស់លាស់ មុននឹងធ្វើការខួង ឬបូមយកទឹកពីប្រភពទឹកក្រោមដី មកប្រើប្រាស់
- ធ្វើការឈូសឆាយតែក្នុងរដូវប្រាំង និងសាងសង់ ដាំដុះភ្លាមៗដោយមិនទុកដីឲ្យនៅទំនេរចោល ដើម្បីការពារ ឬកាត់បន្ថយការហូរច្រោះដីចូលទៅក្នុងប្រភពទឹក
- រក្សាទុកព្រៃតាមទ្រនាប់ដងអូរ និងតំបន់មាត់ទឹក ក្នុងចម្ងាយពី ១០០ម. ទៅ១៥០ម. សងខាង ដើម្បីការពារការហូរច្រោះដី និងការហូរនាំនូវសំណល់ផ្សេងៗចូលទៅក្នុងប្រភពទឹក
- ជៀសវាងការដាក់ជី ឬបាញ់ថ្នាំសម្លាប់សត្វល្អិត និងស្មៅ មុនពេលដែលទំនងជាមានភ្លៀងធ្លាក់ ដើម្បីកាត់បន្ថយការហូរនាំសារធាតុទាំងនេះចូលទៅក្នុងប្រភពទឹក។
- តាមដានគុណភាពទឹកតាមរយៈការយកសំណាកទឹកទៅពិនិត្យនៅមន្ទីរពិសោធន៍ឱ្យបានទៀងទាត់ (៤ដង/ឆ្នាំ) និងសហការជាមួយស្ថាប័នមានសមត្ថកិច្ច ក្នុងការស្វែងរក និងអនុវត្ត វិធានការចាំបាច់នានា ក្នុងករណីពិនិត្យឃើញថាគុណភាពទឹកមានបម្រែបម្រួលជាអវិជ្ជមាន ដើម្បីកែលម្អ ឬស្តារគុណភាពទឹកឲ្យបានល្អប្រសើរឡើងវិញ
- ជៀសវាងការដុតសំណល់គ្រប់ប្រភេទ ដោយអនុវត្តទៅតាមផែនការគ្រប់គ្រងសំណល់រឹង និងប្រើប្រាស់ឱ្យអស់លទ្ធភាពនូវកំទេចកំទីមែកឈើ និងសំណល់កសិកម្មក្នុងដំណើរការដាំដុះ

Draft

- គ្រប់គ្រង និងថែទាំគ្រឿងចក្រ យាន្តជំនិះឱ្យបានល្អ និងទៀងទាត់ (ឧ. ប្តូរប្រេងរំអិល បំពាក់តម្រងចម្រោះឧស្ម័នពុល) ដើម្បីកាត់បន្ថយបរិមាណឧស្ម័នបំភាយចូលបរិយាកាស
- អប់រំ-ណែនាំឱ្យប្រើប្រាស់គ្រឿងចក្រ និងគ្រឿងម៉ាស៊ីន ឲ្យមានប្រសិទ្ធិភាព ដោយជៀសវាងនូវការបញ្ឆេះម៉ាស៊ីនទុកចោលនៅពេលដែលមិនចាំបាច់ ឬពេទ័ខ្លាំងពេក
- ពិនិត្យតាមដានកម្រិតនៃការបញ្ចេញឧស្ម័នបំពុលពីគ្រឿងចក្រ និងយាន្តយន្តដែលប្រើប្រាស់ក្នុងដំណើរការគម្រោង ព្រមទាំងធ្វើការជួសជុល ឬផ្លាស់ប្តូរថ្មីនូវគ្រឿងចក្រ ឬយានយន្តណាដែលបញ្ចេញឧស្ម័នបំពុលលើសកម្រិតស្តង់ដារ
- កំណត់ល្បឿនបើកបរក្នុងការដឹកជញ្ជូនសម្ភារសំណង់ បរិក្ខាផ្សេងៗ និងកសិផល ចេញ-ចូលក្នុងតំបន់គម្រោង ជាពិសេសតំបន់ទីប្រជុំជន មន្ទីរពេទ្យ និងសាលារៀន ជាដើម
- រក្សាទុកដើមឈើនៅតាមព្រំទីតាំងគម្រោងដើម្បីដើម្បីជួយទប់ស្កាត់ការហុយធូលីទៅតំបន់ផ្សេង និងជួយបន្សុទខ្យល់
- អនុវត្តការងារដឹងជញ្ជូន ឈូសឆាយ សាងសង់ និងដាំដុះ តែពេលថ្ងៃ ដោយជៀសវាងអនុវត្តការងារនៅពេលយប់
- ប្រើប្រាស់គ្រឿងចក្រ និងយានយន្ត ដែលមានបំពាក់ឧបករណ៍កាត់បន្ថយសំឡេង ឬមានការបញ្ចេញសំឡេងគោរពតាមស្តង់ដារកំណត់
- ពិនិត្យតាមដានកម្រិតនៃការបញ្ចេញសំឡេងរំខានពីគ្រឿងចក្រ និងយាន្តយន្ត ព្រមទាំងធ្វើការជួសជុលគ្រឿងចក្រ ឬយានយន្តណាដែលបញ្ចេញសំឡេង លើសកម្រិតស្តង់ដារកំណត់
- ចូលរួមឧបត្ថម្ភគាំទ្រសម្រាប់ការអភិរក្សព្រៃគុបក្នុងស្រុក ការគ្រប់គ្រងសហគមន៍ព្រៃឈើកុកព្រៅ ការអភិរក្សចំការពូជឈើ ការដាក់បញ្ចូលបន្ថែមនូវធនធានព្រៃឈើដែលនៅសេសសល់ជាដីអភិរក្ស ឬសហគមន៍ព្រៃឈើ ការការពារព្រៃទ្រនាប់អូរ ជាដើម
- ចូលរួមដាំ និងស្តារឡើងវិញ នូវប្រភេទឈើក្នុងស្រុកឬមានដោយកម្រ នៅតាមព្រៃទ្រនាប់អូរដែលបានកាត់ចេញ ព្រៃសហគមន៍ ដងផ្លូវ និងតំបន់សាធារណៈផ្សេងទៀត
- ចូលរួមឧបត្ថម្ភគាំទ្រដល់សកម្មភាពរបស់ស្ថានីយ៍បណ្តុះកូនឈើ របស់ផ្នែករដ្ឋបាលព្រៃឈើរ៉ុនសែ ដើម្បីផ្គត់ផ្គង់កូនឈើសម្រាប់ការដាំដុះក្នុងតំបន់
- ធ្វើការឈូសឆាយ សាងសង់ និងដាំដុះ ជាដំណាក់ៗតាមអនុតំបន់ដូចមានក្នុងផែនការមេរបស់គម្រោង ដើម្បីទុកផ្លូវ និងពេលវេលាឲ្យសត្វព្រៃធ្វើការភៀសខ្លួនទៅកាន់តំបន់ផ្សេងៗ
- ពន្លឿនការដាំដំណាំឡើងវិញនៅក្នុងអនុតំបន់របស់គម្រោងឱ្យបានឆាប់រហ័ស ដើម្បីបង្កើតជាជម្រកថ្មីដល់ប្រភេទសត្វព្រៃមួយចំនួន
- ចូលរួមធ្វើការដាំដើមឈើនៅក្នុងព្រៃសហគមន៍ និងព្រៃឈើរក្សាទុក ដើម្បីជាជម្រកនៃប្រភេទសត្វព្រៃ
- កាត់បន្ថយឲ្យអស់លទ្ធភាពនូវការរំខានដោយសំឡេង-រំញ័រ តាមរយៈការប្រើប្រាស់គ្រឿងចក្រ ឬយានយន្តដែលបញ្ចេញសំឡេង-រំញ័រតិច
- អប់រំ និងហាមឃាត់បុគ្គលិក-កម្មករគម្រោង និងបុគ្គលិក-កម្មកររបស់អ្នកម៉ៅការ (ឈូសឆាយ សាងសង់ និងដាំដុះ) មិនឱ្យធ្វើការបរបាញ់ប្រភេទសត្វព្រៃដែលមាននៅក្នុងតំបន់ដោយខុសច្បាប់ ព្រមទាំងធ្វើការផ្សព្វផ្សាយឱ្យពួកគាត់បានដឹងពីអត្ថប្រយោជន៍សត្វព្រៃ
- ដាក់បំរាមមិនឲ្យបុគ្គលិក-កម្មករ បរិភោគសាច់សត្វព្រៃ និងមិនអនុញ្ញាឱ្យទិញសាច់ ឬសត្វព្រៃពីអ្នកលក់ ឬពីប្រជាពលរដ្ឋមូលដ្ឋាន



Draft

- លើកទឹកចិត្តដល់បុគ្គលិក-កម្មករ (ផ្តល់ជារង្វាន់) ឱ្យចូលរួមរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ចក្នុងករណីសង្កេតឃើញមានការលួចបរបាញ់ខុសច្បាប់
- ធ្វើការដាក់ពិន័យតឹងរឹង (ឧ. ព្រមាន ឬបញ្ឈប់ពីការងារ) ក្នុងករណីបុគ្គលិក-កម្មករណាមួយប្រព្រឹត្តបទល្មើសនឹងបំរាមពាក់ព័ន្ធនឹងការបរបាញ់ និងបរិភោគសត្វព្រៃ
- សហការជាមួយស្ថាប័នមានសមត្ថកិច្ច ដើម្បីជៀសវាងការរំខានដល់កន្លែង ឬតំបន់ដែលជាជម្រកមច្ឆជាតិសំខាន់ៗ ក្នុងករណីដែលក្រុមហ៊ុនស្តារប្រព័ន្ធផ្លូវទឹកទោះជាក្នុងគោលបំណងអ្វីក៏ដោយ
- ធ្វើការលែងកូនមច្ឆជាតិនៅតាមប្រព័ន្ធផ្លូវទឹក ដែលមាននៅក្នុង និងក្បែរទីតាំងតំបន់គម្រោងក្នុងរយៈពេល១ឆ្នាំម្តង
- ដាក់ពិន័យ ចំពោះបុគ្គលិក-កម្មករ ដែលបានលួចនេសាទត្រីខុសច្បាប់ និងលើកទឹកចិត្តដល់បុគ្គលិក-កម្មករឱ្យចូលរួមរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ច ក្នុងករណីសង្កេតឃើញមានសកម្មភាពលួចធ្វើការនេសាទត្រីខុសច្បាប់
- មិនឈូសឆាយដីហួសពីព្រំដីដែលទទួលបានពីរដ្ឋាភិបាល
- សហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាដីធ្លីដែលប្រជាជននៅតែអះអាងថាមិនទាន់បានដោះស្រាយ (រួមមាន៖ ដីសហគមន៍ជនជាតិដើមភាគតិចគ្រឹង និងដី ចម្ការវិលជុំ និងដីបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ ដូចបង្ហាញក្នុងតារាង៧.១)
- រៀបចំ និងអនុវត្ត គម្រោងកសិកម្មបែបកិច្ចសន្យា (គាំទ្របច្ចេកទេសដាំដុះ និងទិញយក កសិផល) ចំពោះមុខដំណាំដែលជាមុខព្រួញនៃគម្រោងវិនិយោគនេះ (ដូចជា កាកាវ ដូង អាកាស្យាសេណេហ្គាល់ សណ្តែកសៀង)
- សហការជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបណ្តុះបណ្តាលចំណេះដឹង ជំនាញចិញ្ចឹមសត្វ និងជំនាញឯកទេសផ្សេងទៀតដល់ប្រជាជនមូលដ្ឋាន
- ផ្តល់ឱកាសសមស្របដល់ប្រជាជនអាចបម្រើការងារនៅក្នុងតំបន់គម្រោង ដោយមានប្រាក់បៀវត្សសមរម្យអាចទទួលយកបានពីសំណាក់ពួកគាត់ ដើម្បីអាចចូលរួមស្តារស្ថានភាពជីវភាពឡើងវិញ
- ផ្តល់លទ្ធភាពដល់ប្រជាជនមូលដ្ឋានក្នុងការចូលរក និងប្រមូលអនុផលព្រៃឈើជាលក្ខណៈប្រពៃណី (ដូចបានចែងនៅក្នុងច្បាប់ស្តីពីព្រៃឈើ) ក្នុងព្រៃរក្សាទុក ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់
- មិនធ្វើទំនប់ស្ទាក់ទឹក ឬឈូសឆាយលុបប្រភពទឹកដែលធ្វើឲ្យប៉ះពាល់ដល់បរិមាណជាទឹក និងការប្រើប្រាស់ទឹករបស់ប្រជាជននៅខ្សែទឹកខាងក្រោម
- ជីកស្រះស្តុកទឹកភ្លៀងសម្រាប់ប្រើប្រាស់ ដើម្បីកាត់បន្ថយសម្ពាធលើការប្រើប្រាស់ទឹកពីប្រព័ន្ធផ្លូវទឹកធម្មជាតិ និងទឹកក្រោម
- ធ្វើការដាំដើមឈើនៅតាមដងអូរដែលគ្មានគម្របព្រៃ ឬមានព្រៃរចរឹលឲ្យបានចម្ងាយពី ១០០ ម៉ែត្រទៅ ១៥០ម៉ែត្រ ដើម្បីបង្កើតជារនាំងចម្រោះទឹកធម្មជាតិ
- គាំទ្រការបង្កើនសួនបន្លែធម្មជាតិ និងកសិដ្ឋានចិញ្ចឹមសត្វប្រចាំគ្រួសារ ដើម្បីកាត់បន្ថយការទិញចំណីអាហារពីទីផ្សារ
- គាំទ្រដល់កម្មវិធីអប់រំ ផ្សព្វផ្សាយអំពីសុខភាព អនាម័យក្នុងការរស់នៅ (ជាពិសេសរៀបចំ និងចែកចាយនូវផ្ទាំងផ្សព្វផ្សាយអំពីបំរាមក្នុងការប្រើប្រាស់ធុងថ្នាំគីមីកសិកម្មសម្រាប់ស្តុកម្ហូបអាហារ និងទឹកបរិភោគ)
- គាំទ្រដល់អាជ្ញាធរមូលដ្ឋានក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព

Draft

- គាំទ្រដល់ដំណើរការមណ្ឌលសុខភាពដែលមានស្រាប់ក្នុងតំបន់ (មណ្ឌលសុខភាពភ្នំកុក និងមណ្ឌលសុខភាពរ៉ុនសែ)
- គាំទ្រដល់ដំណើរការបង្កើតមណ្ឌលសុខភាពក្នុងភូមិតាឡាត ឬភូមិរំពាត់ នៃឃុំតាឡាត (ភូមិទាំងពីរនេះនៅដាច់ស្រយាលពីទីប្រជុំឃុំ និងស្ថិតនៅក្រោមខ្សែទឹកនៃទីតាំងគម្រោង)
- ផ្តល់លទ្ធភាពដល់ប្រជាជនមូលដ្ឋានក្នុងការអនុវត្តនូវប្រពៃណីនៃការប្រមូលអនុផលព្រៃឈើ ដោយមិនហាមឃាត់ពួកគាត់មិនឱ្យចូលព្រៃរក្សាទុក
- ផ្សព្វផ្សាយអំពីទំនៀមទម្លាប់ ប្រពៃណី (ជាពិសេសតំណមនានា) របស់ជនជាតិដើមភាគតិច ដល់បុគ្គលិក-កម្មករ និងដាក់បំរាមមិនឱ្យបុគ្គលិក-កម្មករធ្វើសកម្មភាពអ្វីដែលអាចប៉ះពាល់ដល់ទំនៀមទម្លាប់ ប្រពៃណីទាំងនោះ
- សហការជាមួយអាជ្ញាធរ និងសហគមន៍មូលដ្ឋាន ដើម្បីរៀបចំពិធីបុណ្យតាមបែបប្រពៃណីរបស់ជនជាតិដើមភាគតិច
- ណែនាំឱ្យអ្នកបើកបរគោរពច្បាប់ចរាចរណ៍ និងពិន័យធ្ងន់ធ្ងរ ប្រសិនបើមិនគោរពច្បាប់ ហើយការមិនគោរពច្បាប់ធ្វើឱ្យមានគ្រោះថ្នាក់ចរាចរណ៍
- ធ្វើការផ្សព្វផ្សាយជាចំណេះដឹងបន្ថែមដល់ប្រជាជនមូលដ្ឋាន ទាក់ទងនឹងសុវត្ថិភាពចរាចរណ៍
- ជ្រើសរើសបុគ្គលិក-កម្មករក្នុងមូលដ្ឋាន ឲ្យអស់លទ្ធភាពមុននឹងសម្រេចជ្រើសរើសអ្នកតំបន់ផ្សេង
- បញ្ចូលក្នុងបទបញ្ជាផ្ទៃក្នុងនូវបំរាមពាក់ព័ន្ធនឹងគ្រឿងញៀន អំពើហិង្សាជាមួយប្រជាជនមូលដ្ឋាន និងករណីចោរកម្ម ពេស្យាចារ រំលោភសេពសន្ថវៈ
- សហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការត្រួតពិនិត្យ និងតាមដានបុគ្គលិក-កម្មករ ដែលជាជនចំណូលថ្មី ដើម្បីធានាថាពួកគេមិនពាក់ព័ន្ធនឹងគ្រឿងញៀន បង្កហិង្សាជាមួយប្រជាជនមូលដ្ឋាន និងបង្កឲ្យមានករណីចោរកម្ម ពេស្យាចារ សេពសន្ថវៈ
- មានផែនការត្រួតពិនិត្យសុខភាពបុគ្គលិក-កម្មករជាប្រចាំ និងបណ្តុះបណ្តាលពួកគាត់អំពីបញ្ហានៃជម្ងឺឆ្លង ការបង្ការជម្ងឺឆ្លងនានា និងផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន ។ល។
- គាំទ្រដល់បេសកកម្មរបស់ប្រជាការពារឃុំ ដើម្បីពង្រឹងសុវត្ថិភាព និងសន្តិសុខមូលដ្ឋាន
- ផ្តល់លំនៅដ្ឋានសម្រាប់ស្នាក់នៅ ក្នុងកម្រិតស្តង់ដារកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ស្របតាមច្បាប់ស្តីពីការងារ
- ផ្តល់នូវការបណ្តុះបណ្តាលអំពីការទប់ស្កាត់ការកើតជម្ងឺគ្រុនចាញ់ និងផ្តល់មុងជ្រលក់ថ្នាំដល់បុគ្គលិក-កម្មករ
- ផ្តល់ការបណ្តុះបណ្តាលអំពីបច្ចេកទេសបញ្ហាគ្រឿងចក្រ និងវិធានសុវត្ថិភាពក្នុងការការពារគ្រោះថ្នាក់ក្នុងពេលបំពេញការងារ និងការពារផលប៉ះពាល់ពីថ្នាំគីមីកសិកម្ម
- ផ្តល់ឱ្យបុគ្គលិក-កម្មករនូវឧបករណ៍សុវត្ថិភាពស្របតាមបទដ្ឋានកំណត់ (ដូចជា ស្បែកជើងកវែង ម៉ាស់ការពារមុខ ស្រោមដៃ ខោអាវសម្រាប់ស្លៀកពាក់ពេលបាញ់ថ្នាំ)
- អនុវត្តកម្មវិធីត្រួតពិនិត្យ និងថែទាំសុខភាពបុគ្គលិក-កម្មករ ជាពិសេសពាក់ព័ន្ធនឹងជម្ងឺគ្រុនចាញ់ និងជម្ងឺដែលបង្កឡើងដោយសារផលប៉ះពាល់នៃថ្នាំគីមីកសិកម្ម
- រៀបចំឱ្យមានស្លាកសញ្ញាបង្ហាញ និងណែនាំនៅទីតាំងស្តុកថ្នាំពុលកសិកម្ម អំពីគ្រោះថ្នាក់ដែលអាចបណ្តាលមកពីថ្នាំពុលកសិកម្ម និងវិធីសាស្ត្រណែនាំអំពីការលាយថ្នាំ

Draft

- មិនអនុញ្ញាតឲ្យបុគ្គលិក-កម្មករដែលគ្មានភារកិច្ច ឬដែលមិនពាក់ឧបករណ៍ការពារ ចូលទីតាំងស្តុកថ្នាំគីមីកសិកម្ម និងជីកសិកម្ម
- រៀបចំទីតាំងស្តុកថ្នាំគីមីកសិកម្ម និងជីកសិកម្ម ទៅតាមលក្ខណៈបច្ចេកទេស ដោយការពារមិនឲ្យប៉ះពាល់ទឹក លេចជ្រាបចូលក្នុងដី ហុយតាមខ្យល់ ឬត្រូវកំដៅ និងត្រូវមានឧបករណ៍ការពារអគ្គិភ័យ និងខ្យល់ចេញចូលល្អ
- លាយតាមស្តង់ដារបច្ចេកទេសនូវថ្នាំពុលកសិកម្ម តាមការណែនាំនៅលើសំបកថ្នាំ នៅទីតាំងរួមមួយក្បែរទីតាំងស្តុកថ្នាំ ដែលធានានូវសុវត្ថិភាពមិនប៉ះពាល់ដល់បរិស្ថាន និងសុខភាពមនុស្ស មុនចែកចាយបន្តឲ្យកម្មករប្រើប្រាស់
- ប្រមូលមកវិញនូវធុងបាញ់ថ្នាំរបស់កម្មករ ដើម្បីរក្សាទុកនៅតាមទីតាំងរួម ដោយមិនអនុញ្ញាតឲ្យកម្មករយកទៅរក្សាទុកតាមផ្ទះរបស់ខ្លួន ដែលអាចធ្វើឲ្យប៉ះពាល់ដល់សុខភាពសមាជិកគ្រួសារ និងខ្លួនឯង
- មានបន្ទប់ព្យាបាលបឋមសម្រាប់ជួយសង្គ្រោះបុគ្គលិក-កម្មករ នៅពេលមានកើតជម្ងឺ ឬមានគ្រោះថ្នាក់ក្នុងពេលបំពេញការងារ
- ផ្តល់ការធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់ការងារដល់គ្រប់បុគ្គលិក-កម្មករ ក្រោមរូបភាពបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)។

**គ. ដំណាក់កាលបញ្ចប់គម្រោង**

- ធ្វើផ្ទេរទីតាំងគម្រោងទៅរដ្ឋាភិបាលជាគ្រប់គ្រងវិញស្របតាមនីតិវិធីដែលមានជាធរមាន (ក្នុងករណីរដ្ឋាភិបាលមិនអនុញ្ញាតឱ្យវិនិយោគបន្ត)
- ធ្វើការផ្សព្វផ្សាយ និងបិទប្រកាសយ៉ាងតិច ០៣ខែ មុនបិទគម្រោង ដើម្បីឲ្យបុគ្គលិក-កម្មករបានដឹង និងមានពេលវេលាគ្រប់គ្រាន់សម្រាប់ស្វែងរកការងារថ្មី
- ថវិកាសម្រាប់ពេលបិទគម្រោងជូនបុគ្គលិក-កម្មករ ដោយគោរពតាមច្បាប់ការងារ និងទៅតាមរយៈពេលធ្វើការ និងស្នាដៃការងារ
- ផ្តល់អត្តិភាពការងារជាចម្បងដល់បុគ្គលិក-កម្មករ ចាស់ធ្លាប់បម្រើការងារឲ្យក្រុមហ៊ុន (ក្នុងករណីក្រុមហ៊ុនមានគម្រោងអភិវឌ្ឍន៍ថ្មី)
- រៀបចំផែនការបិទគម្រោង និងស្តារបរិស្ថានឡើងវិញឱ្យបានត្រឹមត្រូវរយៈពេល ០១ឆ្នាំមុនគម្រោងបញ្ចប់
- បម្រុងថវិកាប្រមាណ ៣.០០០ដុល្លារសម្រាប់សម្អាតអនាម័យបរិស្ថានក្នុងទីតាំងគម្រោង មុនពេលបញ្ចប់ការវិនិយោគ។

ជារួម ក្រុមហ៊ុនម្ចាស់គម្រោងត្រូវ៖

- រៀបចំឲ្យមានក្រុមជំនាញ ឬក្រុមបច្ចេកទេស និងអ្នកជំនាញបរិស្ថានដើម្បីអនុវត្តវិធានការកាត់បន្ថយខាងលើ និងរៀបចំរបាយការណ៍ត្រួតពិនិត្យបរិស្ថាន (២ដង/ឆ្នាំ) ជូនក្រសួងបរិស្ថាន
- រៀបចំផែនការសកម្មភាពការងារឲ្យបានច្បាស់លាស់ចំពោះកិច្ចការការពារបរិស្ថាន ដែលក្នុងនោះផែនការសំខាន់ៗមានដូចជា៖ ការដោះស្រាយវិវាទដីធ្លីជាមួយប្រជាជន និងសហគមន៍មូលដ្ឋាន, ការគ្រប់គ្រងការឈូសឆាយ សាងសង់ និងដាំដុះ, ការលើកកម្ពស់សុខមាលភាពបុគ្គលិក-កម្មករ, ការគ្រប់គ្រងសំណល់ និងប្រភពបំពុលផ្សេងៗ, ការគ្រប់គ្រងការប្រើប្រាស់ដី និងថ្នាំគីមីកសិកម្ម,

Draft

ការរួមចំណែកអភិវឌ្ឍន៍មូលដ្ឋាន និងលើកកម្ពស់សុខមាលភាពសង្គម, ការចូលរួមការពារ និងស្តារឡើងវិញនូវធនធានធម្មជាតិ, និងការគ្រប់គ្រងបញ្ហាទូទៅ (ដូចមានលម្អិតក្នុងតារាងខាងក្រោម)

- រៀបចំប្រព័ន្ធការពារសុវត្ថិភាពការងារ ដោយបំពាក់នូវឧបករណ៍ការពារសុខភាព, បង្ការគ្រោះថ្នាក់, និងគ្រឿងចក្រនានាតាមបែបផែនបច្ចេកទេស
- សហការណ៍ជាមួយស្ថាប័នជំនាញដើម្បីត្រួតពិនិត្យមើលទីតាំង-បច្ចេកទេស និងត្រូវទទួលយកនូវការកែប្រែបច្ចេកទេសណាដែលស្ថាប័នជំនាញតម្រូវឲ្យធ្វើការកែប្រែ។

Draft

## ផែនការ១៖ ការដោះស្រាយវិវាទដីធ្លីជាមួយប្រជាជន និងសហគមន៍មូលដ្ឋាន

<u>គោលបំណង១៖</u> ការពារផលប្រយោជន៍របស់ប្រជាជន/សហគមន៍មូលដ្ឋាន និងក្រុមហ៊ុន ព្រមទាំងបង្កើននូវភាពសុខដុមរមណីយកម្មរវាងភាគីទាំងពីរ

| | សកម្មភាព | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា | សម្គាល់ |
|---|---|---|---|---|---|
| ១.១ | ធ្វើការបង្ហាញដល់ប្រជាជន នូវដំណើរការវិនិយោគ តាំងពីដំណាក់កាលស្នើសុំរាជរដ្ឋាភិបាល រហូតដល់ដំណាក់កាលវិនិយោគ និងបញ្ចប់គម្រោង ព្រមទាំងលើកឡើងនូវរាល់វិធានការកាត់បន្ថយ ដើម្បីបញ្ចៀសនូវការប៉ះពាល់អវិជ្ជមាននានា (រួមទាំងការកាត់ចេញនូវផ្ទៃដីពាក់ព័ន្ធនានាដែលបានធ្វើឡើងកន្លងមក) | ប្រធានផ្នែករដ្ឋបាល និងផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរបរិស្ថាន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី អាជ្ញាធរស្រុក ឃុំពាក់ព័ន្ធ | ក្នុងឆ្នាំ២០១៧ | - | បញ្ចប់មុនពេលចាប់ផ្តើមដំណើរការឈូសឆាយ |
| ១.២ | ធ្វើការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ និងប្រជាពលរដ្ឋដែលមានដីធ្លីជាប់ព្រំទីតាំងគម្រោង ដើម្បីផ្តល់ជាព័ត៌មានលម្អិតស្តីពីព្រំប្រទល់គម្រោង | ប្រធានរដ្ឋបាលក្រុមហ៊ុន / មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | ក្នុងឆ្នាំ២០១៧ | - | បញ្ចប់មុនពេលចាប់ផ្តើមដំណើរការឈូសឆាយ |
| ១.៣ | សហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាដីធ្លីដែលប្រជាជននៅតែអះអាងថាមិនទាន់បានដោះស្រាយ (រួមមាន៖ ដីសហគមន៍ជនជាតិដើមភាគតិចគ្រឹង ដីចម្ការវិលជុំ និងដីបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ ដូចបង្ហាញក្នុងជំពូកទី៧ តារាង៧.១) | ប្រធានរដ្ឋបាលក្រុមហ៊ុន / អាជ្ញាធរឃុំ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | ក្នុងឆ្នាំ២០១៧ | - | បញ្ចប់មុនពេលចាប់ផ្តើមដំណើរការឈូសឆាយ |
| ១.៤ | ចុះបោះបង្គោល (ឬជីប្រឡាយ) សម្គាល់ព្រំដី និងបង្ហាញដល់អ្នកឈូសឆាយឲ្យស្គាល់ពីព្រំដី (ដើម្បីជៀសវាងការឈូសឆាយដីហួសពីព្រំដីដែលទទួលបានពីរដ្ឋាភិបាល) | ប្រធានផ្នែករដ្ឋបាល និងផ្នែកឈូសឆាយក្រុមហ៊ុន / អាជ្ញាធរឃុំ | ចាប់ពីឆ្នាំទី១ (ឆ្នាំ២០១៧) ដល់ឆ្នាំទី៦ (ឆ្នាំ២០២៣) | - | មុនអនុញ្ញាតឲ្យចុះធ្វើប្រតិបត្តិការឈូសឆាយ |

Draft

## ផែនការ២៖ ការគ្រប់គ្រងការឈូសឆាយ សាងសង់ និងដាំដុះ

គោលបំណង២៖ កាត់បន្ថយផលប៉ះពាល់បរិស្ថាន ដោយសារការឈូសឆាយ សាងសង់ និងដាំដុះ

| | សកម្មភាព | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា | សម្គាល់ |
|---|---|---|---|---|---|
| ២.១ | ធ្វើការឈូសឆាយ និងរៀបចំដីទៅតាមលក្ខណៈសណ្ឋានដី និងទៅតាមទំហំដូចដែលបានគ្រោងក្នុងផែនការ រួចធ្វើការបង្ហាប់ដីភ្លាម និងសាងសង់ ដោយមិនទុកដីឲ្យនៅទំនេរចោល | ប្រធានផ្នែកឈូសឆាយ និងផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរបរិស្ថានខេត្ត និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | រាល់ពេលឈូសឆាយ | - | រក្សាទុកទីតាំងមានជម្រាលចោត និងអូរ ឬថ្លុកទឹកដែលមានស្រាប់ |
| ២.២ | ធ្វើការរៀបចំដីសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធ ទៅតាមទំហំដីដូចដែលបានគ្រោងក្នុងផែនការមេ ដើម្បីជៀសវាងការបាត់បង់ដីផលិតកម្មដំបូងលើសផែនការ (៣៨៣ហិកតា) | ប្រធានផ្នែកវិស្វកម្ម និងផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរបរិស្ថានខេត្ត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | រាល់ពេលរៀបចំដីសាងសង់ហេដ្ឋារចនាសម្ព័ន្ធ | - | |
| ២.៣ | ធ្វើការឈូសឆាយតែក្នុងរដូវប្រាំង និងជាដំណាក់ៗតាមអនុតំបន់ដូចកំណត់ក្នុងផែនការមេ ព្រមទាំងរៀបចំដាំដំណាំភ្លាមៗក្រោយពីឈូសឆាយរួច | ប្រធានផ្នែកឈូសឆាយ ផ្នែកដាំដុះ និងផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរបរិស្ថានខេត្ត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | រាល់ពេលឈូសឆាយ និងដាំដុះ | - | មិនឲ្យទុកដីទំនេរចោល ដោយគ្មានគម្របរុក្ខជាតិ ឬដំណាំ |
| ២.៤ | កាប់ឆ្ការព្រៃ ឈូសឆាយដី និងរៀបចំថ្នាលដំណាំ ជាដំណាក់កាលនៅត្រង់តំបន់ដែលមានជម្រាលចោត ហើយចាប់ផ្តើមធ្វើពីតំបន់ដែលមានរយៈកម្ពស់ខ្ពស់មុន ដើម្បីជៀសវាងការបាក់ដី | ប្រធានផ្នែកឈូសឆាយ ផ្នែកដាំដុះ និងផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរបរិស្ថានខេត្ត មន្ទីរកសិកម្ម រុក្ខា | រាល់ពេលឈូសឆាយ និងដាំដុះនៅតំបន់ដែលមានជម្រាលចោត | - | |

| | សកម្មភាព | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា | សម្គាល់ |
|---|---|---|---|---|---|
| | | ប្រមាញ់ និងនេសាទខេត្ត | | | |
| ២.៥ | រៀបចំផ្លូវឆ្លងកាត់នានាក្នុងតំបន់គម្រោងឲ្យមានទំហំសមស្រប ដើម្បីធានាប្រសិទ្ធភាព និងសុវត្ថិភាពការងារ សំដៅជៀសវាងការអូសបន្លាយពេលសាងសង់ និងដាំដុះ (ឬទុកដីនៅទំនេរ) ដែលអាចនឹងបង្កឲ្យមានការហូរច្រោះដីកើតឡើង | ប្រធានផ្នែកវិស្វកម្មក្រុមហ៊ុន / មន្ទីរអភិវឌ្ឍន៍ជនបទ | ក្នុងពេលសាងសង់ផ្លូវក្នុងតំបន់គម្រោង (ឆ្នាំ ២០១៧ - ២០២៣) | - | |
| ២.៦ | សាងសង់ស្ពានឆ្លងកាត់ ឬរៀបចំប្រព័ន្ធលូបង្ហូរឱ្យបានត្រឹមត្រូវ ក្នុងករណីសាងសង់ហេដ្ឋរចនាសម្ព័ន្ធឆ្លងកាត់ប្រព័ន្ធផ្លូវទឹក | ប្រធានផ្នែកវិស្វកម្ម / មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរធនធានទឹក និងឧតុនិយម | ក្នុងពេលសាងសង់ផ្លូវក្នុងតំបន់គម្រោង (ឆ្នាំ ២០១៧ - ២០២៣) | - | |
| ២.៧ | សាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅលើប្រភេទដីដែលមានគុណភាពទាប ឱ្យបានច្រើនជាអតិបរិមា | ប្រធានផ្នែកបរិស្ថាន និងផ្នែកវិស្វកម្មក្រុមហ៊ុន / មន្ទីរបរិស្ថាន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | រាល់ពេលឈូសឆាយ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ | - | ផ្លាស់ប្តូរទីតាំងហេដ្ឋារចនាសម្ព័ន្ធពីតំបន់ដីមានជីជាតិ ទៅដីគ្មានជីជាតិ) |
| ២.៨ | រៀបចំទីតាំងចម្ការដំណាំឱ្យមានប្រព័ន្ធបង្ហូរទឹកត្រឹមត្រូវ និងអនុវត្តការភ្ជួររាស់តាមបច្ចេកទេសដែលមានមេត្រីភាពបរិស្ថាន (ឧ. មិនភ្ជួររាស់ជ្រៅពេក ភ្ជួររាស់ជាលក្ខណៈកាំជណ្តើរ ជាពិសេសនៅទីតាំងដែលមានជម្រាលចោត) | ប្រធានផ្នែកដាំដុះ និងផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរបរិស្ថាន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | រាល់ពេលរៀបចំដីដាំដុះ | - | |
| ២.៩ | ដាំដុះបន្ថែមនូវប្រភេទដំណាំបន្ទាប់បន្សំ ដូចជាពោត សណ្តែក ឬពពួកបន្លែបង្ការនានា នៅតាមចន្លោះរង ឬនៅក្នុងចន្លោះពេលសម្អាតថ្នាលបន្ទាប់ពីពេលប្រមូលផលដំណាំចម្បងរួច ធ្វើជាគម្របដីដើម្បីកាត់បន្ថយការហូរច្រោះ និងបាត់បង់ជីជាតិដី | ប្រធានផ្នែកដាំដុះ / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | បន្ទាប់ពីដាំដុះដំណាំចម្បងរួច និងចន្លោះពេលប្រមូលផល និងដាំដុះដំណាំចម្បងថ្មី | - | |

| | សកម្មភាព | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា | សម្គាល់ |
|---|---|---|---|---|---|
| ២.១០ | សហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញមានសមត្ថកិច្ច ដើម្បីវាយតម្លៃ និងផ្តល់អនុសាសន៍បច្ចេកទេស ក្នុងករណីដែលក្រុមហ៊ុនធ្វើទំនប់ស្ទាក់ទឹក ស្តាប្រព័ន្ធផ្លូវទឹក ឬធ្វើការខួង ឬបូមយកទឹកពីក្រោមដី មកប្រើប្រាស់ ឬក្នុងគោលបំណងអ្វីក៏ដោយ | ប្រធានផ្នែកបរិស្ថាន និងផ្នែកសាងសង់ក្រុមហ៊ុន / មន្ទីរធនធានទឹក និងឧតុនិយម | មុនពេលប្រតិបត្តិការងារនេះ | | បច្ចុប្បន្នមិនទាន់មានផែនការ |
| ២.១១ | ជីកស្រះស្តុកទឹកភ្លៀងសម្រាប់ប្រើប្រាស់ ដើម្បីកាត់បន្ថយសម្ពាធលើការប្រើប្រាស់ទឹកពីប្រព័ន្ធផ្លូវទឹកធម្មជាតិ និងទឹកក្រោមដី | ប្រធានផ្នែកសាងសង់ក្រុមហ៊ុន / មន្ទីរធនធានទឹក និងឧតុនិយម | នៅពេលចាំបាច់ | - | បច្ចុប្បន្នមិនទាន់មានផែនការ |

## ផែនការ៣៖ ការលើកកម្ពស់សុខមាលភាពបុគ្គលិក-កម្មករ

<u>គោលបំណង៣៖</u> ជំរុញឱ្យមានការចូលរួមក្នុងកិច្ចគាំពារបរិស្ថាន អនាម័យ សុខភាព និងសុវត្ថិភាពផ្ទាល់ខ្លួន ព្រមទាំងលើកកម្ពស់សុខុមាលភាពរបស់ពួកគាត់

| | សកម្មភាព | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា (ដុល្លារ/ឆ្នាំ) | សម្គាល់ |
|---|---|---|---|---|---|
| ៣.១ | រៀបចំវគ្គអប់រំ ណែនាំ អំពីបច្ចេកទេសក្នុងការប្រើប្រាស់គ្រឿងចក្រ ការថែទាំ និងវិធានការសុវត្ថិភាព (រួមទាំងច្បាប់ចរាចរណ៍) | ប្រធានផ្នែកវិស្វកម្ម និងផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ឆ្នាំម្តងជាវគ្គសាមញ្ញ (វគ្គវិសាមញ្ញត្រូវធ្វើឡើងសម្រាប់បុគ្គលិកថ្មីដែលមិនបានឆ្លងកាត់វគ្គសាមញ្ញ) | 8000 | រាល់អ្នកប្រើប្រាស់គ្រឿងចក្រ ត្រូវតែឆ្លងកាត់វគ្គអប់រំ ណែនាំនេះ មុននឹងអនុញ្ញាតឲ្យចូលបំពេញការងារ |
| ៣.២ | រៀបចំវគ្គអប់រំ ណែនាំ អំពីបច្ចេកទេសក្នុងការគ្រប់គ្រងជី និងថ្នាំគីមីកសិកម្ម (ដឹកជញ្ជូន ទុកដាក់ ថែទាំ លាយ និងប្រើប្រាស់) និងវិធានការសុវត្ថិភាព | ប្រធានផ្នែកបរិស្ថាន និងផ្នែកដាំដុះក្រុមហ៊ុន / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរការងារ និងបណ្តុះបណ្តាល | ១ឆ្នាំម្តងជាវគ្គសាមញ្ញ (វគ្គវិសាមញ្ញត្រូវធ្វើឡើងសម្រាប់បុគ្គលិកថ្មីដែលមិនបានឆ្លងកាត់វគ្គសាមញ្ញ) | 8000 | រាល់បុគ្គលិក-កម្មករដែលមានភារៈកិច្ចពាក់ព័ន្ធនឹងការគ្រប់គ្រង និងប្រើប្រាស់ជី និងថ្នាំគីមីកសិកម្ម ត្រូវតែឆ្លងកាត់វគ្គអប់រំណែនាំនេះ មុននឹងអនុញ្ញាតឲ្យ |

Draft

| សកម្មភាព | | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា (ដុល្លារ/ឆ្នាំ) | សម្គាល់ |
|---|---|---|---|---|---|
| | | | | | ចូលបំពេញការងារ |
| ៣.៣ | ផ្តល់ឱ្យបុគ្គលិក-កម្មករនូវឧបករណ៍សុវត្ថិភាពស្របតាមបទដ្ឋានកំណត់ (ដូចជា មុងជ្រលក់ថ្នាំ ស្បែកជើងកវែង ម៉ាស់ការពារមុខ ស្រោមដៃ ខោអាវសម្រាប់ស្លៀកពាក់ពេលបាញ់ថ្នាំ) | ប្រធានផ្នែករដ្ឋបាលក្រុមហ៊ុន / មន្ទីរការងារ និងបណ្តុះបណ្តាល | រាល់ពេលមានតម្រូវការ | - | |
| ៣.៤ | រៀបចំវគ្គអប់រំ ណែនាំ អំពីសុខភាព អនាម័យក្នុងការរស់នៅ (ឧ. ការការពារជម្ងឺគ្រុនចាញ់ ជម្ងឺឆ្លង អនាម័យក្នុងការបរិភោគ បន្ទោរបង់ ...) និងសារៈប្រយោជន៍នៃកិច្ចការពារបរិស្ថាន និងជីវៈចម្រុះ | ផ្នែករដ្ឋបាលក្រុមហ៊ុន / មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ឆ្នាំម្តងជាវគ្គសាមញ្ញ (វគ្គវិសាមញ្ញត្រូវធ្វើឡើងសម្រាប់បុគ្គលិកថ្មីដែលមិនបានឆ្លងកាត់វគ្គសាមញ្ញ) | 8000 | |
| ៣.៥ | ផ្តល់នូវបរិក្ខាសង្គ្រោះបឋម និងអប់រំណែនាំអំពីវិធីសាស្ត្រសង្គ្រោះបឋមដល់បុគ្គលិក-កម្មករ មុនពេលចាប់ផ្តើមបំពេញការងារ | ផ្នែករដ្ឋបាលក្រុមហ៊ុន / មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ឆ្នាំម្តងជាវគ្គសាមញ្ញ (វគ្គវិសាមញ្ញត្រូវធ្វើឡើងសម្រាប់បុគ្គលិកថ្មីដែលមិនបានឆ្លងកាត់វគ្គសាមញ្ញ) | - | |
| ៣.៦ | សហការជាមួយមណ្ឌលសុខភាពក្នុងតំបន់ ដើម្បីព្យាបាលសុខភាពបុគ្គលិក-កម្មករនៅពេលមានជម្ងឺក្នុងដំណាក់កាលសាងសង់ | ផ្នែករដ្ឋបាលក្រុមហ៊ុន / មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | រាល់ពេលមានជម្ងឺ ឬគ្រោះថ្នាក់ការងារ | - | ក្នុងពេលបន្ទប់ព្យាបាលបឋមមិនទាន់បានសាងសង់រួច និងដាក់ឲ្យដំណើរការ |
| ៣.៧ | ដំណើរការបន្ទប់ព្យាបាលបឋមសម្រាប់តាមដានសុខភាព និងជួយសង្គ្រោះបុគ្គលិក-កម្មករ នៅពេលកើតជម្ងឺ ឬមានគ្រោះថ្នាក់ក្នុងពេលបំពេញការងារ | ផ្នែករដ្ឋបាលក្រុមហ៊ុន / មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ឆ្នាំម្តង និងរៀងរាល់ពេលមានជម្ងឺ ឬគ្រោះថ្នាក់ការងារ | - | |
| ៣.៨ | ផ្តល់ការធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់ការងារដល់គ្រប់បុគ្គលិក-កម្មករ ក្រោមរូបភាពបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) | ផ្នែករដ្ឋបាលក្រុមហ៊ុន / មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ឆ្នាំម្តង | - | |

Draft

| | សកម្មភាព | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា (ដុល្លារ/ឆ្នាំ) | សម្គាល់ |
|---|---|---|---|---|---|
| ៣.៩ | សាងសង់ និងរៀបចំលំនៅដ្ឋានសម្រាប់ការស្នាក់នៅរបស់បុគ្គលិក-កម្មករ ទៅតាមស្តង់ដារកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច និងស្របតាមច្បាប់ស្តីពីការងារ | ផ្នែកសាងសង់ និងផ្នែករដ្ឋបាលក្រុមហ៊ុន / មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ក្នុងពេលសាងសង់កន្លែងស្នាក់នៅ | - | |
| ៣.១០ | សាងសង់មណ្ឌលសុខភាពក្នុងតំបន់គម្រោងទៅតាមស្តង់ដារកំណត់ដោយមន្ទីរជំនាញ ដើម្បីព្យាបាលសុខភាពបុគ្គលិក-កម្មករនៅពេលមានជម្ងឺ ឬសម្រាលកូន | ផ្នែកសាងសង់ និងផ្នែករដ្ឋបាលក្រុមហ៊ុន / មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ/ មន្ទីរសុខាភិបាល | ចាប់ពីឆ្នាំ២០២២ | - | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរសុខាភិបាលតម្រូវឲ្យក្រុមហ៊ុនមានមណ្ឌលសុខភាពសម្រាប់បុគ្គលិក-កម្មករ នៅពេលគម្រោងមានបុគ្គលិក-កម្មករចាប់ពី២០០០នាក់ឡើងទៅ |

## ផែនការ៤៖ ការគ្រប់គ្រងសំណល់ និងប្រភពបំពុលផ្សេងៗ

<u>គោលបំណង៤៖</u> គ្រប់គ្រងសំណល់រឹង (រួមទាំងកំទេចកំទីមែក និងស្លឹករុក្ខជាតិ) សំណល់រាវ សំណល់ប្រេង និងសំណល់គ្រោះថ្នាក់នានា ដែលជាប្រភពបំពុលបរិស្ថាន ឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងបទដ្ឋានគតិយុត្តដែលមានជាធរមាន

| | សកម្មភាព | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា (ដុល្លារ/ឆ្នាំ) | សម្គាល់ |
|---|---|---|---|---|---|
| ៤.១ | រៀបចំវគ្គអប់រំ ណែនាំ អំពីការគ្រប់គ្រងសំណល់គ្រប់ប្រភេទ (គ្រោះថ្នាក់ រឹង រាវ ប្រេង) ដល់បុគ្គលិក-កម្មករ | ប្រធានផ្នែកបរិស្ថាន / មន្ទីរបរិស្ថានខេត្ត | ១ឆ្នាំម្តងជាវគ្គសាមញ្ញ (វគ្គវិសាមញ្ញត្រូវធ្វើឡើងសម្រាប់បុគ្គលិកថ្មីដែលមិនបានឆ្លងកាត់វគ្គសាមញ្ញ) | 8000 | |



Draft

| | សកម្មភាព | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា (ដុល្លារ/ឆ្នាំ) | សម្គាល់ |
|---|---|---|---|---|---|
| ៤.២ | ប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវកំទេចកំទីមែក ស្លឹករុក្ខជាតិដែលបានកាប់ឆ្ការ ជាគម្របដីដើម្បីកាត់បន្ថយការហូរច្រោះនិងហែ្វត ផ្តល់ជីជាតិដល់ដី និងការពារការចាក់លប់ផ្លូវទឹក | ប្រធានផ្នែកដាំដុះ / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | - | ជៀសវាងការដុតសំណល់កំទេចកំទីមែក ឬស្លឹករុក្ខជាតិដែលបានកាប់ឆ្ការ |
| ៤.៣ | រៀបចំឲ្យមានធុងសំរាម (សំណល់គ្រោះថ្នាក់ សំណល់ប្រើប្រាស់ឡើងវិញបាន សំណល់កែច្នៃឡើងវិញបាន និងសំណល់ទូទៅ) នៅតាមកន្លែងស្នាក់នៅរបស់បុគ្គលិក-កម្មករ ការដ្ឋាន និងថ្នាលពូជ | ប្រធានផ្នែកបរិស្ថាន / មន្ទីរបរិស្ថាន | ចាប់ពីពេលចាប់ផ្តើមដំណើរការគម្រោងតទៅ | 2160 | ត្រួតពិនិត្យ និងផ្លាស់ប្តូរធុងសំរាមថ្មី នៅពេលបាត់បង់ ឬខូចខាត |
| ៤.៤ | ប្រមូល និងដឹកជញ្ជូនទៅបោះចោលនៅទីលានដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ឬទៅគ្រប់គ្រងបន្ត (សំណល់គ្រោះថ្នាក់) | ប្រធានផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរបរិស្ថាន និងអាជ្ញាធរស្រុក ខេត្ត | ១សប្តាហ៍ម្តង ឬនៅពេលដែលធុងសំរាមពេញ | - | |
| ៤.៥ | ធ្វើការប្តូរប្រេង ចាក់ប្រេង និងលាងយានយន្តគ្រប់ប្រភេទ នៅទីតាំងមួយកំណត់ ដែលបានរៀបចំតាមលក្ខណៈបច្ចេកទេស ដើម្បីជៀសវាងការហៀរ ឬជ្រាបប្រេងចូលក្នុងដី ឬប្រព័ន្ធទឹក | ប្រធានផ្នែកវិស្វកម្មក្រុមហ៊ុន / មន្ទីរបរិស្ថាន | រាល់ពេលបំពេញការងារប្តូរប្រេង ចាក់ប្រេង និងលាងយានយន្ត | - | ត្រូវមានទីតាំងថែទាំយានយន្តដែលមានស្តង់ដារច្បាស់លាស់ |
| ៤.៦ | ប្រមូលប្រេងម៉ាស៊ីនចាស់ស្តុកទុក ដើម្បីលក់ចេញទៅទីផ្សារដែលមានតម្រូវការ | ប្រធានផ្នែកវិស្វកម្មក្រុមហ៊ុន / មន្ទីរបរិស្ថាន | រាល់ពេលប្តូរប្រេង | - | |
| ៤.៧ | រៀបចំបង្គន់អនាម័យមានបច្ចេកទេស ឲ្យបានគ្រប់ចំនួនសម្រាប់ការប្រើប្រាស់របស់បុគ្គលិក-កម្មករ | ប្រធានផ្នែកវិស្វកម្មក្រុមហ៊ុន / មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ក្នុងពេលសាងសង់ | - | |
| ៤.៨ | រៀបចំឲ្យមានអាងស្តុកសំណល់រាវចេញពីផ្ទះបាយរបស់បុគ្គលិក-កម្មករ ដើម្បីជៀសវាងការបង្ហូរចូលផ្ទាល់ទៅក្នុងប្រភពទឹក | ប្រធានផ្នែកវិស្វកម្មក្រុមហ៊ុន / មន្ទីរបរិស្ថាន | ក្នុងពេលសាងសង់ | - | |

Draft

| សកម្មភាព | | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា (ដុល្លារ/ឆ្នាំ) | សម្គាល់ |
|---|---|---|---|---|---|
| ៤.៩ | ប្រើប្រាស់ គ្រប់គ្រង និងថែទាំគ្រឿងចក្រ យាន្តជំនិះឱ្យបានល្អ និងទៀងទាត់ (ឧ. ប្ដូរប្រេងរំអិល បំពាក់តម្រងចម្រោះឧស្ម័នពុល ស៊ីម៉ាំងកាត់បន្ថយសំឡេង) ដើម្បីធានាថាកម្រិតនៃការបញ្ចេញឧស្ម័នបំពុលខ្យល់ និងរំខានដោយសំឡេង គោរពតាមស្តង់ដារកំណត់ | ប្រធានផ្នែកវិស្វកម្មក្រុមហ៊ុន / មន្ទីរបរិស្ថាន | រាល់ពេលបញ្ជាទិញ ឬជួល និងថែទាំរៀងរាល់៣ខែម្តង | - | |
| ៤.១០ | ធ្វើការជួសជុល ឬផ្លាស់ប្តូរថ្មីនូវគ្រឿងចក្រ ឬយានយន្តណាដែលបញ្ចេញឧស្ម័នបំពុលខ្យល់ និងសំឡេងរំខាន លើសកម្រិតស្តង់ដារ | ប្រធានផ្នែកវិស្វកម្មក្រុមហ៊ុន / មន្ទីរបរិស្ថាន | រាល់ពេលចាំបាច់ | - | |

## ផែនការ៥៖ ការគ្រប់គ្រងការប្រើប្រាស់ជី និងថ្នាំគីមីកសិកម្ម

<u>គោលបំណង៥៖</u> កាត់បន្ថយផលប៉ះពាល់សុខភាពមនុស្ស និងបរិស្ថាននៃជី និងថ្នាំគីមីកសិកម្ម ដែលក្រុមហ៊ុនប្រើប្រាស់

| សកម្មភាព | | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា | សម្គាល់ |
|---|---|---|---|---|---|
| ៥.១ | បញ្ជាទិញសម្រាប់ប្រើប្រាស់ តែជីគីមីកសិកម្ម ថ្នាំសម្លាប់សត្វល្អិត ថ្នាំកំចាត់ស្មៅចង្រៃ ដែលមានចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធានផ្នែករដ្ឋបាល / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | រាល់ពេលបញ្ជាទិញ | - | |
| ៥.២ | រៀបចំផែនការប្រើប្រាស់ជីឱ្យបានច្បាស់លាស់ និងអនុវត្តតាមផែនការនេះឲ្យបានខ្ជាប់ខ្ជួន ដើម្បីជៀសវាងការប្រើប្រាស់ជីគីមីលើសកម្រិតដែលបណ្តាលឲ្យខូចគុណភាពដី | ប្រធានផ្នែកដាំដុះ / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្នុងឆ្នាំ២០១៧ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ | - | |
| ៥.៣ | ជៀសវាងការដាក់ជី ឬបាញ់ថ្នាំសម្លាប់សត្វល្អិត និងស្មៅ មុនពេលដែលទំនងជាមានភ្លៀងធ្លាក់ ដើម្បីកាត់បន្ថយការហូរនាំសារធាតុទាំងនេះចូលទៅក្នុងប្រភពទឹក | ប្រធានផ្នែកដាំដុះ / មន្ទីរបរិស្ថាន | រៀងរាល់ពេលរៀបចំផែនការដាក់ជី និងបាញ់ថ្នាំ | | |



Draft

| | សកម្មភាព | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា | សម្គាល់ |
|---|---|---|---|---|---|
| ៥.៤ | ជៀសវាងការបាញ់ថ្នាំសម្លាប់សត្វល្អិត និងស្មៅ នៅក្បែរមាត់ទឹកអូរ ឬទន្លេ ដោយប្រើប្រាស់ម៉ាស៊ីនកាត់ស្មៅជំនួស ដើម្បីកាត់បន្ថយការហូរនាំសារជាតុពុលចូលទៅក្នុងប្រភពទឹក | ប្រធានផ្នែកដាំដុះ / មន្ទីរបរិស្ថាន | រៀងរាល់ពេលរៀបចំផែនការបាញ់ថ្នាំ | | |
| ៥.៥ | រៀបចំ និងអនុវត្តផែនការត្រៀមដើម្បីទប់ស្កាត់កំណើនលើសលប់នៃចំនួនសត្វល្អិត (outbreak) សំដៅកាត់បន្ថយការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត | ប្រធានផ្នែកដាំដុះ និងផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្នុងឆ្នាំ២០១៧ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ | - | |
| ៥.៦ | រៀបចំទីតាំងស្តុកថ្នាំគីមីកសិកម្ម និងជីកសិកម្ម ទៅតាមលក្ខណៈបច្ចេកទេស ដោយការពារមិនឲ្យប៉ះពាល់ទឹក លេចជ្រាបចូលក្នុងដី ហុយតាមខ្យល់ ឬត្រូវកំដៅ និងត្រូវមានឧបករណ៍ការពារអគ្គិភ័យ និងខ្យល់ចេញចូលល្អក្នុងឃ្លាំងស្តុក | ប្រធានផ្នែកវិស្វកម្ម / មន្ទីរ បរិស្ថាន និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ក្នុងឆ្នាំ២០១៧ (បញ្ចប់ការសាងសង់មុនពេលដឹកចូលនូវជី និងថ្នាំកសិកម្ម) | | |
| ៥.៧ | អប់រំ ណែនាំឲ្យបុគ្គលិក-កម្មករលាយថ្នាំពុលកសិកម្ម តាមស្តង់ដារបច្ចេកទេសដូចមានបង្ហាញនៅលើសំបកថ្នាំ នៅក្នុងឃ្លាំងស្តុកថ្នាំ មុនចែកចាយបន្តឲ្យកម្មករប្រើប្រាស់ | ប្រធានផ្នែកដាំដុះ / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ឆ្នាំម្តងជាវគ្គសាមញ្ញ (វគ្គវិសាមញ្ញត្រូវធ្វើឡើងសម្រាប់បុគ្គលិកថ្មីដែលមិនបានឆ្លងកាត់វគ្គសាមញ្ញ) | | រាល់បុគ្គលិក-កម្មករដែលមានភារៈកិច្ចពាក់ព័ន្ធនឹងការលាយថ្នាំ ត្រូវឆ្លងកាត់វគ្គអប់រំ ណែនាំនេះ |
| ៥.៨ | ប្រមូលមកវិញនូវធុងបាញ់ថ្នាំរបស់កម្មករ ដើម្បីរក្សាទុកនៅតាមទីតាំងរួម (ឃ្លាំង) ដោយមិនអនុញ្ញាតឲ្យកម្មករយកទៅរក្សាទុកតាមផ្ទះរបស់ខ្លួន ដែលអាចធ្វើឲ្យប៉ះពាល់ដល់សុខភាពសមាជិកគ្រួសារ និងខ្លួនឯង | ប្រធានផ្នែកដាំដុះ / មន្ទីរបរិស្ថាន | រាល់ពេលបញ្ចប់ការងារប្រចាំថ្ងៃ | | |

Draft

## ផែនការ៦៖ ការរួមចំណែកអភិវឌ្ឍន៍មូលដ្ឋាន និងលើកកម្ពស់សុខមាលភាពសង្គម

គោលបំណង៦៖ ចូលរួមលើកកម្ពស់កម្រិតជីវភាពប្រជាជន និងកាត់បន្ថយភាពក្រីក្រ ដើម្បីជាការប៉ះប៉ូវដល់ផលប៉ះពាល់បរិស្ថាន និងសង្គម ដែលបង្កឡើងដោយសារដំណើរការគម្រោង

| | សកម្មភាព | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា (ដុល្លារ/ឆ្នាំ) | សម្គាល់ |
|---|---|---|---|---|---|
| ៦.១ | គាំទ្រអាជ្ញាធរមូលដ្ឋានក្នុងការរៀបចំផែនការប្រើប្រាស់ដីក្នុងតំបន់ឲ្យបានសមរម្យ សំដៅសម្រេចឲ្យបាននូវការរស់នៅដោយចីរភាពរបស់សហគមន៍មូលដ្ឋាន | ប្រធានផ្នែករដ្ឋបាលក្រុមហ៊ុន / មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី | ១ដង ក្នុងឆ្នាំ២០១៨ | 400 | គាំទ្រដល់ស្រុកចំនួន ២ គឺ ស្រុករវៀងសៃ និងស្រុកកូនមុំ |
| ៦.២ | រៀបចំ និងអនុវត្ត គម្រោងកសិកម្មបែបកិច្ចសន្យា (គាំទ្របច្ចេកទេសដាំដុះ និងទិញយកកសិផល) ចំពោះមុខដំណាំដែលជាមុខព្រួញនៃការវិនិយោគរបស់ក្រុមហ៊ុន (ដូចជា កាកាវ ដូង អាកាស្យាសេណេហ្គាល់ សណ្ដែកសៀង) | ប្រធានផ្នែករដ្ឋបាល និងផ្នែកដាំដុះក្រុមហ៊ុន / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ចាប់ពីឆ្នាំ២០១៨ តទៅ | 600 | គាំទ្រតែប្រជាជននៅក្នុងភូមិ-ឃុំពាក់ព័ន្ធនឹងគម្រោង |
| ៦.៣ | គាំទ្រការបង្កើតសួនបន្លែធម្មជាតិ និងកសិដ្ឋានចិញ្ចឹមសត្វប្រចាំគ្រួសារ ដើម្បីកាត់បន្ថយការទិញចំណីអាហារពីទីផ្សារ | ប្រធានផ្នែករដ្ឋបាល និងផ្នែកដាំដុះក្រុមហ៊ុន / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ឆ្នាំ២០១៩ - ២០២១ | 1200 | សហការជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញ និងអង្គការមិនមែនរដ្ឋាភិបាល |
| ៦.៤ | ផ្ដល់អាទិភាពដល់ប្រជាជនមូលដ្ឋាន ចូលបម្រើការងារគម្រោង ដោយមានប្រាក់បៀវត្សសមរម្យ | ប្រធានផ្នែករដ្ឋបាល / អាជ្ញាធរស្រុក ឃុំ | រាល់ពេលមានតម្រូវការកម្លាំងពលកម្ម | - | សហការជាមួយអាជ្ញាធរភូមិ ឃុំ |
| ៦.៥ | មិនហាមឃាត់ ឬបង្កភាពរាំងស្ទះដល់ប្រជាជនមូលដ្ឋានដែលចូលរក និងប្រមូលអនុផលព្រៃឈើជាលក្ខណៈប្រពៃណី (ដូចបានចែងនៅក្នុងច្បាប់ស្ដីពីព្រៃឈើ) ក្នុងព្រៃរក្សាទុក | ប្រធានផ្នែករដ្ឋបាល និងផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | រាល់ពេលប្រជាជនចូលរកអនុផលព្រៃឈើ | - | |

Draft

| សកម្មភាព | | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា (ដុល្លារ/ឆ្នាំ) | សម្គាល់ |
|---|---|---|---|---|---|
| ៦.៦ | ផ្សព្វផ្សាយអំពីទំនៀមទម្លាប់ ប្រពៃណី (ជាពិសេសតំណមនានា) របស់ជនជាតិដើមភាគតិច ដល់បុគ្គលិក-កម្មករ និងដាក់បំរាមមិនឱ្យបុគ្គលិក-កម្មករធ្វើសកម្មភាពអ្វីដែលអាចប៉ះពាល់ដល់ទំនៀមទម្លាប់ ប្រពៃណីទាំងនោះ | ប្រធានផ្នែករដ្ឋបាលក្រុមហ៊ុន / អាជ្ញាធរស្រុក ឃុំ | ១ឆ្នាំម្តងជាវគ្គសាមញ្ញ (វគ្គវិសាមញ្ញត្រូវធ្វើឡើងសម្រាប់បុគ្គលិកថ្មីដែលមិនបានឆ្លងកាត់វគ្គសាមញ្ញ) | 2000 | |
| ៦.៧ | គាំទ្រដល់ការរៀបចំពិធីបុណ្យតាមបែបប្រពៃណីរបស់ជនជាតិដើមភាគតិច របស់ប្រជាជនក្នុងភូមិ-ឃុំពាក់ព័ន្ធនឹងគម្រោង | ប្រធានផ្នែករដ្ឋបាលក្រុមហ៊ុន / អាជ្ញាធរស្រុក ឃុំ | ចាប់ពីឆ្នាំ២០១៧ តទៅ (១ឆ្នាំផ្តល់ការគាំទ្រជាថវិកាម្តង) | 2000 | សហការជាមួយអាជ្ញាធរភូមិ ឃុំ |
| ៦.៨ | គាំទ្រដល់ដំណើរការមណ្ឌលសុខភាពដែលមានស្រាប់ក្នុងតំបន់ (មណ្ឌលសុខភាពភ្នំកុក និងមណ្ឌលសុខភាពរ៉ូនសៃ) | ប្រធានផ្នែករដ្ឋបាលក្រុមហ៊ុន / មន្ទីរសុខាភិបាល | ចាប់ពីឆ្នាំ២០២០ តទៅ (១ឆ្នាំផ្តល់ការគាំទ្រជាថវិកាម្តង) | 400 | |
| ៦.៩ | គាំទ្រដល់ដំណើរការបង្កើតមណ្ឌលសុខភាពក្នុងភូមិតាឡាត ឬភូមិរំពាត់នៃឃុំតាឡាត (ភូមិទាំងពីរនេះនៅដាច់ស្រយោលពីទីប្រជុំឃុំ និងស្ថិតនៅក្រោមខ្សែទឹកនៃទីតាំងគម្រោង) | ប្រធានផ្នែករដ្ឋបាលក្រុមហ៊ុន / មន្ទីរសុខាភិបាល | ក្នុងឆ្នាំ២០២២ | 400 | |
| ៦.១០ | គាំទ្រដល់ការថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់មូលដ្ឋាន ដោយសហការជាមួយអាជ្ញាធរភូមិ-ឃុំពាក់ព័ន្ធ និងរៀបចំសៀវភៅស្នាក់នៅសម្រាប់បុគ្គលិក-កម្មករ នៅក្នុងតំបន់គម្រោង | ប្រធានផ្នែករដ្ឋបាលក្រុមហ៊ុន / អាជ្ញាធរស្រុក ឃុំ | ពេលគម្រោងចាប់ផ្តើមដំណើរការ និងមានបុគ្គលិក-កម្មករអចិន្ត្រៃយ៍ | - | |

## ផែនការ៧៖ ការចូលរួមការពារ និងស្តារឡើងវិញនូវធនធានធម្មជាតិ

គោលបំណង៧៖ រួមចំណែកគាំពារ និងស្តារធនធានបរិស្ថានក្នុងតំបន់ឡើងវិញ

| | សកម្មភាព | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា (ដុល្លារ/ឆ្នាំ) | សម្គាល់ |
|---|---|---|---|---|---|
| ៧.១ | រក្សាគម្របព្រៃឲ្យបានពី ១០០ម ទៅ ១៥០ម ពីប្រភពទឹកនានាដែលមាននៅក្នុងទីតាំងគម្រោង | ប្រធានផ្នែកឈូសឆាយ និងផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរបរិស្ថាន | រាល់ពេលមានផែនការ និងដំណើរការឈូសឆាយ | - | ត្រួតពិនិត្យការឈូសឆាយជាប្រចាំ |
| ៧.២ | រក្សាទុកដើមឈើនៅតាមព្រំទីតាំងគម្រោងដើម្បីដើម្បីជួយទប់ស្កាត់ការហុយធូលីទៅតំបន់ផ្សេង និងជួយបន្សុទខ្យល់ | ប្រធានផ្នែកឈូសឆាយ និងផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរបរិស្ថាន | រាល់ពេលមានផែនការ និងដំណើរការឈូសឆាយ | - | ត្រួតពិនិត្យការឈូសឆាយជាប្រចាំ |
| ៧.៣ | ចូលរួមអភិរក្ស និងស្តារឡើងវិញនូវព្រៃទ្រនាប់អូរ ព្រៃគុបក្នុងស្រុក និងព្រៃរក្សាទុកនានា ដែលបានកាត់ចេញពីផ្ទៃដីគម្រោង ព្រមទាំងឧបត្ថម្ភគាំទ្រដល់សកម្មភាពរបស់ស្ថានីយ៍បណ្តុះកូនឈើ របស់ផ្នែករដ្ឋបាលព្រៃឈើរ៉ូនិសៃ ដើម្បីផ្គត់ផ្គង់កូនឈើសម្រាប់ការដាំដុះក្នុងតំបន់ | ប្រធានផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរបរិស្ថាន | ចាប់ពីឆ្នាំ២០១៧ តទៅ | 500 | គាំទ្រជាថវិកាដល់ផ្នែករដ្ឋបាលព្រៃឈើរ៉ូនិសៃ |
| ៧.៤ | ចូលរួមឧបត្ថម្ភគាំទ្រសម្រាប់ការអភិរក្សនិងគ្រប់គ្រងសហគមន៍ព្រៃឈើកុកព្រៅ និងដំណើរការដាក់បញ្ចូលបន្ថែមនូវធនធានព្រៃឈើដែលនៅសេសសល់ជាដីសហគមន៍ព្រៃឈើ | ប្រធានផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរបរិស្ថាន | ចាប់ពីឆ្នាំ២០១៧ តទៅ | 500 | គាំទ្រជាថវិកាដល់សហគមន៍ព្រៃឈើកុកព្រៅ |

Draft

| សកម្មភាព | | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា (ដុល្លារ/ឆ្នាំ) | សម្គាល់ |
|---|---|---|---|---|---|
| ៧.៥ | ដាំដើមឈើឡើងវិញនៅតាមការដ្ឋាន ជុំវិញសំណង់អាគារនានា និងនៅតាមដងផ្លូវក្នុងទីតាំងគម្រោង | ប្រធានផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរបរិស្ថាន | ចាប់ពីឆ្នាំ២០១៧ តទៅ | - | |
| ៧.៦ | ដាំដើមឈើឡើងវិញនៅតាមដងផ្លូវក្នុងភូមិដែលយានយន្តរបស់ក្រុមហ៊ុនឆ្លងកាត់ និងតាមទីសាធារណៈនានាក្នុងតំបន់ | ប្រធានផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរបរិស្ថាន | ចាប់ពីឆ្នាំ២០១៧ តទៅ | 500 | គាំទ្រជាថវិកាដល់មន្ទីរបរិស្ថាន |
| ៧.៧ | បកយកដីស្រទាប់លើដែលមានដីជាតិ ដើម្បីចាក់គ្របលើទីតាំងជុំវិញសំណង់អគារ និងរៀបចំទីតាំងទាំងនោះទៅជាសួនច្បារ ឬដាំរុក្ខជាតិ ដើមឈើលម្អនៅជុំវិញសំណង់អគារទាំងនោះ | ប្រធានផ្នែកសាងសង់ និងផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរបរិស្ថាន | ចាប់ពីឆ្នាំ២០១៧ (ក្នុងពេលរៀបចំដីសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានា) | - | |
| ៧.៨ | ធ្វើការលែងកូនមច្ឆជាតិនៅតាមប្រព័ន្ធផ្លូវទឹក ដែលមាននៅក្នុង និងក្បែរទីតាំងគម្រោង | ប្រធានផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ឆ្នាំម្តង ចាប់ពីឆ្នាំ ២០១៧ តទៅ | 500 | សហការជាមួយផ្នែករដ្ឋបាលជលផលរ៉ែនសែ និងទន្លេសេសាន |

Draft

## ផែនការ៨៖ ការគ្រប់គ្រងបញ្ហាទូទៅ

<u>គោលបំណង៨៖</u> ធានាការអនុវត្តវិធានការដែលមានលក្ខណៈទូទៅ ប៉ុន្តែចាំបាច់ដើម្បីធានានូវសណ្តាប់ធ្នាប់ និងសុវត្ថិភាពសាធារណៈ

| | សកម្មភាព | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា (ដុល្លារ/ឆ្នាំ) | សម្គាល់ |
|---|---|---|---|---|---|
| ៨.១ | ធ្វើការផ្សព្វផ្សាយជាដំណឹងឲ្យបានមុនទៅកាន់អាជ្ញាធរមូលដ្ឋាន អំពីការចាប់ផ្តើមដំណើរការគម្រោង និងការចល័តគ្រឿងចក្រ ឬគ្រឿងម៉ាស៊ីនចូលទីតាំងគម្រោង | ប្រធានផ្នែករដ្ឋបាល / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរស្រុក | ក្នុងឆ្នាំ២០១៧ | - | មុនចល័តគ្រឿងចក្រចូលទីតាំងគម្រោង ឬរាល់ពេលមុនចល័តគ្រឿងចក្របន្ថែមចូលទីតាំងគម្រោង |
| ៨.២ | បញ្ចូលក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន នូវបំរាម និងពិន័យពាក់ព័ន្ធនឹង៖<br>- គ្រឿងញៀន អំពើហិង្សា ករណីចោរកម្ម ពេស្យាចារ រំលោភសេពសន្ថវៈ<br>- បទល្មើសព្រៃឈើ សត្វព្រៃ ផលផល និងធនធានធម្មជាតិនានា<br>- ការចេញចូលឃ្លាំងស្តុកថ្នាំកសិកម្ម និងទីតាំងដែលមានហានិភ័យលើសារពាង្គកាយ និងសុខភាព<br>- ការធ្វើចរាចរណ៍ឆ្លងកាត់ភូមិ<br>- ម៉ោងពេលប្រតិបត្តិការងារ (ជៀសវាងពេលការរំខានដល់ប្រជាជនមូលដ្ឋាន) | ប្រធានផ្នែករដ្ឋបាល និងផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរបរិស្ថាន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរស្រុក | ក្នុងឆ្នាំ២០១៧ | - | ត្រូវមានបទបញ្ជាផ្ទៃក្នុងនេះ មុនពេលចាប់ផ្តើមដំណើរការគម្រោង |
| ៨.៣ | រៀបចំ និងអនុវត្តកម្មវិធីលើកទឹកចិត្តដល់បុគ្គលិក-កម្មករ ឱ្យចូលរួមរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ច ក្នុងករណីសង្កេតឃើញមានបទល្មើសព្រៃឈើ សត្វព្រៃ ផលផល និងធនធានធម្មជាតិនានា | ប្រធានផ្នែករដ្ឋបាល និងផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរបរិស្ថាន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរស្រុក | ចាប់ពីឆ្នាំ២០១៧ តទៅ | - | ការលើកទឹកចិត្តមានដូចជា៖ ការលើកសរសើរចំៗ ការផ្តល់រង្វាន់ ឬការតម្លើងប្រាក់ខែ ជាដើម |
| ៨.៤ | រៀបចំឱ្យមានស្លាកសញ្ញាបង្ហាញ និងណែនាំ នៅឃ្លាំងស្តុកថ្នាំគីមីកសិកម្ម អំពីគ្រោះថ្នាក់ដែលអាចបណ្តាលមកពីថ្នាំគីមីកសិកម្ម និងវិធីសាស្ត្រណែនាំអំពីការលាយថ្នាំ | ប្រធានផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្នុងឆ្នាំ២០១៧ | - | ត្រូវមានស្លាកសញ្ញានៅឃ្លាំងស្តុកថ្នាំ មុនពេលដឹកជញ្ជូនថ្នាំចូល |

| | សកម្មភាព | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ | ពេលវេលា/ខួប | ថវិកា (ដុល្លារ/ឆ្នាំ) | សម្គាល់ |
|---|---|---|---|---|---|
| ៨.៥ | រៀបចំកម្មវិធីអប់រំ ផ្សព្វផ្សាយអំពីសុខភាព អនាម័យក្នុងការរស់នៅ (ជាពិសេសរៀបចំ និងចែកចាយនូវផ្ទាំងផ្សព្វផ្សាយអំពីបំរាមក្នុងការប្រើប្រាស់ធុងថ្នាំគីមីកសិកម្មសម្រាប់ស្តុកម្ហូបអាហារ និងទឹកបរិភោគ) ដល់ប្រជាជននៅក្នុងភូមិ-ឃុំក្បែរទីតាំងគម្រោង | ប្រធានផ្នែកបរិស្ថានក្រុមហ៊ុន / មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ឆ្នាំម្តង ចាប់ពីឆ្នាំ ២០១៧ តទៅ | 1000 | សហការជាមួយអាជ្ញាធរភូមិ-ឃុំ |
| ៨.៦ | គាំទ្រដល់ការផ្សព្វផ្សាយជាចំណេះដឹងបន្ថែមដល់ប្រជាជនមូលដ្ឋានទាក់ទងនឹងសុវត្ថិភាពចរាចរណ៍ និងបញ្ហាសង្គមចាំបាច់ផ្សេងទៀត | ប្រធានផ្នែករដ្ឋបាលក្រុមហ៊ុន / អាជ្ញាធរស្រុក | ១ឆ្នាំម្តង ចាប់ពីឆ្នាំ ២០១៧ តទៅ | 5000 | គាំទ្រជាថវិកាដល់អធិការដ្ឋានស្រុក |
| ៨.៧ | គាំទ្រដល់អាជ្ញាធរមូលដ្ឋានក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ព្រមទាំងបេសកកម្មរបស់ប្រជាការពារឃុំ ដើម្បីពង្រឹងសុវត្ថិភាព និងសន្តិសុខមូលដ្ឋាន | ប្រធានផ្នែករដ្ឋបាលក្រុមហ៊ុន / អាជ្ញាធរស្រុក | ១ឆ្នាំម្តង ចាប់ពីឆ្នាំ ២០១៧ តទៅ | 2000 | គាំទ្រជាថវិកាដល់អាជ្ញាធរឃុំ |

Draft

## ៨.៣.២. កម្មវិធីបំពាក់បំប៉ន

ដើម្បីបង្កើនការអនុវត្តឱ្យមានប្រសិទ្ធិភាពនូវផែនការគ្រប់គ្រងបរិស្ថាន ក៏ដូចជាការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គមដូចបានលើកឡើងនៅក្នុងជំពូកទី៧ និងដែលបានសង្ខេបក្នុងចំណុច ៧.៣ ខាងលើ ការបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិក/កម្មករគម្រោង អំពីលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធត្រូវគោរពអនុវត្តតាម សកម្មភាពដែលអាចបង្កនូវផលប៉ះពាល់ និងវិធានដែលត្រូវអនុវត្តដើម្បីកាត់បន្ថយ ឬបញ្ចៀសនូវហេតុប៉ះពាល់បរិស្ថាន សុទ្ធសឹងជាតម្រូវការចាំបាច់ដែលម្ចាស់គម្រោងត្រូវធ្វើឡើង។

កម្មវិធីបណ្តុះបណ្តាលដល់បុគ្គលិក/កម្មករ ត្រូវផ្តោតលើប្រធានបទសំខាន់ៗដូចជា៖

- ការប្រើប្រាស់នូវគ្រឿងចក្រ គ្រឿងយន្ត ម៉ាស៊ីន និងឧបករណ៍សម្ភារផ្សេងទៀត
- ការអនុវត្តនូវក្រមប្រតិបត្តិ ឬគោលការណ៍សុវត្ថិភាពនៅក្នុងកសិដ្ឋាន ដូចជាការប្រើប្រាស់នូវសម្ភារការពារសុវត្ថិភាព (PPE) ការប្រុងប្រយ័ត្នក្នុងពេលបំពេញការងារ ការត្រួតពិនិត្យនូវលក្ខខណ្ឌសុវត្ថិភាពនៅកន្លែងធ្វើការ ការទុកដាក់សម្ភារ ការទុកដាក់និងប្រើប្រាស់ថ្នាំគីមីកសិកម្ម។ល។
- ការអនុវត្តនូវនីតិវិធីសង្គ្រោះបឋម ដើម្បីជួយជនរងគ្រោះករណីមានឧប្បត្តិហេតុនានាកើតឡើង
- ការអនុវត្តនូវនីតិវិធីក្នុងការទប់ស្កាត់អំពើចោរកម្មដែលអាចកើតមានឡើងពេលប្រតិបត្តិគម្រោង
- ការរក្សាអនាម័យស្អាតក្នុងកន្លែងធ្វើការ ដោយប្រមូលទុកដាក់សំណល់ ញែកទៅតាមប្រភេទកំណត់ប្រមូលយកទៅស្តុកទុកនៅឃ្លាំងស្តុកទុក និងដឹកសំណល់ទៅចោលនៅទីលានដែលអនុញ្ញាតដោយស្ថាប័នមានសមត្ថកិច្ច
- ការយល់ដឹងអំពីច្បាប់ចរាចរណ៍ផ្លូវគោក ដោយផ្តោតលើការកំណត់ល្បឿនយានយន្តក្នុងតំបន់ទីប្រជុំជនក្រុង តំបន់ក្រៅទីប្រជុំជន និងតំបន់ជនបទ ការប្រើប្រាស់ស៊ីផ្លេ ការចត ការឈប់ និងការត្រួតពិនិត្យអំពីលក្ខណៈសុវត្ថិភាពរបស់យានយន្ត
- ការរក្សាភាពស្ងៀមស្ងាត់នៅក្នុងកន្លែងសម្រាក ឬផ្ទះស្នាក់នៅក្នុងកសិដ្ឋាន
- ការបង្ការជំងឺឆ្លង និងការថែរក្សាសុខភាព ដោយមិនត្រូវប្រើប្រាស់គ្រឿងស្រវឹងច្រើន និងជៀសឆ្ងាយពីគ្រឿងញៀន និងត្រូវជួយតាមដាន ណែនាំ និងរាយការណ៍អំពីការអនុវត្តមិនល្អរបស់បុគ្គលិក/កម្មករដែលមានជាប់ពាក់ព័ន្ធនឹងអំពើល្បែងស៊ីសង ការសេពគ្រឿងញៀន និងសកម្មភាពដទៃទៀតពាក់ព័ន្ធនឹងការបង្កការខូចខាតសណ្តាប់ធ្នាប់សាធារណៈ។

## ៨.៣.៣. កម្មវិធីត្រួតពិនិត្យបរិស្ថាន

កម្មវិធីត្រួតពិនិត្យបរិស្ថាន ត្រូវបានរៀបចំឡើងដើម្បីធានានូវការត្រួតពិនិត្យ និងតាមដានបម្រែបម្រួលគុណភាពទឹក (លើដី និងក្រោមដី) និងគុណភាពដី ព្រមទាំងតាមដានប្រភពបំពុលខ្យល់ និងការរំខានដោយសំឡេង សំដៅទប់ស្កាត់ការបំពុលលើសពីកម្រិតស្តង់ដារកំណត់ និងបង្កឲ្យមានបម្រែបម្រួលគុណភាពបរិស្ថានដែលមិនអាចស្តារឡើងវិញបាន និង/ឬប៉ះពាល់ដល់សុខភាព សុវត្ថិភាពសាធារណៈ។

កម្មវិធីត្រួតពិនិត្យបរិស្ថាននឹងត្រូវអនុវត្តដោយម្ចាស់គម្រោងផ្ទាល់ ក្រោមការត្រួតពិនិត្យ ឃ្លាំមើលពីស្ថាប័នជំនាញដែលពាក់ព័ន្ធ។ ក្រុមហ៊ុនម្ចាស់គម្រោង នឹងធ្វើរបាយការណ៍ជូនក្រសួងបរិស្ថានរៀងរាល់ ៦ខែម្តង ដើម្បីរាយការណ៍ពីលទ្ធផលនៃការវាយតម្លៃលើសកម្មភាពគម្រោង និងឥទ្ធិពលគម្រោងលើធនធានបរិស្ថាន និងសង្គម ក្នុងតំបន់។ របាយការណ៍នេះ នឹងផ្តល់ជាមូលដ្ឋានដល់ក្រសួងពាក់ព័ន្ធ ក្នុងការចុះអង្កេតតាមដាន និងផ្តល់អនុសាសន៍កែលម្អតាមបទពិសោធន៍បច្ចេកទេស ឲ្យបានទាន់ពេលវេលាក្នុងករណីមានភាពមិនប្រក្រតីកើតឡើង។

Draft

# តារាងបង្ហាញពីកម្មវិធីត្រួតពិនិត្យបរិស្ថាន

**គោលបំណង៖** ជានានូវការត្រួតពិនិត្យ និងតាមដានបម្រែបម្រួលគុណភាពទឹក ( លើដី និងក្រោមដី ) និងគុណភាពដី ព្រមទាំងតាមដានប្រភពបំពុលខ្យល់ និងការរំខានដោយសំឡេង សំដៅទប់ស្កាត់ការបំពុលលើសពីកម្រិតស្តង់ដារកំណត់ និងបង្កឲ្យមានបម្រែបម្រួលគុណភាពបរិស្ថានដែលមិនអាចស្តារឡើងវិញបាន

| | សកម្មភាព | ទីតាំង | ពេលវេលា/ខួប | ប៉ារ៉ាម៉ែត្រ | ស្តង់ដារ | ថវិកា ( ដុល្លារ/ឆ្នាំ ) | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ |
|---|---|---|---|---|---|---|---|
| ១ | ត្រួតពិនិត្យ និងតាមដានគុណភាពទឹកអូរ ចំនួន ៧ ទីតាំង | - ទីតាំង១ ( អូរភ្នំ ) SW1 ( X: 694805, Y: 1540310 )<br>- ទីតាំង២ ( អូរតាង ) SW2 ( X: 690215, Y: 1537280 )<br>- ទីតាំង៣ ( ពាមមាត់អូរ ) SW3 ( X: 689027, Y: 1533374 )<br>- ទីតាំង៤ ( អូរតាឡាត ) SW4 ( X: 679698, Y: 1524422 )<br>- ទីតាំង៥ ( អូរជេរិក ) SW5 ( X: 685494, Y: 1530596 )<br>- ទីតាំង៦ ( អូរកន្សែង ) SW6 ( X: 688145, Y: 1531854 )<br>- ទីតាំង៧ ( អូរស្វាយរៀង ) SW7 ( X: 666585, Y: 1515542 )<br>**( ជំពូកទី៥ ផែនទី៥.១.៦ )** | រៀងរាល់ ៣ខែម្តង | pH<br>DO<br>TSS<br>Cl<br>$BOD_5$<br>CODMn<br>TN<br>TP<br>As<br>$Cr^6$<br>Fe total<br>Hg-total<br>Total Coliform | 6.5 – 8.5<br>2.0 – 7.5 mg/l<br>25 – 100 mg/l<br>NV<br>1.0 – 10 mg/l<br>NV<br>0.1 – 0.6 mg/l<br>0.005-0.05 mg/l<br>>0.01 mg/l<br>NV<br>NV<br><0.005 mg/l<br>>5000 MPN/100ml | 2100 | ប្រធានផ្នែកបរិស្ថានក្រុមហ៊ុន / ក្រសួងបរិស្ថាន ( មន្ទីរបរិស្ថានខេត្ត ) |
| ២ | ត្រួតពិនិត្យ និងតាមដានគុណភាពទឹកក្រោមដី ( ទឹកអណ្តូង ) ចំនួន ៣ ទីតាំង | - ទីតាំងទី១ នៅអណ្តូងសាលាបឋមសិក្សាទៀមក្រោGW1(X:690647, 1536658 )<br>- ទីតាំងទី២ នៅអណ្តូងក្នុងភូមិភ្នំ | រៀងរាល់ ៣ខែម្តង | pH<br>Turbidity<br>Dissolved Oxygen<br>Total Hardness<br>Chloride ( Cl- ) | 6.5 - 8.5<br>< 5.0 NTU<br>NV<br><300 mg/l<br><250 mg/l | 900 | ប្រធានផ្នែកបរិស្ថានក្រុមហ៊ុន / ក្រសួងបរិស្ថាន ( មន្ទីរបរិស្ថានខេត្ត ) |

Draft

| | សកម្មភាព | ទីតាំង | ពេលវេលា/ខួប | ប៉ារ៉ាម៉ែត្រ | ស្តង់ដារ | ថវិកា (ដុល្លារ/ឆ្នាំ) | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ |
|---|---|---|---|---|---|---|---|
| | | កុកឡាវ GW2 (X: 695135, Y: 1540876)<br>- ទីតាំងទី៣ នៅអណ្តូងក្នុងភូមិស្វាយរៀង GW3 (X:666145, Y: 1515377)<br>**(ជំពូកទី៥ ផែនទី៥.១.៧)** | | Arsenic (As)<br>Iron (Fe-total)<br>Total Nitrogen<br>Total Phosphorus<br>Total Coliform | <0.05 mg/l<br><0.3 mg/l<br>NV<br>NV<br>100 MPN/100ml | | |
| ៣ | ត្រួតពិនិត្យ និងតាមដានគុណភាពដី ចំនួន ៤ ទីតាំង | - ទីតាំងទី១ ប្រភេទដីPlinthite podzols ដែលយកត្រង់ចំណុចទីប្រជុំទមូន់ Zone I, SS1-1 (X:678072, 1514980)<br>- ទីតាំងទី២ ប្រភេទដី Acid Lithosols ដែលយកត្រង់ចំណុងចទីប្រជុំទមូន់ Zone II, SS2-1 (X:680729, Y:1523234)<br>- ទីតាំងទី៣ និងទី៤ ប្រភេទដី Grey hydromorphics ដែលស្ថិតនៅ Zone III, SS3-1 (X:692579,Y:1534321) និង SS3-2 (X:684469,Y:1527495)<br>- ទីតាំងទី៥ ប្រភេទដី Grey hydromorphics ដែលយកត្រង់ចំណុងចទីប្រជុំទមូន់Zone II, | រៀងរាល់ ៣ខែម្តង | pH<br>Organic matter<br>Copper<br>Zinc<br>Lead<br>Arsenic<br>Total nitrogen<br>Phosphorus<br>Nitrites<br>Ammonia<br>Cadmium | មិនមានស្តង់ដារ | 1200 | ប្រធានផ្នែកជាំដុះក្រុមហ៊ុន / ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត) |

Draft

| សកម្មភាព | | ទីតាំង | ពេលវេលា/ខួប | ប៉ារ៉ាម៉ែត្រ | ស្តង់ដារ | ថវិកា (ដុល្លារ/ឆ្នាំ) | អ្នកទទួលខុសត្រូវ / ស្ថាប័នត្រួតពិនិត្យ |
|---|---|---|---|---|---|---|---|
| | | SS3-3 (X:698273,Y: 154001)<br>**(ជំពូកទី៥ ផែនទី៥.១.៤)** | | | | | |
| ៤ | ត្រួតពិនិត្យ និងតាមដានគុណភាពខ្យល់ក្នុងឃ្លាំងស្តុកជី និងថ្នាំគីមីកសិកម្ម ចំនួន ១ ទីតាំង | នៅក្នុងឃ្លាំងស្តុកជី និងថ្នាំគីមី (X: 686305, Y: 1528876) | រៀងរាល់ ១ឆ្នាំម្តង | Temperature<br>Humidity<br>CO<br>CO2<br>TVOC<br>Light.5 | <30 ºC<br>30-60 %RH<br><20 mg/m³<br>2500 ppm<br><10 ppm<br>NA lux | 600 | ប្រធានផ្នែកបរិស្ថានក្រុមហ៊ុន / ក្រសួងបរិស្ថាន (មន្ទីរបរិស្ថានខេត្ត) |
| ៥ | ត្រួតពិនិត្យ និងតាមដានកំហាប់ឧស្ម័នពុលចេញពីបំពង់ផ្សែងនៃម៉ាស៊ីនភ្លើង និងគ្រឿងយន្តគាំទ្រដល់ដំណើរការគម្រោង ចំនួន២ទីតាំង | - ទីតាំង១ នៅបំពង់ផ្សែងចេញពីម៉ាស៊ីនភ្លើង (X: 686310, Y: 1528876)<br>- ទីតាំង២ នៅបំពង់ផ្សែងចេញពីគ្រឿងយន្ត | រៀងរាល់ ១ឆ្នាំម្តង | <u>ប្រេងសាំង (ក)</u><br>- CO<br>- CH<br><u>ប្រេងសាំង (ខ)</u><br>- CO<br>- SO2<br>**ប្រេងម៉ាស៊ូត**<br>- ផ្សែងខ្មៅ | <br>4.5%<br>1200 ppm<br><br>4%<br>800 ppm<br><br>50% | 3200 | ប្រធានផ្នែកបរិស្ថានក្រុមហ៊ុន / ក្រសួងបរិស្ថាន (មន្ទីរបរិស្ថានខេត្ត) |
| ៦ | ត្រួតពិនិត្យ និងតាមដានកម្រិតសំឡេង ចំនួន ១ ទីតាំង | - នៅជាប់នឹងផ្ទះស្នាក់នៅរបស់កម្មករ (X: 686292, Y: 1528814) | 24 ម៉ោង<br>រៀងរាល់ ១ឆ្នាំម្តង | កម្រិតសំឡេង<br>dB(A) | 75dB(A): 6am-6pm<br>70dB(A): 6pm-10pm<br>50dB(A): 10pm-6am | 600 | ប្រធានផ្នែកបរិស្ថានក្រុមហ៊ុន / ក្រសួងបរិស្ថាន (មន្ទីរបរិស្ថានខេត្ត) |

<u>សម្គាល់៖</u> (ក) សំដៅលើយានយន្តគ្រប់ប្រភេទដែលប្រើប្រាស់ហួសរយៈពេល ០៥ឆ្នាំ គិតពីឆ្នាំផលិត (ខ) សំដៅលើយានយន្តគ្រប់ប្រភេទដែលបាននាំចូលថ្មីក្នុងរយៈពេល ០៥ឆ្នាំ គិតពីឆ្នាំផលិត

Draft

## ៨.៤. ផែនការថវិកាសម្រាប់អនុវត្តផែនការគ្រប់គ្រងបរិស្ថាន

តម្រូវការថវិកាសម្រាប់អនុវត្តផែនការគ្រប់គ្រងបរិស្ថាន ភាគច្រើនបានគិតបញ្ចូលរួចហើយក្នុងផែនការថវិកាសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងប្រតិបត្តិគម្រោង។ ថវិកាបន្ថែមដែលក្រុមហ៊ុនចាំបាច់ត្រូវបម្រុងទុកដើម្បីធានាការអនុវត្តផែនការការពារបរិស្ថាន កម្មវិធីអប់រំ-បណ្តុះបណ្តាល និងត្រួតពិនិត្យបរិស្ថានចាប់ពេលបច្ចុប្បន្ន (ឆ្នាំ២០១៧ ឬ ឆ្នាំទី១) រហូតដល់បញ្ចប់ការវិនិយោគ (រយៈពេលសរុប ៥០ឆ្នាំ) មានបង្ហាញសង្ខេបក្នុងតារាង៨.២។ ថវិកាដែលត្រូវការនេះ មានចំនួនសរុប ៣.០៣៨.០០០ ដុល្លារអាមេរិក សម្រាប់រយៈពេលវិនិយោគ ៥០ឆ្នាំនេះ ឬជាមធ្យមប្រមាណ ៦០.៧៦០ ដុល្លារអាមេរិក/ឆ្នាំ។ ថវិកានេះ ត្រូវបម្រុងទុកសម្រាប់អនុវត្តផែនការ៣ (ការលើកកម្ពស់សុខមាលភាពបុគ្គលិក-កម្មករ), ផែនការ៤ (ការគ្រប់គ្រងសំណល់ និងប្រភពបំពុលផ្សេងៗ), ផែនការ៧ (ការរួមចំណែកអភិវឌ្ឍន៍មូលដ្ឋាន និងលើកកម្ពស់សុខមាលភាពសង្គម), ផែនការ៨ (ការចូលរួមការពារ និងស្តារឡើងវិញនូវធនធានធម្មជាតិ), និងផែនការ៩ (ការគ្រប់គ្រងបញ្ហាទូទៅ) ព្រមទាំងកម្មវិធីត្រួតបរិស្ថាន។

តារាង៨.១៖ ថវិកាសម្រាប់អនុវត្តផែនការការពារបរិស្ថាន កម្មវិធីបំពាក់បំប៉ន និងកម្មវិធីត្រួតពិនិត្យបរិស្ថាន

| ផែនការ | សកម្មភាព | ថវិកា (ដុល្លារ) មធ្យម/ឆ្នាំ | សរុប (៥០ឆ្នាំ) | ពេលដែលត្រូវចំណាយ |
|---|---|---|---|---|
| ផែនការ៣៖ ការលើកកម្ពស់សុខមាលភាពបុគ្គលិក-កម្មករ | | 24,000 | 1,200,000 | |
| ៣.១ | រៀបចំវគ្គអប់រំ ណែនាំ អំពីបច្ចេកទេសក្នុងការប្រើប្រាស់គ្រឿងចក្រ ការថែទាំ និងវិធានការសុវត្ថិភាព (រួមទាំងច្បាប់ចរាចរណ៍) | 8,000 | 400,000 | រៀងរាល់ឆ្នាំ |
| ៣.២ | រៀបចំវគ្គអប់រំ ណែនាំ អំពីបច្ចេកទេសក្នុងការគ្រប់គ្រងជី និងថ្នាំគីមីកសិកម្ម (ដឹកជញ្ជូន ទុកដាក់ ថែទាំ លាយ និងប្រើប្រាស់) និងវិធានការសុវត្ថិភាព | 8,000 | 400,000 | រៀងរាល់ឆ្នាំ |
| ៣.៤ | រៀបចំវគ្គអប់រំ ណែនាំ អំពីសុខភាព អនាម័យក្នុងការរស់នៅ (ឧ. ការការពារជម្ងឺគ្រុនចាញ់ ជម្ងឺឆ្លង អនាម័យក្នុងការបរិភោគ បន្ទោរបង់ ...) និងសារៈប្រយោជន៍នៃកិច្ចការពារបរិស្ថាន និងជីវៈចម្រុះ | 8,000 | 400,000 | រៀងរាល់ឆ្នាំ |
| ផែនការ៤៖ ការគ្រប់គ្រងសំណល់ និងប្រភពបំពុល | | 10,160 | 508,000 | |
| ៤.១ | រៀបចំវគ្គអប់រំ ណែនាំ អំពីការគ្រប់គ្រងសំណល់គ្រប់ប្រភេទ (គ្រោះថ្នាក់ រឹង រាវ ប្រេង) ដល់បុគ្គលិក-កម្មករ | 8,000 | 400,000 | |
| ៤.៣ | រៀបចំឲ្យមានធុងសំរាម (សំណល់គ្រោះថ្នាក់ សំណល់ប្រើប្រាស់ឡើងវិញបាន សំណល់កែច្នៃឡើងវិញបាន និងសំណល់ទូទៅ) នៅតាមកន្លែងស្នាក់នៅរបស់បុគ្គលិក-កម្មករ ការដ្ឋាន និងថ្នាលពូជ | 2,160 | 108,000 | ក្នុងឆ្នាំទី១ ចំនួន 10000 ដុល្លារសម្រាប់ធុងសំរាមថ្មី និងក្នុងឆ្នាំបន្តបន្ទាប់ 2000ដុល្លារ/ឆ្នាំ សម្រាប់ថែទាំ និងប្តូរធុងថ្មី |

Draft

| ផែនការ<br>សកម្មភាព | | ថវិកា (ដុល្លារ) | | ពេលវេលាត្រូវចំណាយ |
|---|---|---|---|---|
| | | មធ្យម/ឆ្នាំ | សរុប (៥០ឆ្នាំ) | |
| ផែនការ៦៖ ការរួមចំណែកអភិវឌ្ឍន៍មូលដ្ឋាន និងលើកកម្ពស់សុខមាលភាពសង្គម | | 7,000 | 350,000 | |
| ៦.១ | គាំទ្រអាជ្ញាធរមូលដ្ឋានក្នុងការរៀបចំផែនការប្រើប្រាស់ដីក្នុងតំបន់ឲ្យបានសមរម្យ សំដៅសម្រេចឲ្យបាននូវការរស់នៅដោយចីរភាពរបស់សហគមន៍មូលដ្ឋាន | 400 | 20,000 | ក្នុងឆ្នាំ២០១៨ ដោយឧបត្ថម្ភថវិកាចំនួន ១០០០០ដុល្លារ/ស្រុក ដល់អាជ្ញាធរស្រុកវឺនសៃ និងស្រុកកូនមុំ |
| ៦.២ | រៀបចំ និងអនុវត្ត គម្រោងកសិកម្មបែបកិច្ចសន្យា (គាំទ្របច្ចេកទេសដាំដុះ និងទិញយកកសិផល) ចំពោះមុខដំណាំដែលជាមុខព្រួញនៃការវិនិយោគរបស់ក្រុមហ៊ុន (ដូចជា កាកាវ ដូងអាកាស្សាសេណេហ្គាល់ សណ្តែកសៀង) | 600 | 30,000 | ចាប់ពីឆ្នាំ២០១៨ (ឆ្នាំទី២) ដល់ឆ្នាំ ២០២០ នឹងមានថវិកាចំនួន ១០០០០ដុល្លារ/ឆ្នាំ សម្រាប់ការងារសម្របសម្រួល (ថវិកាគាំទ្រគម្រោងកសិកម្មបែបកិច្ចសន្យានេះ នឹងយកពីថវិកាប្រតិបត្តិគម្រោង) |
| ៦.៣ | គាំទ្រការបង្កើតសួនបន្លែធម្មជាតិ និងកសិដ្ឋានចិញ្ចឹមសត្វប្រចាំគ្រួសារ ដើម្បីកាត់បន្ថយការទិញចំណីអាហារពីទីផ្សារ | 1,200 | 60,000 | ចាប់ពីឆ្នាំ២០១៩ (ឆ្នាំទី៣) ដល់ឆ្នាំ ២០២១ នឹងមានថវិកាចំនួន ២០០០០ដុល្លារ/ឆ្នាំ សម្រាប់គាំទ្រដល់ការងារនេះ |
| ៦.៦ | ផ្សព្វផ្សាយអំពីទំនៀមទម្លាប់ ប្រពៃណី (ជាពិសេសតំណមនានា) របស់ជនជាតិដើមភាគតិច ដល់បុគ្គលិក-កម្មករ និងដាក់បំរាមមិនឱ្យបុគ្គលិក-កម្មករធ្វើសកម្មភាពអ្វីដែលអាចប៉ះពាល់ដល់ទំនៀមទម្លាប់ ប្រពៃណីទាំងនោះ | 2,000 | 100,000 | ១ឆ្នាំម្តងចាប់ពីឆ្នាំ២០១៧ តទៅ |
| ៦.៧ | គាំទ្រដល់ការរៀបចំពិធីបុណ្យតាមបែបប្រពៃណីរបស់ជនជាតិដើមភាគតិច របស់ប្រជាជនក្នុងភូមិ-ឃុំពាក់ព័ន្ធនឹងគម្រោង | 2,000 | 100,000 | ១ឆ្នាំម្តងចាប់ពីឆ្នាំ២០១៧ តទៅ |
| ៦.៨ | គាំទ្រដល់ដំណើរការមណ្ឌលសុខភាពដែលមានស្រាប់ក្នុងតំបន់ (មណ្ឌលសុខភាពភ្នំកុក និងមណ្ឌលសុខភាពវឺនសៃ) | 400 | 20,000 | គាំទ្រជាថវិកាចំនួន ៤០០០ ដុល្លារ/ឆ្នាំ ក្នុង រយៈពេល ៥ឆ្នាំ គិតចាប់ពីឆ្នាំ២០២០ តទៅ |
| ៦.៩ | គាំទ្រដល់ដំណើរការបង្កើតមណ្ឌលសុខភាពក្នុងភូមិតាឡាត ឬភូមិរំពាត់ នៃឃុំតាឡាត (ភូមិទាំងពីរនេះនៅដាច់ស្រយាលពីទីប្រជុំឃុំ និងស្ថិតនៅក្រោមខ្សែទឹកនៃទីតាំងគម្រោង) | 400 | 20,000 | ឧបត្ថម្ភថវិកាចំនួន ២០០០០ ដុល្លារក្នុងឆ្នាំ២០២២ (ថវិកានៅសល់ជាបន្ទុករបស់រដ្ឋាភិបាល) |
| ផែនការ៧៖ ការចូលរួមការពារ និងស្តារឡើងវិញនូវធនធានធម្មជាតិ | | 2,000 | 1,000,000 | |

Draft

| ផែនការ<br>សកម្មភាព | | ថវិកា (ដុល្លារ)<br>មធ្យម/ឆ្នាំ | សរុប (៥០ឆ្នាំ) | ពេលដែលត្រូវចំណាយ |
|---|---|---|---|---|
| ៧.៣ | ចូលរួមអភិរក្ស និងស្តារឡើងវិញនូវព្រៃទ្រនាប់អូរ ព្រៃគុបក្នុងស្រុក និងព្រៃរក្សាទុកនានា ដែលបានកាត់ចេញពីផ្ទៃដីគម្រោង ព្រមទាំងឧបត្ថម្ភគាំទ្រដល់សកម្មភាពរបស់ស្ថានីយ៍បណ្តុះកូនឈើ របស់ផ្នែករដ្ឋបាលព្រៃឈើរ៉ុនសែ ដើម្បីផ្គត់ផ្គង់កូនឈើសម្រាប់ការដាំដុះក្នុងតំបន់ | 500 | 25,000 | គាំទ្រជាថវិកាចំនួន ៥០០ ដុល្លារ/ឆ្នាំ ចាប់ពីឆ្នាំ២០១៧ តទៅ |
| ៧.៤ | ចូលរួមឧបត្ថម្ភគាំទ្រសម្រាប់ការអភិរក្សនិងគ្រប់គ្រងសហគមន៍ព្រៃឈើកុកព្រៅ និងដំណើរការដាក់បញ្ចូលបន្ថែមនូវធនធានព្រៃឈើដែលនៅសេសសល់ជាដីសហគមន៍ព្រៃឈើ | 500 | 25,000 | គាំទ្រជាថវិកាចំនួន ៥០០ ដុល្លារ/ឆ្នាំ ចាប់ពីឆ្នាំ២០១៧ តទៅ |
| ៧.៦ | ដាំដើមឈើឡើងវិញនៅតាមដងផ្លូវក្នុងភូមិដែលយានយន្តរបស់ក្រុមហ៊ុនឆ្លងកាត់ និងតាមទីសាធារណៈនានាក្នុងតំបន់ | 500 | 25,000 | គាំទ្រជាថវិកាចំនួន ៥០០ ដុល្លារ/ឆ្នាំ ចាប់ពីឆ្នាំ២០១៧ តទៅ |
| ៧.៨ | ធ្វើការលែងកូនមច្ឆជាតិនៅតាមប្រព័ន្ធផ្លូវទឹកដែលមាននៅក្នុង និងក្បែរទីតាំងគម្រោង | 500 | 25,000 | ១ឆ្នាំម្តង ចាប់ពីឆ្នាំ២០១៧ តទៅ |
| ផែនការ៨៖ ការគ្រប់គ្រងបញ្ហាទូទៅ | | 8,000 | 400,000 | |
| ៨.៥ | រៀបចំកម្មវិធីអប់រំ ផ្សព្វផ្សាយអំពីសុខភាព អនាម័យក្នុងការរស់នៅ (ជាពិសេសរៀបចំ និងចែកចាយនូវផ្ទាំងផ្សព្វផ្សាយអំពីបំរាមក្នុងការប្រើប្រាស់ធុងថ្នាំគីមីកសិកម្មសម្រាប់ស្តុកម្ហូបអាហារ និងទឹកបរិភោគ) ដល់ប្រជាជននៅក្នុងភូមិ-ឃុំក្បែរទីតាំងគម្រោង | 1,000 | 50,000 | ១ឆ្នាំម្តង ចាប់ពីឆ្នាំ២០១៧ តទៅ |
| ៨.៦ | គាំទ្រដល់ការផ្សព្វផ្សាយជាចំណេះដឹងបន្ថែមដល់ប្រជាជនមូលដ្ឋាន ទាក់ទងនឹងសុវត្ថិភាពចរាចរណ៍ និងបញ្ហាសង្គមចាំបាច់ផ្សេងទៀត | 5,000 | 250,000 | ១ឆ្នាំម្តង ចាប់ពីឆ្នាំ២០១៧ តទៅ |
| ៨.៧ | គាំទ្រដល់អាជ្ញាធរមូលដ្ឋានក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ព្រមទាំងបេសកកម្មរបស់ប្រជាការពារឃុំ ដើម្បីពង្រឹងសុវត្ថិភាព និងសន្តិសុខមូលដ្ឋាន | 2,000 | 100,000 | ១ឆ្នាំម្តង ចាប់ពីឆ្នាំ២០១៧ តទៅ |
| កម្មវិធីត្រួតពិនិត្យបរិស្ថាន | | 8,600 | 430,000 | |
| ១ | ត្រួតពិនិត្យ និងតាមដានគុណភាពទឹកអូរ ចំនួន ៧ ទីតាំង | 2,100 | 105,000 | ៤ដង/ឆ្នាំ ចាប់ពីឆ្នាំ២០១៧ តទៅ |
| ២ | ត្រួតពិនិត្យ និងតាមដានគុណភាពទឹកក្រោមដី (ទឹកអណ្តូង) ចំនួន ៣ ទីតាំង | 900 | 45,000 | |
| ៣ | ត្រួតពិនិត្យ និងតាមដានគុណភាពដី ចំនួន ៤ ទីតាំង | 1,200 | 60,000 | |

Draft

| ផែនការ | | ថវិកា (ដុល្លារ) | | ពេលវេលាដែលត្រូវចំណាយ |
|---|---|---|---|---|
| | សកម្មភាព | មធ្យម/ឆ្នាំ | សរុប (៥០ឆ្នាំ) | |
| ៤ | ត្រួតពិនិត្យ និងតាមដានគុណភាពខ្យល់ក្នុងឃ្លាំងស្តុកជី និងថ្នាំគីមីកសិកម្ម ចំនួន១ ទីតាំង | 600 | 30,000 | ១ឆ្នាំម្តង ចាប់ពីឆ្នាំ២០១៧ តទៅ |
| ៥ | ត្រួតពិនិត្យ និងតាមដានកំហាប់ឧស្ម័នពុលចេញពីបំពង់ផ្សែងនៃម៉ាស៊ីនភ្លើង និងគ្រឿងយន្តគាំទ្រដល់ដំណើរការគម្រោង ចំនួន២ទីតាំង | 3,200 | 160,000 | ១ឆ្នាំម្តង (គ្រឿងចក្រ ២០) ចាប់ពីឆ្នាំ២០១៧ តទៅ |
| ៦ | ត្រួតពិនិត្យ និងតាមដានកម្រិតសំឡេង ចំនួន ១ ទីតាំង | 600 | 30,000 | ១ឆ្នាំម្តង ចាប់ពីឆ្នាំ២០១៧ តទៅ |
| បៀវត្សប្រធានផ្នែកបរិស្ថាន (ត្រូវជ្រើសរើសបន្ថែម) | | 1,000 | 50,000 | ចាប់ពីឆ្នាំ២០១៧ តទៅ |

ក្រុមហ៊ុននឹងជ្រើសរើសប្រធានផ្នែកបរិស្ថាន ០១រូប ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីទទួលខុសត្រូវលើការងារសម្របសម្រួល និងការអនុវត្តកម្មវិធីគ្រប់គ្រង អប់រំ-បណ្តុះបណ្តាល និងត្រួតពិនិត្យបរិស្ថាន ដូចបានកំណត់ខាងលើ។ ប្រធានផ្នែកបរិស្ថាន នឹងត្រូវមានការទទួលខុសត្រូវដូចតទៅ៖

- ធ្វើជិតស្និទ្ធជាមួយនាយកគ្រប់គ្រងគម្រោង ដើម្បីជានានូវការវិភាជថវិកាបន្ថែមសម្រាប់ការអនុវត្តកម្មវិធីគ្រប់គ្រង និងត្រួតពិនិត្យបរិស្ថាន
- រៀបចំវគ្គបណ្តុះបណ្តាល ដល់បុគ្គលិក-កម្មករ ដើម្បីណែនាំឱ្យយល់ពីតួនាទីភារៈកិច្ចដែលពួកគាត់ត្រូវបំពេញរៀងៗខ្លួន ឬជាសមូហភាព ក្នុងការងារគ្រប់គ្រងផលប៉ះពាល់បរិស្ថាន-សង្គម ទៅតាមកម្មវិធីគ្រប់គ្រង និងត្រួតពិនិត្យបរិស្ថាន ព្រមទាំងធ្វើការអប់រំ-ផ្សព្វផ្សាយ និងសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធនានា ដើម្បីជំរុញការអនុវត្តកម្មវិធីគ្រប់គ្រង និងត្រួតពិនិត្យបរិស្ថាន ឱ្យមានប្រសិទ្ធិភាព និងប្រសិទ្ធិផល
- រៀបចំបណ្តាញទំនាក់ទំនងសម្រាប់ទទួលពាក្យបណ្តឹងពីបុគ្គលិក-កម្មករ និងសហគមន៍មូលដ្ឋាន និងបញ្ជូនព័ត៌មានអំពីកិច្ចដំណើរការគម្រោងទៅពួកគាត់វិញ ព្រមទាំងសម្របសម្រួលការពិភាក្សារកដំណោះស្រាយវិវាទនានាប្រសិនបើមាន
- សម្របសម្រួលការអនុវត្តសកម្មភាពការងារទៅតាមផែនការទាំង៨ ដូចបានកំណត់ខាងលើ
- ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពការងាររបស់បុគ្គលិកផ្សេងទៀត ដូចមានចែងក្នុងកម្មវិធីគ្រប់គ្រង អប់រំ-បណ្តុះបណ្តាល និងត្រួតពិនិត្យបរិស្ថាន (រៀងរាល់ ៦ខែម្តង ចាប់ពីឆ្នាំ២០១៧ រហូតដល់បញ្ចប់គម្រោង) ព្រមទាំងរៀបចំរបាយការណ៍ជូនក្រសួង/ស្ថាប័នពាក់ព័ន្ធ ទៅតាមការកំណត់។

## ៨.៥. ផែនការថវិកាសម្រាប់មូលនិធិបរិស្ថាន និងសង្គម

ទោះជាក្រុមហ៊ុនខិតខំបញ្ចៀស កាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន និងធ្វើការអប់រំ-បណ្តុះបណ្តាលយ៉ាងណាក្តី ក៏គម្រោងនេះនឹងបន្សល់នូវផលប៉ះពាល់មួយចំនួនដល់សហគមន៍មូលដ្ឋាន និងបរិស្ថាននៅតំបន់នោះ ដោយមិនអាចចៀសវាងបាន ឬ ដែលអាចកាត់បន្ថយមកត្រឹមកម្រិតតិចតួចប៉ុណ្ណោះ។ ក្រុមហ៊ុនបានលើកផែនការដើម្បីជួយស្តារបរិស្ថានឡើងវិញ និងប៉ះប៉ូវផលប៉ះពាល់មួយចំនួនរួចហើយ។ ដូចដែលបានបង្ហាញនៅក្នុងតារាង៨.២ សកម្មភាពដែលនឹងជួយស្តារបរិស្ថានឡើងវិញ រួមមានសកម្មភាពនានានៅក្រោមកម្មវិធី៧ ដែលត្រូវចំណាយថវិកាជាមធ្យមប្រមាណ ២០០០ដុល្លារ/ឆ្នាំ ឬ ១.០០០.០០០ ដុល្លារក្នុងរយៈពេល ៥០ឆ្នាំនៃការវិ

Draft

និយោគ។ សកម្មភាពដែលនឹងជួយអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន រួមមានសកម្មភាពនានាក្រោមកម្មវិធី៦ ព្រមទាំងសកម្មភាព៨.៦ និង ៨.៧ ក្រោមកម្មវិធី៨ ដែលត្រូវចំណាយថវិកាជាមធ្យមប្រមាណ ១៤.០០០ ដុល្លារ/ឆ្នាំ ឬ ៧០០.០០០ ដុល្លារក្នុងរយៈពេល ៥០ឆ្នាំនៃការវិនិយោគ។

ក្រុមហ៊ុននឹងផ្ដល់ជូនបន្ថែមនូវថវិកាចំនួន **២.០០០ដុល្លារ/ឆ្នាំ ( ១.០០០ដុល្លារ/ឆ្នាំ សម្រាប់មូលនិធិ បរិស្ថាន និង១.០០០ដុល្លារ/ឆ្នាំ សម្រាប់មូលនិធិសង្គម)** សម្រាប់ក្រសួងបរិស្ថាន យកទៅចាត់ចែងប្រើប្រាស់ស្របតាមលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន។ ក្រុមហ៊ុននឹងបង់ចូលមូលនិធិបរិស្ថាន និងសង្គមនេះ ចាប់ពីឆ្នាំ២០១៨ តទៅ។

ផ្អែកតាមអនុក្រឹត្យស្ដីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម (ឆ្នាំ២០១៦ ក្នុងមាត្រា១០) មូលនិធិនេះត្រូវយកប្រើប្រាស់ក្នុងសកម្មភាព ដូចខាងក្រោម៖

- ការគាំពារបរិស្ថាន ការអភិរក្សព្រៃឈើ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ប្រកបដោយនិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនដែលរស់ក្នុង និងក្បែរតំបន់គម្រោងអភិវឌ្ឍន៍ ឬតំបន់ផ្សេងទៀត
- ការសិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី
- ការស្រាវជ្រាវបច្ចេកទេស និងវិទ្យាស្ត្រលើវិស័យបរិស្ថាន
- ការផ្សព្វផ្សាយអំពីវិស័យបរិស្ថាន
- ទ្រទ្រង់កម្មវិធីបង្កើតសហគមន៍ការពារធម្មជាតិ និងសហគមន៍នានាបម្រើឱ្យវិស័យបរិស្ថាន
- ការបណ្ដុះបណ្ដាលធនធានមនុស្សសម្រាប់វិស័យបរិស្ថាន និងធនធានធម្មជាតិ
- ការអប់រំផ្សព្វផ្សាយលើតំបន់ការពារធម្មជាតិ
- ការដាំដើមឈើ
- កម្មវិធីទិវាបរិស្ថានជាតិ
- កម្មវិធីបណ្ដុះបណ្ដាល និងកសាងសមត្ថភាពមន្ត្រីបរិស្ថានថ្នាក់ជាតិ និងក្រោមជាតិ។

Draft